# ព្រះ
# ត្រៃបិដកបាលី
## នឹង
## សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
## ខុទ្ទកនិកាយ ជាតក
## សត្តមភាគ
# ៥៨

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស. ២៥០១

សុត្តន្តបិដក

ខុទ្ទកនិកាយ ជាតក

សត្តមភាគ

៥៨

ព.ស. ២៥០១

សុត្តន្តបិដកេ

ខុទ្ទកនិកាយស្ស ជាតកំ

សត្តមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ឯកនិបាតជាតកំ

## អបណ្ណកវគ្គោ

## អបណ្ណកជាតកំ

(១) អបណ្ណកំ ឋានមេកេ ទុតិយំ អាហុ តក្កិកា ឯតទញ្ញាយ មេធាវី តំ គណ្ហេ យទបណ្ណកន្តិ (១) ។

អបណ្ណកជាតកំ បឋមំ ។

## វណ្ណុបថជាតកំ (២)

(២) អកិលាសុនោ វណ្ណុបថេ (៣) ខណន្តា ឧទង្គណេ តត្ថ បបំ អវិន្ទុំ

---

១ ម. ធំ. គណ្ហេថ្យ អបណ្ណកំ ។ ២. វណ្ណុបថជាតកំ ។ ៣ ឱ. វណ្ណុបថេ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ ជាតក

សត្តមភាគ

---

សូមថ្វាយបង្គំព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

## ឯកនិបាតជាតក

## អបណ្ណកវគ្គ

## អបណ្ណកជាតក

(១) (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) បុគ្គលពួកខ្លះ ជាបណ្ឌិត រមែងប្រកាន់ហេតុដែលមិនខុស បុគ្គលពួកខ្លះ ត្រិះរិះយកឯង រមែងប្រកាន់ហេតុទី ២ (ហេតុខុស) មេធាវីបុគ្គល បានដឹងនូវហេតុដែលខុសនឹងហេតុដែលមិនខុសនេះហើយ គប្បីកាន់យកនូវហេតុដែលមិនខុសនោះ ។

ចប់ អបណ្ណកជាតក ទី ១ ។

## វណ្ណុបថជាតក

(២) (ព្រះសម្ពុទ្ធត្រាស់ថា) ពួកជនមិនខ្ជិលច្រអូស កាលជីក (ដីខ្សាច់) ត្រង់ផ្លូវខ្សាច់ ក្បែរផ្លូវ បាននូវទឹកត្រង់ផ្លូវនោះ (យ៉ាងណា)

ឯវំ មុនិ វីរិយពលូបបន្នោ

អកិលាសុ វិន្ទេ ហទយស្ស សន្តិន្តិ(១) ។

វណ្ណុបថជាតកំ ទុតិយំ ។

## សេរិវាណិជជាតកំ(២)

(៣) ឥធ ចេ នំ វិរាធេសិ សទ្ធម្មស្ស និយាមតំ

ចិរំ ត្វំ អនុតប្បេសិ សេរិវាយំ វាណិជោតិ(៣) ។

សេរិវាណិជជាតកំ តតិយំ ។

## ចុល្លកសេដ្ឋិជាតកំ

(៤) អប្បកេន បិ មេធាវី បាភតេន វិចក្ខណោ

សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមន្តិ(៤) ។

ចុល្លកសេដ្ឋិជាតកំ ចតុត្ថំ ។

---

១ ម. សន្តិំ ។ ២ ម. សេរិវជាតកំ ។ ៣ ម. តិ-សទ្ទោ នត្ថិ ។ ៤ ម. សន្ធមំ ។



អ្នកប្រាជ្ញ បរិបូណ៌ដោយព្យាយាមនឹងកំឡាំងកាយ មិនខ្ជិលច្រអូស ក៏បាននូវសេចក្ដីស្ងប់រម្ងាប់នៃហឫទ័យយ៉ាងនោះដែរ ។

ចប់ វណ្ណុបថជាតក ទី ២ ។

## សេរិវាណិជជាតក

[៣] (ព្រះសម្ពុទ្ធត្រាស់ថា) បើអ្នកធ្វើនូវសាសនាបដិបត្តិ ជាគ្រឿងកំណត់នូវព្រះសទ្ធម្មនោះ ឲ្យឃ្លាតចាកសាសនានេះហើយ អ្នកនឹងក្ដៅក្រហាយរឿយ ៗ អស់កាលយូរ ដូចជាពាណិជឈ្មោះសេរិវៈនេះ ។

ចប់ សេរិវាណិជជាតក ទី ៣ ។

## ចុល្លកសេដ្ឋិជាតក

[៤] (ព្រះសាស្ដាត្រាស់ថា) អ្នកប្រាជ្ញ ឈ្លាសវៃ រមែងតាំងខ្លួនបាន ដោយទ្រព្យជាដើមទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ។

ចប់ ចុល្លកសេដ្ឋិជាតក ទី ៤ ។

## តណ្ឌុលនាឡិជាតកំ

(៥) កិមគ្ឃតី តណ្ឌុលនាឡិកា ច
ពារាណសី សន្តរពាហិរំ
អស្សបញ្ចសតានិ ឯកា តណ្ឌុលនាឡិកាតិ(១) ។

តណ្ឌុលនាឡិជាតកំ បញ្ចមំ ។

## ទេវធម្មជាតកំ

(៦) ហិរិឱត្តប្បសម្បន្នា សុក្កធម្មសមាហិតា
សន្តោ សប្បុរិសា លោកេ ទេវធម្មាតិ វុច្ចរេតិ ។

ទេវធម្មជាតកំ ឆដ្ឋំ ។

## កដ្ឋហារិជាតកំ

(៧) បុត្តោ ត្យាហំ មហារាជ ត្វំ មំ បោស ជនាធិប
អញ្ញេបិ ទេវោ បោសេតិ កិញ្ច ទេវោ សកំ បជន្តិ ។

កដ្ឋហារិជាតកំ(២) សត្តមំ ។

---

១ ម. កិំ អគ្ឃតិ តណ្ឌុលនាឡិកាយ អស្សានមូលាយ វទេហិ រាជ ពារាណសី សន្តរពាហិរោ អយមគ្ឃតិ តណ្ឌុលនាឡិកា ។ ២ ម. កដ្ឋហារជាតកំ ។



## តណ្ឌុលនាឡិជាតក

(៥) (សាមាត្យពោធិសត្វ សួរថា) អង្ករមួយនាឡិ ថ្លៃ (ស្មើនឹង) ក្រុងពារាណសី ទាំងខាងក្នុងទាំងខាងក្រៅ ឬ (ស្មើនឹង) សេះ ៥០០ នេះថ្លៃត្រឹមតែអង្ករ ១ នាឡិ ទេឬ ។

ចប់ តណ្ឌុលនាឡិជាតក ទី ៥ ។

## ទេវធម្មជាតក

(៦) (ព្រះមហិសាសកុមារពោធិសត្វ ពោលថា) ពួកសប្បុរសអ្នកមានចិត្តស្ងប់រម្ងាប់ ប្រកបដោយហិរិនិងឱត្តប្បៈ តាំងមាំហើយក្នុងធម៌ស លោកពោលថាមានទេវធម៌ ក្នុងលោក ។

ចប់ ទេវធម្មជាតក ទី ៦ ។

## កដ្ឋហារិជាតក

(៧) (ព្រះរាជកុមារពោធិសត្វ ពោលថា) បពិត្រមហារាជ ខ្ញុំជាបុត្ររបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងពួកជន សូមព្រះអង្គចិញ្ចឹមខ្ញុំផង ព្រះសម្មតិទេពទ្រង់ចិញ្ចឹមពួកជនដទៃបាន ម្ដេចព្រះសម្មតិទេពក៏មិនចិញ្ចឹមសត្វដែលជាបុត្ររបស់ព្រះអង្គផង ។

ចប់ កដ្ឋហារិជាតក ទី ៧ ។

## គាមណិជាតកំ

(៨) អបិ អតរមានានំ ផលាសាវ សមិជ្ឈតិ
វិបក្កព្រហ្មចរិយោស្មិ ឯវំ ជានាហិ គាមណិ ។

គាមណិជាតកំ អដ្ឋមំ ។

## មឃទេវជាតកំ (១)

(៩) ឧត្តមង្គរុហា មយ្ហំ ឥមេ ជាតា វយោហរា
បាតុភូតា ទេវទូតា បព្វជ្ជាសមយោ មមាតិ ។

មឃទេវជាតកំ នវមំ ។

## សុខវិហារិជាតកំ

(១០) យញ្ច អញ្ញេ ន រក្ខន្តិ យោ ច អញ្ញេ ន រក្ខតិ
ស វេ រាជ សុខំ សេតិ កាមេសុ អនបេក្ខវាតិ ។

សុខវិហារិជាតកំ ទសមំ ។

អបណ្ណកវគ្គោ បឋមោ ។

---
១ ម. ទេវទូតជាតកំ ។



## គាមណិជាតក

(៨) (គាមណិកុមារ ពោលថា) ការប្រាថ្នានូវផល តែងសម្រេចព្រម ដល់បុគ្គលអ្នកមិនប្រញាប់ អាត្មាអញមានព្រហ្មចរិយចាស់ក្លា ហើយ ម្នាលគាមណិ អ្នកចូរដឹងយ៉ាងនេះចុះ ។

ចប់ គាមណិជាតក ទី ៨ ។

## មឃទេវជាតក

(៩) (ព្រះរាជាពោធិសត្វទ្រង់ត្រាស់ថា) សក់ទាំងឡាយនេះនាំទៅនូវវ័យ (ស្កូវ) កើតដល់អញហើយ ទេវទូត កើតប្រាកដហើយ (នេះ) ជាសម័យនៃផ្នួសរបស់អញ ។

ចប់ មឃទេវជាតក ទី ៩ ។

## សុខវិហារិជាតក

(១០) (ឥសីពោធិសត្វពោលថា) បុគ្គលដទៃ មិនរក្សាជនណា ម្យ៉ាងទៀត ជនណាមិនរក្សាបុគ្គលដទៃ បពិត្រព្រះរាជា ជននោះឯង មិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយទេ រមែងដេកជាសុខ ។

ចប់ សុខវិហារិជាតក ទី ១០ ។

ចប់ អបណ្ណកវគ្គ ទី ១ ។

## តស្សុទ្ទានំ

អបណ្ណកា វណ្ណុបថ សេរិវេ
សុចិន្តកណា តណ្ឌុលនាឡិកាសន្ថា
ហិរិ បុត្ត វុត្តកាមណិនា
យោ ច ន រក្ខតិ តេន ទស ។

---



## ឧទ្ទាននៃអបណ្ណកវគ្គនោះគឺ

និយាយអំពីបុគ្គលទ្រង់ប្រកាន់ហេតុមិនខុសដ៏ប្រសើរ ក្នុងអបណ្ណក-ជាតក ១ វណ្ណុបថជាតក ១ សេរិវាណិជជាតក ១ បុគ្គលមានប្រាជ្ញាជាគ្រឿងពិចារណា ក្នុងចុល្លកសេដ្ឋិជាតក១ តណ្ឌុលនាឡិជាតក១ បុគ្គលមានហិរិ ក្នុងទេវធម្មជាតក១ ព្រះរាជបុត្ត ក្នុងកដ្ឋហារិជាតក១ គាមណិជាតក១ មឃទេវជាតក១ ជនណាមិនរក្សាដោយដៃ ក្នុងសុខវិហារិជាតក ១ ត្រូវជា ១០ ជាតក ។

---

## សីលវគ្គោ

### លក្ខណជាតកំ

(១១) ហោតិ សីលវតំ អត្ថោ បដិសន្ថារវុត្តិនំ
លក្ខណំ បស្ស អាយន្តំ ញាតិសង្ឃបុរក្ខតំ
អថ បស្សសិមំ កាឡំ សុវិហីនំ ញាតិភិ ។

លក្ខណជាតកំ បឋមំ ។

### និគ្រោធមិគជាតកំ

(១២) និគ្រោធមេវ សេវេយ្យ ន សាខំ ឧបសំវសេ
និគ្រោធស្មឹ មតំ សេយ្យោ យញ្ចេ សាខស្មិំ ជីវិតំ ។

និគ្រោធមិគជាតកំ ទុតិយំ ។

១ ម. និគ្រោធជាតកំ ។

## សីលវគ្គ

### លក្ខណជាតក

(១១) (ម្រឹគពោធិសត្វ ពោលថា) សេចក្តីចំរើនតែងមាន ដល់ពួកជន អ្នកមានសីល អ្នកប្រព្រឹត្តបដិសន្ថារៈ តាន់ចូរមើលម្រឹគឈ្មោះ លក្ខណៈ កំពុងដើរមក ដែលពួកញាតិហែហមហើយ តាន់ ឃើញម្រឹគឈ្មោះកាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ (កំពុង ដើរមក) ឬទេ ។

ចប់ លក្ខណជាតក ទី ១ ។

### និគ្រោធមិគជាតក

(១២) (មេម្រឹគ ពោលថា) បុគ្គលគប្បីសេព នូវម្រឹគឈ្មោះនិគ្រោធៈ តែម្យ៉ាង កុំគប្បីសេពនូវម្រឹគឈ្មោះសាខៈឡើយ ការស្លាប់ក្នុង សំណាក់នៃម្រឹគឈ្មោះនិគ្រោធៈ ជាការប្រសើរ ការរស់នៅក្នុង សំណាក់នៃម្រឹគឈ្មោះសាខៈ ពុំប្រសើរឡើយ ។

ចប់ និគ្រោធមិគជាតក ទី ២ ។

## កណ្ឌិនជាតកំ[១]

(១៣) ធិរត្ថុ កណ្ឌិនំ សល្លំ បុរិសំ គាឡ្ហវេធិនំ
ធិរត្ថុ តំ ជនបទំ យត្ថិត្ថី បរិណាយិកា
តេ ចាបិ ធិក្កិតា សត្តា យេ ឥត្ថីនំ វសំ គតា ។

កណ្ឌិនជាតកំ តតិយំ ។

## វាតមិគជាតកំ

(១៤) ន កិរត្ថិ រសេហិ បាបិយោ
អាវាសេហិ វ សន្ថវេហិ វា
វាតមិគំ គហននិស្សិតំ
វសមានេសិ រសេហិ សញ្ជយោ ។

វាតមិគជាតកំ ចតុត្ថំ ។

១ ម. កណ្ឌិជាតកំ ។



## កណ្ឌិនជាតក

(១៣) (ក្រុមទេវតាពោលសង្វេគ ពោលថា) គួរតិះដៀលនូវបុរសអ្នកមានសរមុតចូលទៅ ដែលមានរបួសយ៉ាងខ្លាំង ស្ត្រីជាបរិណាយិកា (អ្នកដឹកនាំ) នៅក្នុងជនបទណា គួរតិះដៀលនូវជនបទនោះ ម្យ៉ាងទៀត សត្វទាំងឡាយណា លុះអំណាចពួកស្រី សត្វទាំងឡាយនោះ ក៏បណ្ឌិតតិះដៀលហើយ ។

ចប់ កណ្ឌិនជាតក ទី ៣ ។

## វាតមិគជាតក

(១៤) (ព្រះរាជាទ្រង់មានព្រះឧទានថា នែអ្នក) ដោយការសេពរសៈទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំងឡាយ ជាសភាវៈលាមកជាងនេះ ដោយរសទាំងឡាយមិនមានទេ ឧយ្យានបាលឈ្មោះ សញ្ជ័យ បាននាំសត្វឈ្លូសដែលអាស្រ័យនូវព្រៃស្បាត មកកាន់អំណាច (របស់ខ្លួន) បាន ព្រោះតែរសទាំងឡាយ ។

ចប់វាតមិគជាតក ទី ៤ ។

## ខរាទិយជាតកំ

(១៥) អដ្ឋក្ខុរំ ខរាទិយេ មិគំ វង្កាតិវង្កិនំ
សត្តកាលេហតិក្កន្តំ(១) ន នំ ឱវទិតុស្សហេ ។

ខរាទិយជាតកំ បញ្ចមំ ។

## តិបល្លត្ថមិគជាតកំ

(១៦) មិគំ តិបល្លត្ថមនេកមាយំ
អដ្ឋក្ខុរំ អឌ្ឍរត្តាបបាយឹ
ឯកេន សោតេន ឆមាស្សសន្តោ
ឆហិ កលាហតិភោតិ ភាគិនេយ្យោតិ ។

តិបល្លត្ថមិគជាតកំ ឆដ្ឋំ ។

## មាលុតជាតកំ

(១៧) កាឡេ វា យទិ វា ជុណ្ហេ យទា វាយតិ មាលុតោ
វាតជានិ ហិ សីតានិ ឧភោត្ថមបរាជិតាតិ ។

មាលុតជាតកំ សត្តមំ ។

១ ម. សត្តហិ កាលាតិក្កន្តំ ។



## ខរាទិយជាតក

(១៥) (ព្រះពោធិសត្វ ពោលថា) ម្នាលនាងខរាទិយា យើងមិនអាចទូន្មានម្រឹគ មានក្រចក ៨ មានស្នែងវៀចកោងនឹងស្រួចពន្លឹកក្រែលង ជាសត្វកន្លងនូវកាលនៃដំបូន្មាន ៧ នោះបានឡើយ ។

ចប់ ខរាទិយជាតក ទី ៥ ។

## តិបល្លត្ថមិគជាតក

(១៦) (ព្រះពោធិសត្វ ពោលថា) ខ្ញុំបានញុំាងម្រឹគ មានដំណេក ៣ មានក្រចក ៨ ជាសត្វផឹកទឹកក្នុងវេលាអធ្រាត្រ ឲ្យរៀនមាយាច្រើនហើយ ម្រឹគជាក្មួយ ចុះដកដង្ហើមទប់នឹងផែនដី ដោយខ្យល់ច្រមុះម្ខាង បញ្ឆោត (ព្រានព្រៃ) ដោយកល ៦ យ៉ាង ។

ចប់ តិបល្លត្ថមិគជាតក ទី ៦ ។

## មាលុតជាតក

(១៧) (ឥសីពោធិសត្វ ពោលថា) កាលណា ខ្យល់បក់ ទោះខាងខ្នោចក្តីខាងខ្នើតក្តី កាលនោះ ត្រជាក់ដោយខ្យល់ ក៏កើតអំពីខ្យល់ អ្នកទាំងពីរ មិនចាញ់គ្នា ក្នុងប្រស្នានេះឡើយ ។

ចប់ មាលុតជាតក ទី ៧ ។

## មតកភត្តជាតកំ

(១៨) ឯវញ្ចេ សត្តា ជានេយ្យុំ ទុក្ខាយំ ជាតិសម្ភវោ
ន បាណោ បាណិនំ ហញ្ញេ បាណឃាតី ហិ សោច-
តីតិ ។

មតកភត្តជាតកំ អដ្ឋមំ ។

## អាយាចិតភត្តជាតកំ

(១៩) សចេ មុញ្ចេ បេច្ច មុញ្ចេ មុច្ចមានោ ហិ ពជ្ឈតិ
ន ហេវំ ធីរា មុច្ចន្តិ មុត្តិ ពាលស្ស ពន្ធនន្តិ ។

អាយាចិតភត្តជាតកំ នវមំ ។

## នឡបានជាតកំ

(២០) ទិស្វា បទមនុត្តិណ្ណំ ទិស្វានោតរិតំ បទំ
នឡេន វារឹ បិស្សាម នេវ មំ ត្វំ វធិស្សសីតិ ។

នឡបានជាតកំ ទសមំ ។

សីលវគ្គោ ទុតិយោ ។



## មតកភត្តជាតក

(១៨) (រុក្ខទេវតាពោធិសត្វ ពោលថា) បើពួកសត្វគប្បីដឹងយ៉ាងនេះ ថា ការកើតនៃជាតិនេះ រមែងនាំមកនូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វ រមែងសោយសោក ។

ចប់ មតកភត្តជាតក ទី ៨ ។

## អាយាចិតភត្តជាតក

(១៩) (រុក្ខទេវតា ពោលថា) បើអ្នកចង់រួច ត្រូវរួចចាកលោកខាងនាយ ព្រោះថា អ្នករួចយ៉ាងនេះ គង់ជាប់ (ដោយបាបកម្ម) អ្នកប្រាជ្ញទាំងឡាយ មិនបានរួចយ៉ាងនេះឡើយ ការរួចរបស់ជនពាល ឈ្មោះថាចំណងវិញទេ ។

ចប់ អាយាចិតភត្តជាតក ទី ៩ ។

## នឡបានជាតក

(២០) (ស្វាពោធិសត្វ ពោលថា) យើងឃើញស្នាមជើងដែលមិនឡើង ឃើញតែស្នាមជើងដែលចុះ យើងផឹកទឹកដោយដើមបបុស អ្នកនឹងសម្លាប់យើងមិនបានឡើយ ។

ចប់ នឡបានជាតក ទី ១០ ។

ចប់ សីលវគ្គ ទី ២ ។

## តស្សុទ្ទានំ

អថ លក្ខណ សាខ ធិវត្ថុ
មុធ ឧត្តរត្ថ វសេហិ ខកនិយា
អតិបាក សយមាលុត តាលណ
មុតេធ ធម្មវរយេន កត្តិ ធស ។

---





## ឧទ្ទាននៃសីលវគ្គនោះគឺ

និយាយអំពីលក្ខណជាតក ១ ម្រឹគឈ្មោះសាខៈ (គឺនិគ្រោធមិគ-ជាតក) ១ ធូរកិរៈផៀល (គឺកណ្ឌិនជាតក) ១ មិនលាមកជាងរសចាំងមួយ (គឺវាតមិគជាតក) ១ ខរាទិយជាតក ១ ម្រឹគបញ្ឆោតព្រានព្រៃ (គឺតិបល្លត្ថមិគជាតក) ១ មាលុតជាតក ១ បុគ្គលមិនត្រូវសម្លាប់សត្វដទៃ (គឺមតកភត្តជាតក) ១ ការបួង (គឺអាយាចិតភត្តជាតក) ១ នឡបានជាតក ១ ត្រូវជា ១០ ។

---

## កុរុង្គវគ្គោ

### កុរុង្គមិគជាតកំ

(២១) ញាតមេតំ កុរុង្គស្ស យំ ត្វំ សេបណ្ណិ សេយ្យសិ
អញ្ញំ សេបណ្ណិ គច្ឆាមិ ន មេ តេ រុច្ចតេ ផលន្តិ ។

កុរុង្គមិគជាតកំ បឋមំ ។

### កុក្កុរជាតកំ

(២២) យេ កុក្កុរា រាជកុលម្ហិ វឌ្ឍា
កោលេយ្យកា វណ្ណពលូបបន្នា
តេមេ ន វជ្ឈា មយមស្ម វជ្ឈា
នាយំ សឃច្ចា ទុព្ពលឃាតិកាយន្តិ ។

កុក្កុរជាតកំ ទុតិយំ ។

### ភោជាជានីយជាតកំ (១)

(២៣) អបិ បស្សេន សេមានោ សល្លេហិ សល្លលីកតោ
សេយ្យោវ វឡវា ភោជ្ជោ យុញ្ជ មញ្ញេវ សារថីតិ ។

ភោជាជានីយជាតកំ តតិយំ ។

១ ម. ភោជាជានីយជាតកំ ។

## កុរុង្គវគ្គ

### កុរុង្គមិគជាតក

(២១) (ព្រះពោធិសត្វ ពោលថា) ម្នាលដើមចម្បក់ អ្នកជម្រុះផ្លែមកឲ្យយ៉ាងណា ហេតុនុ៎ះអញជាម្រឹគបានដឹងហើយ អញនឹងទៅកាន់ដើមចម្បក់ឯទៀត ផ្លែរបស់អ្នកអញមិនគាប់ចិត្តទេ ។

ចប់ កុរុង្គមិគជាតក ទី ១ ។

### កុក្កុរជាតក

(២២) (សុនខពោធិសត្វ ពោលថា) ពួកឆ្កែណាកើតក្នុងរាជត្រកូល បរិបូណ៌ដោយសម្បុរនិងកំឡាំង ចំរើនហើយក្នុងរាជត្រកូល ឆ្កែទាំងនោះ គេមិនសម្លាប់ទេ យើងទាំងឡាយត្រូវគេសម្លាប់ នេះមិនឈ្មោះថាសម្លាប់ដោយត្រឹមត្រូវឡើយ នេះឈ្មោះថាសម្លាប់តែឆ្កែដែលមានកំឡាំងខ្សោយ ។

ចប់ កុក្កុរជាតក ទី ២ ។

### ភោជាជានីយជាតក

(២៣) (សេះភោជាជានីយពោធិសត្វ ពោលថា) សេះភោជាជានីយ សូម្បីត្រូវសរទាំងឡាយមុតហើយ ដេកផ្អៀង ក៏នៅប្រសើរជាងសេះសាមញ្ញ ម្នាលសារថី អ្នកចូរទឹមខ្ញុំដោយគ្រឿងក្រែសទាំងឡាយចុះ ។

ចប់ ភោជាជានីយជាតក ទី ៣ ។

## អាជញ្ញជាតកំ

(២៤) យទា យទា យត្ថ យទា យត្ថ យត្ថ យទា យទា
អាជញ្ញោ កុរុតេ វេគំ ហាយន្តិ តត្ថ វាឡវា ។

អាជញ្ញជាតកំ ចតុត្ថំ ។

## តិត្ថជាតកំ

(២៥) អញ្ញមញ្ញេហិ តិត្ថេហិ អស្សំ បាយេហិ សារថិ
អច្ចាសនស្ស បុរិសោ(១) បាយាសស្សបិ តប្បតិ ។

តិត្ថជាតកំ បញ្ចមំ ។

## មហិឡាមុខជាតកំ

(២៦) បុរាណចោរាន វចោ និសម្ម
មហិឡាមុខោ បោថយមនុចារី
សុសញ្ញតានំ ហិ វចោ និសម្ម
គជុត្តមោ សព្វគុណេសុ អដ្ឋាតិ ។

មហិឡាមុខជាតកំ ឆដ្ឋំ ។

---
១ ម. សុហិតោ ។





## អាជញ្ញជាតក

(២៤) (សេះអាជានេយ្យពោធិសត្វ ពោលថា) សេះអាជានេយ្យ ធ្វើល្បឿនក្នុងទីណា ក្នុងកាលណាមួយ ។ ឬក្នុងខណៈណា ក្នុងមណ្ឌលចំបាំងណា ក្នុងកាលណាមួយ ។ សេះសាមញ្ញទាំងឡាយ តែងសាបសូន្យ ក្នុងកាលនោះ ក្នុងទីនោះ ។

ចប់ អាជញ្ញជាតក ទី ៤ ។

## តិត្ថជាតក

(២៥) (អាមាត្យពោធិសត្វ ពោលថា) ម្នាលសារថី អ្នកចូរញុំាងសេះឲ្យផឹក (ទឹក) តាមកំពង់ទឹកទាំងឡាយដទៃ ៗ ចុះ ដ្បិតសេះឆ្អែត ដោយបាយាស ដោយការស៊ីច្រើនហើយ (រមែងមិនត្រូវការ បរិភោគទៀតទេ) ។

ចប់ តិត្ថជាតក ទី ៥ ។

## មហិឡាមុខជាតក

(២៦) (អាមាត្យពោធិសត្វ ពោលថា) ដំរីដ៏ឧត្តមឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាម បានបោកសម្លាប់ (មនុស្ស) លុះបានស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រួមល្អហើយ ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង ។

ចប់ មហិឡាមុខជាតក ទី ៦ ។

## អភិណ្ហជាតកំ

(២៧) នាលំ កពលំ បទាតវេ
ន បិណ្ឌំ ន កុសេ ន ឃំសិតុំ
មញ្ញាមិ អភិណ្ហទស្សនា
នាគោ សិនេហមកាសិ កុក្កុរេ ។

អភិណ្ហជាតកំ សត្តមំ ។

## នន្ទិវិសាលជាតកំ

(២៨) មនុញ្ញមេវ ភាសេយ្យ នាមនុញ្ញំ កុទាចនំ
មនុញ្ញំ ភាសមានស្ស គរុំ ភារំ ឧទទ្ធរិ
ធនញ្ច នំ អលាភេសិ តេន ចត្តមនោ អហូតិ ។

នន្ទិវិសាលជាតកំ អដ្ឋមំ ។

## កណ្ហជាតកំ

(២៩) យតោ យតោ គរុ ធុរំ យតោ គម្ភីរវត្តនិ
តទស្សុ កណ្ហំ យុញ្ជន្តិ ស្វាស្សុ តំ វហតេ ធុរន្តិ ។

កណ្ហជាតកំ នវមំ ។



## អភិណ្ហជាតក

(២៧) (អាមាត្យពោធិសត្វ ពោលថា) (ដំរី) មិនអាចកាន់យកនូវពំនូតបាយ មិនអាចកាន់យកនូវដុំបាយ មិនអាចកាន់យកនូវស្មៅចំណីឡាយ មិនអាចត្រដុស (សរីរៈ) ទេ ខ្ញុំសំគាល់ថាដំរីបានធ្វើសេចក្ដីស្រឡាញ់ស្នេហ៍ចំពោះឆ្កែ ព្រោះការឃើញរឿយ ៗ ។

ចប់ អភិណ្ហជាតក ទី ៧ ។

## នន្ទិវិសាលជាតក

(២៨) (ព្រះសាស្ដាទ្រង់ត្រាស់ថា) បុគ្គលគប្បីនិយាយពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីនិយាយពាក្យមិនជាទីគាប់ចិត្តក្នុងកាលណាឡើយ កាលព្រាហ្មណ៍និយាយពាក្យជាទីគាប់ចិត្ត (គោនន្ទិវិសាល) បានទាញភារៈដ៏ធ្ងន់រួច ញុំាងព្រាហ្មណ៍នោះឲ្យបានទ្រព្យផង ជាសត្វមានចិត្តរីករាយដោយការញុំាងព្រាហ្មណ៍នោះឲ្យបានទ្រព្យនោះផង ។

ចប់ នន្ទិវិសាលជាតក ទី ៨ ។

## កណ្ហជាតក

(២៩) (ព្រះសាស្ដាទ្រង់ត្រាស់ថា) ធុរៈធ្ងន់ ក្នុងទីណា ៗ ផ្លូវដីជ្រៅក្នុងទីណា កាលនោះឯង ពួកជនតែងតែទឹមគោឈ្មោះកណ្ហៈ គោឈ្មោះកណ្ហៈនោះ ក៏អូសនូវធុរៈដ៏ធ្ងន់នោះទៅបាន ។

ចប់ កណ្ហជាតក ទី ៩ ។

## មុណិកជាតកំ

(៣០) មា មុណិកស្ស បិហយិ អាតុរន្នានិ ភុញ្ជតិ
អប្បោស្សុក្កោ ភុសំ ខាទ ឯតំ ទីឃាយុលក្ខណន្តិ ។

មុណិកជាតកំ ទសមំ ។

កុរុង្គវគ្គោ តតិយោ ។

## តស្សុទ្ទានំ

កុរុង្គស្ស កុក្កុរ ភោជវរោ
បុន ភណ្ឌស្សសិរិវ្ហយនោ
មហិឡាមុខ នាមនុញ្ញវរោ
វហតេ ធុរ មុណិកេន ទស ។

---



## មុណិកជាតក

(៣០) (គោពោធិសត្វឈ្មោះមហាលោហិតៈ ពោលថា) អ្នកកុំចូលចិត្ត (ភោជន) របស់ជ្រូកឈ្មោះមុណិកៈ (ព្រោះ) ជ្រូកមុណិកៈ ស៊ីភោជនក្តៅក្រហាយ អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិច ហើយស៊ីតែចំបើងចុះ នេះជាលក្ខណៈនៃអាយុវែង ។

ចប់ មុណិកជាតក ទី ១០ ។

ចប់ វគ្គទី ៣ ។

## ឧទ្ទាននៃវគ្គនោះគឺ

និយាយអំពីកុរុង្គមិគជាតក ១ កុក្កុរជាតក ១ ភោជាជានីយជាតក ១ សេះដ៏ប្រសើរ (គឺអាជញ្ញជាតក) ១ សេះសាមញ្ញនឹងសេះដ៏ប្រសើរ (គឺតិត្ថជាតក) ១ មហិឡាមុខជាតក ១ អភិណ្ហជាតក ១ បុគ្គលមិនត្រូវពោលពាក្យមិនគាប់ចិត្ត (គឺនន្ទិវិសាលជាតក) ១ គោកណ្ហសម្បុរខ្មៅ (គឺកណ្ហជាតក) ១ មុណិកជាតក ១ ត្រូវជា ១០ ។

---

## កុលាវកជាតកំ

(៣១) កុលាវកា មាតលិ សិម្ពលិស្មឹ
ឦសាមុខេន បរិវជ្ជយស្សុ
កាមំ ចជាម អសុរេសុ បាណំ
មាយិមេ ទិជា វិកុលាវា អហេសុំ ។

កុលាវកជាតកំ បឋមំ ។

## នច្ចជាតកំ

(៣២) រុទំ មនុញ្ញំ រុចិរា ច បិដ្ឋិ
វេឡុរិយវណ្ណូបដិកា(១) ច គីវា
ព្យាមមត្តានិ ច បេក្ខុណានិ
នច្ចេន តេ ធីតរំ នោ ទទាមិ ។

នច្ចជាតកំ ទុតិយំ ។

## សម្មោទមានជាតកំ

(៣៣) សម្មោទមានា គច្ឆន្តិ ជាលមាទាយ បក្ខិនោ
យទា តេ វិវទិស្សន្តិ តទា ឯហិន្តិ មេ វសំ ។

សម្មោទមានជាតកំ តតិយំ ។

១ ម. វេឡុរិយវណ្ណូបនិភា ។



## កុលាវកជាតក

(៣១) (ព្រះឥន្ទ្រពោធិសត្វ ពោលថា) ម្នាលមាតលិ ពួកកូនគ្រុឌ (ទាំង) នៅលើដើមរកា អ្នកចូរចៀសរថ (កុំឲ្យពួកវាលំបាក) ដោយមុខចន្ទោលរថឡើយ តាមពិត យើងស៊ូលះជីវិត ចំពោះពួកអសុរវិញ កុំឲ្យតែកូនគ្រុឌទាំងនេះ មានសំបុកខ្ចាត់ខ្ចាយ ។

ចប់ កុលាវកជាតក ទី ១ ។

## នច្ចជាតក

(៣២) (ស្តេចហង្សមាស ពោលថា) សំឡេងយំ (របស់អ្នក) គឺពីរោះ ខ្នងក៏ល្អស្រើន ក មានសម្បុរប្រហាក់ប្រហែលគ្នានឹងពណ៌នៃកែវពិទូរ្យ ស្លាបទាំងឡាយ ប្រមាណមួយព្យាម អញមិនឲ្យកូនស្រីដល់អ្នក ព្រោះតែការរាំឡើយ ។

ចប់ នច្ចជាតក ទី ២ ។

## សម្មោទមានជាតក

(៣៣) (ព្រានសត្វស្លាប ពោលថា) ពួកបក្សីស្រុះស្រួលគ្នានាំយកលប់ទៅបាន តែបើពួកបក្សីទាំងនោះជជែកតាស់គ្នានឹងកាលណា ពួកបក្សីទាំងនោះ នឹងលុះអំណាចអញក្នុងកាលនោះមិនខានឡើយ ។

ចប់ សម្មោទមានជាតក ទី ៣ ។

## មច្ឆជាតកំ

(៣៤) ន មំ សីតំ ន មំ ឧណ្ហំ ន មំ ជាលស្មិ ពាធនំ
យញ្ច មំ មញ្ញតេ មច្ឆី អញ្ញំ សោ រតិយា គតោតិ ។

មច្ឆជាតកំ ចតុត្ថំ ។

## វដ្ដកជាតកំ

(៣៥) សន្តិ បក្ខា អបតនា សន្តិ បាទា អវញ្ចនា
មាតា បិតា ច និក្ខន្តា ជាតវេទ បដិក្កមាតិ ។

វដ្ដកជាតកំ បញ្ចមំ ។

## សកុណជាតកំ

(៣៦) យំ និស្សិតា ជគតិរុហំ (វិហង្គមា) ស្វាយំ អគ្គឹ បមុញ្ចតិ
ទិសា ភជថ វក្កង្គា ជាតំ សរណតោ ភយន្តិ ។

សកុណជាតកំ ឆដ្ឋំ ។



## មច្ឆជាតក

(៣៤) (ត្រីឈ្មោល ពោលថា) ត្រជាក់មិន (បៀតបៀន) អញទេ ក្តៅក៏មិន (បៀតបៀន) អញដែរ ការបៀតបៀនអញព្រោះលបមិនមានឡើយ (អញ) ព្រួយតែត្រង់ត្រីញីសំគាល់អញថា ត្រីឈ្មោលនោះទៅកេត្រីញីដទៃ ដោយតម្រេក ។

ចប់ មច្ឆជាតក ទី ៤ ។

## វដ្តកជាតក

(៣៥) (កូនវដ្តបោធិសត្វ ពោលថា) ស្លាបទាំងឡាយមាន តែហើរមិនរួច ជើងទាំងឡាយមាន តែដើរមិនបាន មេនិងបា (របស់យើង) ចេញចាកទៅហើយ នែភ្លើងព្រៃ អ្នកចូរថយទៅចុះ ។

ចប់ វដ្តកជាតក ទី ៥ ។

## សកុណជាតក

(៣៦) (សត្វស្លាបពោធិសត្វ ពោលថា ពួកសត្វស្លាប) អាស្រ័យនឹងដើមឈើណា ដែលដុះលើផែនដី ដើមឈើនោះ ក៏បញ្ចេញភ្លើង ម្នាលអ្នកមានអវយវៈ (ក្បាលនឹងក) វៀចទាំងឡាយ អ្នកទាំងឡាយ ចូរគប់ទិស (ទាំង ៤) ចុះ ភ័យកើតអំពីដើមឈើជាទីពឹងហើយ ។

ចប់ សកុណជាតក ទី ៦ ។

## តិត្តិរជាតកំ

(៣៧) យេ វុឌ្ឍមបចាយន្តិ នរា ធម្មស្ស កោវិទា
ទិដ្ឋេ ធម្មេ ច បាសំសា សម្បរាយេ ច សុគ្គតិ[១] ។

តិត្តិរជាតកំ សត្តមំ ។

## ពកជាតកំ

(៣៨) នាច្ចន្តំ និកតិប្បញ្ញោ និកត្យា សុខមេធតិ
អារាធេតិ និកតិប្បញ្ញោ ពកោ កក្កដកាមិវ ។

ពកជាតកំ អដ្ឋមំ ។

## នន្ទជាតកំ

(៣៩) មញ្ញេ សោវណ្ណយោ រាសិ សោវណ្ណមាលា ច
នន្ទកោ
យត្ថ ទាសោ អាមជាតោ ឋិតោ ថុល្លានិ គជ្ជតិ ។

នន្ទជាតកំ នវមំ ។

---

១ ម. ទិដ្ឋេវ ធម្មេ បាសំសា សម្បរាយេ ច សុគតិ ។



## តិត្តិរជាតក

(៣៧) (ព្រះសាស្តាត្រាស់ថា) ពួកជនណា ជាអ្នកឈ្លាសក្នុងធម៌ ប្រព្រឹត្តកោតក្រែង ចំពោះបុគ្គលដែលចំរើនហើយ ពួកជននោះ អ្នកដទៃតែងសរសើរ ក្នុងបច្ចុប្បន្នផង សម្បរាយភព គឺសុគតិ ក៏កើត (ដល់ពួកជននោះ) ផង ។

ចប់ តិត្តិរជាតក ទី ៧ ។

## ពកជាតក

(៣៨) (ព្រះទេវតាពោធិសត្វពោលថា) បុគ្គលមានប្រាជ្ញាជាគ្រឿងបញ្ឆោត រមែងមិនដល់សេចក្តីសុខ អស់កាលជានិច្ច ព្រោះបញ្ញាជាគ្រឿងបញ្ឆោតឡើយ បុគ្គលមានប្រាជ្ញាជាគ្រឿងបញ្ឆោត (នោះ) រមែងបាន (នូវលទ្ធផលអាក្រក់) ដូចសត្វកុក (បាននូវការដាច់ក) អំពីក្តាមៗ

ចប់ ពកជាតក ទី ៨ ។

## នន្ទជាតក

(៣៩) (កុដុម្ពិកពោធិសត្វ ពោលថា) យើងសំគាល់ថា គំនរមាស និងកម្រងមាស មានក្នុងទីដែលទាសប្រុសឈ្មោះនន្ទកៈ ជាកូនរបស់ទាសស្រី ឈ្មោះគទា ឈរពោលនូវពាក្យអាក្រក់នោះ ។

ចប់ នន្ទជាតក ទី ៩ ។

## ខទិរង្គារជាតកំ

(៤០) កាមំ បតាមិ និរយំ ឧទ្ធំបាទោ អវំសិរោ
នានរិយំ ករិស្សាមិ ហន្ទ បិណ្ឌំ បដិគ្គហាតិ ។

ខទិរង្គារជាតកំ ទសមំ ។

កុលាវកវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

សមាតលិ និច្ចៈ បក្ខិវរោ
រតិយាគតកោ មាគបំកា ច បុន
ជតធីរុបហ ទ្វិជ សុគាក្កដកោ
គជា ឧទ្ធកា បិណ្ឌវរេន ទស ។



## ខទិរង្គារជាតក

(៤០) (សេដ្ឋីពោធិសត្វពោលថា) តាមពិត ខ្ញុំព្រះអង្គ ស៊ូមានជើងឡើងលើ មានក្បាលចុះក្រោម ហើយធ្លាក់ទៅកាន់នរក ខ្ញុំមិនធ្វើអំពើមិនប្រសើរទេ បើដូច្នោះ សូមព្រះអង្គ ទទួលនូវបិណ្ឌបាតចុះ ។

ចប់ ខទិរង្គារជាតក ទី ១០ ។

ចប់ កុលាវកវគ្គ ទី ៤ ។

## ឧទ្ទាននៃកុលាវកវគ្គនោះគឺ

និយាយអំពីមាតលី (គឺកុលាវកជាតក) ១ និល (គឺនច្ចជាតក) ១ ពួកបក្សីដ៏ប្រសើរ (គឺសម្មោទមានជាតក) ១ ត្រីឈ្មោលទៅដោយការស្រេក (គឺមច្ឆជាតក) ១ មេឃា (គឺវដ្ដកជាតក) ១ ដើមឈើដុះលើផែនដី (គឺសកុណជាតក) ១ បុគ្គលចំរើន (គឺតិត្តិរជាតក ១ កាមឃ្លាសៅគឺពកជាតក ១ នន្ទជាតក ១ ដុំធ្យូងដ៏ប្រសើរ គឺខទិរង្គារជាតក ១ ត្រូវជា ១០ ។

# អត្ថកាមវគ្គោ

## លោសកជាតកំ

(៤១) យោ អត្ថកាមស្ស ហិតានុកម្បិនោ
ឱវជ្ជមានោ ន ករោតិ សាសនំ
អជិយា បាទមោលុត្តោ មិត្តកោ វិយ សោចតីតិ ។

លោសកជាតកំ បឋមំ ។

## កបោតកជាតកំ

(៤២) យោ អត្ថកាមស្ស ហិតានុកម្បិនោ
ឱវជ្ជមានោ ន ករោតិ សាសនំ
កបោតកស្ស វចនំ អកត្វា
អមិត្តហត្ថត្តគតោវ សេតីតិ ។

កបោតកជាតកំ ទុតិយំ ។

# អត្ថកាមវគ្គ

## លោសកជាតក

*(៤១) (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្ដីចំរើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងសោកសៅ ដូចជាមិត្តវិន្ទុកៈប្រហារនឹងជើងនៃមេពពែសោកសៅ ។*

ចប់ លោសកជាតក ទី ១ ។

## កបោតកជាតក

*(៤២) (ព្រះពោធិសត្វ ពោលថា) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្ដីចំរើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះរមែងដេកសោកសៅ ដូចក្អែកកាំងនៅក្នុងកណ្ដាប់ដៃ នៃបុគ្គលជាសត្រូវ ព្រោះមិនធ្វើតាមពាក្យនៃសត្វព្រាប ។*

ចប់ កបោតកជាតក ទី ២ ។

## វេឡុកជាតកំ

(៦៣) យោ អត្តកាមស្ស ហិតានុកម្បិនោ
ឱវជ្ជមានោ ន ករោតិ សាសនំ
ឯវំ សោ និហតោ សេតិ វេឡុកស្ស យថា បិតាតិ ។

វេឡុកជាតកំ តតិយំ ។

## មកសជាតកំ

(៦៤) សេយ្យោ អមិត្តោ មតិយា ឧបេតោ
ន ត្វេវ មិត្តោ មតិវិប្បហីនោ
មកសំ វធិស្សន្តិ ហិ ឯឡមូគោ
បុត្តោ បិតុ អព្ភិទា ឧត្តមង្គន្តិ ។

មកសជាតកំ ចតុត្ថំ ។

## រោហិណីជាតកំ

(៦៥) សេយ្យោ អមិត្តោ មេធាវី យញ្ចេ ពាលានុកម្បកោ
បស្ស រោហិណិកំ ជម្មឹ មាតរំ ហន្ត្វាន សោចតីតិ ។

រោហិណីជាតកំ បញ្ចមំ ។





## វេឡុកជាតក

(៦៣) (ឥសីពោធិសត្វ ពោលថា) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចំរើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងដេកស្លាប់ ដូចជាបិតានៃពស់ឈ្មោះវេឡុកៈ ។

ចប់ វេឡុកជាតក ទី ៣ ។

## មកសជាតក

(៦៤) (ឈ្មួញពោធិសត្វ ពោលថា) បុគ្គលជាសត្រូវ តែប្រកបដោយប្រាជ្ញា ប្រសើរជាង ឯបុគ្គលជាមិត្ត ដែលប្រាសចាកប្រាជ្ញា មិនប្រសើរឡើយ ដូចយ៉ាងកូនបង្កើតដែលល្ងង់ខ្លៅ គិតថាអញនឹងសម្លាប់មូស ក្រឡប់ដាប់បែកក្បាលបិតាវិញ ។

ចប់ មកសជាតក ទី ៤ ។

## រោហិណីជាតក

(៦៥) (សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលជាសត្រូវ តែជាអ្នកប្រាជ្ញ ប្រសើរជាង ឯបុគ្គលពាល ជាអ្នកទំនុកបម្រុង មិនប្រសើរឡើយ អ្នកចូរមើលទាសីឈ្មោះរោហិណី ជាស្រីអាក្រក់ សម្លាប់ម្តាយ ហើយសោកសៅ ។

ចប់ រោហិណីជាតក ទី ៥ ។

## អារាមទូសកជាតកំ

(៤៦) ១. ន វេ អនត្ថកុសលេន អត្ថចរិយា សុខាវហា
ហាបេតិ អត្ថំ ទុម្មេធោ កបិ អារាមិកោ យថាតិ ។

អារាមទូសកជាតកំ ឆដ្ឋំ ។

## វារុណិទូសកជាតកំ

(៤៧) ១. ន វេ អនត្ថកុសលេន អត្ថចរិយា សុខាវហា
ហាបេតិ អត្ថំ ទុម្មេធោ កោណ្ឌញ្ញោ វារុណិំ យថាតិ ។

វារុណិទូសកជាតកំ សត្តមំ ។

## វេទព្ភជាតកំ

(៤៨) អនុបាយេន យោ អត្ថំ ឥច្ឆតិ សោ វិហញ្ញតិ
ចេតា ហនឹសុ វេទព្ភំ សព្វេ តេ ព្យសនមជ្ឈគូតិ ។

វេទព្ភជាតកំ អដ្ឋមំ ។



## អារាមទូសកជាតក

(៤៦) (បណ្ឌិតបុរសពោធិសត្វ ពោលថា) ការប្រព្រឹត្តិនូវសេចក្តីចំរើនរបស់អ្នកមិនឈ្លាសក្នុងហេតុចំរើន រមែងមិននាំមកនូវសេចក្តីសុខទេ បុគ្គលឥតប្រាជ្ញ តែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចស្វារក្សាសួន (បានធ្វើប្រយោជន៍ឲ្យវិនាស) ។

ចប់ អារាមទូសកជាតក ទី ៦ ។

## វារុណិទូសកជាតក

(៤៧) (សេដ្ឋីពោធិសត្វ ពោលថា) ការប្រព្រឹត្តិនូវសេចក្តីចំរើនរបស់អ្នកមិនឈ្លាសក្នុងហេតុចំរើន រមែងមិននាំមកនូវសេចក្តីសុខទេ បុគ្គលឥតប្រាជ្ញ តែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចកោណ្ឌញ្ញៈ បានញុំាំងស្រាឲ្យវិនាស ។

ចប់ វារុណិទូសកជាតក ទី ៧ ។

## វេទព្ភជាតក

(៤៨) (ក្មេងសិស្សពោធិសត្វ ពោលថា) បុគ្គលណា ប្រាថ្នាសេចក្តីចំរើន ដោយអនុបាយ បុគ្គលនោះ រមែងលំបាក ដូចពួកចោរនៅក្នុងដែនចេតៈ បានសម្លាប់នូវវេទព្ភព្រាហ្មណ៍ ហើយទាំងអស់នោះ ក៏ដល់នូវសេចក្តីវិនាស ។

ចប់ វេទព្ភជាតក ទី ៨

## នក្ខត្តជាតកំ

(៤៩) នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា
អត្ថោ អត្ថស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកា ។

នក្ខត្តជាតកំ នវមំ ។

## ទុម្មេធជាតកំ

(៥០) ទុម្មេធានំ សហស្សេន យញ្ញោ មេ ឧបយាចិតោ
ឥទានិ ខោហំ យជិស្សាមិ ពហុ អធម្មិកោ ជនោ ។

ទុម្មេធជាតកំ ទសមំ ។

អត្ថកាមវគ្គោ បញ្ចមោ ។

បឋមបណ្ណាសកោ ។

## តស្សុទ្ទានំ

អថ មិត្តកាមាតុ កាបោតវរោ
អថ វេឡុក ឋលម្ភោតា រោហិណិ
ឥថ ការុណិ ចេតបោ ច បុន
អថ តារក យញ្ញវរេន ទស ។

---



## នក្ខត្តជាតក

(៤៩) (បណ្ឌិតបុរសពោធិសត្វ ពោលថា) ប្រយោជន៍បានកន្លងផុតនូវមនុស្សល្ងង់ ដែលរង់ចាំនូវនក្ខត្តឫក្ស (ព្រោះ) សេចក្តីចំរើននៃប្រយោជន៍ ឈ្មោះថានក្ខត្តឫក្ស តើផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

ចប់ នក្ខត្តជាតក ទី ៩ ។

## ទុម្មេធជាតក

(៥០) (ព្រះកុមារពោធិសត្វ ពោលថា) ការបួង អញបានបន់ស្រន់ហើយ ដោយសារមនុស្សអាប់ប្រាជ្ញាមួយពាន់នាក់ ឥឡូវនេះ អញនឹងបួង (ព្រោះ) ជនមិនប្រកបដោយធម៌ច្រើននាក់ ។

ចប់ ទុម្មេធជាតក ទី ១០ ។

ចប់ អត្ថកាមវគ្គ ទី ៥ ។

ចប់ បឋមបណ្ណាសក ។

## ឧទ្ទាននៃអត្ថកាមវគ្គនោះគឺ

និយាយអំពីមិត្តនៃគេ: (គឺលោសកជាតក)១ កាបោតកជាតក ១ វេឡុកជាតក ១ បុគ្គលល្ងង់ខ្លៅ (គឺមកសជាតក)១ រោហិណីជាតក ១ ស្វា(គឺអារាមទូសកជាតក)១ វារុណិទូសកជាតក ១ ចោរនៅក្នុងដៃនៃគេ: (គឺវេទព្ភជាតក)១ ផ្កាយ(គឺនក្ខត្តជាតក)១ ការបួង(គឺទុម្មេធជាតក)១ ត្រូវជា ១០ ។

អាសីសវគ្គោ

## មហាសីលវជាតកំ

(៥១) អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ យថា ឥច្ឆឹ តថា អហុ ។

មហាសីលវជាតកំ បឋមំ ។

## ចូឡជនកជាតកំ

(៥២) វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ ឧទកា ថលមុព្ភតំ ។

ចូឡជនកជាតកំ ទុតិយំ ។

## បុណ្ណបាតិជាតកំ

(៥៣) តថេវ បុណ្ណា បាតិយោ អញ្ញាយំ វត្តតេ កថា
អាការកេន(១) ជានាមិ នចាយំ ភទ្ទិកា សុរា ។

បុណ្ណបាតិជាតកំ តតិយំ ។

អាសីសវគ្គ

## មហាសីលវជាតក

(៥១) (ព្រះរាជាសីលវៈពោធិសត្វ ពោលថា) បុរសជាបណ្ឌិត គប្បីប៉ុនប៉ងឲ្យមុតមាំ មិនគប្បីនឿយណាយឡើយ យើងឃើញខ្លួនយើងស្រាប់ហើយ យើងប្រាថ្នាយ៉ាងណា បានយ៉ាងនោះ ។

ចប់ មហាសីលវជាតក ទី ១ ។

## ចូឡជនកជាតក

(៥២) (ព្រះបាទជនកពោធិសត្វ ពោលថា) បុរសជាបណ្ឌិត ត្រូវតែប្រឹងប្រែង មិនត្រូវនឿយណាយឡើយ យើងឃើញខ្លួនយើងដែលឡើងអំពីទឹក កាន់គោកស្រាប់ហើយ ។

ចប់ ចូឡជនកជាតក ទី ២ ។

## បុណ្ណបាតិជាតក

(៥៣) (សេដ្ឋីពោធិសត្វ ពោលថា) ភាជន៍សុរានៅពេញដដែល តែសំដីចេញទៅដោយឡែក យើងដឹងបាន ដោយហេតុ (នេះ) សុរានេះមិនមែនស្រួលទេ ។

ចប់ បុណ្ណបាតិជាតក ទី ៣ ។

១ ឱ. អាការកេន ។

## ផលជាតកំ

(៥៤) នាយំ រុក្ខោ ទុរារុហោ ន បិ គាមតោ អារកា
អាការកេន ជានាមិ នាយំ សាទុផលោ ទុមោ ។

ផលជាតកំ ចតុត្ថំ ។

## បញ្ចាវុធជាតកំ

(៥៥) យោ អលីនេន ចិត្តេន អលីនមនសោ នរោ
ភាវេតិ កុសលំ ធម្មំ យោគក្ខេមស្ស បត្តិយា
បាបុណេ អនុបុព្វេន សព្វសំយោជនក្ខយន្តិ ។

បញ្ចាវុធជាតកំ បញ្ចមំ ។

## កញ្ចនក្ខន្ធជាតកំ

(៥៦) យោ បហដ្ឋេន ចិត្តេន បហដ្ឋមនសោ នរោ
ភាវេតិ កុសលំ ធម្មំ យោគក្ខេមស្ស បត្តិយា
បាបុណេ អនុបុព្វេន សព្វសំយោជនក្ខយន្តិ ។

កញ្ចនក្ខន្ធជាតកំ ឆដ្ឋំ ។



## ផលជាតក

(៥៤) (ឈ្មួញនោះជាពោធិសត្វ ពោលថា) ឈើនេះ មិនមែនលំបាកឡើងទេ ទាំងមិនឋិតនៅឆ្ងាយអំពីស្រុក ខ្ញុំដឹងបានដោយអាការៈ(នេះ) ឈើនេះ មិនមែនមានផ្លែស្រួលទេ ។

ចប់ ផលជាតក ទី ៤ ។

## បញ្ចាវុធជាតក

(៥៥) (ព្រះសាស្តា ទ្រង់ត្រាស់ថា) បុរសណា មានចិត្តមិនរួញរា ចំរើនកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តមិនរួញរា បុរសនោះ គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួង តាមលំដាប់ ។

ចប់ បញ្ចាវុធជាតក ទី ៥ ។

## កញ្ចនក្ខន្ធជាតក

(៥៦) (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) បុរសណា មានចិត្តរីករាយ ចំរើនកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តដែលរីករាយ បុរសនោះ គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួង តាមលំដាប់ ។

ចប់ កញ្ចនក្ខន្ធជាតក ទី ៦ ។

## វានរិន្ទជាតកំ

(៨៧) យស្សេតេ ចតុរោ ធម្មា វានរិន្ទ យថា តវ
សច្ចំ ធម្មោ ធិតិ ចាគោ ទិដ្ឋំ សោ អតិវត្តតិ ។

វានរិន្ទជាតកំ សត្តមំ ។

## តយោធម្មជាតកំ

(៨៨) យស្សេតេ ច តយោ ធម្មា វានរិន្ទ យថា តវ
ទក្ខិយំ សូរិយំ បញ្ញា ទិដ្ឋំ សោ អតិវត្តតិ ។

តយោធម្មជាតកំ អដ្ឋមំ ។

## ភេរិវាទជាតកំ

(៨៩) ធមេ ធមេ នាតិធមេ អតិធន្តំ ហិ បាបកំ
ធមេន្តេន[១] សតំ លទ្ធំ អតិធន្តេន នាសិតំ ។

ភេរិវាទជាតកំ នវមំ ។

១ ម. ធមន្តេន ហិ ។



## វានរិន្ទជាតក

(៨៧) (ក្រពើ ពោលថា) បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក គឺសេចក្តីទៀងត្រង់ ១ ធម៌គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការលះ ១ បុគ្គលនោះ រមែងកន្លងនូវបង់ខ្លួសត្រូវបាន ។

ចប់ វានរិន្ទជាតក ទី ៧ ។

## តយោធម្មជាតក

(៨៨) (រាក្សសទឹក ពោលថា) បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៣ ដូចអ្នក គឺសេចក្តីស្ទាត់ ១ សេចក្តីក្លៀវក្លា ១ បញ្ញា ១ បុគ្គលនោះ រមែងកន្លងនូវបង់ខ្លួសត្រូវបាន ។

ចប់ តយោធម្មជាតក ទី ៨ ។

## ភេរិវាទជាតក

(៨៩) (អ្នកវាយស្គរពោធិសត្វ ពោលថា) បុគ្គលគប្បីវាយ (ស្គរ) ចុះ ប៉ុន្តែកុំវាយឲ្យជ្រុល ព្រោះការវាយស្គរជ្រុល ជាការអាក្រក់ កហាបណៈមួយរយ ដែលបានហើយដោយការវាយស្គរ (ក្នុងកំឡុង) វិនាសហើយ ដោយការវាយស្គរជ្រុល ។

ចប់ ភេរិវាទជាតក ទី ៩ ។

## សង្ខធមនជាតកំ

(៦០) ធមេ ធមេ នាតិធមេ អតិធន្តំ ហិ បាបកំ
ធន្តេនាធិគតា ភោគា តេ តាតោ វិធមី ធមន្តិ ។

សង្ខធមនជាតកំ ទសមំ ។

អាសីសវគ្គោ ឆដ្ឋោ ។

## តស្សុទ្ទានំ

យថា វត្ថិ គតាហុ ឧទកា ផលា
សុរ សាធុជលោរ៍ អាលីនមនោ
សំបហដ្ឋមនោ ធម្មេ ច តយោ
សកលទ្ធកោភកធមេន ធម ។

---





## សង្ខធមនជាតក

(៦០) (អ្នកផ្លុំស័ង្ខពោធិសត្វ ពោលថា) បុគ្គលគប្បីផ្លុំ (ស័ង្ខ) ចុះ ប៉ុន្តែកុំគប្បីផ្លុំឲ្យជ្រុល ព្រោះការផ្លុំជ្រុល ជាការអាក្រក់ ភោគៈទាំងឡាយដែលបានហើយដោយការផ្លុំ បិតាផ្លុំបំផ្លាញភោគៈទាំងនោះ ។

ចប់ សង្ខធមនជាតក ទី ១០ ។

ចប់ អាសីសវគ្គ ទី ៦ ។

## ឧទ្ទាននៃអាសីសវគ្គនោះគឺ

និយាយអំពីអ្នកប្រាថ្នាប្រាថ្នាយ៉ាងណា ប្រយោជន៍ក៏កើតយ៉ាងនោះ (គឺមហាសីលវជាតក)១ ការឡើងអំពីទឹកមកកាន់គោក (គឺចូឡជនកជាតក)១ សុរា(គឺបុណ្ណបាតិជាតក)១ ឈើមានផ្លែមិនស្រួល (គឺផលជាតក)១ បុរសមានចិត្តមិនរួញរា (គឺបញ្ចាវុធជាតក)១ បុរសមានចិត្តរីករាយ(គឺកញ្ចនក្ខន្ធជាតក)១ ធម៌ ៤ (គឺវានរិន្ទជាតក)១ ធម៌ ៣ (គឺតយោធម្មជាតក)១ ការបានកហាបណៈមួយរយ (គឺភេរិវាទជាតក)១ ផ្លុំស័ង្ខបានភោគៈ (គឺសង្ខធមនជាតក)១ ត្រូវជា ១០ ។

# ឥត្ថីវគ្គោ

## អសាតមន្តជាតកំ

(៦១) អសា លោកិត្ថិយោ នាម វេលា តាសំ ន វិជ្ជតិ
សារត្តា ច បគព្ភា ច សិខី សព្វឃសោ យថា
តា ហិត្វា បព្វជិស្សាមិ វិវេកមនុព្រូហយន្តិ ។

អសាតមន្តជាតកំ បឋមំ ។

## អណ្ឌភូតជាតកំ

(៦២) យំ ព្រាហ្មណោ អវាទេសិ វីណំ សម្មុខវេឋិតោ
អណ្ឌភូតា ភតា ភរិយា តាសុ កោ ជាតុ វិស្សសេតិ ។

អណ្ឌភូតជាតកំ ទុតិយំ ។

# ឥត្ថីវគ្គ

## អសាតមន្តជាតក

(៦១) (មាណពពោលថា) ឈ្មោះថាពួកស្ត្រីក្នុងលោក តែងមានសេចក្តីប្រាថ្នា (ចំពោះបុរសដែលមានចិត្តជាប់ចំពោះខ្លួន) វេលា (ឬកម្រិត) របស់ស្ត្រីទាំងនោះ មិនមានឡើយ (ស្ត្រីទាំងនោះ) ត្រេកត្រអាលផង រណោរណៅផង ដូចភ្លើងដែលឆេះវត្ថុគ្រប់យ៉ាង (មិនរើសមុខ) ខ្ញុំនឹងលះបង់ស្ត្រីទាំងនោះហើយបួស ចំរើននូវវិវេកធម៌ ។

ចប់ អសាតមន្តជាតក ទី ១ ។

## អណ្ឌភូតជាតក

(៦២) (ព្រះពោធិសត្វទ្រង់ត្រាស់ថា) ព្រាហ្មណ៍ បាំងមុខរបស់ខ្លួន ហើយដេញពិណដោយហេតុណា (មិនដឹងហេតុនោះទេ) ប្រពន្ធដែលខ្លួនចិញ្ចឹមតាំងពីនៅជាអណ្ឌៈ (កូននៅក្នុងពង) អ្នកណាគប្បីទុកចិត្តចំពោះប្រពន្ធទាំងនោះ ដោយដាច់ខាតបាន ។

ចប់ អណ្ឌភូតជាតក ទី ២ ។

## តក្កជាតកំ

(៦៣) កោធនា អកតញ្ញូ ច បិសុណា ច វិភេទិកា (១)
ព្រហ្មចរិយំ ចរ ភិក្ខុ សោ សុខំ ន វិហាហិសីតិ ។

តក្កជាតកំ តតិយំ ។

## ទុរាជានជាតកំ

(៦៤) មា សុ នន្ទិ ឥច្ឆតិ មំ មា សុ សោចិ ន ឥច្ឆតិ
ថីនំ ភាវោ ទុរាជានោ មច្ឆស្សេវោទកេ គតន្តិ ។

ទុរាជានជាតកំ ចតុត្ថំ ។

## អនភិរតិជាតកំ

(៦៥) យថា នទី ច បន្ថោ ច បានាគារំ សភា បបា
ឯវំ លោកិត្ថិយោ នាម នាសំ កុជ្ឈន្តិ បណ្ឌិតាតិ ។

អនភិរតិជាតកំ បញ្ចមំ ។

---

១ ម. បិសុណា មិត្តភេទិកា ។



## តក្កជាតក

(៦៣) (ព្រះសាស្តាទ្រង់ត្រាស់ថា) (ពួកស្ត្រី) ច្រើនទឹង មិនដឹងឧបការៈ ដែលគេធ្វើដល់ខ្លួន ជាអ្នកញុះញង់ ចំបែកបំបាក់មិត្ត ម្នាលភិក្ខុ អ្នកចូរប្រព្រឹត្តព្រហ្មចរិយៈចុះ អ្នកនោះនឹងមិនឃ្លាតសេចក្ដីសុខ ។

ចប់ តក្កជាតក ទី ៣ ។

## ទុរាជានជាតក

(៦៤) (កាលទ្រង់ប្រារព្ធឧបាសកម្នាក់ ត្រាស់ថា) អ្នកកុំត្រេកអរ (ថាស្ត្រីនេះ) ប្រាថ្នាអញ កុំសោកសៅ (ថាស្ត្រីនេះ) មិនប្រាថ្នាអញ ភាពរបស់ស្ត្រីទាំងឡាយ ដឹងបានដោយក្រ ដូចជាដំណើរទៅនៃត្រីក្នុងទឹក ។

ចប់ ទុរាជានជាតក ទី ៤ ។

## អនភិរតិជាតក

(៦៥) (កាលទ្រង់ប្រារព្ធឧបាសកម្នាក់ ត្រាស់ថា) ទន្លេក្ដី ផ្លូវក្ដី ទៀមស្រាក្ដី សាលាសំណាក់ក្ដី អណ្ដូងទឹកក្ដី (ជារបស់សាធារណៈ) យ៉ាងណា ពួកស្ត្រីទាំងឡាយ ក្នុងលោក គឺយ៉ាងនោះដែរ បណ្ឌិតទាំងឡាយ មិនខឹងនឹងស្ត្រីទាំងនោះទេ ។

ចប់ អនភិរតិជាតក ទី ៥ ។

## មុទុលក្ខណជាតកំ

(៦៦) ឯកា ឥច្ឆា បុរេ អាសិ អលទ្ធា មុទុលក្ខណំ
យតោ លទ្ធា អឡារក្ខី ឥច្ឆា ឥច្ឆំ វិជាយថាតិ ។

មុទុលក្ខណជាតកំ ឆដ្ឋំ ។

## ឧច្ឆង្គជាតកំ

(៦៧) ឧច្ឆង្គេ ទេវ មេ បុត្តោ បថេ ធាវន្តិយា បតិ
តញ្ច ទេសំ ន បស្សាមិ យតោ សោទរិយំ អានយេតិ ។

ឧច្ឆង្គជាតកំ សត្តមំ ។

## សាកេតជាតកំ

(៦៨) យស្មឹ មនោ និវិសតិ ចិត្តញ្ចាបិ បសីទតិ
អទិដ្ឋបុព្វកេ បោសេ កាមំ តស្មឹបិ វិស្សសេតិ ។

សាកេតជាតកំ អដ្ឋមំ ។





## មុទុលក្ខណជាតក

(៦៦) (ឥសីពោធិសត្វ ពោលថា) មុនអំពីកាលដែលមិនទាន់បាននូវនាងមុទុលក្ខណា សេចក្តីប្រាថ្នាមានតែមួយ កាលណាអាត្មាអញបាននាងមុទុលក្ខណា ជាស្រីមានភ្នែកល្អហើយ សេចក្តីប្រាថ្នានោះក៏តែញុំាងសេចក្តីប្រាថ្នា (ផ្សេងៗ) ឲ្យកើតឡើងទៀត ។

ចប់ មុទុលក្ខណជាតក ទី ៦ ។

## ឧច្ឆង្គជាតក

(៦៧) (ស្រីម្នាក់ ពោលថា) បពិត្រព្រះសម្មតិទេព កូនរបស់ខ្ញុំព្រះអង្គ (ដូចជាអន្លក់ដែលដក់) ក្នុងថ្នក់ (បានដោយងាយ) ស្រីដែលដើរទៅតាមផ្លូវរកប្តី (បានដោយងាយ) ចំណែកខ្ញុំព្រះអង្គមិនឃើញប្រទេស គឺផ្ទៃមាតានោះ ដែលខ្ញុំព្រះអង្គគួរនាំយកបងប្អូនប្រុសបង្កើតមកបាន ។

ចប់ ឧច្ឆង្គជាតក ទី ៧ ។

## សាកេតជាតក

(៦៨) (ព្រះសាស្តាទ្រង់ត្រាស់ថា) ចិត្តតាំងនៅស៊ប់ ឬក៏ចិត្តជ្រះថ្លា ក្នុងបុគ្គលណា ដែលខ្លួនមិនធ្លាប់ឃើញហើយ ជនតែងស្និទ្ធស្នាលចំពោះបុគ្គលនោះ ដោយពិត ។

ចប់ សាកេតជាតក ទី ៨ ។

## វិសវន្តជាតកំ

(៦៩) ធិរត្ថុ តំ វិសំ វន្តំ យមហំ ជីវិតការណា
វន្តំ បច្ចាវមិស្សាមិ(១) មតំ មេ ជីវិតា វរំ ។

វិសវន្តជាតកំ នវមំ ។

## កុទ្ទាលជាតកំ

(៧០) ន តំ ជិតំ សាធុ ជិតំ យំ ជិតំ អវជីយតិ
តំ ខោ ជិតំ សាធុ ជិតំ យំ ជិតំ នាវជីយតីតិ ។

កុទ្ទាលជាតកំ ទសមំ ។

ឥត្ថីវគ្គោ សត្តមោ ។

## តស្សុទ្ទានំ

សង្ខី សត្តុស្សោបេច វីណាវេក
បំសុណា មិត្តកេនិកា ឧដ្ឋិ ឧតី
មុទុលក្ខណា សោតរិយា ច មតោ
វិស សាធុជិតេន ភវន្តិ ទស ។

---

១ ម. បច្ចាវមិស្សំ ។





## វិសវន្តជាតក

(៦៩) (ពស់ពោលថា) អញនឹងស្រូបយកពិសណាវិញ ដែលអញបានខ្ជាក់ចោលហើយ ព្រោះហេតុនៃជីវិត ចូរតិះដៀលនូវពិសដែលអញខ្ជាក់ចោលហើយនោះចុះ អញស្លាប់ប្រសើរជាងរស់នៅ ។

ចប់ វិសវន្តជាតក ទី ៩ ។

## កុទ្ទាលជាតក

(៧០) (កុទ្ទាលកបណ្ឌិតពោធិសត្វ ពោលថា) សេចក្តីឈ្នះណា ត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ មិនឈ្មោះថា ឈ្នះប្រពៃទេ សេចក្តីឈ្នះណា មិនត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ ទើបឈ្មោះថា ឈ្នះប្រពៃមែនពិត ។

ចប់ កុទ្ទាលជាតក ទី ១០ ។

ចប់ ឥត្ថីវគ្គ ទី ៧ ។

## ឧទ្ទាននៃឥត្ថីវគ្គនោះគឺ

និយាយអំពីស្រីនៅរក្សាគ្រប់យាម(ក្នុងអសាតមន្តជាតក) ១ ពិណដ៏ប្រសើរ(ក្នុងអណ្ឌភូតជាតក) ១ ស្ត្រីជាអ្នកញុះញង់នឹងបំបែកបំបាក់មិត្ត(ក្នុងតក្កជាតក) ១ ការក្រោកអរ(ក្នុងទុរាជានជាតក) ១ ស្ទឹង(ក្នុងអនភិរតិជាតក) ១ នាងមុទុលក្ខណា(ក្នុងមុទុលក្ខណជាតក) ១ បងប្អូន(ក្នុងឧច្ឆង្គជាតក) ១ ចិត្ត(ក្នុងសាកេតជាតក) ១ ពិស(ក្នុងវិសវន្តជាតក) ១ សេចក្តីឈ្នះប្រពៃ(ក្នុងកុទ្ទាលជាតក) ១ ត្រូវជា ១០ ។

# វរុណវគ្គោ

## វរុណជាតកំ

(៧១) យោ បុព្វេ ករណីយានិ　បច្ឆា សោ កាតុមិច្ឆតិ
វរុណកដ្ឋំ ភញ្ជោវ　ស បច្ឆា អនុតប្បតិ ។

វរុណជាតកំ បឋមំ ។

## សីលវនាគជាតកំ

(៧២) អកតញ្ញុស្ស បោសស្ស　និច្ចំ វិវរទស្សិនោ
សព្វញ្ចេ បឋវឹ ទជ្ជា　នេវ នំ អភិរាធយេ ។

សីលវនាគជាតកំ ទុតិយំ ។

## សច្ចង្កិរជាតកំ

(៧៣) សច្ចំ កិរេវមាហំសុ　នរា ឯកច្ចិយា ឥធ
កដ្ឋំ និប្លវិតំ(១) សេយ្យោ　នត្វេវេកច្ចិយោ នរោ ។

សច្ចង្កិរជាតកំ តតិយំ ។

---
១ ម. និប្លវិតំ ។

# វរុណវគ្គ

## វរុណជាតក

(៧១) (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) អំពើទាំងឡាយ ដែលគេគួរធ្វើក្នុងកាលមុន ជនណាប្រាថ្នាធ្វើខាងក្រោយវិញ ជននោះ រមែងក្តៅក្រហាយក្រោយ ៗ ក្នុងកាលជាខាងក្រោយ ដូចជាមាណព ដែលកាច់មែកឈើស្រស់ ។

ចប់ វរុណជាតក ទី ១ ។

## សីលវនាគជាតក

(៧២) (រុក្ខទេវតា ពោលថា) ប្រសិនបើគេឲ្យផែនដីទាំងមូលដល់បុរសអកតញ្ញូ ជាអ្នកឃើញតែទោសជានិច្ច ក៏មិនគប្បីញុំាងបុរសអកតញ្ញូនោះឲ្យត្រេកអរបានឡើយ ។

ចប់ សីលវនាគជាតក ទី ២ ។

## សច្ចង្កិរជាតក

(៧៣) (តាបសពោធិសត្វ ពោលថា) បានឮថា ជនពួកខ្លះ ក្នុងលោកនេះ បាននិយាយពាក្យនេះថា ឈើដែលគេស្រង់ឡើងអំពីទឹក ប្រសើរជាង ជនពួកខ្លះដែលគេស្រង់ឡើង (អំពីទឹក) មិនប្រសើរឡើយ ។

ចប់ សច្ចង្កិរជាតក ទី ៣ ។

## រុក្ខធម្មជាតកំ

(៧៤) សាធូ សម្ពហុលា ញាតី អបិ រុក្ខា អរញ្ញជា
វាតោ វហតិ ឯកដ្ឋំ ព្រហន្តម្បិ វនប្បតិន្តិ ។

រុក្ខធម្មជាតកំ ចតុត្ថំ ។

## មច្ឆជាតកំ

(៧៥) អភិត្ថនយ បជ្ជុន្ន និធឹ កាកស្ស នាសយ
កាកំ សោកាយ រន្ធេហិ មញ្ច សោកា បមោចយាតិ ។

មច្ឆជាតកំ បញ្ចមំ ។

## អសង្កិយជាតកំ

(៧៦) អសង្កិយោម្ហិ គាមម្ហិ អរញ្ញេ នត្ថិ មេ ភយំ
ឧជុមគ្គំ សមារុឡ្ហោ មេត្តាយ ករុណាយ ចាតិ ។

អសង្កិយជាតកំ ឆដ្ឋំ ។



## រុក្ខធម្មជាតក

(៧៤) (ព្រះទេវតាពោធិសត្វ ពោលថា) មានពួកញាតិច្រើននាក់ ប្រពៃ សូម្បីពួកឈើ ដែលដុះក្នុងព្រៃច្រើនដើម ក៏ប្រពៃដែរ ឯខ្យល់រមែងរំលំ នូវឈើដាច់ក្នុងព្រៃ បរិបូណ៌ដោយមែកធំប្រាកដ ដែលតាំងនៅតែឯង ។

ចប់ រុក្ខធម្មជាតក ទី ៤ ។

## មច្ឆជាតក

(៧៥) (ព្រះពោធិសត្វ ពោលថា) បជ្ជុន្នមេឃ សូមអ្នកញុំាងផ្គរឲ្យលាន់ឡើង សូមបំផ្លាញកំណប់របស់ក្អែកឲ្យវិនាស សូមធ្វើក្អែកឲ្យសោកសៅ សូមញុំាងខ្ញុំ(និងពួកញាតិខ្ញុំ)ឲ្យរួចចាកសេចក្ដីសោក ។

ចប់ មច្ឆជាតក ទី ៥ ។

## អសង្កិយជាតក

(៧៦) (តាបសពោធិសត្វ ពោលថា) យើងជាអ្នកមិនមានសេចក្ដីរង្កៀស ក្នុងស្រុក យើងជាអ្នកមិនមានភ័យ ក្នុងព្រៃ បានឡើងកាន់ផ្លូវត្រង់ ដោយមេត្តានិងករុណាហើយ ។

ចប់ អសង្កិយជាតក ទី ៦ ។

# មហាសុបិនជាតកំ

(៧៧) ឧសភា រុក្ខា គាវិយោ គវា ច
អស្សោ កំសោ សិគាលី ច កុម្ភោ
បោក្ខរណី ច អបាកចន្ទនំ
លាពូនិ សីទន្តិ សិលា ប្លវន្តិ
មណ្ឌូកិយោ កណ្ហសប្បេ គិលន្តិ
កាកំ សុវណ្ណា បរិវារយន្តិ
តសា វកា ឯឡកានំ ភយា ហិ
វិបរិយាសោ វត្តតិ នយិធមត្ថីតិ ។

មហាសុបិនជាតកំ សត្តមំ ។

# ឥល្លិសជាតកំ

(៧៨) ឧភោ ខញ្ជា ឧភោ កុណី ឧភោ វិសមចក្ខុកា
ឧភិន្នំ បិឡកា ជាតា នាហំ បស្សាមិ ឥល្លិសន្តិ ។

ឥល្លិសជាតកំ អដ្ឋមំ ។



# មហាសុបិនជាតក

(៧៧) (ព្រះរាជាទ្រង់ក្រាស់ថា មហាសុបិន ១៦ គឺ) គោឧសភទាំងឡាយ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ ១ ភាជន៍ (មាស) ១ មេចចក ១ ក្អម ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយអណ្តែត ១ មេកង្កែបទាំងឡាយទំពាស៊ីពស់វែកទាំងឡាយ ១ កងហង្សមាសទាំងឡាយចោមរោមក្អែក ១ ឆ្កែចចកទាំងឡាយ (តក់ស្លុត) ព្រោះភ្ញាក់ផ្អើល ដោយសេចក្តីខ្លាចអំពីពពែទាំងឡាយ ១ បរិយាយដ៏វិបរិតប្រព្រឹត្តទៅ ន័យទាំងឡាយមានក្នុងសុបិនទាំងនេះ ។

ចប់ មហាសុបិនជាតក ទី ៧ ។

# ឥល្លិសជាតក

(៧៨) (ជាងកោរសក់ពោលចំពោះស្តេច ថា) ជនទាំងពីរនាក់ខ្វិន ជនទាំងពីរនាក់ក្ញិន ជនទាំងពីរនាក់មានភ្នែកស្រលៀង ពកកើត (លើក្បាល) របស់ជនទាំងពីរនាក់ ខ្ញុំព្រះអង្គមិនស្គាល់ (អ្នកណា) ជាឥល្លិសសេដ្ឋីទេ ។

ចប់ ឥល្លិសជាតក ទី ៨ ។

## ខរស្សរជាតកំ

(៧៩) យតោ វិលុត្តា ច ហតា ច គាវោ
ទឌ្ឍានិ គេហានិ ជនោ ច នីតោ
អថាគមា បុត្តហតាយ បុត្តោ
ខរស្សរំ ឌេណ្ឌិមំ វាទយន្តោ ។

ខរស្សរជាតកំ នវមំ ។

## ភីមសេនជាតកំ

(៨០) យន្តេ បវិកត្ថិតំ បុរេ
អថ តេ បូតិសរា សជន្តិ បច្ឆា
ឧភយំ ន សមេតិ ភីមសេន
យុទ្ធកថា ច ឥទញ្ច តេ វិហញ្ញតិ ។

ភីមសេនជាតកំ ទសមំ ។

វរុណវគ្គោ អដ្ឋមោ ។



## ខរស្សរជាតក

(៧៩) (ពាណិជពោធិសត្វ ពោលថា) កាលណា (ពួកចោរ) ប្លន់ សម្លាប់គោទាំងឡាយ ដុតផ្ទះទាំងឡាយ និងនាំជនយកទៅហើយ ក្នុងកាលនោះ កូនរបស់ស្ត្រីដែលមានកូនស្លាប់ហើយ (គឺចៅហ្វាយស្រុកឥតមានសេចក្តីអៀនខ្មាស) វាយស្គរឲ្យមានសំឡេងទ្រាំង ដើរមក ។

ចប់ ខរស្សរជាតក ទី ៩ ។

## ភីមសេនជាតក

(៨០) (ចូឡធនុគ្គហបណ្ឌិតពោធិសត្វ ពោលថា) ម្នាលភីមសេន ក្នុងកាលមុន ឯងបានអួតហើយ ក្នុងកាលក្រោយ ស្រាប់តែគ្រឿងសំអុយសម្រាប់ហូរចេញ (កាចម៍) របស់ឯង ហូរចេញមក ហេតុទាំងពីរមិនសមគ្នា គឺការនិយាយអំពីចំបាំងនឹងការចង្អៀតចង្អល់ចិត្តរបស់ឯងនេះ ។

ចប់ ភីមសេនជាតក ទី ១០ ។

ចប់ វរុណវគ្គ ទី ៨ ។

# គស្សព្ទាធិ

ពុណា អភាគញ្ញាបែ ចុ សម្ពុទ្ធ

សាវខត្តិតា ៨ អភិញ្ញូមយ

ករុណាយ សីលាបូរ វេល្យិសពោ

បុណ ធិតិ ឬតិសារេខ ធស ។

---



# ខ្លាំងនៃពុណវត្តជោះគឺ

និយាយអំពីព្រះជាតក ១ អកតញ្ញូ(ក្នុងសីលវនាគជាតក) ១ ពាក្យពិតដ៏ប្រសើរ (ក្នុងសច្ចំកិរជាតក) ១ ឈើម្ចាស់ព្រៃ (ក្នុងរុក្ខធម្មជាតក) ១ ការធ្វើឲ្យផ្លូវភ្លៀងធ្លាក់ (ក្នុងមច្ឆជាតក) ១ ករុណា (ក្នុងអសម្ពទ្ធិយជាតក) ១ ចម្ងល់ (ក្នុងមហាសុបិនជាតក) ១ ល្បិចសេដ្ឋី (ក្នុងល្បិចសជាតក) ១ ស្គរ (ក្នុងខរស្សរជាតក) ១ គ្រឿងសំអុយសម្រាប់ហូបចេញ (ក្នុងភីមសេនជាតក) ១ គ្រប់ជា ១០ ។

# អបាយិម្ហវគ្គោ

## សុរាបានជាតកំ

(៨១) អបាយិម្ហ អនច្ចិម្ហ អគាយិម្ហ រុទិម្ហ ច
វិសញ្ញីករណឹ បិត្វា ទិដ្ឋា នាហុម្ហ វានរាតិ ។

សុរាបានជាតកំ បឋមំ ។

## មិត្តវិន្ទជាតកំ

(៨២) អតិក្កម្ម រមណកំ សទាមត្តញ្ច ទូភកំ(១)
ស្វាសិ បាសាណមាសីនោ យស្មា ជីវំ ន មោក្ខសីតិ ។

មិត្តវិន្ទជាតកំ ទុតិយំ ។

## កាឡកណ្ណិជាតកំ

(៨៣) មិត្តោ ហវេ សត្តបទេន ហោតិ
សហាយោ បន ទ្វាទសកេន ហោតិ

១ ម. ទូភកំ ។

# អបាយិម្ហវគ្គ

## សុរាបានជាតក

(៨១) (ពួកតាបស ពោលថា) ពួកយើងបានផឹកសុរា បានរាំ បានច្រៀង បានយំហើយ ពួកយើង មិនមែនជាពានរៈ ព្រោះតែផឹកសុរា ដែលធ្វើឲ្យវង្វេងសញ្ញា ទើបឃើញ (កាព្រក់ជាល្អ) ។

ចប់ សុរាបានជាតក ទី ១ ។

## មិត្តវិន្ទជាតក

(៨២) (ទេវបុត្រពោធិសត្វ ពោលថា) អ្នកនោះ កន្លងនូវប្រាសាទកែវផ្លេកផន៍ ប្រាសាទប្រាក់ផន៍ ប្រាសាទកែវមណីផន៍ ជាអ្នកត្រូវចក្រ (គឺចក្រមានមុខមុតដូចកាំបិតកោរ) គ្របសង្កត់ហើយ អ្នកគាល់ រស់នៅមិនរួចអំពីចក្រនោះទេ ។

ចប់ មិត្តវិន្ទជាតក ទី ២ ។

## កាឡកណ្ណិជាតក

(៨៣) (មហាយសសេដ្ឋីពោធិសត្វ ពោលថា) បុគ្គលដែលជាមិត្តបាន ដោយ (ហេតុត្រឹមតែដើរជាមួយគ្នា) ប្រាំពីរជំហាន បុគ្គលជាសម្លាញ់បាន ដោយ (ហេតុត្រឹមតែដើរជាមួយគ្នា) ដប់ពីរជំហាន

មាសឌ្ឍមាសេន ច ញាតិ ហោតិ
តតុត្តរឹ អត្តសមោបិ ហោតិ
សោហំ កថំ អត្តសុខស្ស ហេតុ
ចិរសន្ថុតំ(១) កាឡកណ្ណឹ ជហេយ្យន្តិ ។

កាឡកណ្ណិជាតកំ តតិយំ ។

## អត្ថស្ស ទ្វារជាតកំ

(៨៦) អារោគ្យមិច្ឆេ បរមញ្ច លាភំ
សីលញ្ច ពុទ្ធានុមតំ សុតញ្ច
ធម្មានុវត្តី ច អលីនតា ច (២)
អត្ថស្ស ទ្វារា បមុខា ឆឡេតេ ។

អត្ថស្ស ទ្វារជាតកំ ចតុត្ថំ ។

## កិម្បក្កជាតកំ

(៨៧) អាយតឹ ទោសំ នាញ្ញាយ យោ កាមេ បដិសេវតិ
វិបាកន្តេ ហនន្តិ នំ កិម្បក្កមិវ ភក្ខិតន្តិ ។

កិម្បក្កជាតកំ បញ្ចមំ ។

---
១ ឱ. ចិរសន្តុំ ។ ២ ម. ធម្មានុវត្តិញ្ច អលីនតញ្ច ។



បុគ្គលដែលជាញាតិបាន ដោយ (ការនៅជាមួយគ្នា) មួយខែឬកន្លះខែ បុគ្គលដែលទុកស្មើនឹងខ្លួន ព្រោះនៅលើសអំពីកាលនោះទៅទៀត ខ្ញុំនោះនឹងលះបង់នូវសំឡាញ់ឈ្មោះកាឡកណ្ណី ដែលធ្លាប់ស្និទ្ធស្នាលអស់កាលយូរ ព្រោះហេតុនៃសេចក្តីសុខរបស់ខ្លួន ដូចម្តេចបាន ។

ចប់ កាឡកណ្ណិជាតក ទី ៣ ។

## អត្ថស្ស ទ្វារជាតក

(៨៦) (សេដ្ឋីពោធិសត្វជាបិតា ពោលថា) បុគ្គលគប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ១ សីល(គឺមារយាទ)១ ការយល់ឃើញតាមបណ្ឌិតអ្នកដឹង១ ការស្តាប់ស្តាប់១ ការអនុវត្តនូវសុចរិតធម៌១ ការមិនរួញរានៃចិត្ត១ ធម៌ទាំង៦នេះ ជាទ្វារ ទាំងជាប្រធាននៃសេចក្តីចំរើន ។

ចប់ អត្ថស្ស ទ្វារជាតក ទី ៤ ។

## កិម្បក្កជាតក

(៨៧) (ព្រះសាស្តាត្រាស់ថា) បុគ្គលណា មិនយល់ទោសក្នុងអនាគត ហើយសេពកាមទាំងឡាយ (កាមទាំងនោះ) តែងសម្លាប់បុគ្គលនោះ ក្នុងទីបំផុតនៃផល ដូចបុគ្គលស៊ីផ្លែឈើកិម្បក្កៈ (ឈើពុល) ។

ចប់ កិម្បក្កជាតក ទី ៥ ។

## សីលវីមំសនជាតកំ

(៨៦) សីលំ កិរេវ កល្យាណំ សីលំ លោកេ អនុត្តរំ
បស្ស ឃោរវិសោ នាគោ សីលវាតិ ន ហញ្ញតីតិ ។

សីលវីមំសនជាតកំ ឆដ្ឋំ ។

## មង្គលជាតកំ

(៨៧) យស្ស មង្គលា សមូហតា (១)
ឧប្បាតា សុបិនា ច លក្ខណា ច
សោ មង្គលទោសវីតិវត្តោ
យុគយោគាធិគតោ ន ជាតុមេតីតិ ។

មង្គលជាតកំ សត្តមំ ។

១ ម. សមូហតាសេ ។



## សីលវីមំសនជាតក

(៨៦) (ព្រាហ្មណ៍បុរោហិតពោធិសត្វពោលថា) បានឮថា សីលជាគុណជាតល្អ សីលជាគុណជាតដ៏លើសលុបក្នុងលោក សូមព្រះអង្គទតមើល ពស់មានពិសដ៏ពន្លឹក មិនបៀតបៀនគេ ឈ្មោះថាជាសត្វមានសីល ។

ចប់ សីលវីមំសនជាតក ទី ៦ ។

## មង្គលជាតក

(៨៧) (ព្រះសាស្ដាទ្រង់ត្រាស់ថា) មង្គលទាំងឡាយក្ដី ឧប្បាតទាំងឡាយក្ដី សុបិនទាំងឡាយក្ដី លក្ខណៈទាំងឡាយក្ដី ដែលបុគ្គលណាបានផ្ដាច់បង់ហើយ បុគ្គលនោះ ឈ្មោះថា អ្នកកន្លងផុតនូវទោសនៃមង្គល (ភ្ញាក់ផ្អើល) ជាអ្នកគ្របសង្កត់នូវយុគក្កិលេស(១) និងយោគក្កិលេស(២) រមែងមិនមកកើតទៀត ។

ចប់ មង្គលជាតក ទី ៧ ។

១ យុគក្កិលេសនេះ បានដល់កិលេសទាំងឡាយ គឺ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ជាដើម ។ ២ យោគក្កិលេសនេះ បានដល់យោគៈ ៤ យ៉ាងគឺ កាមយោគៈ១ ភវយោគៈ១ ទិដ្ឋិយោគៈ១ អវិជ្ជាយោគៈ១ ។ អដ្ឋកថា ។

## សារម្ភជាតកំ

[៨៨] កល្យាណិមេវ មុញ្ចេយ្យ ន ហិ មុញ្ចេយ្យ បាបិកំ
មោក្ខោ កល្យាណិយា សាធុ មុត្វា តប្បតិ បាបិកន្តិ ។

សារម្ភជាតកំ អដ្ឋមំ ។

## កុហកជាតកំ

[៨៩] វាចាវ កិរ តេ អាសិ សណ្ហា សខិលភាណិនោ
តិណមត្តេ អសជ្ជិត្ថោ នោ ច និក្ខសតំ ហរន្តិ ។

កុហកជាតកំ នវមំ ។

## អកតញ្ញុជាតកំ

[៩០] យោ បុព្វេ កតកល្យាណោ កតត្ថោ នាវពុជ្ឈតិ
បច្ឆា កិច្ចេ សមុប្បន្នេ កត្តារំ នាធិគច្ឆតីតិ ។

អកតញ្ញុជាតកំ ទសមំ ។

អត្ថកាមវគ្គោ នវមោ ។



## សារម្ភជាតក

[៨៨] (ព្រះសាស្តាទ្រង់ត្រាស់ថា) បុគ្គលគប្បីបញ្ចេញវាចាល្អតែម្យ៉ាង មិនគប្បីបញ្ចេញវាចាអាក្រក់ឡើយ ការបញ្ចេញវាចាល្អ ជាការប្រពៃ ព្រោះបុគ្គលបញ្ចេញវាចាអាក្រក់ រមែងក្តៅក្រហាយ ៕

ចប់ សារម្ភជាតក ទី ៨ ។

## កុហកជាតក

[៨៩] (ឈ្មួញពោធិសត្វ ពោលថា) បានឮថា វាចារបស់អ្នកដែលពោលទន់ភ្លន់ ជាវាចាពីរោះ អ្នកបានជាប់ចិត្តក្នុងត្រឹមតែស្មៅ ប្រវ៉ាន់ នាំគ្រឿងមាស ១០០ យកទៅ មិនជាប់សោះ ៕

ចប់ កុហកជាតក ទី ៩ ។

## អកតញ្ញុជាតក

[៩០] (សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលណា មិនដឹងនូវអំពើល្អ ដែលគេធ្វើហើយ នូវប្រយោជន៍ដែលគេធ្វើហើយ ក្នុងកាលមុន បុគ្គលនោះ កាលបើកិច្ចកើតក្រោយហើយ ក្នុងកាលខាងក្រោយ រមែងមិនបាននូវបុគ្គលអ្នកធ្វើ (ឧបការគុណមុននោះជាគ្នា) ឡើយ ៕

ចប់ អកតញ្ញុជាតក ទី ១០ ។

ចប់ អត្ថកាមវគ្គ ទី ៩ ។

## តស្សុទ្ទានំ

អយាចិត្ត ច ឧភតោ សត្តបថំ

ឧឡុង្កយ ច អាយកិតា ច ឃុង

អហិសីលវំ មគ្គលំ តាបិកាស្សា

សកិណិត្វា កាកត្វនេន ទស ។

---



## ឧទ្ទាននៃអបាយម្ហវគ្គនោះគឺ

រឿងបានផឹកស្រា (ក្នុងសុរាបានជាតក) ១ ព្រះសាទកែវមណី (ក្នុងមិត្តវិន្ទជាតក) ១ ៧ដំហាន (ក្នុងកាឡកណ្ណិជាតក) ១ ធម៌៦ (ក្នុងអត្ថស្សទ្វារជាតក) ១ ទោសក្នុងអនាគត (ក្នុងកិម្បក្កជាតក) ១ តស់មានសីល (ក្នុងសីលវីមំសជាតក) ១ ការប្រកាន់មង្គល (ក្នុងមង្គលជាតក) ១ កថាលាមក (ក្នុងសារម្ភជាតក) ១ ភ្នោទោស ១០០ (ក្នុងកុហកជាតក) ១ ប្រយោជន៍ដែលគេនឹងបានវិញ (ក្នុងអកតញ្ញុ-ជាតក) ១ ត្រូវជា ១០ ។

## លិត្តវគ្គោ

## លិត្តជាតកំ

(៩១) លិត្តំ បរមេន តេជសា
គិលមក្ខំ បុរិសោ ន ពុជ្ឈតិ
គិល រេ គិល បាបធុត្តក
បច្ឆា តេ កដុកំ ភវិស្សតិ ។

លិត្តជាតកំ បឋមំ ។

## មហាសារជាតកំ

(៩២) ឧក្កដ្ឋេ សូរមិច្ឆន្តិ មន្តីសុ អកុតូហលំ
បិយញ្ច អន្នបានម្ហិ អត្ថេ ជាតេ ច បណ្ឌិតំ ។

មហាសារជាតកំ ទុតិយំ ។

## លិត្តវគ្គ

## លិត្តជាតក

(៩១) (អ្នកលេងស្កាពោធិសត្វ ពោលថា) បុរសកាលលេបនូវកូនស្កា ប្រឡាក់ដោយថ្នាំពិស មានតេជះដ៏ខ្លាំង ក៏មិនដឹងខ្លួន ម្នាលអ្នកចង្រៃ អ្នកចូរលេបទៅ នែអ្នកលេងកាក្រក់ អ្នកចូរលេបទៅ ពិសដ៏ផ្សាក្តៅ នឹងមានដល់អ្នក ក្នុងកាលជាខាងក្រោយ ។

ចប់ លិត្តជាតក ទី ១ ។

## មហាសារជាតក

(៩២) (ព្រះរាជាទ្រង់ត្រាស់ថា) ក្នុងកាលសង្គ្រាម កើតឡើង ពួកជនរមែងប្រាថ្នានូវបុរសអ្នកក្លៀវក្លា ក្នុងពួកអ្នកប្រឹក្សាការ គេប្រាថ្នានូវបុរសអ្នកមានពាក្យមិនរាយរាយ ក្នុងកាលមានបាយទឹកឆ្ងាញ់ គេប្រាថ្នានូវបុរសជាទីស្រឡាញ់ ក្នុងកាលអត្ថ (កំបាំង) កើតឡើង គេប្រាថ្នានូវបណ្ឌិត ។

ចប់ មហាសារជាតក ទី ២ ។

## វិស្សាសភោជនជាតកំ

(៩៣) ន វិស្សសេ អវិស្សត្ថេ វិស្សត្ថេបិ ន វិស្សសេ
វិស្សាសា ភយមន្វេតិ សីហំវ មិគមាតុកាតិ ។

វិស្សាសភោជនជាតកំ តតិយំ ។

## លោមហំសជាតកំ

(៩៤) សោតត្តោ សោសីនោ ចេវ (១) ឯកោ ភឹសន-
កេ វនេ
នគ្គោ ន ចគ្គិមាសីនោ ឯសនាបសុតោ មុនីតិ ។

លោមហំសជាតកំ ចតុត្ថំ ។

## មហាសុទស្សនជាតកំ

(៩៥) អនិច្ចា វត សង្ខារា ឧប្បាទវយធម្មិនោ
ឧប្បជ្ជិត្វា និរុជ្ឈន្តិ តេសំ វូបសមោ សុខោតិ ។

មហាសុទស្សនជាតកំ បញ្ចមំ ។

---

១ ម. សោសិន្នោ ចេវ ។



## វិស្សាសភោជនជាតក

(៩៣) (សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលមិនគប្បីស្និទ្ធស្នាលក្នុងបុគ្គលដែលមិនធ្លាប់ស្និទ្ធស្នាល មិនគប្បីស្និទ្ធស្នាលក្នុងបុគ្គល សូម្បីធ្លាប់ស្និទ្ធស្នាលហើយ ភ័យរមែងទៅតាមបុគ្គលនោះ ព្រោះសេចក្តីស្និទ្ធស្នាល ដូចជាភ័យដែលជាប់តាមខ្លួនសត្វសីហៈ ព្រោះមេម្រឹគ ។

ចប់ វិស្សាសភោជនជាតក ទី ៣ ។

## លោមហំសជាតក

(៩៤) (អាជីវកពោធិសត្វ ពោលថា) អាត្មាអញ ក្តៅណាស់ហើយ ត្រជាក់ណាស់ហើយ នៅតែម្នាក់ឯង ក្នុងព្រៃគួរខ្លាច ជាមនុស្សអាក្រាត ទាំងមិនអាំងភ្លើង ជាអ្នកខ្វល់ខ្វាយក្នុងការស្វែងរក (នូវព្រហ្មចរិយធម៌) ប្រតិបត្តិ ដើម្បីមោនៈ ។

ចប់ លោមហំសជាតក ទី ៤ ។

## មហាសុទស្សនជាតក

(៩៥) (ព្រះពោធិសត្វ ពោលថា) សង្ខារទាំងឡាយមិនទៀងទេ មានការកើតឡើងនិងសូន្យទៅជាធម្មតា (ព្រោះ) កើតឡើងហើយតែងរលត់ទៅវិញ ការរម្ងាប់សង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្តីសុខ ។

ចប់ មហាសុទស្សនជាតក ទី ៥ ។

# តេលបត្តជាតកំ

(៩៦) សមតិត្តិកំ អនវសេសកំ
តេលបត្តំ យថា បរិហរេយ្យ
ឯវំ សចិត្តមនុរក្ខេ (សតិយា)
បត្ថយានោ ទិសំ អគតបុព្វន្តិ ។

តេលបត្តជាតកំ ឆដ្ឋំ ។

# នាមសិទ្ធិជាតកំ

(៩៧) ជីវកញ្ច មតំ ទិស្វា ធនបាលិញ្ច ទុគ្គតំ
បន្ថកញ្ច វនេ មូឡ្ហំ បាបកោ បុនរាគតោតិ ។

នាមសិទ្ធិជាតកំ សត្តមំ ។

# កូដវាណិជជាតកំ

(៩៨) សាធុ ខោ បណ្ឌិតោ នាម ន ត្វេវ អតិបណ្ឌិតោ
អតិបណ្ឌិតេន បុត្តេន មនម្ហិ ឧបកុដ្ឋិតោតិ(១) ។

កូដវាណិជជាតកំ អដ្ឋមំ ។

---
១ ម. ធនម្ហិ ឧបកុដ្ឋិតោ ។





# តេលបត្តជាតក

(៩៦) (ព្រះសាស្តាទ្រង់ត្រាស់ថា) បុគ្គលគប្បីនាំទៅនូវភាជន៍ប្រេង ដែលពេញត្រឹមកណ្តាប់មាត់ មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ (ព្រះយោគាវចរ) កាលប្រាថ្នានូវទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវចិត្តរបស់ខ្លួន (ដោយសតិ) យ៉ាងនោះដែរ ។

ចប់ តេលបត្តជាតក ទី ៦ ។

# នាមសិទ្ធិជាតក

(៩៧) (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) មាណពឈ្មោះបាបកៈ បានឃើញបុរសរស់ហើយស្លាប់ផង ឃើញទាសីឈ្មោះ ធនបាលីក្រទ្រព្យហើយខ្សត់ទ្រព្យផង ឃើញបុរសអ្នកដើរផ្លូវ ហើយវង្វេង ក្នុងព្រៃផង មកវិញហើយ ។

ចប់ នាមសិទ្ធិជាតក ទី ៧ ។

# កូដវាណិជជាតក

(៩៨) (បិតារបស់អតិបណ្ឌិតពាណិជ ពោលថា) បុគ្គលដែលឈ្មោះថាបណ្ឌិត ជាអ្នកប្រពៃពិត ឯបុគ្គលឈ្មោះថាអតិបណ្ឌិត មិនប្រពៃទេ អាត្មាអញត្រូវភ្លើងរោល ព្រោះតែកូនឈ្មោះអតិបណ្ឌិត ។

ចប់ កូដវាណិជជាតក ទី ៨ ។

## បរោសហស្សជាតកំ

(៩៩) បរោសហស្សម្បិ សមាគតានំ
កន្ទេយ្យុំ តេ វស្សសតំ អបញ្ញា
ឯកោវ សេយ្យោ បុរិសោ សបញ្ញោ
យោ ភាសិតស្ស វិជានាតិ អត្ថំ ។

បរោសហស្សជាតកំ នវមំ ។

## អសាតរូបជាតកំ

(១០០) អសាតំ សាតរូបេន បិយរូបេន អប្បិយំ
ទុក្ខំ សុខស្ស រូបេន បមត្តមតិវត្តតីតិ ។

អសាតរូបជាតកំ ទសមំ ។

លិត្តវគ្គោ ទសមោ ។

មជ្ឈិមបណ្ណាសកោ ។



## បរោសហស្សជាតក

(៩៩) (មហាព្រហ្មពោធិសត្វ ពោលថា) ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញអស់ ១០០ ឆ្នាំ បុរសណា ប្រកបដោយប្រាជ្ញា បានដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះទោះតែម្នាក់ឯង ប្រសើរជាង ។

ចប់ បរោសហស្សជាតក ទី ៩ ។

## អសាតរូបជាតក

(១០០) (ព្រះសាស្តាទ្រង់ត្រាស់ថា) របស់មិនឆ្ងាញ់ រមែងគ្របសង្កត់ នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់ឆ្ងាញ់ របស់មិនគួរស្រឡាញ់ រមែងគ្របសង្កត់ នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់គួរស្រឡាញ់ សេចក្តីទុក្ខ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃសេចក្តីសុខ ។

ចប់ អសាតរូបជាតក ទី ១០ ។

ចប់ លិត្តវគ្គ ទី ១០ ។

ចប់ មជ្ឈិមបណ្ណាសកៈ ។

## តស្សុទ្ទានំ

លិត្តំ មហាសារ វិស្សាស
លោមហំស សុទស្សន តេលបត្តំ
នាមសិទ្ធិ អតិបណ្ឌិតកោ
សបរោសហស្ស អសាត ទស ។

---





## ឧទ្ទាននៃលិត្តវគ្គនោះគឺ

និយាយអំពីការលេបគ្រាប់ស្កា (ក្នុងលិត្តជាតក) ១ បុរសមានចិត្តមិនកោងកាច (ក្នុងមហាសារជាតក) ១ មេម្រឹគ (ក្នុងវិស្សាសភោជនជាតក) ១ ប្រតិបត្តិដើម្បីគោរព (ក្នុងលោមហំសជាតក) ១ សត្វមិនទៀង (ក្នុងមហាសុទស្សនជាតក) ១ ការជាប់ប្រែង (ក្នុងតេលបត្តជាតក) ១ តាសីឈ្មោះនាមកាលគ្រប់គ្រង (ក្នុងនាមសិទ្ធិជាតក) ១ អតិបណ្ឌិតពាណិជ (ក្នុងកូដវាណិជជាតក) ១ ផលជាងពាន់នាក់ (ក្នុងបរោសហស្សជាតក) ១ របស់មិនគួរញ៉ាំ (ក្នុងអសាតរូបជាតក) ១ ត្រូវជា ១០ ។

---

## បរោសតជាតកំ

(១០១) បរោសតំ ចេបិ[១] សមាគតានំ
ឈាយេយ្យុំ តេ វស្សសតំ អបញ្ញា
ឯកោវ សេយ្យោ បុរិសោ សបញ្ញោ
យោ ភាសិតស្ស វិជានាតិ អត្ថំ ។

បរោសតជាតកំ បឋមំ ។



## បរោសតជាតក

(១០១) ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងរយនាក់ ជនទាំងនោះឥតប្រាជ្ញ គប្បីពិចារណា (នូវអត្ថនៃភាសិត) អស់ ១០០ ឆ្នាំ បុរសណាប្រកបដោយប្រាជ្ញ ដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះនៅតែម្នាក់ឯងប្រសើរវិញ ។

ចប់ បរោសតជាតក ទី ១ ។

## បណ្ណិកជាតកំ

(១០២) យោ ទុក្ខផុដ្ឋាយ ភវេយ្យ តាណំ
សោ មេ បិតា ទុព្ភិ វនេ ករោតិ
សា កស្ស កន្ទាមិ វនស្ស មជ្ឈេ
យោ តាយិតា សោ សហសា ករោតីតិ ។

បណ្ណិកជាតកំ ទុតិយំ ។

១ ម. សតញ្ចេបិ ។

## បណ្ណិកជាតក

(១០២) (កូនស្រីរបស់ឧបាសក ពោលថា) បុគ្គលណាគប្បីជាទីពឹងរបស់ខ្ញុំ ដែលមានទុក្ខពាល់ត្រូវហើយ បុគ្គលនោះឈ្មោះថាជាបិតារបស់ខ្ញុំ នឹងធ្វើនូវការប្រទូស្តក្នុងព្រៃ ខ្ញុំនោះកន្ទក់កន្ទេញ ក្នុងកណ្តាលព្រៃ ដើម្បីបុគ្គលដូចម្តេច បុគ្គលណាជាអ្នករក្សា បុគ្គលនោះនឹងធ្វើនូវកម្មដ៏ខ្លាំងក្លា(មេថុន) ។

ចប់ បណ្ណិកជាតក ទី ២ ។

## វេរិជាតកំ

(១០៣) យត្ថ វេរី និវិសតិ ន វសេ តត្ថ បណ្ឌិតោ
ឯករត្តំ ទិរត្តំ វា ទុក្ខំ វសតិ វេរិសូតិ ។

វេរិជាតកំ តតិយំ ។

## មិត្តវិន្ទជាតកំ(១)

(១០៤) ចតុព្ភិ អដ្ឋជ្ឈគមា អដ្ឋាហិបិ ច សោឡស
សោឡសាហិ ច ពត្តឹស អត្រិច្ឆំ ចក្កមាសទោ
ឧបហតស្ស(២) បោសស្ស ចក្កំ ភមតិ មត្ថកេតិ ។

មិត្តវិន្ទជាតកំ ចតុត្ថំ ។

## ទុព្ពលកដ្ឋជាតកំ

(១០៥) ពហុម្បេតំ វនេ កដ្ឋំ វាតោ ភញ្ជតិ ទុព្ពលំ
តស្ស ចេ ភាយសិ នាគ កិសោ នូន ភវិស្សសីតិ ។

ទុព្ពលកដ្ឋជាតកំ បញ្ចមំ ។

---

១ ម. មិត្តវិន្ទកជាតកំ ។ ២ ម. ឋិហតស្ស ។





## វេរិជាតក

(១០៣) (សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា អ្នកប្រាជ្ញមិនគប្បីនៅក្នុងទីនោះ បុគ្គលនៅក្នុងសំណាក់នៃបុគ្គលមានពៀរអស់មួយរាត្រី ឬពីររាត្រី គឹនាំមកនូវសេចក្តីទុក្ខ ។

ចប់ វេរិជាតក ទី ៣ ។

## មិត្តវិន្ទជាតក

(១០៤) (ទេវបុត្រពោធិសត្វ ពោលថា) អ្នក(ចេញ)អំពីវិមានិកប្រេត ៤ បានវិមានិកប្រេត ៨ (ចេញ)អំពីវិមានិកប្រេត ៨ បានវិមានិកប្រេត ១៦ (ចេញ)អំពីវិមានិកប្រេត ១៦ បានវិមានិកប្រេត ៣២ (ក៏នៅតែមិនស្កប់ស្កល់) ចក្រក៏វិលលើក្បាលនៃបុរស កាលប្រាថ្នា ក្នុងទីនោះ ៗ ទើបមកដល់កង់ចក្រ កង់ចក្រ រមែងវិលលើក្បាលបុគ្គលដែលមានសេចក្តីប្រាថ្នាគ្របសង្កត់ ។

ចប់ មិត្តវិន្ទជាតក ទី ៤ ។

## ទុព្ពលកដ្ឋជាតក

(១០៥) (រុក្ខទេវតាពោធិសត្វ ពោលថា) ឈើស្រាំស្រា ដែលខ្យល់កាច់បំបាក់បានក្នុងព្រៃនោះ មានច្រើន ម្នាលដំរី ប្រសិនបើអ្នកខ្លាចឈើនោះអ្នកមុខជានឹងស្គមមិនខាន ។

ចប់ ទុព្ពលកដ្ឋជាតក ទី ៥ ។

## ឧទញ្ចនីជាតកំ

(១០៦) សុខំ វត មំ ជីវន្តំ បចមានា ឧទញ្ចនី
ចោរី ជាយប្បវាទេន តេលំ លោណញ្ច យាចតីតិ ។

ឧទញ្ចនីជាតកំ ឆដ្ឋំ ។

## សាលិត្តកជាតកំ

(១០៧) សាធុ ខោ សិប្បកំ នាម អបិ យាទិសកីទិសំ
បស្ស ខញ្ជប្បហារេន លទ្ធា គាមា ចតុទ្ទិសាតិ ។

សាលិត្តកជាតកំ សត្តមំ ។

## ពាហិយជាតកំ

(១០៨) សិក្ខេយ្យ សិក្ខិតព្វានិ សន្តិ តច្ឆន្ទិនោ ជនា
ពាហិយាបិ សុហន្នេន រាជានំ អភិរាធយីតិ ។

ពាហិយជាតកំ អដ្ឋមំ ។



## ឧទញ្ចនីជាតក

(១០៦) (កូនតាបសពោធិសត្វ ពោលថា) មេចោរផុតចំណិនរឡោកស៊ី ដូចជាកាដង់ដងទឹក រមែងសូមខ្ញុំប្រេងផង ខ្ញុំអំបិលផង នឹងទីទំរំដែលធ្លាប់រស់នៅជាសុខ ដោយសំដីហាក់ដូចជាប្រពន្ធ ។

ចប់ ឧទញ្ចនីជាតក ទី ៦ ។

## សាលិត្តកជាតក

(១០៧) (ព្រះពោធិសត្វ ពោលថា) ធម្មតាសិល្បសាស្ត្រយ៉ាងណាក៏ដោយ សុទ្ធតែសំរេចប្រយោជន៍ សូមព្រះអង្គទត ស្រុកសួយតាំង៤ទិស ដែលបុរសខ្វិនបានហើយ ដោយការផ្ទាត់ (អាចម៍ពពែ) នៃបុរសខ្វិន ។

ចប់ សាលិត្តកជាតក ទី ៧ ។

## ពាហិយជាតក

(១០៨) (ព្រះពោធិសត្វ ពោលថា) ជនគប្បីសិក្សានូវកិច្ចដែលគួរសិក្សា ពួកជន រមែងមានសេចក្តីពេញចិត្តក្នុងកិច្ចនោះ ចំណែកស្រីអ្នកស្រុកពាហិយៈ បានញុំាងព្រះរាជាឲ្យត្រេកអរ ដោយការត្នាសបៀន (របស់ខ្លួន) ។

ចប់ ពាហិយៈជាតក ទី ៨ ។

## កុណ្ឌកបូវជាតកំ

(១០៩) យទន្នោ បុរិសោ ហោតិ តទន្នា តស្ស ទេវតា
អាហរេតំ កុណ្ឌបូវំ មា មេ ភាគំ វិនាសយោតិ ។

កុណ្ឌកបូវជាតកំ នវមំ ។

## សព្វសំហារកបញ្ហោ

(១១០) សព្ព(១)សំហារកោ នត្ថិ សុទ្ធំ កង្គុ បវាយតិ
អលិកំ ភាសតិយំ ធុត្តី សច្ចមាហុ មហល្លិកាតិ ។

សព្វសំហារកបញ្ហោ ទសមោ ។

បរោសតវគ្គោ ឯកាទសមោ ។

## តស្សុទ្ទានំ

សបរោសត តាយិត វេរី បុន
គមមន្តី ច ជាតសរាហ្វយោ
សុខកាញ្ច វត សំបុក តាហិយា
កុណ្ឌបូវ មហល្លិកា ទស ។

១ ម. សព្វស្សហារកោ ។





## កុណ្ឌកបូវជាតក

(១០៩) (ព្រះទេវតាពោលថា) បុរសស៊ីបាយដូចណា ទេវតារបស់
បុរសនោះ ក៏ស៊ីបាយដូចនោះដែរ អ្នកចូរនាំយកនំកុណ្ឌកនុះមក
អ្នកកុំញុំាងនំកុណ្ឌក ជាចំណែករបស់ខ្ញុំឲ្យវិនាសទៅ ។

ចប់ កុណ្ឌកបូវជាតក ទី ៩ ។

## សព្វសំហារកបញ្ហា

(១១០) គ្រឿងអប់ទាំងពួងគ្មានទេ សុទ្ធតែផ្កាប្រយង្គុះវាក៏ ហក់ផ្សាយ
ទៅ(នោះ) ឯស្ត្រីអ្នកលេង វែងនីពោលពាក្យមិនពិត ស្ត្រីចាស់
ទើបបានពោលពាក្យពិត ។

ចប់ សព្វសំហារកបញ្ហា ទី ១០ ។

ចប់ បរោសតវគ្គ ទី ១១ ។

## ឧទ្ទាននៃបរោសតវគ្គនោះគឺ

និយាយអំពីបុគ្គលជាន័យមួយរយ ១ បុគ្គលជាទីពឹង ១ បុគ្គលចង
ពៀរ ១ ចក្រៀល ១ ដីប្រាសាទ ១ សេរ៉ៅជាសុខ ១ សិល្បៈ ១
ស្ត្រីអ្នកស្រុកកាសិយៈ ១ នំកណ្ឌក ១ ស្ត្រីចាស់ ១ ត្រូវជា ១០ ។

## ហំសិវគ្គោ

### គទ្រភបញ្ហោ

(១១១) ហំសិ តុវំ ឯវំ មញ្ញសិ សេយ្យោ
បុត្តេន បិតរំ ភជ សេដ្ឋ
ហត្ថស្សតរស្ស តេ អយំ
អស្សតរស្ស ហិ គទ្រភោ បិតា ។

គទ្រភបញ្ហោ បឋមោ ។

### អមរាទេវីបញ្ហោ

(១១២) យេន សត្តុពិលង្គា ច
ទ្វិគុណបលាសោ ច បុប្ផិតោ
យេនាទាមិ តេន វទាមិ
យេន នាទាមិ ន តេន វទាមិ
ឯស មគ្គោ យវមជ្ឈកស្ស
ឯតំ ឆន្នបថំ វិជានាហិ ។

អមរាទេវីបញ្ហោ ទុតិយោ ។

## ហំសវគ្គ

### គទ្រភបញ្ហា

(១១១) បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គតែកាយ រមែងសំគាល់ថា បិតា ប្រសើរជាងកូនយ៉ាងនេះ បើដូច្នោះ មានតែសត្វលារបស់ព្រះអង្គនេះប្រសើរជាងសេះកាត់ ព្រោះសត្វលាជាបិតានៃសេះកាត់ ។

ចប់ គទ្រភបញ្ហា ទី ១ ។

### អមរាទេវីបញ្ហា

(១១២) (បពិត្រអ្នកម្ចាស់) កន្សោរដែលគេលក់សម្លូ ទឹកម្ជូរ នឹងដើមល្ហុងមានស្លឹកពីរជាន់ មាននៅក្នុងទិសាភាគណា ខ្ញុំកាន់បាយដោយដៃណា ខ្ញុំម្ចាស់ប្រាប់ផ្លូវដោយដៃនោះ ខ្ញុំមិនបានកាន់បាយដោយដៃណា ខ្ញុំមិនប្រាប់ផ្លូវដោយដៃនោះទេ ទិសាភាគនុ៎ះឯង ហើយ ជាផ្លូវនៃយាយមជ្ឈគ្រាម អ្នកចូរដឹងផ្លូវដ៏កំបាំងនុ៎ះចុះ ។

ចប់ អមរាទេវីបញ្ហា ទី ២ ។

## សិគាលជាតកំ

[១១៣] សទ្ទហាសិ សិគាលស្ស សុរាបីតស្ស ព្រាហ្មណ
សិប្បិកានំ សតំ នត្ថិ កុតោ កំសសតា ទុវេ ។

សិគាលជាតកំ តតិយំ ។

## មិតចិន្តិជាតកំ

[១១៤] ពហុចិន្តី អប្បចិន្តី ឧភោ ជាលេ អពជ្ឈរេ
មិតចិន្តិ បមោចេសិ ឧភោ តត្ថ សមាគតា ។

មិតចិន្តិជាតកំ ចតុត្ថំ ។

## អនុសាសិកជាតកំ

[១១៥] យាយញ្ញ(១)មនុសាសតិ សយំ លោលុប្បចារិនី
សាយំ វិបក្ខិកា សេតិ ហតា ចក្កេន សាសិកា ។

អនុសាសិកជាតកំ បញ្ចមំ ។

១ ម. យាយញ្ញេ ។



## សិគាលជាតក

(១១៣) (គ្រូទៅតាទេវតាពោលថា) ម្នាលព្រាហ្មណ៍ អ្នកជឿពាក្យ
ចចកដែលផឹកសុរាដូចម្តេចបាន (សូម្បីសម្បក) ខ្យងចំនួនមួយរយ
មិនមានទេ តើកហាបណៈពីររយ នឹងមានមកអំពីណា ។

ចប់ សិគាលជាតក ទី ៣ ។

## មិតចិន្តិជាតក

(១១៤) (ព្រះសាស្តាត្រាស់ថា) ត្រីឈ្មោះពហុចិន្តី នឹងអប្បចិន្តី(*) ទាំង
ពីរ បានជាប់នៅក្នុងសំណាញ់ ត្រីឈ្មោះមិតចិន្តី(*) បានដោះ
ឲ្យរួចខ្លួន ត្រីទាំងពីរ បានជួបគ្នាក្នុងទឹកនោះ ។

ចប់ មិតចិន្តិជាតក ទី ៤ ។

## អនុសាសិកជាតក

(១១៥) (បក្សីជាធំពោធិសត្វពោលថា) មេបក្សីណា ប្រៀនប្រដៅនូវ
បក្សីដទៃ តែជាអ្នកប្រព្រឹត្តលោភ ដោយខ្លួនឯង មេបក្សីនោះ
ដេកបាក់ស្លាប ដូចជាសត្វសាលិកា ដែលកង់កិនហើយ ។

ចប់ អនុសាសិកជាតក ទី ៥ ។

* ត្រី ៣ មួយគិតច្រើន មួយគិតតិច មួយគិតល្មម ។

## ទុព្វចជាតកំ

(១១៦) អតិករមករាចរិយ មយ្ហម្បេតំ ន រុច្ចតិ
ចតុត្ថេ លង្ឃយិត្វាន បញ្ចមាយសិ អាវុតោ ។

ទុព្វចជាតកំ ឆដ្ឋំ ។

## តិត្តិរជាតកំ

(១១៧) អច្ចុគ្គតា អតិពលតា អតិវេលំ បភាសិតា
វាចា ហនតិ ទុម្មេធំ តិត្តិរំ វាតិវស្សិតន្តិ ។

តិត្តិរជាតកំ សត្តមំ ។

## វដ្ដកជាតកំ

(១១៨) នាចិន្តយន្តោ បុរិសោ វិសេសមធិគច្ឆតិ
ចិន្តិតស្ស ផលំ បស្ស មុត្តោស្មិ វធពន្ធនាតិ ។

វដ្ដកជាតកំ អដ្ឋមំ ។



## ទុព្វចជាតក

(១១៦) (កូនសិស្សពោធិសត្វ ពោលថា) បពិត្រលោកអាចារ្យ អំពើដែលលោកធ្វើនេះ មិនគាប់ចិត្តខ្ញុំទេ លោកឆ្លងនៅកន្លែងទី ៤ ហើយត្រូវលំពែងទី ៥ មុតហើយ ។

ចប់ ទុព្វចជាតក ទី ៦ ។

## តិត្តិរជាតក

(១១៧) (តាបសពោធិសត្វ ពោលថា) ពាក្យដែលខ្ពស់ហួស ខ្លាំងហួស ពោលហួសកាលវេលា រមែងសម្លាប់បុគ្គលពាល អ្នកឥតបញ្ញា ដូចជាពាក្យដែលសម្លាប់ នូវសត្វទទាដែលស្រែកហួស ។

ចប់ តិត្តិរជាតក ទី ៧ ។

## វដ្ដកជាតក

(១១៨) (បាបពោធិសត្វ ពោលថា) បុរសកាលមិនបានគិតគិត រមែងមិនបានសម្រេច នូវគុណវិសេសឡើយ អ្នកចូរឃើញផលនៃឧបាយដែលខ្ញុំគិតហើយ ព្រោះខ្ញុំរួចអំពីសេចក្ដីស្លាប់និងចំណង ។

ចប់ វដ្ដកជាតក ទី ៨ ។

## អកាលរាវិជាតកំ

(១១៩) អមាតាបិតុសំវឌ្ឍោ អនាចេរកុលេ វសំ
នាយំ កាលំ អកាលំ វា អភិជានាតិ កុក្កុដោតិ ។

អកាលរាវិជាតកំ នវមំ ។

## ពន្ធនមោក្ខជាតកំ

(១២០) អពទ្ធា តត្ថ ពជ្ឈន្តិ យត្ថ ពាលា បភាសរេ
ពទ្ធាបិ តត្ថ មុច្ចន្តិ យត្ថ ធីរា បភាសរេតិ ។

ពន្ធនមោក្ខជាតកំ ទសមំ ។

ហំសិវគ្គោ ទ្វាទសមោ ។

## តស្សុទ្ទានំ

អជ គទ្រភ សត្តុ កិំសសរមិ
ពហុចិន្តិ សាសិកា យាតិការ
អតិវេល វិសេសមតា ចកិយោ
ធីរ បភាសរេតេន ទស ។

---



## អកាលរាវិជាតក

(១១៩) (ព្រះសាស្តាទ្រង់ប្រារព្ធភិក្ខុ ១ រូប ត្រាស់ថា) មាន់នេះ ចំរើន នៅក្នុងសំណាក់នៃបុគ្គល មិនមែនជាមាតាបិតា កាលនៅក្នុងត្រកូលនៃបុគ្គលមិនមែនជាអាចារ្យ រមែងមិនដឹងច្បាស់នូវកាលគួររងាវ ឬកាល មិនគួររងាវ ។

ចប់ អកាលរាវិជាតក ទី ៩ ។

## ពន្ធនមោក្ខជាតក

(១២០) (ប្រារព្ធកោដិកសត្ថ ត្រាស់ថា) ជនពាលទាំងឡាយ ពោលក្នុងទីណា ពួកជនដែលមិនទាន់ជាប់ រមែងជាប់នៅក្នុងទីនោះ អ្នកប្រាជ្ញទាំងឡាយ ពោលក្នុងទីណា ពួកជនសូម្បីជាប់ហើយ រមែងរួចក្នុងទីនោះ ។

ចប់ ពន្ធនមោក្ខជាតក ទី ១០ ។

ចប់ ហំសិវគ្គ ទី ១២ ។

## ឧទ្ទាននៃហំសិវគ្គនោះគឺ

និយាយអំពីគទ្រភបញ្ហា ១ សង្ឃ ១ មេឃបាបណៈ ១ ត្រីឈ្មោះពហុចិន្តិ ១ មេបក្សី ១ អំពើដែលធ្វើផ្សេង ១ ហួសវេលា ១ គុណវិសេស ១ មាន់គ្មានអាចារ្យ ១ អ្នកប្រាជ្ញពោល ១ ត្រូវជា ១០ ។

---

## កុសនាឡិជាតកំ

(១២១) ករេ សរិក្ខោ អថវាបិ សេដ្ឋោ
និហីនកោ វាបិ ករេយ្យ ឯកោ
ករេយ្យុមេតេ ព្យសនេ ឧត្តមត្ថំ
យថា អហំ កុសនាឡិ រុចាយំ ។

កុសនាឡិជាតកំ បឋមំ ។



## កុសនាឡិជាតក

(១២១) (រុក្ខទេវតា ពោលថា) ជនស្មើគ្នាក្តី ជាងជនប្រសើរជាងក្តី គប្បីធ្វើ (នូវមិត្តធម៌) សូម្បីជនម្នាក់ជាអ្នកថោកទាប ក៏គប្បីធ្វើ (នូវមិត្តធម៌ដែរ) ព្រោះមិត្តទាំងនោះ គប្បីធ្វើនូវប្រយោជន៍ដ៏ឧត្តម ក្នុងកាលដែលមានសេចក្តីវិនាស ដូចជាខ្ញុំជាទេវតា ឈ្មោះកុសនាឡិ នឹងទេវតា ឈ្មោះរុចា ធ្វើនូវប្រយោជន៍ដ៏ឧត្តម (ក្នុងកាលដែលមានសេចក្តីវិនាស) ។

ចប់ កុសនាឡិជាតក ទី ១ ។

## ទុម្មេធជាតកំ

(១២២) យសំ លទ្ធាន ទុម្មេធោ អនត្ថំ ចរតិ អត្តនោ
អត្តនោ ច បរេសញ្ច ហឹសាយ បដិបជ្ជតិ ។

ទុម្មេធជាតកំ ទុតិយំ ។

## ទុម្មេធជាតក

(១២២) (ព្រម៉ាកដំរី ពោលថា) បុគ្គលឥតប្រាជ្ញា បានយសបរិវារហើយ តែងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់ខ្លួន ជាងប្រកតិ ដើម្បីបៀតបៀនដល់ខ្លួនឯងផង ដល់ជនទាំងឡាយដទៃផង ។

ចប់ ទុម្មេធជាតក ទី ២ ។

## នង្គលីសជាតកំ

(១២៣) អសព្វត្ថគាមឹ វាចំ ពាលោ សព្វត្ថ ភាសតិ
នាយំ ទធឹ វេទិ ន នង្គលីសំ[1]
ទធិប្បយំ មញ្ញតិ នង្គលីសន្តិ ៕

នង្គលីសជាតកំ តតិយំ ៕

## អម្ពជាតកំ

(១២៤) វាយមេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
វាយាមស្ស ផលំ បស្ស ភុត្តា អម្ពា អនីតិហន្តិ ៕

អម្ពជាតកំ ចតុត្ថំ ៕

## កដាហកជាតកំ

(១២៥) ពហុម្បិ សោ វិកត្ថេយ្យ អញ្ញំ ជនបទំ គតោ
អន្វាគន្ត្វាន ទូសេយ្យ ភុញ្ជ ភោគេ កដាហកាតិ ៕

កដាហកជាតកំ បញ្ចមំ ៕

---
១ ម. នាយំ ទធិនង្គលីសំ ៕



## នង្គលីសជាតក

(១២៣) (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលពាល រមែងពោលនូវពាក្យ ដែលមិនគួរទៅក្នុងទីគ្រប់ទីកន្លែង ក្នុងទីទាំងពួង មាណពនេះមិនស្គាល់ទឹកដោះជូរ មិនស្គាល់បន្ទោលនង្គ័ល ឡើយ រមែងសំគាល់នូវទឹកដោះជូរនឹងទឹកដោះស្រស់ ថាជាបន្ទោលនៃនង្គ័លទៅវិញ ៕

ចប់ នង្គលីសជាតក ទី ៣ ៕

## អម្ពជាតក

(១២៤) (តាបសពោធិសត្វពោលថា) បុរសជាបណ្ឌិតគប្បីប្រឹងប្រែងមិនគប្បីធុញទ្រាន់ឡើយ អ្នកចូរឃើញផលនៃសេចក្តីព្យាយាមដ៏ជាក់ស្តែង (ព្រោះ)ផ្លែស្វាយទាំងឡាយជាដើម ដែលពួកសិស្សបរិភោគហើយ ៕

ចប់ អម្ពជាតក ទី ៤ ៕

## កដាហកជាតក

(១២៥) (ធីតានៃសេដ្ឋី ពោលថា) ទាសៈឈ្មោះកដាហកៈនោះ ទៅកាន់ជនបទដទៃ ពោលអួតនូវពាក្យច្រើន សេដ្ឋីជាម្ចាស់មកតាម (ម្តងទៀត)គប្បីប្រទូស្តមិនខាន ម្នាលកដាហកៈ អ្នកចូរបរិភោគនូវភោគៈទាំងឡាយទៅ ៕

ចប់ កដាហកជាតក ទី ៥ ៕

## អសិលក្ខណជាតកំ

(១២៦) តេនេវេកស្ស(១) កល្យាណំ តេនេវេកស្ស បាបកំ
តស្មា សព្វំ ន កល្យាណំ សព្វំ វាបិ ន បាបកន្តិ ។

អសិលក្ខណជាតកំ ឆដ្ឋំ ។

## កលណ្ឌុកជាតកំ

(១២៧) តេ ទេសា តានិ វត្ថូនិ អហញ្ច វនគោចរោ
អនុវិច្ច ខោ តំ គណ្ហេយ្យុំ បិវ ខីរំ កលណ្ឌុកាតិ ។

កលណ្ឌុកជាតកំ សត្តមំ ។

## មូសិកជាតកំ

(១២៨) យោ វេ ធម្មទ្ធជំ កត្វា និគូឡ្ហោ បាបមាចរេ
វិស្សាសយិត្វា ភូតានិ ពិឡារំ នាម តំ វតន្តិ ។

មូសិកជាតកំ(២) អដ្ឋមំ ។

---
១ ម. តេនេវេកស្ស ។ ២ ម. ពិឡារវតជាតកំ ។



## អសិលក្ខណជាតក

(១២៦) (ព្រះពោធិសត្វ ពោលថា) ការកណ្តាស់នោះ របស់បុគ្គលខ្លះល្អ ការកណ្តាស់នោះ របស់បុគ្គលខ្លះអាក្រក់ ហេតុនោះការកណ្តាស់មិនមែនល្អទាំងអស់ មិនមែនអាក្រក់ទាំងអស់ទេ ។

ចប់ អសិលក្ខណជាតក ទី ៦ ។

## កលណ្ឌុកជាតក

(១២៧) (កូនរេក ពោលថា) នោះជាប្រទេស នោះជាទីកន្លែង ( គឺផ្លូវនៃការស៊ី ) សូម្បីខ្ញុំជាសត្វគោចរ ក្នុងព្រៃ ( គង់ដឹងដំណើរនុះ ម្ចាស់ទាំងឡាយរបស់អ្នក ) គេឃើញហើយចាប់អ្នកមិនខាន ម្នាលកលណ្ឌុកៈ អ្នកចូរផឹកទឹកដោះ ។

ចប់ កលណ្ឌុកជាតក ទី ៧ ។

## មូសិកជាតក

(១២៨) ( កណ្ដុរពោធិសត្វ ពោលថា ) បុគ្គលអ្នកបិទបាំងទោសណា ធ្វើនូវធម៌ឲ្យជាទង់ជ័យ ញុំាងសត្វទាំងឡាយឲ្យទុកចិត្ត ហើយប្រព្រឹត្តនូវអំពើអាក្រក់ វត្តរបស់បុគ្គលនោះ ឈ្មោះថា ពិឡារវត្ត ( វត្តឆ្មា ) ។

ចប់ មូសិកជាតក ទី ៨ ។

## អគ្គិកជាតកំ

(១២៩) នាយំ សិខា បុញ្ញហេតុ ឃាសហេតុ អយំ សិខា
នង្គុដ្ឋគណនំ យាតិ អលន្តេ ហោតុ អគ្គិកាតិ ។

អគ្គិកជាតកំ នវមំ ។

## កោសិយជាតកំ

(១៣០) យថា វាចា ច ភុញ្ជស្សុ យថា ភុត្តញ្ច ព្យាហរ
ឧភយន្តេ ន សមេតិ វាចា ភុត្តញ្ច កោសិយេតិ ។

កោសិយជាតកំ ទសមំ ។

កុសនាឡិវគ្គោ(១) តេរសមោ ។

### តស្សុទ្ទានំ

កុសនាឡិ សិរិវ្ហយោ ច យសំ
ធជិមច្ឆ កាជាហក បញ្ចមកោ
អថ ធាម សទ្ទំ ពិឡារគ្គិ
សិទ្ធិ កោសិយ សវ្ហយនេន ទស ។

---

១ ម. សរីវគ្គោ ។





## អគ្គិកជាតក

[១២៩] (កណ្ដុរពោធិសត្វ ពោលថា) កំប៉ោយនេះមិនមែនមាន ព្រោះហេតុនៃបុណ្យទេ កំប៉ោយនេះមាន ព្រោះហេតុតែគ្រឿងបរិភោគ ការរាប់ដោយកន្ទុយ រមែងប្រព្រឹត្តទៅ នែអគ្គិកៈ ការនៅរួមគ្នាដល់អ្នកហើយ ។

ចប់ អគ្គិកជាតក ទី ៩ ។

## កោសិយជាតក

[១៣០] (ព្រាហ្មណ៍ជាប្ដី ពោលថា) នាងចូរបរិភោគឲ្យដូចជាសំដី ចូរពោល (ថ្នាំ) ឲ្យដូចជាបាយដែលនាងស៊ីហើយ នែនាងព្រាហ្មណី ជាកោសិយគោត្រ (ព្រោះ) ពាក្យនឹងភត្តដែលនាងបរិភោគហើយ ទាំងពីរ (នេះ) មិនស្មើគ្នាទេ ។

ចប់ កោសិយជាតក ទី ១០ ។

ចប់ កុសនាឡិវគ្គ ទី ១៣ ។

### ឧទ្ទាននៃកុសនាឡិវគ្គនោះគឺ

និយាយអំពីកុសនាឡិជាតក ១ យស ១ ទឹកដោះជូរ ១ ស្វាយ ១ ពាសៈឈ្មោះកកជាហកៈជាតិរបស់ទ្រាំ ១ ទឹកដោះស្រស់ ១ ពិឡារគ្គ ១ ចចកមានកំប៉ោយ ១ កណ្ដាស់តក្រក់ ១ ព្រាហ្មណីជាកោសិយ-គោត្រ ១ ត្រូវជា ១០ ។

# អសម្បទានវគ្គោ

## អសម្បទានជាតកំ

(១៣១) អសម្បទានេនិតរីតរស្ស

ពាលស្ស មិត្តានិ កលី ភវន្តិ

តស្មា ហរាមិ ភុសំ អឌ្ឍមានំ

មា មេ មិត្តំ ជីយិត្ថ សស្សតាយំ ។

អសម្បទានជាតកំ បឋមំ ។

## បញ្ចភីរុកជាតកំ

(១៣២) កុសលូបទេសេ ធិតិយា ទឡ្ហាយ ច

អនិវត្តិតត្តា (១) ភយភីរុតាយ ច

ន រក្ខសីនំ វសមាគមិម្ហ (២)

ស សោត្ថិភាវោ មហតា ភយេន មេ ។

បញ្ចភីរុកជាតកំ ទុតិយំ ។

---

១ ម. អនិវត្តិតត្តា ។ ២ ម. វសមាគមិម្ហសេ ។

# អសម្បទានវគ្គ

## អសម្បទានជាតក

(១៣១) (សេដ្ឋីពោធិសត្វ ពោលថា) ការរាប់អានទាំងឡាយ របស់ជនពាល រមែងទៅជាទោស ព្រោះតែមិនទទួលខ្ទុក តាមមានតាមបាន ព្រោះហេតុនោះបានជាយើងខ្ញុំ នាំយកសំបកស្រូវកន្លះ មានៈ (៤តាវ) មក កុំឲ្យការមេត្រីរាប់អានរបស់យើង បែកធ្លាក់ទៅឡើយ សូមឲ្យការមេត្រីរាប់អាននេះនៅទៀងទាត់ ។

ចប់ អសម្បទានជាតក ទី ១ ។

## បញ្ចភីរុកជាតក

(១៣២) (ព្រះរាជាពោធិសត្វ ពោលថា) យើងមិនបានលុះក្នុងអំណាច នៃពួកយក្ខិនីឡើយ ព្រោះមានសេចក្ដីព្យាយាមដ៏មាំ ក្នុងឧបាយ គ្រឿងណែនាំរបស់ព្រះបច្ចេកពុទ្ធ ជាអ្នកឈ្លាសវៃ ព្រោះភាព ជាអ្នកគ្របសង្កត់សេចក្ដីខ្លាច និងសេចក្ដីតក់ស្លុតផង សួស្តិភាព ចាកភ័យដ៏ធំនោះ មានដល់ខ្ញុំ ។

ចប់ បញ្ចភីរុកជាតក ទី ២ ។

## ឃតាសនជាតកំ

(១៣៣) ខេមំ យហិំ តត្ថ អរី ឧទីរិតោ(១)
ទកស្ស មជ្ឈេ ជលតេ ឃតាសនោ
ន អជ្ជ វាសោ មហិយា មហីរុហេ
ទិសា ភជវ្ហោ សរណជ្ជ នោ ភយន្តិ ។

ឃតាសនជាតកំ តតិយំ ។

## ឈានសោធនជាតកំ

(១៣៤) យេ សញ្ញិនោ តេបិ ទុគ្គតា
យេបិ អសញ្ញិនោ តេបិ ទុគ្គតា
ឯតំ ឧភយំ វិវជ្ជយ
តំ សមាបត្តិ សុខំ អនង្គណន្តិ ។

ឈានសោធនជាតកំ ចតុត្ថំ ។

---

១ ម. ឧទ្ទីរិតោ ។



## ឃតាសនជាតក

(១៣៣) (ស្ដេចបក្សីពោធិសត្វ ពោលថា) សេចក្ដីក្សេមក្សាន្ដមានទៅលើទីទឹកណា លើទីទឹកនោះ មានសត្រូវកើតហើយ ព្រោះភ្លើងឆេះត្រង់កណ្ដាលនៃទឹក ទីអាស្រ័យនៅ (នៃពួកយើង) លើដើមឈើ (ដែលដុះ) លើផែនដី ក្នុងថ្ងៃនេះគ្មានទេ អ្នកទាំងឡាយ ចូរទៅកាន់ទិសឯទៀតទៅ ថ្ងៃនេះភ័យកើតឡើងដល់យើងទាំងឡាយ អំពីឈើជាទីពឹងហើយ ។

ចប់ ឃតាសនជាតក ទី ៣ ។

## ឈានសោធនជាតក

(១៣៤) (មហាព្រហ្មពោធិសត្វ ពោលថា) ពួកសត្វណា មានសញ្ញា ពួកសត្វនោះ ក៏ទុគ៌ត (មិនបានសមាបត្តិ) ពួកសត្វណាមិនមានសញ្ញា ពួកសត្វនោះក៏ទុគ៌ត អ្នកចូរវៀរនូវសត្វទាំងពីរពួកនោះចេញ សុខដែលកើតអំពីសមាបត្តិនោះ ឈ្មោះថា មិនមានទីទួលគឺកិលេសឡើយ ។

ចប់ ឈានសោធនជាតក ទី ៤ ។

## ចន្ទាភជាតកំ

(១៣៥) ចន្ទាភំ សុរិយាភញ្ច យោធ បញ្ញាយ គាធតិ
អវិតក្កេន ឈានេន ហោតិ អាភស្សរូបគោ ។

ចន្ទាភជាតកំ បញ្ចមំ ។

## សុវណ្ណហំសជាតកំ

(១៣៦) យំ លទ្ធំ តេន តុដ្ឋព្វំ អតិលោភោ ហិ បាបកោ
ហំសរាជំ គហេត្វាន សុវណ្ណា បរិហាយថាតិ(១)។

សុវណ្ណហំសជាតកំ ឆដ្ឋំ ។

## ពព្វុជាតកំ

(១៣៧) យត្ថេកោ លភតេ ពព្វុ ទុតិយោ តត្ថ ជាយតិ
តតិយោ ច ចតុត្ថោ ច ឥទន្តេ ពព្វុកា ពិលន្តិ។

ពព្វុជាតកំ សត្តមំ ។

១ ម. បរិហាយថ ។



## ចន្ទាភជាតក

(១៣៥) (មហាព្រហ្មពោធិសត្វ ពោលថា) បុគ្គលណាក្នុងលោកនេះបាន នូវកសិណ មានពន្លឺដូចព្រះចន្ទ (ឱទាតកសិណ) មានពន្លឺដូចព្រះអាទិត្យ (បីតកសិណ) ដោយបញ្ញា បុគ្គលនោះ រមែងទៅកើតក្នុងអាភស្សរព្រហ្មលោក ដោយឈានមិនមានវិតក្កៈ (ទុតិយជ្ឈាន) ។

ចប់ ចន្ទាភជាតកទី ៥ ។

## សុវណ្ណហំសជាតក

(១៣៦) (ព្រះសាស្តាត្រាស់ថា) ទ្រព្យណា ដែលបុគ្គលបានមកហើយ បុគ្គលគប្បីត្រេកអរដោយទ្រព្យនោះ ព្រោះថាសេចក្តីលោភហួស ជាបាបលាមក (ដូចនាងព្រាហ្មណី) ក៏សាបសូន្យ ចាកមាស ព្រោះចាប់ស្តេចហង្ស ។

ចប់ សុវណ្ណហំសជាតកទី ៦ ។

## ពព្វុជាតក

(១៣៧) (ព្រះសាស្តាត្រាស់ថា) ឆ្មា ១ បានកណ្តុរ ក្នុងទីណា ឆ្មាទីពីរទីបីទីបួន រមែងកើតក្នុងទីនោះ ឆ្មាទាំងនោះ(ប្រហារ) នូវកែវនេះ ហើយដល់នូវសេចក្តីស្លាប់ ។

ចប់ ពព្វុជាតកទី ៧ ។

## គោធជាតកំ

(១៣៨) កិំ តេ ជដាហិ ទុម្មេធ កិំ តេ អជិនសាដិយា
អព្ភន្តរំ តេ គហនំ ពាហិរំ បរិមជ្ជសីតិ ។

គោធជាតកំ អដ្ឋមំ ។

## ឧភតោភដ្ឋជាតកំ

(១៣៩) អក្ខី ភិន្នា បដោ នដ្ឋោ សខិគេហេ ច ភណ្ឌនំ
ឧភតោ បទុដ្ឋកម្មន្តា ឧទកម្ហិ ថលម្ហិ ចាតិ ។

ឧភតោភដ្ឋជាតកំ នវមំ ។

## កាកជាតកំ

(១៤០) និច្ចំ ឧព្វិគ្គហទយា សព្វលោកវិហេសកា
តស្មា នេសំ វសា នត្ថិ កាកានម្ហាក ញាតិនន្តិ ។

កាកជាតកំ ទសមំ ។

អសម្បទានវគ្គោ ចុទ្ទសមោ ។



## គោធជាតក

(១៣៨) (ឧត្តមគោធបោធិសត្វ ពោលថា) ម្នាលតាបស ឥតប្រាជ្ញ ប្រយោជន៍អ្វីដោយជដារបស់អ្នក ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ព្រោះគ្រឿងសៅហ្មងដោយ (កាមាទិកិលេស) មានខាងក្នុងរបស់អ្នក អ្នកដុះខាត់តែខាងក្រៅ ។

ចប់ គោធជាតក ទី ៨ ។

## ឧភតោភដ្ឋជាតក

(១៣៩) (រុក្ខទេវតាពោធិសត្វ ពោលថា) ភ្នែកទាំងពីរក៏បែកធ្លាយហើយ សំពត់បាត់ហើយ ការឈ្លោះ ក៏មានក្នុងផ្ទះនៃស្រ្តីជាសំឡាញ់ ការងារទាំងពីរខូចទាំងសងខាង គឺក្នុងទឹកផង លើគោកផង ។

ចប់ ឧភតោភដ្ឋជាតក ទី ៩ ។

## កាកជាតក

(១៤០) (ក្អែកពោធិសត្វ ពោលថា) ក្អែកទាំងឡាយ ជាសត្វមានហឫទ័យភ្ញាក់ផ្អើលជានិច្ច ជាសត្វបៀតបៀនមនុស្សលោកទាំងពួង ព្រោះហេតុនោះ បានជាខ្លាញ់ក្នុងខ្លួនក្អែក ជាញាតិរបស់យើងទាំងនោះ មិនមានឡើយ ។

ចប់ កាកជាតក ទី ១០ ។

ចប់ អសម្បទានវគ្គ ទី ១៤ ។

## តស្សុទ្ទានំ

ឥតរោតា រត្តាសិ ទេមំយោ ច

បកាសតបញ្ហោ អាភស្សរេ ឬន

អជ ហំសុត្តម ពព្ពុ ជង

បជ្ជន្តក កាកាវេន ទស ។

---



## ឧទ្ទាននៃអសម្បទានវគ្គនោះគឺ

និយាយអំពីក្តីកាមមាន កាមបាន ១ យក្ខិនី ១ ទីក្សេម ១ អាភស្សរមហាព្រហ្មដូចក្តីបកស្រាយបញ្ហា ១ អាភស្សរមហាព្រហ្មទៀត ហង្សឧត្តមប្រសើរ ១ ឆ្មា ១ ផង ១ ព្រានខុបាក់សំពត់ ១ ក្អែក ១ ត្រូវជា ១០ ។

---

# កកណ្ដកវគ្គោ

## គោធជាតកំ

(១៤១) ន បាបជនសំសេវី អច្ចន្តសុខមេធតិ
គោធាកុលំ កកណ្ដាវ កលឹ បាបេតិ អត្តនំ ។

គោធជាតកំ បឋមំ ។

## សិង្គាលជាតកំ

(១៤២) ឯតំ ហិ តេ ទុរាជានំ យំ សេសិ មតសាយិតំ
យស្ស តេ កឌ្ឍមានស្ស ហត្ថា ទណ្ឌោ ន មុច្ចតិ ។

សិង្គាលជាតកំ ទុតិយំ ។

## វិរោចនជាតកំ

(១៤៣) លសី ច តេ និប្ផលិតា មត្ថកោ ច បទាលិតោ
សព្វា តេ ផាសុកា ភគ្គា អជ្ជ ខោ ត្វំ វិរោចសិ ។

វិរោចនជាតកំ តតិយំ ។

# កកណ្ដកវគ្គ

## គោធជាតក

(១៤១) (ស្ដេចទន្សោងពោធិសត្វ ពោលថា) បុគ្គលអ្នកសេពគប់នូវជនបាប រមែងមិនដល់នូវសេចក្ដីសុខពិតទេ ដូចជាត្រកូលទន្សោងមិនបានសេចក្ដីសុខ ព្រោះត្រកួត រមែងញ៉ាំងខ្លួនឲ្យដល់នូវសេចក្ដីវិនាស ។

ចប់ គោធជាតក ទី ១ ។

## សិង្គាលជាតក

(១៤២) (ស្ដេចចចកពោធិសត្វ ពោលថា) អ្នកដេកធ្វើពុតជាស្លាប់ ដោយហេតុណា ហេតុរបស់អ្នកនុ៎ះ ដឹងបានដោយក្រ តែដំបងមិនរបូតអំពីដៃរបស់អ្នក កំពុងទាញទៅនោះ ។

ចប់ សិង្គាលជាតក ទី ២ ។

## វិរោចនជាតក

(១៤៣) (កេសរសីហពោធិសត្វ ពោលថា) ខួរក្បាលរបស់អ្នកធ្លាយចេញផង លលាដ៍ក្បាលរបស់អ្នកបែកធ្លាយផង ឆ្អឹងជំនីទាំងអស់របស់អ្នកដាច់បាក់ហើយផង ក្នុងថ្ងៃនេះ អ្នកនៅរុងរឿងក្រៃទៀត ។

ចប់ វិរោចនជាតក ទី ៣ ។

## នង្គុដ្ឋជាតកំ

(១៤៤) ពហុម្បេតំ អសព្ភិ ជាតវេទ
យំ តំ វាលធិនាភិបូជយាម
មំសារហស្ស នត្ថជ្ជ មំសំ
នង្គុដ្ឋម្បិ ភវំ បដិគ្គហាតុ ។

នង្គុដ្ឋជាតកំ ចតុត្ថំ ។

## រាធជាតកំ

(១៤៥) ន ត្វំ រាធ វិជានាសិ អឌ្ឍរត្តេ អនាគតេ
អព្យាយតំ វិលបសិ វិរត្តា កោសិយាយនេតិ ។

រាធជាតកំ បញ្ចមំ ។

## កាកជាតកំ

(១៤៦) អបិ នុ ហនុកា សន្តា មុខញ្ច បរិសុស្សតិ
ឱរមាម ន បារេម បូរតេវ មហោទធីតិ ។

កាកជាតកំ[១] ឆដ្ឋំ ។

---
១ ម. សមុទ្ទកាកជាតកំ ។



## នង្គុដ្ឋជាតក

(១៤៤) (តាបសពោធិសត្វ ពោលថា) ម្នាលភ្លើង ជាអសប្បុរស យើងនឹងបូជាភ្លើងដោយកន្ទុយណា កន្ទុយប៉ុណ្ណោះច្រើនហើយ ក្នុងថ្ងៃនេះ សាច់មិនមានដល់អ្នកដ៏គួរដល់សាច់ទេ អ្នកដ៏ចំរើន ចូរទទួលយកតែកន្ទុយចុះ ។

ចប់ នង្គុដ្ឋជាតក ទី ៤ ។

## រាធជាតក

(១៤៥) (សេកពោធិសត្វ ពោលថា) ម្នាលរាធៈ អ្នកមិនដឹងច្បាស់ថា ក្នុងមនុស្សប៉ុណ្ណោះ ក្នុងវេលាពាក់កណ្តាលអធ្រាត្រមិនទាន់មកដល់ ពោលចរចានូវពាក្យមិនប្រាកដ នឹងនាងព្រាហ្មណីជាកោសិយានគោត្រ អ្នកមិនមានតម្រេក(នឹងស្វាមីខ្លួន) ។

ចប់ រាធជាតក ទី ៥ ។

## កាកជាតក

(១៤៦) (ក្អែកក្អក ពោលថា) អើ ចង្កាយើងក៏រោយ ទាំងមាត់ក៏ស្ងួតក្រៀមក្រោះ យើងមិនអាចបាចទឹកក្នុងសមុទ្រឲ្យរីងបានទេ ព្រោះមហាសមុទ្រនៅតែពេញដដែល ។

ចប់ កាកជាតក ទី ៦ ។

## បុប្ផរត្តជាតកំ

(១៤៧) នយិទំ ទុក្ខំ អទុំ ទុក្ខំ យំ មំ តុទតិ វាយសោ

យំ សាមា បុប្ផរត្តេន កត្តិកំ នានុភោស្សតិ។

បុប្ផរត្តជាតកំ សត្តមំ ។

## សិង្គាលជាតកំ

(១៤៨) នាហំ បុនំ ន ច បុនំ ន ចាបិ អបុនប្បុនំ

ហត្ថិពោន្ទឹ បវេក្ខាមិ តថា ហិ ភយតជ្ជិតោ ។

សិង្គាលជាតកំ អដ្ឋមំ ។

## ឯកបណ្ណជាតកំ

(១៤៩) ឯកបណ្ណោ អយំ រុក្ខោ ន ភូម្យា ចតុរង្គុលោ

ផលេន វិសកប្បេន មហាយំ(១) កឹ ភវិស្សតិ។

ឯកបណ្ណជាតកំ នវមំ ។

១ ឱ. បហាយ ។



## បុប្ផរត្តជាតក

(១៤៧) (មនុស្សទុគ៌ត ពោលថា) ក្អែកចោះអញ ដោយហេតុណា ហេតុនេះ មិនជាទុក្ខទេ សេចក្ដីទុក្ខនោះ ក៏មិនមានដល់យើងឡើយ ទុក្ខមានដល់យើងនោះ ត្រង់ការិយាឈ្មោះសាមា មិនស្លៀកដណ្ដប់សំពត់ ដែលជ្រលក់ដោយទឹកដកគាំ ដើរមើលមហោស្រព ក្នុងខែកត្តិក ។

ចប់ បុប្ផរត្តជាតក ទី ៧ ។

## សិង្គាលជាតក

(១៤៨) (ចចកពោធិសត្វ ពោលថា) យើង នឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីញយៗទេ ព្រោះយើងត្រូវភ័យតម្រាមហើយ ដូច្នោះ ។

ចប់ សិង្គាលជាតក ទី ៨ ។

## ឯកបណ្ណជាតក

(១៤៩) (ឥសីពោធិសត្វ ពោលថា) ឈើនេះទើបតែនឹងមានស្លឹកតែមួយៗ ផុសអំពីផែនដី មិនទាន់ដល់ ៤ ធ្នាប់ មានផ្លែដូចជាថ្នាំពិសទៅហើយ ចំណង់ឈើនេះធំឡើង នឹងដូចម្ដេចទៅទៀត ។

ចប់ ឯកបណ្ណជាតក ទី ៩ ។

## សញ្ជីវជាតកំ

(១៥០) អសន្តំ យោ បគ្គណ្ហាតិ អសន្តំ ចូបសេវតិ

តមេវ ឃាសំ កុរុតេ ព្យគ្ឃោ សញ្ជីវកោ យថាតិ ។

សញ្ជីវជាតកំ ទសមំ ។

កកណ្ដកវគ្គោ(១) បណ្ណរសមោ ។

## តស្សុទ្ទានំ

សុខមេតតិ ចណ្ឌរកោ ច បុន

សសិ ភិលធិ បញ្ចមកវរកោ

សមហោធនំ(២) កត្តិកា ពោធិ បុន

ចតុរង្គុល ព្យគ្ឃវរេន ទស ។

---

១ ម. ជាចសេវនវគ្គោ ។ ២ ម. បំសមហោធតិ ។



## សញ្ជីវជាតក

(១៥០) (សាស្ដាជាអភិសម្ពុទ្ធ ពោលថា) បុគ្គលណាលើកដំកើងនូវជន ជាអសប្បុរសផង ចូលទៅសេពគប់នូវជន ជាអសប្បុរសផង ជនជាអសប្បុរសនោះ រមែងធ្វើនូវបុគ្គលនោះឯង ឲ្យទៅជាអាហារដូចខ្លាធំនឹងសញ្ជីវមាណព ។

ចប់ សញ្ជីវជាតក ទី ១០ ។

ចប់ កកណ្ដកវគ្គ ទី ១៥ ។

## ឧទ្ទាននៃកកណ្ដកវគ្គនោះគឺ

និយាយអំពីបុគ្គលដល់នូវសេចក្ដីសុខ ១ ជ័យនីប្រសើរ ១ ខ្លួនក្បាល ១ កន្ទុយ ១ សេកឈ្មោះរាធៈដ៏ប្រសើរជាតិរបស់ក្រុង ១ សមុទ្រ ១ មហាស្រពនៃកត្តិក ១ គោះដំរ ១ ឈើផុះ ៤ ញាប់ ១ ខ្លាធំប្រសើរ ១ ត្រូវជា ១០ ។

## តត្រ វគ្គុទ្ទានំ ភវតិ ។

អបណ្ណកំ សីលវគ្គំ កុរុង្គំ
កុលាវកំ អត្ថកាមេន បញ្ចមំ
អាសីសោ ឥត្ថី វរុណំ អបាយិ
លិត្តវគ្គេន តេ ទស
បរោសតំ ហំសិ សរក្ខំ អសម្បទំ
តាបសេវវគ្គោ ឯកនិបាតម្ហិ លក្ខិតា ។

ឯកនិបាតំ និដ្ឋិតំ ។

---





## ឧទ្ទាននៃវគ្គមានក្នុងឯកនិបាតនោះគឺ

អបណ្ណកវគ្គ ១ សីលវគ្គ ១ កុរុង្គវគ្គ ១ កុលាវកវគ្គ ១ អត្ថកាមវគ្គ ជាគំរប់ប្រាំ ១ អាសីសវគ្គ ១ ឥត្ថីវគ្គ ១ វរុណវគ្គ ១ អបាយិម្ហវគ្គ ១ លិត្តវគ្គ ១ ត្រូវជា ១០ បរោសតវគ្គ ១ ហំសិវគ្គ ១ កុសនាឡិវគ្គ ១ អសម្បទានវគ្គ ១ កកណ្តកវគ្គ ១ ក្នុងឯកនិបាតប្រដាប់ (ដោយវត្ថុរបស់ឯង) ។

ចប់ ឯកនិបាត ។

---

## ទុកនិបាតជាតកំ

### ទឡ្ហវគ្គោ

### រាជោវាទជាតកំ

(១៥១) ទឡ្ហំ ទឡ្ហស្ស ខិបតិ ពល្លិកោ មុទុនា មុទុំ
សាធុម្បិ សាធុនា ជេតិ អសាធុម្បិ អសាធុនា
ឯតាទិសោ អយំ រាជា មគ្គា ឧយ្យាហិ សារថិ។

(១៥២) អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ
ឯតាទិសោ អយំ រាជា មគ្គា ឧយ្យាហិ សារថីតិ។

រាជោវាទជាតកំ បឋមំ ។

### ទឡ្ហវគ្គ

### រាជោវាទជាតក

(១៥១) (សារថីរបស់ព្រះបាទពល្លិកៈ ពោលថា) ព្រះបាទពល្លិកៈ រមែងបោះនូវរបស់រឹងដល់បុគ្គលអ្នករឹង ឈ្នះនូវបុគ្គលទន់ដោយការទន់ ឈ្នះនូវសប្បុរស ដោយសប្បុរស ឈ្នះនូវអសប្បុរស ដោយអសប្បុរស ព្រះរាជានេះ (មានសីលធម៌អាចារៈ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅ ។

(១៥២) (សារថីរបស់ព្រះបាទកោសល ពោលថា) ព្រះរាជាតែងឈ្នះបុគ្គលអ្នកក្រោធ ដោយសេចក្ដីមិនក្រោធ តែងឈ្នះអសប្បុរស ដោយសប្បុរស តែងឈ្នះបុគ្គលកំណាញ់ ដោយការឲ្យ តែងឈ្នះបុគ្គលអ្នកពោលពាក្យកុហក ដោយការពោលពាក្យពិត ព្រះរាជានេះ (មានសីលធម៌អាចារៈ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅ ។

ចប់ រាជោវាទជាតកទី ១ ។

## សិគាលជាតកំ

(១៥៣) អសមេក្ខិតកម្មន្តំ តុរិតាភិនិបាតិនំ
សានិ(១) កម្មានិ តប្បេន្តិ ឧណ្ហំវជ្ឈោហិតំ មុខេ ។
(១៥៤) សីហោ ច សីហនាទេន ទទ្ទរំ អភិនាទយិ
សុត្វា សីហស្ស និគ្ឃោសំ សិគាលោ ទទ្ទរេ វសំ
ភីតោ សន្តាសមាបាទិ ហទយញ្ចស្ស អប្ផលីតិ ។

សិគាលជាតកំ ទុតិយំ ។

## សូករជាតកំ

(១៥៥) ចតុប្បទោ អហំ សម្ម ត្វម្បិ សម្ម ចតុប្បទោ
ឯហិ សម្ម និវត្តស្សុ កិន្នុ ភីតោ បលាយសិ ។
(១៥៦) អសុចិ បូតិលោមោសិ ទុគ្គន្ធោ វាសិ សូករ
សចេ យុជ្ឈិតុកាមោសិ ជយំ សម្ម ទទាមិ តេ ។

សូករជាតកំ តតិយំ ។

---
១ ម. សានិ ។





## សិគាលជាតក

(១៥៣) (រាជសីហ៍ពោធិសត្វ ពោលថា) ការងារទាំងឡាយនោះ ញុំាងបុគ្គលអ្នកមានការងារមិនបានពិចារណា ដោយត្រឹមត្រូវ ឲ្យសំរេចដោយស្រួល តែងឲ្យក្តៅក្រហាយ ដូចជាវត្ថុក្តៅដែលបុគ្គលបៀមចូលទៅក្នុងមាត់ ។

(១៥៤) (ព្រះសាស្តាត្រាស់ថា) សីហៈញុំាងភ្នំក្រហុកឲ្យលាន់ឮខ្ទាំង ដោយសីហនាទ ចចកនៅក្នុងភ្នំក្រហុក បានឮសម្លេងគឹកកង នៃសត្វសីហៈហើយ ក៏ភ័យតក់ស្លុតបែកហឫទ័យស្លាប់ ។

ចប់ សិគាលជាតក ទី ២ ។

## សូករជាតក

(១៥៥) (សូករៈ ពោលថា) ម្នាលសំឡាញ់អ្នកមានធុរៈស្មើ ខ្ញុំមានជើង ៤ ម្នាលសំឡាញ់ អ្នកឯងក៏មានជើង ៤ ដែរ ម្នាលសំឡាញ់ អ្នកចូរត្រឡប់មក អ្នកខ្លាចឬ បានជារត់ចេញ ។

(១៥៦) (សីហៈពោធិសត្វ ពោលថា) ម្នាលសូករៈ អ្នកមានកាយមិនស្អាត មានរោមប្រឡាក់ដោយវត្ថុស្អុយ មានក្លិនអាក្រក់បក់ទៅ បើអ្នកចង់ច្បាំងនឹងគ្នា ម្នាលសំឡាញ់ យើងឲ្យជ័យដល់អ្នកឯង ។

ចប់ សូករជាតក ទី ៣ ។

## ឧរគជាតកំ

(១៥៧) ឥធូរគានំ បវរោ បវិដ្ឋោ
សេលស្ស វណ្ណេន បមោក្ខមិច្ឆំ
ព្រហ្មញ្ច វណ្ណំ អបចាយមានោ
ពុភុក្ខិតោ នោ វិសហាមិ(១) ភោត្តុំ ។

(១៥៨) សោ ព្រហ្មគុត្តោ ចិរមេវ ជីវ
ទិព្យា ច តេ បាតុភវន្តុ ភក្ខា
សោ ព្រហ្មវណ្ណំ អបចាយមានោ
ពុភុក្ខិតោ នោ វិតរាសិ ភោត្តុន្តិ ។

ឧរគជាតកំ ចតុត្ថំ ។

## ភគ្គជាតកំ

(១៥៩) ជីវ វស្សសតំ គគ្គ អបរានិ ច វីសតិំ
មា មំ បិសាចា ខាទន្តុ ជីវ ត្វំ សរទោសតំ ។

(១៦០) ត្វម្បិ វស្សសតំ ជីវ អបរានិ ច វីសតិំ
វិសំ បិសាចា ខាទន្តុ ជីវ ត្វំ សរទោសតន្តិ ។

ភគ្គជាតកំ បញ្ចមំ ។

---
១ ម. វិតរាមិ ។



## ឧរគជាតក

(១៥៧) (គ្រុឌ ពោលថា) ស្តេចនាគដ៏ប្រសើរជាងពស់ទាំងឡាយ មានភេទដូចជាថ្មដែលកើតអំពីភ្នំ ប្រាថ្នាដើម្បីរួច បានចូលទៅក្នុងសំពត់ស្បៀតនេះ ខ្ញុំកោតក្រែងនូវបុគ្គលមានភេទដ៏ប្រសើរ ខ្ញុំប្រាថ្នានឹងបរិភោគ តែមិនអាចនឹងបរិភោគបាន ។

(១៥៨) (តាបសពោធិសត្វ ពោលថា) អ្នកមានបុគ្គលដ៏ប្រសើរគ្រប់គ្រងហើយ ចូររស់នៅអស់កាលយូរ អាហារជាទិព្វទាំងឡាយ ចូរកើតប្រាកដដល់អ្នក (ព្រោះថា) អ្នកកោតក្រែងនូវបុគ្គលមានភេទដ៏ប្រសើរ អ្នកប្រាថ្នានឹងបរិភោគ តែមិនអាចបរិភោគបាន ។

ចប់ ឧរគជាតក ទី ៤ ។

## ភគ្គជាតក

(១៥៩) (មាណពពោធិសត្វ ពោលថា) បពិត្រគគ្គៈ សូមលោករស់នៅអស់ ១២០ ឆ្នាំ បិសាចទាំងឡាយ ចូរកុំខាំស៊ីខ្ញុំឡើយ សូមលោករស់នៅអស់ ១២០ ឆ្នាំ ។

(១៦០) (បិតារបស់ពោធិសត្វ ពោលថា) អ្នកចូររស់នៅអស់ ១២០ ឆ្នាំដែរ បិសាចទាំងឡាយ ចូរខាំស៊ីនូវថ្នាំពិស អ្នកចូររស់នៅអស់ ១២០ ឆ្នាំ ។

ចប់ ភគ្គជាតក ទី ៥ ។

## អលីនចិត្តជាតកំ

(១៦១) អលីនចិត្តំ និស្សាយ បហដ្ឋា មហតី ចមូ
កោសលំ សេនាសន្តុដ្ឋំ ជីវគ្គាហំ អគាហយិ ។

(១៦២) ឯវំ និស្សយសម្បន្នោ ភិក្ខុ អារទ្ធវីរិយោ
ភាវយំ កុសលំ ធម្មំ យោគក្ខេមស្ស បត្តិយា
បាបុណេ អនុបុព្វេន សព្វសំយោជនក្ខយន្តិ ។

អលីនចិត្តជាតកំ ឆដ្ឋំ ។

## គុណជាតកំ

(១៦៣) យេន កាមំ បណាមេតិ ធម្មោ ពលវតំ មិគិ
ឧន្នទន្តី វិជានាហិ ជាតំ សរណតោ ភយំ ។



## អលីនចិត្តជាតក

(១៦១) (ព្រះសាស្ដាត្រាស់ថា) សេនាដ៏ច្រើន មានចិត្តរីករាយ ព្រោះអាស្រ័យនូវអលីនចិត្តរាជកុមារ បានញុំាងដំរីឲ្យចាប់យកព្រះបាទកោសលទាំងរស់ដែលមិនត្រេកអរហើយ ដោយរាជសម្បត្តិរបស់ខ្លួនយ៉ាងណាមិញ ។

(១៦២) ភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ មានសេចក្ដីព្យាយាមប្រារព្ធហើយ កាលចំរើននូវកុសលធម៌ ដើម្បីសម្រេចនូវព្រះនិព្វានជាទីក្សេមចាកយោគៈ គប្បីដល់នូវការអស់ទៅនៃសំយោជនៈទាំងពួងដោយលំដាប់ ក៏យ៉ាងនោះដែរ ។

ចប់ អលីនចិត្តជាតក ទី ៦ ។

## គុណជាតក

(១៦៣) (ចចក ពោលថា) អ្នកមានកំឡាំងបណ្ដាញ(នូវបុគ្គលអ្នកសេពគប់នឹងខ្លួន) តាមសេចក្ដីប្រាថ្នាបាន បពិត្រស្ដេចម្រឹគ(នេះ)ជាធម្មតានៃអ្នកមានកំឡាំង បពិត្រស្ដេចម្រឹគ អ្នកមានចង្កូមស្រួច លោកចូរដឹងចុះ មរណភ័យកើតហើយអំពីទីពឹង(របស់យើង) ។

(១៦៦) អបិ ចេបិ ទុព្ពលោ មិត្តោ មិត្តធម្មេសុ តិដ្ឋតិ
សោ ញាតកោ ច ពន្ធុ ច សោ មិត្តោ សោ ច មេ សខា
ទាឋិនិ មាតិមញ្ញវ្ហោ សិគាលោ មម បាណទោតិ ។

គុណជាតកំ សត្តមំ ។

## សុហនុជាតកំ

(១៦៧) នយិទំ វិសមសីលេន សោណេន សុហនូ សហ
សុហនូបិ តាទិសោ យេវ យោ សោណស្ស សគោចរោ ។

(១៦៨) បក្ខន្ទិនា បគព្ភេន និច្ចំ សន្ទានខាទិនា
សមេតិ បាបំ បាបេន សមេតិ អសតា អសំ ។

សុហនុជាតកំ អដ្ឋមំ ។



(១៦៦) (សីហៈពោធិសត្វ ពោលថា) ប្រសិនបើមិត្រមានកំឡាំងខ្សោយ តែតាំងនៅក្នុងមិត្រធម៌ទាំងឡាយ បុគ្គលនោះហៅថាជាញាតិផង ជាផៅពង្សផង បុគ្គលនោះហៅថា មិត្រផង បុគ្គលនោះហៅថា សំឡាញ់របស់យើងផង ម្នាលមេម្រឹគមានចង្កូម ឯងកុំមើលងាយចចកឈ្មោល នឹងចចកញី ជាសំឡាញ់យើងឡើយ ព្រោះចចក ជាអ្នកឲ្យជីវិតដល់យើង ។

ចប់ គុណជាតក ទី ៧ ។

## សុហនុជាតក

(១៦៧) (អមាត្យពោធិសត្វ ពោលថា) សេះឈ្មោះសុហនុ ធ្វើនូវសេចក្តីស្រឡាញ់នេះ ជាមួយនឹងសេះឈ្មោះសោណៈ មិនមែនដោយមារយាទមិនស្មើគ្នាទេ សេចក្តីប្រព្រឹត្តិរបស់សេះឈ្មោះសោណៈ យ៉ាងណា សេះឈ្មោះសុហនុ ក៏ប្រាកដយ៉ាងនោះដែរ ។

(១៦៨) អំពើរមែងស្មើគ្នាដោយការស្ទុះទៅ នឹងការឃ្លើសឃ្លង់នឹងការខាំកាត់នូវខ្សែកន្ទុំ អំពើអាក្រក់ស្មើគ្នា ដោយអំពើអាក្រក់ ការមិនរៀបរយស្មើគ្នា ដោយការមិនរៀបរយ ។

ចប់ សុហនុជាតក ទី ៨ ។

# មោរជាតកំ

(១៦៧) ឧទេតយញ្ចក្ខុមា ឯករាជា
ហរិស្សវណ្ណោ បឋវិប្បភាសោ
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ
តយជ្ជ គុត្តា វិហរេមុ ទិវសំ
យេ ព្រាហ្មណា វេទគុ(១) សព្វធម្មេ
តេ មេ នមោ តេ ច មំ បាលយន្តុ
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា
នមោ វិមុត្តានំ នមោ វិមុត្តិយា
ឥមំ សោ បរិត្តំ កត្វា មោរោ ចរតិ ឯសនា ។

(១៦៨) អបេតយញ្ចក្ខុមា ឯករាជា
ហរិស្សវណ្ណោ បឋវិប្បភាសោ
តំ តំ នមស្សាមិ ហរិស្សវណ្ណំ បឋវិប្បភាសំ
តយជ្ជ គុត្តា វិហរេមុ រត្តឹ

១ ឱ. វេទគូ ។



# មោរជាតក

(១៦៧) (ក្ងោកពោធិសត្វ ពោលថា) សុរិយទេវបុត្រណា ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងរះឡើង ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សា អស់វេលាថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សំរេចនូវវេទ ក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះ រក្សាខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វនោះធ្វើបរិត្តនេះរួចហើយ ទើបត្រាច់ទៅស្វែងរកអាហារ ។

(១៦៨) (សុរិយទេវបុត្រណា) ជាឯករាជមានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងអស្តង្គតទៅ ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សា អស់រាត្រីនៃថ្ងៃនេះ

យេ ព្រាហ្មណា វេទគូ សព្វធម្មេ
តេ មេ នមោ តេ ច មំ បាលយន្តុ
នមត្ថុ ពុទ្ធានំ នមត្ថុ ពោធិយា
នមោ វិមុត្តានំ នមោ វិមុត្តិយា
ឥមំ សោ បរិត្តំ កត្វា មោរោ វាសមកប្បយីតិ ។

មោរជាតកំ នវមំ ។

## វិនីលកជាតកំ

(១៦៩) ឯវមេវ នូន រាជានំ វេទេហំ មិថិលគ្គហំ
អស្សា វហន្តិ អាជញ្ញា យថា ហំសា វិនីលកំ ។
(១៧០) វិនីល ទុគ្គំ ភជសិ អភូមឹ តាត សេវសិ
គាមន្តកានិ(១) សេវស្សុ ឯតំ មាតាលយំ តវន្តិ ។

វិនីលកជាតកំ ទសមំ ។

ទឡ្ហវគ្គោ បឋមោ ។

១ ម. គាមន្តានិ ។



ព្រាហ្មណ៍ទាំងឡាយណា សំរេចនូវវេទ គឺធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វធ្វើបរិត្តនេះរួចហើយ ទើបបានសម្រេចការនៅ ។

ចប់ មោរជាតក ទី ៩ ។

## វិនីលកជាតក

(១៦៩) (កូនក្អែកកាត់ហង្ស ពោលថា) ហង្សទាំងឡាយ(ក៏មកនាំយើង) ឈ្មោះវិនីលកៈទៅបានយ៉ាងណាមិញ សេះអាជានេយ្យទាំងឡាយ នាំនូវព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលាក៏យ៉ាងនោះដែរ ។

(១៧០) (ហង្សពោធិសត្វជាបិតា ពោលថា) ម្នាលវិនីលកៈ អ្នកគប់រកនូវព្រៃភ្នំមានប្រហោងជ្រៀក ម្នាលកូន អ្នកសេពនូវកន្លែងមិនមែនជាទីរបស់អ្នក ។ ចូរសេពនូវកន្លែងជាទីបំផុតនៃស្រុកចុះ ទីនោះជាលំនៅ របស់មាតាអ្នកហើយ ។

ចប់ វិនីលកជាតក ទី ១០ ។

ចប់ ទឡ្ហវគ្គ ទី ១ ។

## តស្សុទ្ទានំ

ពេល្លិកា ឈម្ពុ សូករោ
ឧរគុត្តម បញ្ចមភគ្គវោ
មហាតិឧម្មាយ សិគាលវោ
សុហនុត្តម មោរ វិនីលំ ទស ។

---



## ឧទ្ទាននៃទឡ្ហវគ្គនោះគឺ

និយាយអំពីព្រះបាទពល្លិកៈដ៏ប្រសើរ ១ កំប្រុក ១ សូករៈ ១ នាគប្រសើរជាធំពស់ ១ បិតាឈ្មោះភគ្គៈ ១ ជាតិរបស់ ៤ សេនាធំ ១ ចចកប្រសើរ ១ សេះឈ្មោះសុហនុដ៏ឧត្តម ១ ក្ងោក ១ វិនីលកៈ ១ ត្រូវជា ១០ ។

---

## សន្ថវវគ្គោ

## ឥន្ទសមានគោត្តជាតកំ

(១៧១) ន សន្ថវំ កាបុរិសេន កយិរា
អរិយោ អនរិយេន បជានមត្ថំ
ចិរានុវុត្ថម្បិ[១] ករោតិ បាបំ
គជោ យថា ឥន្ទសមានគោត្តំ ។

(១៧២) យទេវ[២] ជញ្ញា សទិសោ មមន្តិ
សីលេន បញ្ញាយ សុតេន ចាបិ
តេនេវ មេត្តឹ[៣] កយិរាថ សទ្ធឹ
សុខោ ហវេ សប្បុរិសេន សង្គមោ ។

ឥន្ទសមានគោត្តជាតកំ បឋមំ ។

## សន្ថវជាតកំ

(១៧៣) ន សន្ថវស្មា បរមត្ថិ បាបិយោ
យោ សន្ថវោ កាបុរិសេន ហោតិ
សន្តប្បិតោ សប្បិនា បាយសេន
កិច្ឆា កតំ បណ្ណកុដឹ អទយ្ហិ[៤] ។

១ ម. ចិរានុវុត្ថម្បិ ។ ២ យ. ទេវ ។ ៣ ម. មិត្តិំ ។ ៤ ម. អទយ្ហ ។

## សន្ថវវគ្គ

## ឥន្ទសមានគោត្តជាតក

(១៧១) (តាបសពោធិសត្វ ពោលថា) បុគ្គលកុំគប្បីធ្វើសេចក្តីស្និទ្ធស្នាល ជាមួយនឹងបុរសលាមក អរិយបុគ្គល ដឹងច្បាស់នូវប្រយោជន៍ (កុំគប្បីធ្វើនូវសេចក្តីស្និទ្ធស្នាល) ជាមួយនឹងបុគ្គលមិនមែនជាអរិយៈ (បុគ្គលមិនមែនជាអរិយៈ) សូម្បីនៅជាមួយគ្នាអស់កាលយូរ រមែងធ្វើអំពើអាក្រក់ ដូចជាដំរីកាលព្រួចនូវតាបសឈ្មោះ ឥន្ទសមានគោត្ត ។

(១៧២) បុគ្គលគប្បីដឹងនូវជនណាថា បុគ្គលនេះស្មើគ្នា ដោយសីលផង បញ្ញាផង សុតៈផង របស់អញ គប្បីធ្វើនូវមេត្រីជាមួយនឹងជននោះចុះ (ព្រោះ) ការគប់រកដោយសប្បុរស តែងនាំមកនូវសេចក្តីសុខដោយពិត ។

ចប់ ឥន្ទសមានគោត្តជាតក ទី ១ ។

## សន្ថវជាតក

(១៧៣) (តាបសពោធិសត្វ ពោលថា) ការស្និទ្ធស្នាលណា ជាមួយនឹងបុរសលាមក របស់អាក្រក់ក្រៃលែងជាងការស្និទ្ធស្នាល (នោះ)មិនមានទេ ដូចជាភ្លើងដែលយើងឲ្យឆ្អែតដោយសប្បិនិងបាយាសនៅតែដុតខ្ទមស្លឹកដែលយើងធ្វើហើយដោយលំបាក ។

(១៧៤) ន សន្ថវស្មា បរមត្ថិ សេយ្យោ
យោ សន្ថវោ សប្បុរិសេន ហោតិ
សីហស្ស ព្យគ្ឃស្ស ច ទីបិនោ ច
សាមា មុខំ លេហតិ សន្ថវេនាតិ ។

សន្ថវជាតកំ ទុតិយំ ។

## សុសីមជាតកំ

(១៧៥) កាឡា មិគា សេតទន្តា តវីមេ
បរោសតំ ហេមជាលាភិឆន្នា
តេ តេ ទទាមីតិ សុសីម ព្រូសិ
អនុស្សរំ បេត្តិបិតាមហានំ ។

(១៧៦) កាឡា មិគា សេតទន្តា មមីមេ
បរោសតំ ហេមជាលាភិឆន្នា
តេ តេ ទទាមីតិ វទាមិ មាណវ
អនុស្សរំ បេត្តិបិតាមហានន្តិ ។

សុសីមជាតកំ តតិយំ ។



(១៧៤) ការស្និទ្ធស្នាលណា ជាមួយនឹងសប្បុរស របស់ដទៃប្រសើរក្រៃលែងជាងការស្និទ្ធស្នាល (នោះ) មិនមានទេ ដូចជាមេម្រឹគឈ្មោះសាមា លិទ្ធមាត់នៃស្តេចរាជសីហផង ខ្លាធំផង ខ្លាដម្បងផង ព្រោះការស្និទ្ធស្នាល ។

ចប់ សន្ថវជាតក ទី ២ ។

## សុសីមជាតក

(១៧៥) (ពោធិសត្វពោលថា) បពិត្រព្រះរាជា ទ្រង់ព្រះនាមសុសីមៈ ម្រឹគខ្មៅ មានភ្លុកស (ដំរី) នេះរបស់ព្រះអង្គច្រើនជាងរយ បិទបាំងដោយបណ្តាញមាស ព្រះអង្គទ្រង់រឭកនូវព្រះបិតានឹងជីតា (របស់ខ្លួនព្រះអង្គ) ទើបត្រាស់ថា អញនឹងឲ្យដំរីទាំងឡាយនោះដល់ព្រាហ្មណ៍ទាំងនោះមែន ឬ ។

(១៧៦) (ព្រះរាជាត្រាស់ថា) ម្នាលមាណព ម្រឹគខ្មៅមានភ្លុកសនេះរបស់ខ្ញុំច្រើនជាងរយ បិទបាំងដោយបណ្តាញមាស ខ្ញុំកាលរឭកនូវបិតានឹងជីតា ទើបពោលថា ខ្ញុំនឹងឲ្យនូវដំរីទាំងឡាយនោះដល់ព្រាហ្មណ៍ទាំងនោះមែន ។

ចប់ សុសីមជាតក ទី ៣ ។

## គិជ្ឈជាតកំ

(១៧៧) យន្នុ គិជ្ឈោ យោជនសតំ កុណបានិ អវេក្ខតិ
កស្មា ជាលញ្ច បាសញ្ច អាសជ្ជាបិ ន ពុជ្ឈសិ (១) ។
(១៧៨) យទា បរាភវោ ហោតិ បោសោ ជីវិតសង្ខយេ
អថ ជាលញ្ច បាសញ្ច អាសជ្ជាបិ ន ពុជ្ឈតិ ។

គិជ្ឈជាតកំ ចតុត្ថំ ។

## នកុលជាតកំ

(១៧៩) សន្ធឹ កត្វា អមិត្តេន អណ្ឌជេន ជលាពុជ
វិវរិយ ទាឋំ សេសិ កុតោ តេ ភយមាគតំ ។
(១៨០) សង្កេថេវ អមិត្តស្មឹ មិត្តស្មិម្បិ ន វិស្សសេ
អភយា ភយមុប្បន្នំ អបិ មូលានិ កន្តតិ ។

នកុលជាតកំ បញ្ចមំ ។

---

១ ម. ពុជ្ឈតិ ។



## គិជ្ឈជាតក

(១៧៧) (ព្រះរាជាពារាណសី ត្រាស់ថា) ត្មាតរមែងក្រឡេកមើលឃើញសាកសពចម្ងាយ ១០០ យោជន៍បាន ចុះហេតុអ្វី បានជាអ្នកហើរមកដល់បណ្តាញនិងអន្ទាក់ហើយ ក៏នៅតែមិនភ្ញាក់ខ្លួន ។

(១៧៨) (ត្មាតពោធិសត្វ ពោលថា) សេចក្តីវិនាស មានក្នុងវេលាណា សត្វមកដល់បណ្តាញនិងអន្ទាក់ រមែងមិនបានភ្ញាក់ខ្លួនក្នុងការអស់ទៅនៃជីវិត ក្នុងវេលានោះ ។

ចប់ គិជ្ឈជាតក ទី ៤ ។

## នកុលជាតក

(១៧៩) (តាបសពោធិសត្វ ពោលថា) ម្នាលស្កាជាជលាពុជៈ អ្នកធ្វើនូវមិត្តភាព ដោយសត្រូវដែលជាអណ្ឌជៈកំណើតហើយ មកដេកបញ្ចេញចង្កូម តើសេចក្តីភ័យ មានមកដល់អ្នកអំពីទីណា ។

(១៨០) (ស្កា ពោលថា) បុគ្គលគប្បីរង្កៀសក្នុងសត្រូវ មិនគប្បីស្និទ្ធស្នាលសូម្បីក្នុងមិត្រ ភ័យដែលកើតឡើងអំពីជនដែលមិនគួរភ័យ រមែងកាត់នូវឫសគល់ទាំងឡាយបាន ។

ចប់ នកុលជាតក ទី ៥ ។

## ឧបសាឡ្ហជាតកំ

[១៨១] ឧបសាឡ្ហកនាមានំ(១) សហស្សានិ ចតុទ្ទស
អស្មឹ បទេសេ ទឌ្ឍានិ នត្ថិ លោកេ អនាមតំ ។

[១៨២] យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សញ្ញមោ ទមោ
ឯតទរិយា សេវន្តិ ឯតំ លោកេ អនាមតំ ។

ឧបសាឡ្ហកជាតកំ ឆដ្ឋំ ។

## សមិទ្ធិជាតកំ

[១៨៣] អភុត្វា ភិក្ខសិ ភិក្ខុ ន ហិ ភុត្វាន ភិក្ខសិ
ភុត្វាន ភិក្ខុ ភិក្ខស្សុ មា តំ កាលោ ឧបច្ចគា ។

១ ម. ឧបសាឡ្ហកនាមានិ ។



## ឧបសាឡ្ហកជាតក

(១៨១) (តាបសពោធិសត្វ ពោលថា) ពួកញាតិឈ្មោះឧបសាឡ្ហកៈ ចំនួន ១៤០០០ នាក់ គេដុតហើយ ក្នុងប្រទេសនេះ ក្នុងលោក រកទីដែលមិនមានគេស្លាប់មិនមានឡើយ ។

(១៨២) សច្ចៈ ១ ធម្មៈ ១ អហឹសា ១ សញ្ញមៈ ១ ទមៈ ១ មាននៅក្នុងបុគ្គលណា ព្រះអរិយៈទាំងឡាយ រមែងសេពគប់នូវបុគ្គលនុ៎ះ គុណជាតនុ៎ះឈ្មោះថា មិនចេះស្លាប់ ក្នុងលោក ។

ចប់ ឧបសាឡ្ហកជាតក ទី ៦ ។

## សមិទ្ធិជាតក

(១៨៣) (នាងទេពធីតា ពោលប្រាប់ថា) បពិត្រភិក្ខុ លោកមិនទាន់បរិភោគកាមសិន ហើយត្រាច់ទៅ ដើម្បីភិក្ខុភាព បើលោកបរិភោគកាមរួចហើយ សឹមត្រាច់ទៅ ដើម្បីភិក្ខាមិនបានឬ បពិត្រភិក្ខុ សូមលោកបរិភោគកាមសិន ហើយសឹមត្រាច់ទៅ ដើម្បីភិក្ខាចុះ កុំឲ្យកាល(ជាទីបរិភោគកាម)កន្លងនូវលោកបានឡើយ ។

(១៨៤) កាលំ វោហំ ន ជានាមិ ឆន្នោ កាលោ ន ទិស្សតិ

តស្មា អភុត្វា ភិក្ខាមិ មា មំ កាលោ ឧបច្ចគាតិ ។

សមិទ្ធិជាតកំ សត្តមំ ។

## សកុណគ្ឃិជាតកំ

(១៨៥) សេនោ ពលសា បតមានោ លាបំ គោចរដ្ឋាយិនំ

សហសា អជ្ឈបត្តោវ មរណំ តេនុបាគមិ ។

(១៨៦) សោហំ នយេន សម្បន្នោ បេត្តិកេ គោចរេ រតោ

អបេតសត្តុ មោទាមិ សម្បស្សំ អត្ថមត្តនោតិ ។

សកុណគ្ឃិជាតកំ អដ្ឋមំ ។

## អារកជាតកំ

(១៨៧) យោ វេ មេត្តេន ចិត្តេន សព្វលោកានុកម្បតិ

ឧទ្ធំ អធោ ច តិរិយញ្ច អប្បមាណេន សព្វសោ ។



(១៨៤) (តាបសពោធិសត្វ ពោលថា) យើងមិនបានដឹងនូវមរណកាល ដោយពិត មរណកាលក៏បាំងមិនប្រាកដ ព្រោះហេតុនោះ បានជាយើងមិនបរិភោគកាម ហើយត្រាច់ទៅដើម្បីភិក្ខា កុំឲ្យកាល (ធ្វើសមណធម៌) កន្លងនូវយើងបានឡើយ ។

ចប់ សមិទ្ធិជាតក ទី ៧ ។

## សកុណគ្ឃជាតក

(១៨៥) (ព្រះសាស្តាត្រាស់ថា) សត្វខ្លែងបោះពួយចុះមក ដោយកំឡាំង ហើយ ចាប់នូវសត្វក្រួចដែលទំនៅលើ (ក្អេចដំណាះ) ជាទីគោចរ (របស់ខ្លួន) ក៏ដល់នូវសេចក្តីស្លាប់ ដោយហេតុនោះទៅ ។

(១៨៦) (ក្រួច ពោលថា) ខ្ញុំនោះជាអ្នកបរិបូណ៌ដោយឧបាយ ត្រេកអរក្នុងទីគោចរ ជារបស់បិតា ឃើញនូវប្រយោជន៍របស់ខ្លួន ហើយប្រាសចាកសត្រូវ នៅរីករាយ ។

ចប់ សកុណគ្ឃិជាតក ទី ៨ ។

## អារកជាតក

(១៨៧) (អារកសាស្តា ពោលថា) បុគ្គលណាសង្គ្រោះដល់សត្វលោកទាំងមូល ដោយមេត្តាចិត្តក្នុងទិសខាងលើផង ទិសខាងក្រោមផង ទិសទទឹងផង ដោយអាការទាំងពួង គេប្រមាណមិនបាន ។

(១៨៨) អប្បមាណំ ហិតំ ចិត្តំ បរិបុណ្ណំ សុភាវិតំ
យំ បមាណំ កតំ កម្មំ ន តំ តត្រាវសិស្សតីតិ ។

អរកជាតកំ នវមំ ។

## កកណ្ដកជាតកំ

(១៨៩) នាយំ បុរេ ឧន្នមតិ តោរណគ្គេ កកណ្ដកោ
មហោសធ វិជានាហិ កេន ថទ្ធោ កកណ្ដកោ ។

(១៩០) អលទ្ធបុព្វំ លទ្ធាន អឌ្ឍមាសំ កកណ្ដកោ
អតិមញ្ញតិ រាជានំ វេទេហំ មិថិលគ្គហន្តិ ។

កកណ្ដកជាតកំ ទសមំ ។

សន្ថវវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

អថ ឥន្ទសមាន សបណ្ណកុដិ
សុសិមុត្តម គិជ្ឈ វលាតុដកោ
ឧបសាឡ្ហក ភិក្ខុ សលាបវរោ
អថ មេត្តវរោ ទស បុណ្ណមាតិ ។

---



(១៨៨) ចិត្តដែលប្រកបដោយប្រយោជន៍ ដែលប្រមាណមិនបានឈ្មោះថា បុគ្គលបានចំរើនបរិបូណ៌ហើយ អំពើណា ដែលបុគ្គលបានធ្វើល្មមប្រមាណ អំពើនោះ រមែងមិនសល់នៅក្នុងចិត្តរបស់បុគ្គលអ្នកបានចំរើននោះឡើយ ។

ចប់ អរកជាតក ទី ៩ ។

## កកណ្ដកជាតក

(១៨៩) (ព្រះបាទវិទេហៈ ត្រាស់ថា) កាលពីដើមបង្គួយនេះនៅលើក្លោងទ្វារមិនក្រអើតក្រអាងទេ ម្នាលមហោសថ អ្នកចូរដឹងព្រោះហេតុអ្វី បានជាបង្គួយត្រឡប់ទៅជារឹងរូសវិញ ។

(១៩០) (មហោសថពោធិសត្វ ពោលថា) បង្គួយបានរបស់ដែលមិនធ្លាប់បាន ចំនួនកន្លះមាសក រមែងមើលងាយព្រះបាទវិទេហៈ ដែលសោយរាជ្យក្នុងនគរមិថិលា ។

ចប់ កកណ្ដកជាតក ទី ១០ ។

ចប់ សន្ថវវគ្គ ទី ២ ។

## ឧទ្ទាននៃសន្ថវវគ្គនោះគឺ

និយាយអំពីឥន្ទសមានគោត្ត ១ ខ្ទមស្លឹក ១ ព្រះកេសាសុសីមៈ ១ ត្មាត ១ ស្ពាយផលកុដ ១ ឧបសាឡ្ហកព្រាហ្មណ៍ ១ ភិក្ខុ ១ ប្រាបវៀចដ៏ប្រសើរ ១ មេត្តាដ៏ប្រសើរ ១ បង្គួយក្រអើតក្រអាង ១ ត្រូវជា ១០ ។

## កល្យាណធម្មវគ្គោ

## កល្យាណធម្មជាតកំ

(១៨១) កល្យាណធម្មោតិ យទា ជនិន្ទ
លោកេ សមញ្ញំ អនុបាបុណាតិ
តស្មា ន ហិយ្យេថ នរោ សបញ្ញោ
ហិរិយាបិ សន្តោ ធុរមាទិយន្តិ ។

(១៨២) សាយំ សមញ្ញា ឥធ មជ្ជ បត្តា(១)
កល្យាណធម្មោតិ ជនិន្ទ លោកេ
តាហំ សមេក្ខំ ឥធ បព្វជិស្សំ
ន ហិ មត្ថិ ឆន្ទោ ឥធ កាមភោគេតិ ។

កល្យាណជាតកំ បឋមំ ។

## ទទ្ទរជាតកំ

(១៨៣) កោ នុ សទ្ទេន មហតា អភិនាទេតិ ទទ្ទរំ
តំ សីហា នប្បដិនទន្តិ(២) កោ នាមេសោ មិគាធិភូ(៣) ។

---

១ ម. មជ្ឈ បត្តា ។ ២ ម. ន សីហា បដិនទន្តិ ។ ៣ ម. មិគាធិភូ ។

## កល្យាណធម្មវគ្គ

## កល្យាណធម្មជាតក

(១៨១) (សេដ្ឋីពោធិសត្វពោលថា) បពិត្រព្រះអង្គជាធំជាងជន កាលណា នរជនប្រកបដោយបញ្ញា ដល់នូវសមញ្ញា (ឈ្មោះ) ថាជាអ្នកមានកល្យាណធម៌ក្នុងលោក (កាលនោះ) មិនគប្បីឲ្យសាបសូន្យចាកសមញ្ញានោះ សប្បុរសទាំងឡាយ តែងកាន់យកនូវបុព្វធុរៈដោយហិរិនិងឱត្តប្បៈ ។

(១៨២) បពិត្រព្រះអង្គជាធំជាងជន សមញ្ញានោះឯង ថាជាអ្នកមានកល្យាណធម៌ក្នុងលោក មកដល់ខ្ញុំក្នុងថ្ងៃនេះ ហើយខ្ញុំព្រះអង្គពិចារណាឃើញនូវសមញ្ញានោះនឹងបួសក្នុងថ្ងៃនេះ សេចក្ដីពេញចិត្តក្នុងការបរិភោគកាមក្នុងលោកនេះ មិនមានដល់ខ្ញុំទេ ។

ចប់ កល្យាណធម្មជាតក ទី ១ ។

## ទទ្ទរជាតក

(១៨៣) (កូនសីហៈសួរថា) បពិត្រសីហពុក ជាធំជាងម្រឹគ នរណាហ្ន៎ បានសម្លេងខ្លាំង ញុំាងភ្នំទទ្ទរៈឲ្យលាន់ឮ ពួកសីហៈ មិនបន្លឺតបទៅនឹងគេឡើយ សត្វដែលបន្លឺសំឡេងគឹកកងប្រាមនុ៎ះ ជាសត្វឈ្មោះអ្វី ។

(១៨៦) អធមោ មិគជាតានំ សិគាលោ តាត វស្សតិ
ជាតិមស្ស ជិគុច្ឆន្តា តុណ្ហី សីហា សមច្ឆរេតិ ។

ទទ្ទរជាតកំ ទុតិយំ ។

## មក្កដជាតកំ

(១៨៨) តាត មាណវកោ ឯសោ តាលមូលំ អបស្សិតោ
អគារកញ្ចិទំ អត្ថិ ហន្ទ ទេមស្សាគារកំ(១) ។

(១៨៩) មា ខោ តំ(២) តាត បក្កោសិ ទូសេយ្យ នោ អគារកំ
នេតាទិសំ មុខំ ហោតិ ព្រាហ្មណស្ស សុសីលិនោតិ ។

មក្កដជាតកំ តតិយំ ។

## ទុព្ភិយមក្កដជាតកំ

(១៩០) អទម្ហ តេ វារិ បហុត្តរូបំ
ឃម្មាភិតត្តស្ស បិបាសិតស្ស
សោទានិ បិត្វាន គិំគី ករោសិ
អសង្គមោ បាបជនេន សេយ្យោ ។

---

១ ម. ហន្ទ ទេមស្សគារកំ ។ ២ ម. មា ខោ ត្វំ ។



(១៨៦) (សីហៈពោធិសត្វ ពោលថា) ម្នាលកូន ចចក ជាសត្វថោក ទាបជាងប្រភេទម្រឹគទាំងឡាយ កំពុងស្រែក ពួកសីហៈ កាលខ្ពើម រអើមនូវជាតិរបស់វា ក៏បង់នាំគ្នាអង្គុយនៅស្ងៀម ។

ចប់ ទទ្ទរជាតក ទី ២ ។

## មក្កដជាតក

(១៨៨) (តាបសជាកូន ពោលថា) បពិត្របិតា មាណពនុ៎ះ ថ្កោងឈរ ផ្អែកនឹងគល់ត្នោត ខ្ទមរបស់យើងនេះមាន បើដូច្នោះ យើងនឹងប្រគល់ខ្ទមឲ្យទៅមាណពនោះចុះ ។

(១៨៩) (តាបសពោធិសត្វ ពោលថា) ម្នាលកូន អ្នកកុំហៅវាឡើយ ក៏វាគប្បីប្រទូស្តខ្ទមរបស់យើងមិនខាន មុខព្រាហ្មណ៍ដែលមានសីលល្អ មិនមែនបែបយ៉ាងនេះទេ ។

ចប់ មក្កដជាតក ទី ៣ ។

## ទុព្ភិយមក្កដជាតក

(១៩០) (ព្រាហ្មណ៍ពោធិសត្វ ពោលថា) យើងបានឲ្យទឹកច្រើនដល់ឯង ដែលត្រូវកំដៅថ្ងៃបៀតបៀនស្រេកហើយ ឥឡូវនេះ ឯងផឹកហើយធ្វើសម្លេងគំហកថាគិកគិកដូច្នេះ ការសេពគប់ដោយជនអាក្រក់ មិនប្រសើរឡើយ ។

(១៩៨) កោ តេ សុតោ វា ទិដ្ឋោ វា សីលកោ នាម មក្កដោ
ឥទានិ ខោ តំ ឱហច្ឆំ ឯសា អស្មាកធម្មតាតិ ។

ទុព្ភិយមក្កដជាតកំ ចតុត្ថំ ។

## អាទិច្ចុបដ្ឋានជាតកំ

(១៩៩) សព្វេសុ កិរ ភូតេសុ សន្តិ សីលសមាហិតា
បស្ស សាខមិគំ ជម្មំ អាទិច្ចមុបតិដ្ឋតិ ។

(២០០) នាស្ស សីលំ វិជានាថ អនញ្ញាយ បសំសថ
អគ្គិហុត្តញ្ច ឧហន្នំ(១) ទ្វេ ច ភិន្នា កមណ្ឌលូតិ ។

អាទិច្ចុបដ្ឋានជាតកំ បញ្ចមំ ។

## កឡាយមុដ្ឋិជាតកំ

(២០១) ពាលោ វតាយំ ទុមសាខគោចរោ
បញ្ញា ជនិន្ទ នយិមស្ស វិជ្ជតិ
កឡាយមុដ្ឋឹ អវកិរិយ កេវលំ
ឯកំ កឡាយំ បតិតំ គវេសតីតិ ។

១ ម. ឧហន្នំ ។





(១៩៨) (ស្វាទៅទត្ត ពោលថា) អ្នកឯងដែលបានឮ ឬបានឃើញថា ស្វាណាមានសីលធម៌ ក្នុងវេលានេះ យើងនឹងបន្ទោបង់អាចម៍លើក្បាលរបស់អ្នកឯង នេះជាធម្មតា របស់ពួកយើង ។

ចប់ ទុព្ភិយមក្កដជាតក ទី ៤ ។

## អាទិច្ចុបដ្ឋានជាតក

(១៩៩) (ពួកមនុស្ស ពោលថា) បានឮថា បណ្ដាពួកសត្វទាំងអស់ (មានពួកសត្វទូទៅ) ប្រកបដោយសីលធម៌ អ្នកចូរមើលស្វាដ៏លាមកដែលកំពុងឈរនមស្ការព្រះអាទិត្យ ។

(២០០) (តាបសពោធិសត្វ ពោលថា) អ្នកទាំងឡាយមិនបានដឹងច្បាស់នូវមារយាទរបស់ស្វានេះទេ អ្នកទាំងឡាយពោលសរសើរស្វា ព្រោះមិនដឹងស្វានោះ ដុតខ្លោកនបូជាភ្លើងផង ទំលាយខ្ទុក្អមទឹកពីរផង ។

ចប់ អាទិច្ចុបដ្ឋានជាតក ទី ៥ ។

## កឡាយមុដ្ឋិជាតក

(២០១) (អមាត្យពោធិសត្វក្រាបទូលថា) បពិត្រព្រះអង្គជាធំជាងជន ស្វានេះល្ងង់ ប្រាជ្ញារបស់វាមិនមានទេ វាបានបាចសណ្ដែកមួយក្ដាប់ចោលអស់ ហើយទៅស្វែងរកសណ្ដែកមួយគ្រាប់ដែលជ្រុះទៅ ។

(២០៦) ឯវមេវ មយំ រាជ យេ ចញ្ញេ អតិលោភិនោ
អប្បេន ពហុំ ជិយ្យាម កឡាយេនេវ វានរោ ។

កឡាយមុដ្ឋិជាតកំ ឆដ្ឋំ ។

## តិន្ទុកជាតកំ

(២០៧) ធនុហត្ថកលាបេហិ នេត្តឹសវរធារិភិ
សមន្តា បរិកិណ្ណម្ហា កថំ មោក្ខោ ភវិស្សតិ ។
(២០៨) អប្បេវ ពហុកិច្ចានំ អត្ថោ ជាយេថ កោចិ នំ(១)
អត្ថិ រុក្ខស្ស អច្ឆិន្នំ ខជ្ជថញ្ញេវ តិន្ទុកំ ។

តិន្ទុកជាតកំ សត្តមំ ។

## កច្ឆបជាតកំ

(២០៩) ជនិត្តំ មេ ភវិត្តំ មេ ឥតិ បង្កេ អវស្សយឹ
តំ មំ បង្កោ អជ្ឈភវិ យថា ទុព្វលកំ តថា
តំ តំ វទាមិ ភគ្គវ សុណោហិ វចនំ មម ។

១ ម. ពោនំ ។



(២០៦) បពិត្រព្រះរាជា យើងខ្ញុំទាំងឡាយក្តី ជនទាំងឡាយដទៃដែលលោភក្រៃលែងក្តី តប្បីលះបង់របស់ច្រើនព្រោះរបស់តិច ដូចជាស្វាកាលលះបង់សណ្តែកច្រើន ព្រោះសណ្តែកតិចមួយគ្រាប់ឯង ។

ចប់ កឡាយមុដ្ឋិជាតក ទី ៦ ។

## តិន្ទុកជាតក

(២០៧) (ពួកស្វា ពោលថា) យើងត្រូវពួកមនុស្សមានធ្នូនិងបំពង់ព្រួញក្នុងដៃ កាន់ដាវដ៏មុតព័ទ្ធជុំវិញហើយ ធ្វើម្តេចនឹងរួចខ្លួនបាន ។
(២០៨) (ស្វាចៅសេនក ពោលថា) សេចក្តីត្រូវការនីមួយ គប្បីកើតឡើងដល់ពួកមនុស្សដែលមានកិច្ចច្រើនដោយពិត ផ្លែឈើច្រើន យើងរើសប្រមូលមកហើយ អ្នកទាំងឡាយ ចូរនាំគ្នាស៊ីនូវផ្លែទន្លាប់នោះចុះ ។

ចប់ តិន្ទុកជាតក ទី ៧ ។

## កច្ឆបជាតក

(២០៩) (អណ្តើក និយាយថា) ខ្ញុំនៅក្នុងភក់ដោយគិតថា ខ្ញុំកើតហើយ ខ្ញុំចំរើនហើយ (ក្នុងទីនេះ) តែភក់បានគបសង្កត់ខ្ញុំនោះធ្វើឲ្យទុព្វលភាព បពិត្រភគ្គវៈ ខ្ញុំសូមពោលនូវហេតុនោះនឹងអ្នក អ្នកចូរស្តាប់នូវពាក្យខ្ញុំចុះ ។

(៦០៦) គាមេ វា យទិ វា រញ្ញេ សុខំ យត្រាធិគច្ឆតិ
តំ ជនិត្តំ ភវិត្តញ្ច បុរិសស្ស បជានតោ
យម្ហិ ជីវេ តម្ហិ គច្ឆេ ន និកេតហតោ សិយាតិ ។

កច្ឆបជាតកំ អដ្ឋមំ ។

## សតធម្មជាតកំ

(៦០៧) តញ្ច អប្បញ្ច ឧច្ឆិដ្ឋំ តញ្ច កិច្ឆេន នោ អទា
សោហំ ព្រាហ្មណជាតិកោ យំ ភុត្តំ តម្បិ ឧគ្គតំ ។
(៦០៨) ឯវំ ធម្មំ និរង្កត្វា យោ អធម្មេន ជីវតិ
សតធម្មោវ លាភេន លទ្ធេនាបិ ន នន្ទតីតិ ។

សតធម្មជាតកំ នវមំ ។



(៦០៦) បុគ្គលបានសេចក្តីសុខក្នុងទីណា នោះក្នុងស្រុក ឬក្នុងព្រៃ ទីនោះហើយ ជាទីកើតជាទីចំរើន របស់បុរសជាអ្នកដឹង (នូវប្រយោជន៍និងមិនមែនប្រយោជន៍) បុគ្គលគប្បីរស់នៅក្នុងទីណា គប្បីទៅក្នុងទីនោះចុះ កុំគប្បីឲ្យទីដែលធ្លាប់នៅ សម្លាប់ខ្លួនបានឡើយ ។

ចប់ កច្ឆបជាតក ទី ៨ ។

## សតធម្មជាតក

(៦០៧) (មាណពឈ្មោះសតធម្ម ពោលថា) (អាហារណា ដែលបានបរិភោគហើយ) បាយនោះជារបស់តិចផង សល់ដែលផង បុរសចណ្ឌាល បានឲ្យបាយនោះដល់យើងដោយសេចក្តីពិបាក យើងប្រកបដោយជាតិជាព្រាហ្មណ៍ អាហារណាដែលយើងបានបរិភោគហើយ អាហារនោះឯង ក៏ក្អួតចេញមក ។

(៦០៨) (ព្រះសាស្តា ត្រាស់ថា) អ្នកណាលះបង់នូវធម៌ គឺអាជីវបារិសុទ្ធិសីល ហើយចិញ្ចឹមជីវិតដោយអធម៌យ៉ាងនេះ អ្នកនោះមិនត្រេកអរ ដោយលាភដែលខ្លួនបានហើយ ដូចជាសតធម្មមាណព ។

ចប់ សតធម្មជាតក ទី ៩ ។

## ទុទ្ទទជាតកំ

(២០៩) ទុទ្ទទំ ទទមានានំ ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្នយោ ។
(២១០) តស្មា សតញ្ច អសតញ្ច នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ យន្តិ សន្តោ សគ្គបរាយណា ។

ទុទ្ទទជាតកំ ទសមំ ។

កល្យាណធម្មវគ្គោ តតិយោ ។

## តស្សុទ្ទានំ

សុសមញ្ញ មិតាមិត្ត មាណវកោ
ភិតហុតូមាទិច្ចុបដ្ឋាតា
សកាឡាយ សតិន្ទុកា បគ្គំ បុន
សតធម្ម សុទុទ្ទទកេន ទស ។

---



## ទុទ្ទទជាតក

(៦០៩) (តបស្វីពោលថា) ពួកសប្បុរសកាលឲ្យនូវទានដែលគេឲ្យបានដោយកម្រ ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ពួកអសប្បុរសធ្វើតាម (នូវអំពើនោះ) មិនបាន សភាពនៃសប្បុ-រសតាំងនៅឆ្ងាយ គេដឹងបានដោយកម្រ ។

(៦១០) ព្រោះហេតុនោះ ដំណើរអំពីលោកនេះរបស់សប្បុរសនឹងអសប្បុរស រមែងប្លែកផ្សេងៗគ្នា ពួកអសប្បុរស រមែងទៅកាន់នរក ពួកសប្បុរស រមែងទៅកាន់ឋានសួគ៌ ។

ចប់ ទុទ្ទទជាតក ទី ១០ ។

ចប់ កល្យាណធម្មវគ្គ ទី ៣ ។

## ឧទ្ទាននៃកល្យាណធម្មវគ្គនោះ គឺ

និយាយអំពីសមញ្ញាល្អ ១ មិតាមិត្តប្ដូរសីហៈជាធំជាងត្រមឹក ១ មាណព ១ ទឹកច្រើន ១ សំពះព្រះអាទិត្យ ១ សណ្ដែក ១ ផ្លែទន្លាប់ ១ អក ១ មាណពឈ្មោះសតធម្ម ១ ទានដែលឲ្យបានដោយក្រលំបាក ១ ត្រូវជា ១០ ។

---

## អសទិសវគ្គោ

## អសទិសជាតកំ

(២០១) ធនុគ្គហោ អសទិសោ រាជបុត្តោ មហព្ពលោ
ទូរេបាតី អក្ខណវេធី មហាកាយប្បទាលនោ ។
(២០២) សព្ពាមិត្តេ រណំ កត្វា ន ច កញ្ចិ វិហេឋយិ
ភាតរំ សោត្ថឹ កត្វាន សញ្ញមំ អជ្ឈុបាគមីតិ ។

អសទិសជាតកំ បឋមំ ។

## សង្គាមាវចរជាតកំ

(២០៣) សង្គាមាវចរោ សូរោ ពលវា ឥតិ វិស្សុតោ
កិំ នុ តោរណមាសជ្ជ បដិក្កមសិ កុញ្ជរ ។
(២០៤) ឱមទ្ទ ខិប្បំ បលិឃំ ឯសិកានិ ច អព្ពហ(១)
តោរណានិ ច មទ្ទិត្វា ខិប្បំ បវិស កុញ្ជរាតិ ។

សង្គាមាវចរជាតកំ ទុតិយំ ។

(១) ម. ឧព្ពហ ។

## អសទិសវគ្គ

## អសទិសជាតក

(២០១) (ព្រះសាស្តាត្រាស់ថា) ព្រះរាជបុត្រទ្រង់ព្រះនាមអសទិសៈ ជាខ្មាន់ធ្នូមានកំឡាំងច្រើន បាញ់ធ្នូទៅកន្លែងឆ្ងាយ បាញ់ត្រូវ ទំលាយនូវកាយដ៏ធំបាន ។

(២០២) ព្រះរាជកុមារទ្រង់ច្បាំងនឹងសត្រូវទាំងពួងបាន តែមិនបានបៀតបៀននូវជនណាមួយឡើយ ធ្វើព្រះអនុជឲ្យសួស្តី ហើយដល់នូវសេចក្តីសង្រួម គឺចូលទៅកាន់ផ្នួស ។

ចប់ អសទិសជាតក ទី ១ ។

## សង្គាមាវចរជាតក

(២០៣) (ហ្មត់ដំរីពោធិសត្វពោលថា) ម្នាលដំរី អ្នកល្បីថាជាសត្វចូលសង្គ្រាម មានកំឡាំងក្លៀវក្លា ហេតុអ្វី មកដល់ខ្លោងទ្វារហើយ ក៏ថយក្រោយទៅវិញ ។

(២០៤) ម្នាលដំរី អ្នកចូរញាំញីទំលាយនូវសន្ទះទ្វារ ហើយដកគោលសសរទៀនចេញឲ្យឆាប់ ចូរញាំញីនូវខ្លោងទ្វារ ហើយចូលទៅឲ្យឆាប់ ។

ចប់ សង្គាមាវចរជាតក ទី ២ ។

# វាលោទកជាតកំ

(២០៥) វាលោទកំ អប្បរសំ និហីនំ
បិត្វា មទោ ជាយតិ គទ្រភានំ
ឥមញ្ច បិត្វាន រសំ បណីតំ
មទោ ន សញ្ជាយតិ សិន្ធវានំ ។

(២០៦) អប្បម្បិវិត្វាន និហីនជច្ចោ
សោ មជ្ជតី តេន ជនិន្ទ ផុដ្ឋោ(១)
ធោរយ្ហសីលី(២) ច កុលម្ហិ ជាតោ
ន មជ្ជតី អគ្គរសំ បិវិត្វា ។

វាលោទកជាតកំ តតិយំ ។

# គិរិទត្តជាតកំ

(២០៧) ទូសិតោ គិរិទត្តេន ហយោ សាមស្ស បណ្ឌវោ
បោរាណំ បកតឹ ហិត្វា តស្សេវានុវិធិយ្យតិ ។

១ ឱ. ផុដ្ឋោ ។ ២ ឱ. ធោរយ្ហសីលោ ។



# វាលោទកជាតក

(២០៥) (ព្រះរាជាពារាណសី ត្រាស់ថា) សេចក្តីស្រវឹងកើតឡើងដល់ពួកលា ព្រោះផឹកទឹកដែលច្រោះ ដោយសម្បកក្រវៅ មានរសតិច ជារបស់ថោកទាប សេចក្តីស្រវឹងមិនកើតដល់ពួកសេះសិន្ធព ព្រោះផឹកទឹក មានរសដ៏ឧត្តមនេះទេ ។

(២០៦) (អមាត្យពោធិសត្វ ក្រាបទូលថា) បពិត្រព្រះអង្គជាធំជាងជន សត្វដែលមានជាតិថោកទាបផឹកទឹកមានរសតិចហើយ សត្វនោះត្រូវទឹកមានរសតិច ពាល់ត្រូវហើយ ក៏រមែងស្រវឹង ចំណែកសត្វអ្នកនាំធុរៈ ដ៏មានមារយាទ កើតក្នុងត្រកូល(ដ៏ខ្ពស់) បានផឹកទឹកមានរសដ៏ប្រសើរ ក៏រមែងមិនស្រវឹងទេ ។

ចប់ វាលោទកជាតក ទី ៣ ។

# គិរិទត្តជាតក

(២០៧) (អមាត្យពោធិសត្វ ក្រាបទូលថា) សេះឈ្មោះបណ្ឌវៈ របស់ព្រះរាជាទ្រង់ព្រះនាមសាមៈ ដែលគ្រូឈ្មោះគិរិទត្តប្រទូស្តហើយ បានលះប្រក្រតីរបស់ខ្លួនពីដើមចេញ ហើយប្រព្រឹត្តតាមនាយគ្រូនោះ ។

(២១៨) សចេ ច តនុជោ ពោសោ សិង្គាលកាកម្បិតោ(១)
អាចេរ តំ អហោ ត្វាន មឡ្ហាល បរិត្តយេ
ទិព្វមេវ បហាត្វាន នាស្សន្តិ ឧទ្ធិយ្យតីតិ ។

និរុទ្ធជាតកំ ចតុត្ថំ ។

## អនភិរតិជាតកំ

(២១៩) យថោទកេ អាវិលេ អប្បសន្នេ
ន បស្សតិ សិប្បិកសម្ពុកញ្ច
សក្ខរំ វាលុកំ មច្ឆគុម្ពំ
ឯវំ អាវិលម្ហិ ចិត្តេ
ន សោ បស្សតិ អត្តទត្ថំ បរញ្ច ។

(២២០) យថោទកេ អច្ឆេ វិប្បសន្នេ
សោ បស្សតិ សិប្បិកសម្ពុកញ្ច
សក្ខរំ វាលុកំ មច្ឆគុម្ពំ
ឯវំ អនាវិលម្ហិ ចិត្តេ
សោ បស្សតិ អត្តទត្ថំ បរត្ថន្តិ ។

១ ម. សិង្គាលកាកម្បិតោ ។

អនភិរតិជាតកំ បញ្ចមំ ។



(២១៨) បើបុរសមានជាតិជាសេះម្ចាស់សេះនោះ កាត់កាលសក់ទឹង ពុកមាត់ដោយកាំបិតល្អ សម្រាប់សេះនោះត្រឡប់ទៅវិញហើយ ដឹកក្រឡ្ហ៊ីងកន្សែងណាលក្រោល សេះនោះនឹងលះបង់នូវ (ការខ្លួនចេញ) ហើយធ្វើតាមបុរសនោះវិញ ដោយពិត ។

ចប់ និរុទ្ធជាតក ទី ៤ ។

## អនភិរតិជាតក

(២១៩) (កាលនោះវិសាខាមាតុ ពោលថា) កាលបើទឹកល្អក់មិនថ្លា បុគ្គលក៏មិនមើលមិនឃើញខ្យងនិងខ្ចៅ នឹងក្រួស ដីខ្សាច់ ហ្វូងត្រី យ៉ាងណាមិញ កាលបើចិត្តល្អក់ហើយ បុគ្គលនោះក៏មើលមិនឃើញនូវប្រយោជន៍ខ្លួននឹងប្រយោជន៍អ្នកដទៃ យ៉ាងនោះដែរ ។

(២២០) កាលបើទឹកថ្លាស្អាត បុគ្គលក៏មើលឃើញ ខ្យងនិង ខ្ចៅ នឹងក្រួស ខ្សាច់ ហ្វូងត្រីបាន យ៉ាងណាមិញ កាលបើចិត្តមិនល្អក់ហើយ បុគ្គលនោះក៏មើលឃើញ នូវប្រយោជន៍របស់ខ្លួននឹងប្រយោជន៍អ្នកដទៃបាន យ៉ាងនោះដែរ ។

ចប់ អនភិរតិជាតក ទី ៥ ។

## ទធិវាហនជាតកំ

(៦៦១) វណ្ណគន្ធរសូបេតោ អម្ពោយំ អហុវា បុរេ
តមេវ បូជំ លភមានោ កេនម្ពោ កដុកប្ផលោ ។

(៦៦២) បុចិមន្ទបរិវារោ អម្ពោ តេ ទធិវាហន
មូលំ មូលេន សំសដ្ឋំ សាខា សាខំ និសេវរេ(១)
អសាតសន្និវាសេន តេនម្ពោ កដុកប្ផលោតិ ។

ទធិវាហនជាតកំ ឆដ្ឋំ ។

## ចតុមដ្ឋជាតកំ

(៦៦៣) ឧច្ចេ វិដបិមារុយ្ហ មន្តយវ្ហោ រហោ គតា
នីចេ ឱរុយ្ហ មន្តវ្ហោ មិគរាជាបិ សោស្សតិ ។

១ ម. និវិសរេ ។





## ទធិវាហនជាតក

(៦៦១) (ព្រះបាទទធិវាហនៈ ត្រាស់សួរថា) ក្នុងកាលមុន ដើមស្វាយនេះ ប្រកបដោយពណ៌ក្លិននិងរស បានទទួលគ្រឿងសក្ការៈបូជានោះដដែល ហេតុអ្វីស្វាយ ក៏មានផ្លែល្វីងទៅវិញ ។

(៦៦២) (អមាត្យពោធិសត្វ ពោលថា) បពិត្រព្រះរាជាទ្រង់ព្រះនាមទធិ-វាហនៈ ស្វាយរបស់ព្រះអង្គ មានដើមស្ដៅព័ទ្ធជុំវិញ ឫសប្រទាក់គ្នាដោយឫស មែកពាក់ព័ន្ធគ្នានឹងមែក ដោយការនៅជាមួយនឹងដើមស្ដៅមិនមានសេចក្ដីផ្អែម ព្រោះហេតុនោះ បានជាស្វាយត្រឡប់ជាមានផ្លែល្វីងទៅវិញ ។

ចប់ ទធិវាហនជាតក ទី ៦ ។

## ចតុមដ្ឋជាតក

(៦៦៣) (ចចក ពោលថា) អ្នកទាំងពីរឡើងទៅលើប្រគាបឈើដ៏ខ្ពស់ ហើយនិយាយគ្នាក្នុងទីស្ងាត់ អ្នកទាំងពីរ ចូរចុះមកខាងក្រោម និយាយគ្នាវិញ ស្ដេចម្រឹគនឹងស្ដាប់ឮ ។

(២២៤) យំ សុបណ្ណោ សុបណ្ណេន(១) ទេវោ ទេវេន មន្តយេ

កឹ តត្ថ ចតុប្បទស្ស វិលំ បវិស ជម្ពុកាតិ ។

ចតុមដ្ឋជាតកំ សត្តមំ ។

## សីហកោត្ថុកជាតកំ

(២២៥) សីហង្គុលិ សីហនខោ សីហបាទបតិដ្ឋិតោ

សោ សីហោ សីហសង្ឃម្ហិ ឯកោ នទតិ អញ្ញថា ។

(២២៦) មា ត្វំ នទិ រាជបុត្ត អប្បសទ្ទោ វនេ វស

សរេន ខោ តំ(២) ជានេយ្យុំ ន ហិ តេ បេត្តិកោ សរោតិ ។

សីហកោត្ថុកជាតកំ អដ្ឋមំ ។

## សីហចម្មជាតកំ

(២២៧) នេតំ សីហស្ស នទិតំ ន ព្យគ្ឃស្ស ន ទីបិនោ

បារុតោ សីហចម្មេន ជម្មោ នទតិ គទ្រភោ ។

១ ម. សុវណ្ណោ សុវណ្ណេន ។ ២ ម. ញាតិ ។



(២២៤) (ក្អែកទៅតាមពោធិសត្វ ពោលថា) ហង្សនិយាយគ្នានឹងហង្ស ទេវតានិយាយគ្នានឹងទេវតា ប្រយោជន៍អ្វីដល់ចចកជាសត្វទទេ ប្លែកចាកសម្បត្តិ ៤(១) ក្នុងរឿងនោះ ម្នាលសត្វណាមក ឯងចូរទៅកាន់រូងវិញទៅ ។

ចប់ ចតុមដ្ឋជាតក ទី ៧ ។

## សីហកោត្ថុកជាតក

(២២៥) (កូនសីហៈ ពោលថា) សីហៈមួយនោះ មានម្រាមជើងជាសីហៈ មានក្រចកជាសីហៈ ឈរដោយជើងជាសីហៈ តែបន្លឺឡើងប្លែកម្នាក់ឯងក្នុងហ្វូងសីហៈ ។

(២២៦) (សីហពោធិសត្វពោលថា) ម្នាលកូនស្តេចសីហៈ អ្នកកុំបន្លឺឡើយ អ្នកចូរមានសម្លេងតិចនៅក្នុងព្រៃ ហ្វូងសត្វនឹងស្គាល់អ្នកដោយសម្លេង ព្រោះសម្លេងអ្នកមិនមែនកាត់បានមកខាងឪពុកឡើយ ។

ចប់ សីហកោត្ថុកជាតក ទី ៨ ។

## សីហចម្មជាតក

(២២៧) (អ្នកស្រែពោធិសត្វ ពោលថា) នុ៎ះមិនមែនសំរែកសីហៈ មិនមែនសំរែកខ្លាធំ មិនមែនសំរែកខ្លាដំបងទេ លាចំលាមក គេដណ្តប់គ្របដោយស្បែកសីហៈ ស្រែកទេតើ ។

១ ហេតុ ៤ យ៉ាង គឺ សរីរៈ ជាតិ សម្លេង គុណ (អដ្ឋកថា) ។

(២៦៨) ចិរម្បិ ខោ តំ ខាទេយ្យ គទ្រភោ ហរិតំ យវំ

បារុតោ សីហចម្មេន រវមានោ ច ទូសយីតិ ។

សីហចម្មជាតកំ នវមំ ។

# សីលានិសំសជាតកំ

(២៦៩) បស្ស សទ្ធាយ សីលស្ស ចាគស្ស ច អយំ ផលំ

នាគោ នាវាយ(១) វណ្ណេន សទ្ធំ វហតុបាសកំ ។

(២៧០) សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ

សតំ ហិ សន្និវាសេន សោត្ថឹ គច្ឆតិ ន្ហាបិតោតិ ។

សីលានិសំសជាតកំ ទសមំ ។

អសទិសវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

ធនុគ្គហ កុញ្ជរ អប្បរសោ

គិរិទត្ត មហាវិលចិត្តវរំ

ទធិវាហន ចតុមដ្ឋ សីហចរោ

ហរិតយវ នាគវរេន ទស ។

---

១ ម. នាគាយ ។





(២៦៨) (ពាណិជ ពោលថា) លាដណ្តប់ដោយស្បែកសីហៈ ស៊ីស្រូវស្រស់ខ្ចីនោះ អស់កាលជាយូរណាស់ហើយ លាតែស្រែក (ឡើងដឹង) បានជាប្រទូស្តខ្លួន ។

ចប់ សីហចម្មជាតក ទី ៩ ។

# សីលានិសំសជាតក

(២៦៩) (សមុទ្ទទេវតា ពោលថា) អ្នកចូរឃើញផលនៃសទ្ធា សីល ចាគៈ នាគនេះ មានភេទដូចជាសំពៅ នាំឧបាសក មានសទ្ធា ។

(២៧០) បុគ្គលគប្បីសេពគប់ជាមួយនឹងពួកសប្បុរស គប្បីធ្វើនូវសេចក្តីស្និទ្ធស្នាលជាមួយនឹងពួកសប្បុរស ដូចជាងកោរដល់នូវសួស្តី ព្រោះនៅរួមជាមួយនឹងពួកសប្បុរស ។

ចប់ សីលានិសំសជាតក ទី ១០ ។

ចប់ អសទិសវគ្គ ទី ៤ ។

## ឧទ្ទាននៃអសទិសវគ្គនោះ គឺ

និយាយអំពីខ្មាន់ធ្នូ ១ កុញ្ជរ ១ មានរសតិច ១ គិរិទត្តសេះ ឈ្មោះគិរិទត្ត ១ ចិត្តថាជាចិត្តប្រសើរ ១ ព្រះរាជាទធិវាហនៈ ១ ចតុមដ្ឋកៈ ១ សត្វមានក្រចកជាសីហៈ ១ ស្បែកសីហ ១ នាគដ៏ប្រសើរ ១ ត្រូវជា ១០ ។

## រុហកវគ្គោ

### រុហកជាតកំ

(២៣១) អម្ភោ រុហក ឆិន្នាបិ ជិយា សន្ធិយ្យតេ បុន
សន្ធិយស្សុ បុរាណិយា មា កោធស្ស វសំ គមិ ។

(២៣២) វិជ្ជមានេសុ (មុទុ) វាកេសុ វិជ្ជមានេសុ ការិសុ
អញ្ញំ ជិយំ ករិស្សាមិ អលញ្ញេវ បុរាណិយាតិ ។

រុហកជាតកំ បឋមំ ។

### សិរីកាឡកណ្ណិជាតកំ

(២៣៣) ឥត្ថី សិយា រូបវតី សា ច សីលវតី សិយា
បុរិសោ តំ ន ឥច្ឆេយ្យ សទ្ទហាសិ មហោសធ ។

(២៣៤) សទ្ទហាមិ មហារាជ បុរិសោ ទុព្ភគោ សិយា
សិរី ច កាឡកណ្ណី ច ន សមេន្តិ កុទាចនន្តិ ។

សិរីកាឡកណ្ណិជាតកំ ទុតិយំ ។

## រុហកវគ្គ

### រុហកជាតក

(២៣១) (ព្រះរាជាពោធិសត្វ ត្រាស់ថា) ម្នាលរុហកព្រាហ្មណ៍ដ៏ចំរើន ខ្សែប្រត្នាះធ្នូសូម្បីដាច់ហើយ គេតឲ្យជាប់វិញ អ្នកចូរតភ្ជាប់ជាមួយនឹងនាងបុរាណីវិញចុះ កុំលុះក្នុងអំណាចនៃសេចក្ដីក្រោធឡើយ ។

(២៣២) (រុហកបុរោហិត ក្រាបទូលថា) កាលបើសំបកឈើដែល(ទន់)មាន ទាំងជនអ្នកធ្វើក៏មាន ទូលព្រះបង្គំនឹងធ្វើខ្សែប្រត្នាះធ្នូដទៃ មិនគួរឡើយនឹងតភ្ជាប់ជាមួយនឹងនាងបុរាណីទេ ។

ចប់ រុហកជាតក ទី ១ ។

### សិរីកាឡកណ្ណិជាតក

(២៣៣) (ព្រះបាទវិទេហរាជ ត្រាស់ថា) ម្នាលមហោសធ ស្ត្រីដែលមានរូបល្អ តែស្ត្រីនោះមានសីល បុរសមិនគប្បីប្រាថ្នាស្ត្រីនោះ អ្នកជឿឬទេ ។

(២៣៤) (មហោសធ ក្រាបទូលថា) បពិត្រមហារាជ ទូលព្រះបង្គំជឿ បុរសដែលថោកទាប (មិនត្រូវការនឹងស្ត្រីនោះទេ) (ព្រោះ) សិរីនឹងកាឡកណ្ណី រមែងមិនចួបប្រសព្វគ្នាក្នុងកាលណាមួយឡើយ ។

ចប់ សិរីកាឡកណ្ណិជាតក ទី ២ ។

# ចុល្លបទុមជាតកំ

(២៣៥) អយមេវ សា អហមបិ សោ អនញ្ញោ
អយមេវ សោ ហត្ថគ្គហោ អនញ្ញោ
យមាហ កោមារិបតិ មមន្តិ
វជ្ឈិត្ថិយោ នត្ថិ ឥត្ថីសុ សច្ចំ ។

(២៣៦) ឥមញ្ច ជម្មឹ មុសលេន ហន្ត្វា
លុទ្ទំ ឆវំ បរទារូបសេវឹ
ឥមិស្សា ច នំ បាបបតិព្វតាយ
ជីវន្តិយា ឆិន្ទថ កណ្ណនាសន្តិ ។

ចុល្លបទុមជាតកំ អដ្ឋមំ ។



# ចុល្លបទុមជាតក

(២៣៥) (ព្រះពោធិសត្វពោលថា) ស្ត្រីឈ្មោះសីលានោះ គឺមេនេះឯង បទុមកុមារនោះ មិនមែនអ្នកដទៃឡើយ គឺអញនេះឯង (ស្ត្រីនោះ) និយាយចំពោះបុរសណាថា ជាប្តីអំពីក្មេងរបស់អញ បុរសនោះ មានដៃកំបុតមិនមែនអ្នកដទៃឡើយ គឺតាកំបុតនេះឯង ស្ត្រីទាំងឡាយគួរតែសម្លាប់ចោល ព្រោះស្ត្រីទាំងឡាយមិនមានពាក្យសច្ចៈ ។

(២៣៦) អ្នកទាំងឡាយ ចូរសំពន់បុរសលាមកកាក្រក់ ប្រៀបស្មើដោយសាកសព ដែលសេពគប់ប្រពន្ធ នៃបុគ្គលដទៃនេះ ដោយអង្រែផង ហើយកាត់ត្រចៀកនិងច្រមុះ នៃស្ត្រីដែលរស់នៅគោរពប្តីអាក្រក់នេះផង ។

ចប់ ចុល្លបទុមជាតក ទី ៨ ។

## មណិចោរជាតកំ

(៦៣៧) ន សន្តិ ទេវា បវសន្តិ នូន
ន ហិ នូន សន្តិ ឥធ លោកបាលា
សហសា ករោន្តានមសញ្ញតានំ
ន ហិ នូន សន្តិ បដិសេធិតារោ ។

(៦៣៨) អកាលេ វស្សតី តស្ស កាលេ តស្ស ន វស្សតិ
សគ្គា ច ចវតិ ឋានា ននុ សោ តាវតា ហតោ ។

មណិចោរជាតកំ ចតុត្ថំ ។

## បព្វតូបត្ថរជាតកំ

(៦៣៩) បព្វតូបត្ថរេ រម្មេ ជាតា បោក្ខរណី សិវា
តំ សិង្គាលោ អបាបាសិ ជានំ សីហេន រក្ខិតំ ។





## មណិចោរជាតក

(៦៣៧) (នាងសុជាតា ពោលថា) ពួកទេវតា (ជាអ្នករក្សាមើលពួកជនអ្នកមានសីលក្នុងលោកនេះ) មិនមាន រមែងប្រាសចាកឆ្ងាយដោយពិត (ពួកសមណព្រាហ្មណ៍) ដែលគេសន្មតថាជាលោក-បាលក្នុងលោកនេះ ក៏មិនមានដោយពិត ចាំងពួកជនអ្នកហាមឃាត់ នូវជនពាលឡើយអ្នកមិនសង្រួម ធ្វើនូវអំពើសាហស (ការគ្រក់) ក៏មិនមានដោយពិត ។

(៦៣៨) (ព្រះឥន្ទ្រ ពោលថា) ក្នុងដែនរបស់ស្តេចមិនប្រកបដោយធម៌នោះ ភ្លៀងរមែងបង្អុរចុះក្នុងកាលមិនគួរ មិនបង្អុរចុះក្នុងកាលដែលគួរ ឯស្តេចមិនប្រកបដោយធម៌នោះ រមែងច្យុតចាកឋានសួគ៌ ត្រូវគេសម្លាប់ដោយហេតុត្រឹមប៉ុណ្ណោះ ដោយពិត ។

ចប់ មណិចោរជាតក ទី៤ ។

## បព្វតូបត្ថរជាតក

(៦៣៩) (ព្រះបាទព្រហ្មទត្ត ពោលថា) ស្រះបោក្ខរណី ដ៏ត្រជាក់ កើតហើយក្បែរភ្នំ ជាទីរីករាយ ចចកកាលដឹងថា ស្រះបោក្ខ-រណីនោះ សីហៈរក្សាហើយ ក៏នៅតែផឹក (ទឹកក្នុងស្រះនោះ) ។

(៦៦០) បិវន្តិ ចេ មហារាជ សាបទានិ មហានទឹ

ន តេន អនទី ហោតិ ខមស្សុ យទិ តេ បិយាតិ ។

បព្ពតូបត្ថរជាតកំ បញ្ចមំ ។

## វលាហកជាតកំ

(៦៦១) យេ ន កាហន្តិ ឱវាទំ នរា ពុទ្ធេន ទេសិតំ

ព្យសនំ តេ គមិស្សន្តិ រក្ខសីហិវ វាណិជា ។

(៦៦២) យេ ច កាហន្តិ ឱវាទំ នរា ពុទ្ធេន ទេសិតំ

សោត្ថឹ បារំ គមិស្សន្តិ វលាហេនេវ វាណិជាតិ ។

វលាហកជាតកំ ឆដ្ឋំ ។



(៦៦០) (អមាត្យក្រាបទូលថា) បពិត្រមហារាជ (មិនត្រឹមតែ ចបកប៉ុណ្ណោះទេ) ពួកសត្វដែលមានជើង រមែងនាំគ្នាចុះផឹកទឹក ស្ទឹងធំដែរ (តែស្ទឹងធំនោះ) មិនក្លាយទៅជាមិនមែនស្ទឹងដោយ ហេតុនោះក៏ទេ បើ (ស្ត្រីនោះ) ជាទីស្រឡាញ់របស់ព្រះអង្គ ហើយ សូមព្រះអង្គអត់ទោសចុះ ។

ចប់ បព្ពតូបត្ថរជាតក ទី ៥ ។

## វលាហកជាតក

(៦៦១) (ព្រះសាស្តាត្រាស់ថា) ពួកនរជនណា មិនធ្វើតាមឱវាទ ដែលព្រះពុទ្ធសំដែងហើយ ពួកនរជននោះ នឹងដល់នូវសេចក្តី វិនាស ដូចពួកឈ្មួញដែលរាក្សសីទាំងឡាយ (លួងលោម ហើយ) ។

(៦៦២) មួយទៀត ពួកនរជនណា ធ្វើតាមឱវាទដែលព្រះពុទ្ធសំដែង ហើយ ពួកនរជននោះ នឹងដល់នូវត្រើយគឺព្រះនិព្វានដោយ សួស្តី ដូចពួកឈ្មួញ (ធ្វើតាមពាក្យ) ដែលសេះវលាហក (ពោលហើយ) ។

ចប់ វលាហកជាតក ទី ៦ ។

## មិត្តាមិត្តជាតកំ

(៦៦៣) ន នំ ឧម្ហយតេ ទិស្វា ន ច នំ បដិនន្ទតិ
ចក្ខូនិ ចស្ស ន ទទាតិ បដិលោមញ្ច វត្តតិ ។
(៦៦៤) ឯតេ ភវន្តិ អាការា អមិត្តស្មឹ បតិដ្ឋិតា
យេហិ អមិត្តំ ជានេយ្យ ទិស្វា សុត្វា ច បណ្ឌិតោតិ ។

មិត្តាមិត្តជាតកំ សត្តមំ ។

## រាធជាតកំ

(៦៦៥) បវាសា អាគតោ តាត ឥទានិ ន ចិរាគតោ
កច្ចិន្នុ តាត តេ មាតា ន អញ្ញមុបសេវតិ ។
(៦៦៦) ន ខោ បនេតំ សុភណំ គិរំ សច្ចូបសញ្ហិតំ
សយេថ បោដ្ឋបាទោវ មុម្មុរេ[១] ឧបកូសិតោតិ ។

រាធជាតកំ អដ្ឋមំ ។

១ ម. មុម្មុរេ ។



## មិត្តាមិត្តជាតក

(៦៦៣) (ព្រះពោធិសត្វ ពោលថា) បុគ្គលឃើញបុគ្គលនោះហើយ មិនញញឹមផង មិនរីករាយតបនឹងបុគ្គលនោះផង មិនឲ្យភ្នែកចំពោះបុគ្គលនោះ គឺមិនសំឡឹងចំភ្នែកនឹងភ្នែកផង ប្រព្រឹត្តទាស់ស្រឡៅ (ចំពោះបុគ្គលនោះផង) ។

(៦៦៤) បុគ្គលជាបណ្ឌិត ឃើញហើយ ឮហើយ គប្បីស្គាល់នូវបុគ្គលមិនមែនជាមិត្ត ដោយអាការៈទាំងឡាយណា អាការៈទាំងឡាយនុ៎ះ រមែងមានតាំងនៅក្នុងបុគ្គលមិនមែនជាមិត្ត ។

ចប់ មិត្តាមិត្តជាតក ទី ៧ ។

## រាធជាតក

(៦៦៥) (ព្រាហ្មណ៍ ពោលថា) ម្នាលអ្នក អញមកអំពីទីព្រាត់ប្រាសហើយ ទើបនឹងមកដល់ក្នុងកាលអម្បាញ់មិញនេះ ម្នាលអ្នក ចុះមាតារបស់អ្នក មិនចូលទៅសេពនឹងបុរសដទៃខ្លះទេឬ ។

(៦៦៦) (សេកឈ្មោះរាធៈ ពោលថា) បុគ្គលកាលពោលវាចា ដែលប្រកបដោយសច្ចៈនេះ តែមិនល្អ គប្បីដេកដូចជាសេកឈ្មោះបោដ្ឋបាទ ត្រូវនាងព្រាហ្មណីដុត ក្នុងជើងក្រានដូច្នោះ ។

ចប់ រាធជាតក ទី ៨ ។

## គហបតិជាតកំ

(៦៦៧) ឧភយំ មេ ន ខមតិ ឧភយំ មេ ន រុច្ចតិ
យា ចាយំ កោដ្ឋមោតិណ្ណា ន ទស្សំ ឥតិ ភាសតិ ។
(៦៦៨) តំ តំ គាមបតិ ព្រូមិ កទរេ អប្បស្មិ ជីវិតេ
ទ្វេ មាសេ សង្គរំ កត្វា មំសំ ជរគ្គំ កិសំ
អប្បត្តកាលេ ចោទេសិ តម្បិ មយ្ហំ ន រុច្ចតីតិ ។

គហបតិជាតកំ នវមំ ។

## សាធុសីលជាតកំ

(៦៦៩) សរីរទព្យំ វុឌ្ឍព្យំ សោជច្ចំ សាធុសីលិយំ
ព្រាហ្មណន្តេ បុច្ឆាម កន្នុ តេសំ វនិម្ហសេ ។



## គហបតិជាតក

(៦៦៧) (គហបតីភរិយាពោលថា) ហេតុទាំងពីរយ៉ាងមិនគួរដល់យើង ហេតុទាំងពីរយ៉ាង យើងមិនពេញចិត្តទេ ស្រីនេះចុះកាន់ជង្រុកហើយនិយាយថា ខ្ញុំមិនសងឲ្យទេ ។

(៦៦៨) ម្នាលចាស់ស្រុក ព្រោះហេតុនោះ បានជាយើងនិយាយនឹងអ្នក កាលបើជីវិតលំបាក តិច (ប្រព្រឹត្តទៅយ៉ាងនេះ កាលយើងកាន់យក) នូវសាច់អ្នក (បានឲ្យ) នូវគោចាស់ស្គមហើយធ្វើនូវការកំណត់ពីរខែ ឥឡូវនេះ មកទៀតទារក្នុងកាលដែលមិនទាន់ដល់កំណត់ គឺហេតុនោះ យើងមិនពេញចិត្តឡើយ ។

ចប់គហបតិជាតក ទី ៩ ។

## សាធុសីលជាតក

(៦៦៩) (ព្រាហ្មណ៍សួរថា) កាលនៃបុគ្គលមានសរីរៈល្អ កាលនៃបុគ្គលចាស់ កាលនៃបុគ្គលមានជាតិល្អ កាលនៃបុគ្គលមានសីលល្អ យើងសូមសួរអ្នកជាព្រាហ្មណ៍ថា បណ្ដាបុគ្គលទាំង ៤ នាក់នោះ តើយើងត្រូវជ្រើសនូវបុគ្គលណា ។

(៦៨០) អត្ថោ អត្ថិ សរីរស្មឹំ វុឌ្ឍព្យស្ស នមោ ករេ
អត្ថោ អត្ថិ សុជាតស្មឹំ សីលំ អស្មាក រុច្ចតិ ។

សាធុសីលជាតកំ ទសមំ ។

រូហកវគ្គោ ចតុត្ថោ ។

តស្សុទ្ទានំ

អបរិបាក រូបវតី មុសលោ
បរសត្ថុ សបញ្ចម ពោក្ខរណី
អថ មុត្តិមភណិផ ទុព្ហយកេ
ធរាគត កោដ្ឋ សរ៉ ធស ។

---



(៦៨០) (ព្រះពោធិសត្វ ពោលថា) សេចក្តីចំរើនរបស់មានគុណបុគ្គល មានសរីរៈល្អ យើងសូមធ្វើនមស្ការចំពោះបុគ្គលចាស់ សេចក្តីចំរើន របស់មានគុណបុគ្គលដែលមានជាតិល្អ តែសីលរបស់ ពេញចិត្តដល់យើងទាំងឡាយ ។

ចប់ សាធុសីលជាតក ទី ១០ ។

ចប់ រូហកវគ្គ ទី ៤ ។

ឧទ្ទាននៃរូហកវគ្គនោះគឺ

និយាយអំពីរូហកព្រាហ្មណ៍ ១ ស្រីមានរូបល្អ ១ បុរសដែលគេប្រហារដោយអង្រែ ១ ទៅកាត់ព្រៃព្រាស ១ ស្រះបោក្ខ-រណី ១ ជាតរបស់ ៥ គតិនោះមក ពួកឈ្មួញរួចពីការស្ទឹក ១ ញញឹម ១ ការមកអស់កាលដ៏យូរ ១ ជង្រុក ១ សរៈ ១ ត្រៃជា ១០ ជាតក ។

---

## នតំទឡ្ហវគ្គោ

### ពន្ធនាគារជាតកំ

(៤៨១) ន តំ ទឡ្ហំ ពន្ធនមាហុ ធីរា
យទាយសំ ទារុជបព្វជញ្ច
សារត្តរត្តា មណិកុណ្ឌលេសុ
បុត្តេសុ ទារេសុ ច យា អបេក្ខា ។

(៤៨២) ឯតំ ទឡ្ហំ ពន្ធនមាហុ ធីរា
ឱហារិនំ សិថិលំ ទុប្បមុញ្ចំ
ឯតម្បិ ឆេត្វាន បរិព្វជន្តិ
អនបេក្ខិនោ កាមសុខំ បហាយាតិ ។

ពន្ធនាគារជាតកំ បឋមំ ។

### កេឡិសីលជាតកំ

(៤៨៣) ហំសា កោញ្ចា មយូរា ច ហត្ថយោ បសទា មិគា
សព្វេ សីហស្ស ភាយន្តិ នត្ថិ កាយស្មិំ តុល្យតា ។

## នតំទឡ្ហវគ្គ

### ពន្ធនាគារជាតក

(៤៨១) (តាបសពោធិសត្វ ពោលថា) ចំណងណា កើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅជំណោកទន្សាយក្តី ចំណងនោះអ្នកប្រាជ្ញទាំងឡាយមិនហៅថាចំណងមាំឡើយ ជនទាំងឡាយមានសេចក្តីត្រេកអរជាប់ក្រៃលែង ក្នុងកែវមណី និងកុណ្ឌលទាំងឡាយផង សេចក្តីអាឡោះអាល័យ ក្នុងកូននិងប្រពន្ធទាំងឡាយផង ។

(៤៨២) អ្នកប្រាជ្ញទាំងឡាយ ពោលថា ចំណងនុ៎ះមាំ ទាបទាញសត្វចំណាក់ចុះក្នុងអបាយ ជាចំណងធូរ តែបុគ្គលស្រាយបានដោយក្រ ចំពោះតែអ្នកប្រាជ្ញទាំងឡាយ បានកាត់នូវចំណងគឺកិលេសៈនុះ ហើយមិនមានសេចក្តីអាឡោះអាល័យ បានលះបង់នូវសេចក្តីសុខក្នុងកាម ចៀសចេញទៅ ។

ចប់ពន្ធនាគារជាតក ទី ១ ។

### កេឡិសីលជាតក

(៤៨៣) (ព្រះសាស្តា ត្រាស់ថា) ហង្សទាំងឡាយក្តី ក្រៀលទាំងឡាយក្តី ក្ងោកទាំងឡាយក្តី ដំរីទាំងឡាយក្តី ពួកម្រឹគពិសេសក្តី សត្វទាំងអស់នោះតែងខ្លាចសត្វសីហៈ (ព្រោះ) ការប្រៀបផ្ទឹមក្នុងកាយមិនមានឡើយ ។

(២៨៦) យំ វេ មនុស្សេសុ ធនាកេ ចេបំ បញ្ញាក

សោ ហិ តត្ថ មហា ហោតិ នេវ ពាលោ សរីរវា ។

កេឡិសីលជាតកំ ទុតិយំ ។

# ខន្ធបរិត្តជាតកំ

(២៨៧) វិរូបក្ខេហិ មេ មេត្តំ មេត្តំ ឯរាបថេហិ មេ

ឆព្យាបុត្តេហិ មេ មេត្តំ មេត្តំ កណ្ហាគោតមកេហិ ច

អបាទកេហិ មេ មេត្តំ មេត្តំ ទិបាទកេហិ មេ

ចតុប្បទេហិ មេ មេត្តំ មេត្តំ ពហុប្បទេហិ មេ



[២៨៦] បណ្ដាមនុស្សទាំងឡាយ (មនុស្សណា) បើទុកជាខ្លួននៅក្មេង តែមានប្រាជ្ញាកើតឡើង មនុស្សនោះ ទើបឈ្មោះថា ធំក្នុងពួកមនុស្សនោះ មនុស្សល្ងង់ខ្លៅ សូម្បីមានសរីរៈ (ធាត់ធំ) ក៏មិនឈ្មោះថាធំឡើយ ។

ចប់ កេឡិសីលជាតក ទី ២ ។

# ខន្ធបរិត្តជាតក

[២៨៧] (ពាក្យពោធិសត្វ ពោលថា) ការៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្ដេចនាគឈ្មោះវិរូបក្ខៈទាំងឡាយផង ការៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្ដេចនាគឈ្មោះឯរាបថៈទាំងឡាយផង ការៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្ដេចនាគឈ្មោះឆព្យាបុត្តៈទាំងឡាយផង ការៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្ដេចនាគឈ្មោះកណ្ហាគោតមកៈទាំងឡាយផង ការៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វឥតជើងទាំងឡាយផង ការៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងពីរទាំងឡាយផង ការៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើង ៤ ទាំងឡាយផង ការៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងច្រើនទាំងឡាយផង

មា មំ អជគរោ ហឹសិ  មា មំ ហឹសិ វិច្ឆិកោ
មា មំ ចតុប្បទោ ហឹសិ  មា មំ ហឹសិ ពហុប្បទោ
សព្វេ សត្តា សព្វេ បាណា  សព្វេ ភូតា ច កេវលា
សព្វេ ភទ្រានិ បស្សន្តុ  មា កញ្ចិ បាបមាគមា ។

(៦៨៦) អប្បមាណោ ពុទ្ធោ អប្បមាណោ ធម្មោ អប្បមាណោ សង្ឃោ បមាណវន្តានិ សិរឹសបានិ អហិវិច្ឆិកា សតបទី ឧណ្ណានាភី សរពូ មូសិកា កតា មេ រក្ខា កតា មេ បរិត្តា បដិក្កមន្តុ ភូតានិ សោហំ នមោ ភគវតោ នមោ សត្តន្នំ សម្មាសម្ពុទ្ធានំ ។

ខន្ធវត្តជាតកំ តតិយំ ។



សត្វឥតជើងកុំបៀតបៀនអាត្មាអញឡើយ សត្វជើងពីរកុំបៀតបៀនអាត្មាអញឡើយ សត្វជើង ៤ កុំបៀតបៀនអាត្មាអញឡើយ សត្វជើងច្រើនកុំបៀតបៀនអាត្មាអញឡើយ សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូតទាំងឡាយផង ទាំងអស់គ្នា សូមសព្វសត្វ(ទាំងនោះ)ឃើញនូវសេចក្តីចំរើនទាំងឡាយ សេចក្តីលាមកអាក្រក់តិចតួច កុំមកដល់ឡើយ គឺថាកុំកើតមានដល់សត្វទាំងនោះឡើយ ។

(៦៨៦) ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន សត្វលូន ឬសត្វវារទាំងឡាយ គឺពស់ ខ្ទួយ ក្អែប ពីងពាង តុកកែនិង កណ្តុរ សុទ្ធតែមានប្រមាណ (មិនច្រើនដូចគុណព្រះរតនត្រ័យ) កិរិយារក្សា អាត្មាអញបានធ្វើហើយ កិរិយាការពារអាត្មាអញបានធ្វើហើយ ពួកសត្វ (កាច) ទាំងឡាយ ចូរចៀសចេញទៅ អាត្មាអញ(ធ្វើ)នូវនមស្ការ ចំពោះព្រះមានព្រះភាគ នមស្ការចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ ។

ចប់ ខន្ធវត្តជាតក ទី ៣ ។

# វីរកជាតកំ

(៦៥៧) អបិ វីរក បស្សេសិ   សកុណំ មញ្ជុភាណកំ
មយូរគីវសង្កាសំ   បតឹ មយ្ហំ សវិដ្ឋកំ ។
(៦៥៨) ឧទកថលចរស្ស បក្ខិនោ
និច្ចំ អាមកមច្ឆភោជិនោ
តស្សានុករំ សវិដ្ឋកោ
សេវាលេហិ បលិគុណ្ឋិតោ មតោ ។

វីរកជាតកំ ចតុត្ថំ ។

# គង្គេយ្យជាតកំ

(៦៥៩) សោភតិ មច្ឆោ គង្គេយ្យោ   អថោ សោភតិ យាមុនោ
ចតុប្បទាយំ បុរិសោ   និគ្រោធបរិមណ្ឌលោ
ឦសកាយតគីវោ ច   សព្វេវ អតិរោចតិ ។
(៦៦០) យំ បុច្ឆិតោ ន តំ អក្ខា   អញ្ញំ អក្ខាតិ បុច្ឆិតោ
អត្តប្បសំសកោ បោសោ   នាយំ អស្មាក រុច្ចតិ ។

គង្គេយ្យជាតកំ បញ្ចមំ ។



# វីរកជាតក

(៦៥៧) (ប្រពន្ធរបស់ក្អែកគោក សួរថា) នែក្អែកទឹកឈ្មោះវីរកៈ អ្នកឃើញសត្វស្លាប ដែលពោលពាក្យពីរោះ មានកក្ដួកដូចជាក្ដួកនៃក្ងោក ជាក្អែកគោកឈ្មោះសវិដ្ឋកៈ ជាប្តីរបស់ខ្ញុំដែរឬ ។
(៦៥៨) (ក្អែកទឹកពោធិសត្វ ពោលថា) ក្អែកសវិដ្ឋកៈ កាលធ្វើតាមសត្វស្លាប អ្នកត្រាច់ទៅក្នុងទឹកនិងលើគោក បានបរិភោគត្រីស្រស់ជានិច្ចនោះ ត្រូវសារាយព័ន្ធព័ទ្ធស្លាប់ទៅហើយ ។

ចប់ វីរកជាតក ទី ៤ ។

# គង្គេយ្យជាតក

(៦៥៩) (អណ្តើក ពោលថា) ត្រីទាំងឡាយ នៅក្នុងទន្លេគង្គាក៏ល្អ ត្រីទាំងឡាយនៅក្នុងទន្លេយមុនាក៏ល្អ តែបុរសមានជើង ៤ នេះ(១) មានបរិមណ្ឌលដូចដើមជ្រៃផង មានកវែងដូចឆ្នូលនៃរថផង ល្អរុងរឿងលើសអ្នកទាំងឡាយគ្រប់គ្នាទៅទៀត ។
(៦៦០) (ត្រីទាំងឡាយ ពោលថា) យើងសួរហេតុណា មិនប្រាប់ហេតុនោះ យើងសួរហើយត្រឡប់ប្រាប់ហេតុដទៃវិញ សត្វសរសើរតែខ្លួនឯង នេះមិនគាប់ចិត្តយើងទេ ។

ចប់ គង្គេយ្យជាតក ទី ៥ ។

---

១ បុរសមានជើង៤នេះ សំដៅយកអណ្តើកនេះឯង ។ អដ្ឋកថា ។

## កុរុង្គមិគជាតកំ

(៦៦១) ឥង្ឃ វទ្ធមយំ បាសំ ឆិន្ទ ទន្តេហិ កច្ឆប
អហំ តថា ករិស្សាមិ យថា នេហិតិ លុទ្ទកោ ។

(៦៦២) កច្ឆបោ បាវិសី វារឹ កុរុង្គោ បាវិសី វនំ
សតបត្តោ ទុមគ្គម្ហា ទូរេ បុត្តេ អបានយីតិ ។

កុរុង្គមិគជាតកំ ឆដ្ឋំ ។

## អស្សកជាតកំ

(៦៦៣) អយមស្សករាជេន ទេសោ វិចរិតោ មយា
អនុកាមយកាមេន បិយេន បតិនា សហ ។

(៦៦៤) នវេន សុខទុក្ខេន បោរាណំ អបិធិយ្យតិ
តស្មា អស្សករញ្ញាវ កីដោ បិយតរោ មមន្តិ ។

អស្សកជាតកំ សត្តមំ ។



## កុរុង្គមិគជាតក

(៦៦១) (សត្វចចាក ពោលថា) ម្នាលអណ្ដើក សូមអ្នកកាត់ ខ្សែ-
អន្ទាក់ព្រ័ត្រ ដោយធ្មេញចុះ យើងនឹងធ្វើព្រានមិនឲ្យមកបាន ។

(៦៦២) (ព្រះសាស្ដា ត្រាស់ថា) អណ្ដើកចូលទៅកាន់ទឹក សត្វប្រើស
ក៏ចូលទៅព្រៃ ឯសត្វចចាក បាននាំកូនចាកឆ្ងាយ អំពីចុងឈើ
ទៅកាន់ទីឆ្ងាយ ។

ចប់ កុរុង្គមិគជាតក ទី ៦ ។

## អស្សកជាតក

(៦៦៣) (សត្វកំពោងញី ពោលថា កាលពីដើម) ទស្សនប្រទេសនេះ
ខ្ញុំបានត្រាច់ទៅជាមួយនឹងស្ដេចអស្សកៈ ជាប្ដី ជាទីស្រឡាញ់
ដែលខ្ញុំត្រូវការគេ ៗ ត្រូវការខ្ញុំ ។

(៦៦៤) សេចក្ដីសុខនឹងទុក្ខថ្មី រមែងបិទបាំងនូវសុខនឹងទុក្ខចាស់ ព្រោះ
ហេតុនោះ សត្វកំពោងឈ្មោល ជាទីស្រឡាញ់របស់ខ្ញុំជាង
ស្ដេចអស្សកៈទៅទៀត ។

ចប់ អស្សកជាតក ទី ៧ ។

## សុំសុមារជាតកំ

(៤៦៥) អលំ មេតេហិ អម្ពេហិ ជម្ពូហិ បនសេហិ ច
យានិ បារំ សមុទ្ទស្ស វរំ មយ្ហំ ឧទុម្ពរោ ។
(៤៦៦) មហតី វត តេ ពោន្ទិ ន ច បញ្ញា តទូបិកា
សុំសុមារ វញ្ចិតោ មេសិ គច្ឆ ទានិ យថាសុខំ ។

សុំសុមារជាតកំ អដ្ឋមំ ។

## កក្ករជាតកំ(១)

(៤៦៧) ទិដ្ឋា មយា វនេ រុក្ខា អស្សកណ្ណា វិភេទកា
ន តានិ ឯវំ សក្កន្តិ យថា ត្វំ រុក្ខ សក្កសិ ។
(៤៦៨) បុរាណកាកកោ អយំ ភេត្វា(២) បញ្ជរមាគតោ
កុសលោ វាលបាសានំ អបក្កមតិ ភាសតិ ។

កក្ករជាតកំ នវមំ ។

១ ម. កុក្កុដជាតកំ ។ ២ ម. បុរាណកុក្កុដោ អយំ ភិត្វា ។



## សុំសុមារជាតក

(៤៦៥) (ស្វាពោធិសត្វ ពោលថា) ផ្លែឈើទាំងឡាយណា (ដែលអ្នកឃើញហើយ) នាត្រើយសមុទ្រខាងនាយ ផ្លែឈើទាំងនោះ គឺផ្លែស្វាយក្តី ផ្លែព្រីងក្តី ផ្លែខ្នុរក្តី មិនគួរដល់យើងឡើយ ដើមល្វា (ខាងអាយ) ជាឈើដ៏ប្រសើររបស់យើង ។

(៤៦៦) សរីរៈរបស់អ្នក ធំមែន ប៉ុន្តែប្រាជ្ញាសមគួរនឹងសរីរៈនោះមិនមាន នែក្រពើ ឯងត្រូវអញបញ្ឆោតហើយ ឥឡូវចូរឯងទៅតាមស្រួលចុះ ។

ចប់ សុំសុមារជាតក ទី ៨ ។

## កក្ករជាតក

(៤៦៧) (មាន់ព្រៃ ពោលថា) ដើមត្រចៀកសេះ នឹងដើមស្រមំ-ពិភេទទាំងឡាយដុះក្នុងព្រៃ យើងធ្លាប់ឃើញហើយ អ្នកអាចឈានដើរទៅកាន់ដើមឈើបានយ៉ាងណា ឯឈើទាំងនោះមិនអាចឈានដើរទៅបានយ៉ាងនោះទេ ។

(៤៦៨) (ព្រាន ពោលថា) មាន់ព្រៃចាស់នេះ ទំលាយទ្រុងចេញមកហើយ ជាសត្វឈ្លាសក្នុងអន្ទាក់ ដែលធ្វើដោយរោមកន្ទុយ ក៏បានចេញទៅផង និយាយផង ។

ចប់ កក្ករជាតក ទី ៩ ។

## កន្ទគលកជាតកំ

(៤២៩) អម្ភោ កោ នាម យំ រុក្ខោ សិន្នបត្តោ សកណ្ដកោ
យត្ថ ឯកប្បហារេន ឧត្តមង្គំ វិសាដិតំ(១) ។

(៤៣០) អចារិ វតាយំ វិតុទំ វនានិ
កដ្ឋង្គរុក្ខេសុ អសារកេសុ
អថាសទា ខទិរំ ជាតសារំ
យត្ថព្ភិទា គរុឡោ ឧត្តមង្គំ ។

កន្ទគលកជាតកំ ទសមំ ។

នតំទឡ្ហវគ្គោ ឆដ្ឋោ ។

## តស្សុទ្ទានំ

នតំទឡ្ហ ហំសវរោ ច បុន
វិរូបក្ខ សវិដ្ឋក មច្ឆវរោ
សក្កុវត្ត សអស្សក អម្ពវរោ
បុន កុក្កុដកោ គរុឡេន ទស ។

១ ម. វិភិន្នំ ។





## កន្ទគលកជាតក

(៤២៩) (សត្វសាសេះឈ្មោះកន្ទគលកៈ ពោលថា) ម្នាលសាសេះឈ្មោះ ខទិរនិយៈដ៏ចំរើន ដែលបែកក្បាលបែកហើយ ដោយការប្រហារ តែម្តង ព្រឹក្សដើមឈើណា ដើមឈើនេះ មានស្លឹកល្អិតប្រកប ដោយបន្លា តើជាឈើឈ្មោះអ្វី ។

(៤៣០) (ខទិរនិយបក្សី ពោលថា) ឱហ្ន៎ សាសេះនេះ កាលចោះខ្លួឈើ ក្នុងព្រៃទាំងឡាយ បានទៅហើយ ក្នុងកូតឈើមិនមានខ្លឹម ជា ចំណែកនៃឈើស្ងួត ក្នុងកាលជាខាងក្រោយមក សាសេះ (នេះ) បានហើយមកទំលាយបែកក្បាល (របស់ខ្លួន) នឹងដើមសន្ទ្រ ជាឈើ(១)មានខ្លឹមកើតហើយ ។

ចប់ កន្ទគលកជាតក ទី ១០ ។

ចប់ នតំទឡ្ហវគ្គ ទី ៦ ។

## ឧទ្ទាននៃនតំទឡ្ហវគ្គនោះគឺ

និយាយអំពីចំណងទាំ ១ ហង្សប្រសើរ ១ ស្តេចសត្វឈ្មោះ វិរូបក្ខៈ ១ ក្អែកឈ្មោះសវិដ្ឋកៈ ១ ត្រីដ៏ប្រសើរ ១ ព្រែស ១ ស្តេចឈ្មោះអស្សកៈ ១ ផ្លែស្វាយដ៏ប្រសើរ ១ មាន់ ១ សាសេះ ១ ត្រូវជា ១០ ។

១ ន័យដោយច្រើន ឆន្ទ្រោត ជើងគគី ។

## សោមទត្តជាតកំ

[៤៧១] អកាសិ យោគ្គំ ធុវមប្បមត្តោ
សំវច្ឆរំ ពីរណត្ថម្ភកស្មឹ
ព្យាកាសិ អញ្ញំ បរិសំ វិគយ្ហ
ន និយ្យមោ តាយតិ អប្បបញ្ញំ ។

[៤៧២] ទ្វយំ យាចនកោ តាត សោមទត្ត និគច្ឆតិ
អលាភំ ធនលាភំ វា ឯវំធម្មា ហិ យាចនា ។

សោមទត្តជាតកំ ចប់ ។

## ឧច្ឆិដ្ឋភត្តជាតកំ

[៤៧៣] អញ្ញោ ឧបរិមោ វណ្ណោ អញ្ញោ វណ្ណោ ច ហេដ្ឋិមោ
ព្រាហ្មណិ ត្វេវ បុច្ឆាមិ កឹ ហេដ្ឋា កិញ្ចុបរិ ។



## សោមទត្តជាតក

[៤៧១] (ពោធិសត្វ ពោលថា បពិត្រលោកសាពុក) លោកមិនមានសេចក្ដីធ្វេសប្រហែសជានិច្ច បានធ្វើសេចក្ដីព្យាយាម ក្នុងព្រៃស្មាន ដំរីផែតសាដោយគុម្ពស្បូវកណ្ដាស អស់ ១ ឆ្នាំ (កាលបើដូច្នេះ) លោកចូលទៅកាន់បរិស័ទ ហើយធ្វើ (ឲ្យហេតុនោះ) ឲ្យទៅជាហេតុដទៃវិញ សេចក្ដីព្យាយាម រមែងមិនរក្សានូវបុគ្គលដែលឥតប្រាជ្ញាឡើយ ។

[៤៧២] (ព្រាហ្មណ៍ ពោលថា) ម្នាលសោមទត្តជាកូន ធម្មតាជនអ្នកសូមគេ រមែងដល់នូវហេតុពីរយ៉ាង គឺមិនបាននូវទ្រព្យ ១ បាននូវទ្រព្យ ១ ព្រោះថា ការសូមគេ រមែងមានសភាពយ៉ាងនេះជាធម្មតា ។

ចប់ សោមទត្តជាតកទី ១ ។

## ឧច្ឆិដ្ឋភត្តជាតក

[៤៧៣] (ព្រាហ្មណ៍ ពោលថា) ពណ៌បាយខាងលើដទៃ ពណ៌បាយខាងក្រោមដទៃ ម្នាលនាងព្រាហ្មណី អញសួរចំពោះនាងថា បាយខាងក្រោមកើតដូចម្ដេច បាយខាងលើកើតដូចម្ដេច ។

(២៧៦) អហំ នដោស្មិ ភទ្ទន្តេ ភិក្ខកោស្មិ ឥធាគតោ
អយំ ហិ កោដ្ឋមោតិណ្ណោ អយំ សោ យំ គវេសសីតិ ។

ឧច្ឆិដ្ឋភត្តជាតកំ ទុតិយំ ។

## ភរុរាជជាតកំ[១]

(២៧៧) ឥសីនមន្តរំ កត្វា ភរុរាជាតិ មេ សុតំ
ឧច្ឆិន្នោ សហ រដ្ឋេហិ ស រាជា វិភវំ គតោ ។

(២៧៨) តស្មា ហិ ឆន្ទាគមនំ នប្បសំសន្តិ បណ្ឌិតា
អទុដ្ឋចិត្តោ ភាសេយ្យ គិរំ សច្ចូបសញ្ហិតំ ។

ភរុរាជជាតកំ តតិយំ ។

១ ម. ភរុជាតកំ ។



(២៧៦) (ក្លួនអ្នករបាំពោលតប ពោលថា) ម្នាលអ្នកដ៏ចំរើន ខ្ញុំអ្នករបាំ ជាអ្នកសូម មកដល់ក្នុងទីនេះ ឯសហាយរបស់នាងព្រាហ្មណី នេះ ចុះទៅហើយកាន់ជង្រុក អ្នកស្វែងរកនូវបុរសណា បុរស នោះ នេះឯង ។

ចប់ ឧច្ឆិដ្ឋភត្តជាតក ទី ២ ។

## ភរុរាជជាតក

(២៧៧) (ព្រះសាស្តា ត្រាស់ថា) តថាគតបានឮដូច្នេះថា ស្តេចនៅក្នុង ដែនភរុ បានធ្វើនូវទោសដល់ពួកឥសី ស្តេចនោះ (ដល់នូវ ឆន្ទាគតិ) ក៏ដាច់សូន្យព្រមទាំងដែន ដល់នូវសេចក្តីវិនាស ។

(២៧៨) ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ តែងមិនសរសើរនូវការ លុះក្នុងឆន្ទាគតិ (បុគ្គល) មានចិត្តគឺកិលេសមិនប្រទូស្តហើយ គប្បីពោលនូវពាក្យដែលប្រកបដោយសច្ចៈ ។

ចប់ ភរុរាជជាតក ទី ៣ ។

## បុណ្ណនទីជាតកំ

(៦៧៧) បុណ្ណំ នទឹ យេន ច បេយ្យមាហុ
ជាតំ យវំ យេន ច គុយ្ហមាហុ
ទូរំ គតំ យេន ច អវ្ហយន្តិ
សោ ត្យាគតោ ហន្ទ ច ភុញ្ជ ព្រាហ្មណ ។
(៦៧៨) យតោ មំ សរតី រាជា វាយសម្បិ បហេតវេ
ហំសា កោញ្ចា មយូរា ច អសតិយេវ បាបិយា ។

បុណ្ណនទីជាតកំ ចតុត្ថំ ។

## កច្ឆបជាតកំ

(៦៧៩) អវធិ វត អត្តានំ កច្ឆបោ ព្យាហរំ(១)
សុគ្គហិតស្មឹ កដ្ឋស្មឹ វាចាយ សកិយា វធិ ។

១ ម. កច្ឆបោ សោ ព្យាហរំ ។



## បុណ្ណនទីជាតក

(៦៧៧) (ព្រះរាជាទ្រង់លិខិតកុងព្រះរាជសាសន៍ថា) ជនទាំងឡាយពោលនូវស្ទឹង ដែលល្មមសត្វណាផឹកបាន ថាជាស្ទឹងពេញ ហើយផង ជនទាំងឡាយពោលនូវស្រូវ ដែលល្មមសត្វណាពួនបាន ថាជាស្រូវកើតហើយផង ជនទាំងឡាយហៅនូវបុគ្គលដែលទៅហើយកាន់ទីឆ្ងាយដោយសត្វណាផង សត្វនោះ យើងនាំមកហើយដើម្បីអ្នក ម្នាលព្រាហ្មណ៍ ចូរអ្នកបរិភោគ (នូវសាច់ក្អែកនេះ) ចុះ ។

(៦៧៨) (ពោធិសត្វ ពោលថា) កាលណាស្ដេចរឭកអញ សូម្បីតែសាច់ក្អែកក៏ផ្ញើមក (កាលស្ដេចបាន) ហង្សក្ដី ក្រៀលក្ដី ក្ងោកក្ដី (ហេតុអ្វីក៏មិនរឭក) ការមិនរឭកនេះឯង ជាសេចក្ដីលាមកបំផុត (គឺលោភ) ។

ចប់ បុណ្ណនទីជាតក ទី ៤ ។

## កច្ឆបជាតក

(៦៧៩) (ភាគព្រះពោធិសត្វ ពោលថា) អណ្ដើក កាលបើឈើខ្លួនខាំស៊ប់ហើយ បាននិយាយសម្លាប់នូវខ្លួនឯង ឈ្មោះថាសម្លាប់ដោយវាចារបស់ខ្លួន ។

(៤៨០) ឯតម្បិ ទិស្វា នរវីរសេដ្ឋ
វាចំ បមុញ្ចេ កុសលំ នាតិវេលំ
បស្សសិ ពហុភាណេន កច្ឆបំ ព្យសនំ គតន្តិ ។

កច្ឆបជាតកំ បញ្ចមំ ។

## មច្ឆជាតកំ

(៤៨១) ន មាយមគ្គិ តបតិ ន សូលោ សាធុតច្ឆិតោ
យញ្ច មំ មញ្ញតេ មច្ឆី អញ្ញំ សោ រតិយា គតោ ។
(៤៨២) សោ មំ ទហតិ រាគគ្គិ ចិត្តញ្ចូបតបេតិ មំ
ជាលិនោ មុញ្ចថយ្យោ មំ ន កាមេ ហញ្ញតេ ក្វចីតិ ។

មច្ឆជាតកំ ឆដ្ឋំ ។



(៤៨០) បពិត្រព្រះអង្គមានព្យាយាមប្រសើរជាងជន (ឯបណ្ឌិតបុរស) ឃើញនូវហេតុនេះហើយ មិនគប្បីបញ្ចេញវាចាជាកុសល ឲ្យហួសវេលា ព្រះអង្គគង់ទតឃើញអណ្តើក ដែលដល់នូវសេចក្តីវិនាសព្រោះតែនិយាយច្រើន ។

ចប់ កច្ឆបជាតក ទី ៥ ។

## មច្ឆជាតក

(៤៨១) (ត្រីឈ្មោល ពោលថា) ភ្លើងនេះអញមិនក្តៅ ឈើស្រួច ដែលគេចិតសំរួចល្អហើយក៏អញមិនឈឺ អញឈឺតែត្រីមេត្រី សំគាល់អញ ថាទៅត្រេកអរនឹងមេត្រីដទៃនោះ ។

(៤៨២) ភ្លើងគឺតណ្ហានោះ រោលខ្លួនអញផង ចិត្ត (ដ៏សម្បយុត្តដោយតណ្ហា) ក៏ញាំញីអញឲ្យក្តៅផង បពិត្រព្រានសំណាញ់ទាំងឡាយ សូមអ្នកទាំងឡាយលែងខ្ញុំទៅ (សត្វដែលជិតនៅ) ក្នុងកាម អ្នកទាំងឡាយកុំបៀតបៀនក្នុងហេតុនីមួយ ។

ចប់ មច្ឆជាតក ទី ៦ ។

## សេគ្គុជាតកំ

(៤៨៣) សព្វោ លោកោ អត្តមនោ អហោសិ
អកោវិទា កាមធម្មស្ស សេគ្គុ
កោមារិកោ នាម តវជ្ជ ធម្មោ
យំ ត្វំ គហិតា បវនេ បរោទសិ ។

(៤៨៤) យោ ទុក្ខផុដ្ឋាយ ភវេយ្យ តាណំ
សោ មេ បិតា ទុព្ភិ វនេ ករោតិ
សា កស្ស កន្ទាមិ វនស្ស មជ្ឈេ
យោ តាយិតា សោ សហសា ករោតីតិ ។

សេគ្គុជាតកំ សត្តមំ ។

## កូដវាណិជជាតកំ

(៤៨៥) សឋស្ស សាឋេយ្យមិទំ សុចិន្តិតំ
បច្ចោឌ្ឌិតំ បដិកូដស្ស កូដំ
ផាលំ ចេ ខាទេយ្យុំ មូសិកា
កស្មា កុមារំ កុលលា នោ ហរេយ្យុំ ។



## សេគ្គុជាតក

(៤៨៣) (បិតា ពោលថា) សត្វលោកទាំងអស់ ជាអ្នកមានចិត្តរីករាយ (ដោយការសេពកាម) នាងសេគ្គុ ជាស្រីមិនឈ្លាសក្នុងធម៌របស់អ្នកស្រុក នាងដែលយើងចាប់ហើយយំក្នុងព្រៃ ដោយធម្មតាណា ធម្មតានោះរបស់នាង ឈ្មោះថា នៅក្មេងទេឬ ។

(៤៨៤) (នាងសេគ្គុធីតា ពោលថា) ជនណាគប្បីជាទីពឹងរបស់ខ្ញុំ ដែលទុក្ខពាល់ត្រូវហើយ ជននោះជាបិតារបស់ខ្ញុំបានប្រទូស្តក្នុងព្រៃ ខ្ញុំនោះកន្ទក់កន្ទេញចំពោះអ្នកណា ក្នុងកណ្តាលព្រៃ បិតាណា ជាអ្នកការពារ បិតានោះធ្វើនូវកម្មដ៏សហស ។

ចប់ សេគ្គុជាតក ទី ៧ ។

## កូដវាណិជជាតក

(៤៨៥) (វិនិច្ឆយាមាត្យពោធិសត្វ ពោលថា) កលបញ្ឆោតតបចំពោះបុគ្គលអ្នកមានកលបញ្ឆោត អ្នកគិតល្អហើយ ការកោងតបចំពោះបុគ្គលអ្នកកោង អ្នកបានតទល់(ល្អ)ហើយ ជាបើកណ្តុរទាំងឡាយ គប្បីស៊ីនូវផាលដែក ហេតុអ្វីក៏សត្វខ្លែងទាំងឡាយ នាំក្មេងទៅមិនបាន ។

(២៨៦) កូដស្ស ហិ សន្តិ កូដកូដា
ភវតិ(១)ចាបិ និកតិនោ និកត្យា
ទេហិ បុត្តនដ្ឋ ផាលនដ្ឋស្ស ផាលំ
មា តេ បុត្តមហាសិ ផាលនដ្ឋោ ។

កូដវាណិជជាតកំ អដ្ឋមំ ។

## គរហិតជាតកំ

(២៨៧) ហិរញ្ញំ មេ សុវណ្ណំ មេ ឯសា រត្តិំ ទិវា កថា
ទុម្មេធានំ មនុស្សានំ អរិយធម្មំ អបស្សតំ ។

(២៨៨) ទ្វេ ទ្វេ គហបតយោ គេហេ ឯកោ តត្ថ អមស្សុកោ
លម្ពត្ថនោ វេណិកតោ អថោ អង្កិតកណ្ណកោ
កីតោ ធនេន ពហុនា សោ តំ វិតុទតេ ជនន្តិ ។

គរហិតជាតកំ នវមំ ។

១. ម. ភវន្តិ ឥតិបិ ។



(២៨៦) ព្រោះថា បុគ្គលកោងនិងបោកទាំងឡាយ រមែងមានចំពោះបុគ្គលអ្នកកោង បុគ្គលអ្នកបោកប្រាស ដទៃអំពីបុគ្គលអ្នកបោកប្រាស រមែងមាន (ដល់) បុគ្គលអ្នកបោកប្រាស ម្នាលបុរសអ្នកបាត់កូន អ្នកចូរឲ្យនូវផាលដល់បុរសអ្នកបាត់ផាល កុំឲ្យអ្នកបាត់ផាលលួចកូនអ្នកទៅឡើយ ។

ចប់ កូដវាណិជជាតក ទី ៨ ។

## គរហិតជាតក

(២៨៧) (ការពោលសន្ទនា ពោលថា) ពាក្យដែលពោលថា ប្រាក់របស់អញ មាសរបស់អញ អស់យប់នឹងថ្ងៃនេះ ជាកថារបស់មនុស្សទាំងឡាយអ្នកឥតប្រាជ្ញា មិនឃើញអរិយធម៌ ។

(២៨៨) ក្នុងផ្ទះមួយ មានម្ចាស់ផ្ទះពីរនាក់ បណ្ដាម្ចាស់ផ្ទះពីរនាក់នោះ ម្ចាស់ផ្ទះម្នាក់(១)មិនមានពុកមាត់ មានដោះយារធ្លុះ មានផ្នួងសក់បួនហើយ មានត្រចៀកចោះប្រហោងហើយ ដែលគេទិញដោយទ្រព្យដ៏ច្រើន ម្ចាស់ផ្ទះនោះ តែងពោលចាក់ដោតនូវជននោះ ។

ចប់ គរហិតជាតក ទី ៩ ។

១ សំដៅយកមនុស្សស្រី ។ អដ្ឋកថា ។

## ធម្មទ្ធជជាតកំ

(៤៨៩) សុខំ ជីវិតរូបោសិ រដ្ឋា វិវនមាគតោ
សោ ឯកកោ (អរញ្ញស្មឹ) រុក្ខមូលេ កបណោ វិយ
ឈាយសិ ។

(៤៩០) សុខំ ជីវិតរូបោស្មិ រដ្ឋា វិវនមាគតោ
សោ ឯកកោ (អរញ្ញស្មឹ) រុក្ខមូលេ កបណោ វិយ ឈា-
យាមិ សតំ ធម្មំ អនុស្សរន្តិ ។

ធម្មទ្ធជជាតកំ ទសមំ ។

ពីរណត្ថម្ភកវគ្គោ សត្តមោ ។

### តស្សុទ្ទានំ

អថ ពីរណត្ថម្ភ វរេ ច នរោ
កុក្កុដវេឡុម បុណ្ណនទី
ពហុភាណិ អត្ថិ ឧបរេ ទុស្សិកោ
សហ លម្ពត្ថនោ កាបណោ ធស ។



## ធម្មទ្ធជជាតក

(៤៨៩) (សក្កទេវរាជ ពោលថា) អ្នកមានសភាពរស់នៅ ជាសុខ ចេញចាកដែន ហើយមកកាន់ព្រៃស្ងាត់ អ្នកនោះតែម្នាក់ឯង អង្គុយសញ្ជប់សញ្ជឹងនៅ ជិតគល់ឈើ (ក្នុងព្រៃ) ដូចជាមនុស្សកំព្រា ។

(៤៩០) (បុរោហិតពោធិសត្វ ពោលថា) ខ្ញុំមានសភាពរស់នៅ ជាសុខ ចេញចាកដែនហើយមកកាន់ព្រៃស្ងាត់ ខ្ញុំនោះតែម្នាក់ឯង ការរឭកធម៌របស់សប្បុរស អង្គុយសញ្ជប់សញ្ជឹង ជិតគល់ឈើ (ក្នុងព្រៃ) ដូចជាមនុស្សកំព្រា ។

ចប់ ធម្មទ្ធជជាតក ទី ១០ ។

ចប់ ពីរណត្ថម្ភកវគ្គ ទី ៧ ។

### ឧទ្ទាននៃពីរណត្ថម្ភកវគ្គនោះគឺ

និយាយអំពីគុម្ពស្មៅរណ្តាសដ៏ប្រសើរ ១ អ្នករបាំ ១ ស្តេចកុរុ ដ៏ឧត្តមប្រសើរ ១ ស្ទឹងពេញដោយទឹក ១ បុគ្គលនិយាយច្រើន ១ ក្អែក ១ ព្រៃធំ ១ សត្វកណ្តុរ ១ មនុស្សដោរយោរ ១ មនុស្សកំព្រា ១ ត្រូវជា ១០ ។

## កាសាវវគ្គោ

## កាសាវជាតកំ

(២៩១) អនិក្កសាវោ កាសាវំ យោ វត្ថំ បរិទហិស្សតិ

អបេតោ ទមសច្ចេន ន សោ កាសាវមរហតិ ។

(២៩២) យោ ច វន្តកសាវស្ស សីលេសុ សុសមាហិតោ

ឧបេតោ ទមសច្ចេន ស វេ កាសាវមរហតីតិ ។

កាសាវជាតកំ បឋមំ ។

## ចុល្លនន្ទិយជាតកំ

(២៩៣) ឥទំ តទាចរិយវចោ បារាសរិយោ យទព្រវិ (១)

មា សុ ត្វំ អករិ បាបំ យំ ត្វំ បច្ឆា កតំ តបេ ។

១ ម. បោរាណាចរិយោ ព្រវិ ។

## កាសាវវគ្គ

## កាសាវជាតក

(២៩១) (ដំរីពាលិសត្វ ពោលថា) បុគ្គលណា មានចិត្តជក់ពីកិលេស មិនទាន់លះចេញហើយ ជាអ្នកប្រាសចាកទមៈ (ការទូន្មានខ្លួនឥន្ទ្រិយ) និងសច្ចៈ នឹងស្លៀកដណ្តប់នូវសំពត់ ដែលជ្រលក់ដោយទឹកចត់ បុគ្គលនោះ មិនគួរនឹងស្លៀកដណ្តប់នូវសំពត់ជ្រលក់ ដោយទឹកចត់ឡើយ ។

(២៩២) ចំណែកខាងបុគ្គលណា មានចិត្តជក់ពីកិលេសខ្ជាក់ចោលហើយ មានចិត្តតាំងមាំល្អ ក្នុងសីលទាំងឡាយ ជាអ្នកប្រកបដោយទមៈ និងសច្ចៈ បុគ្គលនោះឯង ទើបគួរនឹងស្លៀកដណ្តប់នូវសំពត់ជ្រលក់ ដោយទឹកចត់បាន ។

ចប់ កាសាវជាតក ទី ១ ។

## ចុល្លនន្ទិយជាតក

(២៩៣) (នាយព្រាន ពោលថា) បារាសរិយព្រាហ្មណ៍ បានពោលនូវពាក្យណាថា បាបកម្មណា ដែលធ្វើហើយ ញ៉ាំងអ្នកឲ្យក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ អ្នកកុំធ្វើបាបកម្មនោះឡើយ នេះជាពាក្យ របស់អាចារ្យ ។

(២៩៦) យានិ ករោតិ បុរិសោ តានិ អត្តនិ បស្សតិ
កល្យាណការី កល្យាណំ បាបការី ច បាបកំ
យាទិសំ វបតេ ពីជំ តាទិសំ ហរតេ ផលន្តិ ។

ចុល្លនន្ទិយជាតកំ ទុតិយំ ។

## បុដភត្តជាតកំ

(២៩៧) នមេ នមន្តស្ស ភជេ ភជន្តំ
កិច្ចានុកុព្វស្ស ករេយ្យ កិច្ចំ
នានត្ថកាមស្ស ករេយ្យ អត្ថំ
អសម្ភជន្តម្បិ ន សម្ភជេយ្យ ។

(២៩៨) ចជេ ចជន្តំ វនថំ ន កយិរា
អបេតចិត្តេន ន សម្ភជេយ្យ
ទិជោ ទុមំ ខីណផលន្តិ ញត្វា
អញ្ញំ សមេក្ខេយ្យ មហា ហិ លោកោតិ ។

បុដភត្តជាតកំ តតិយំ ។



(២៩៦) បុរសធ្វើនូវអំពើទាំងឡាយណា រមែងឃើញនូវអំពើទាំងឡាយនោះ ចំពោះខ្លួន បុរសអ្នកធ្វើអំពើល្អ រមែងទទួលផលល្អ ចំណែកខាងបុរសអ្នកធ្វើអំពើអាក្រក់ រមែងទទួលផលអាក្រក់ បុគ្គលសាបព្រោះនូវពូជបែបណា រមែងបាននូវផ្លែបែបនោះ ។

ចប់ ចុល្លនន្ទិយជាតក ទី ២ ។

## បុដភត្តជាតក

(២៩៧) (ភរិយាក្សត្រពោធិសត្វ ពោលថា) បុគ្គលគប្បីឱនលំទោនតប ចំពោះបុគ្គលអ្នកឱនលំទោនខ្លួន គប្បីគប់រកនូវបុគ្គលអ្នកគប់រកខ្លួន គប្បីធ្វើកិច្ច តបចំពោះបុគ្គលអ្នកធ្វើនូវកិច្ចដល់ខ្លួន គួរគប្បីធ្វើប្រយោជន៍ដល់បុគ្គលអ្នកប្រាថ្នា នូវសេចក្តីវិនាសដល់ខ្លួន មិនគប្បីគប់រកនូវបុគ្គលអ្នកមិនគប់រកខ្លួន ។

(២៩៨) បុគ្គលគប្បីលះនូវបុគ្គលអ្នកលះបង់នូវខ្លួន មិនគប្បីធ្វើនូវឈើដែលតាំងនៅក្នុងព្រៃគឺសេចក្តីប៉ុនប៉ងក្នុងបុគ្គលនោះ មិនគប្បីសមាគមជាមួយនឹងបុគ្គលដែលមានចិត្តវៀរលាស សត្វស្លាបដឹងនូវឈើដែលមានផ្លែអស់ហើយ រមែងសំឡឹងរកនូវដើមឈើឯទៀតដែលមានផ្លែយ៉ាងណា (បុគ្គលគប្បីរកបុគ្គលដទៃយ៉ាងនោះដែរ) ព្រោះថា លោកសន្និវាសនៅធំទូលាយណាស់ ។

ចប់ បុដភត្តជាតក ទី ៣ ។

## កុម្ភិលជាតកំ

(៦៩៧) យស្សេតេ ចតុរោ ធម្មា គុណា បរមភទ្ទកា (១)
សច្ចំ ធម្មោ ធិតិ ចាគោ ទិដ្ឋំ សោ អតិវត្តតិ ។
(៦៩៨) យស្ស ចេតេ ន វិជ្ជន្តិ គុណា បរមភទ្ទកា
សច្ចំ ធម្មោ ធិតិ ចាគោ ទិដ្ឋំ សោ នាតិវត្តតីតិ ។

កុម្ភិលជាតកំ ចតុត្ថំ ។

## ខន្តិវណ្ណនជាតកំ

(៦៩៩) អត្ថិ មេ បុរិសោ ទេវ សព្វកិច្ចេសុ ព្យាវដោ
តស្ស ចេកោបរជ្ឈតិ តត្ថ ត្វំ កិន្តិ មញ្ញសិ
(៧០០) អម្ហាកំ អត្ថិ (២) បុរិសោ ឯទិសោ ឥធ វិជ្ជតិ
ទុល្លភោ អង្គសម្បន្នោ ខន្តិ អស្មាក រុច្ចតីតិ ។

ខន្តិវណ្ណនជាតកំ បញ្ចមំ ។

---

១ ម. វានរិន្ទ យថា តវ ។ ២ ម. អម្ហាកំ បតិ ។





## កុម្ភិលជាតក

(៦៩៧) (ក្រពើ បាននិយាយថា) បុគ្គលណាមានធម៌ ៤ យ៉ាង គឺ សច្ចៈ ១ សុចរិតធម៌ ១ សេចក្តីព្យាយាម ១ ចាគៈ ១ ជាគុណដ៏ចំរើនក្រៃលែង បុគ្គលនោះ រមែងកន្លងនូវសត្រូវបាន ។

(៦៩៨) ចំណែកបុគ្គលណា មិនមានធម៌ ៤ យ៉ាងនេះ គឺសច្ចៈ ១ សុចរិតធម៌ ១ សេចក្តីព្យាយាម ១ ចាគៈ ១ ជាគុណដ៏ចំរើនក្រៃលែង បុគ្គលនោះ រមែងមិនកន្លងនូវសត្រូវបានទេ ។

ចប់ កុម្ភិលជាតក ទី ៤ ។

## ខន្តិវណ្ណនជាតក

(៦៩៩) (អាមាត្យ បានក្រាបទូលថា) បពិត្រព្រះសម្មតិទេព មានបុរសរបស់ទូលព្រះបង្គំម្នាក់ ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចការទាំងពួង តែបុរសនោះមានកំហុសមួយ ព្រះអង្គទ្រង់សំគាល់ក្នុងកំហុសរបស់បុរសនោះថា គួរធ្វើដូចម្តេច ។

(៧០០) (ព្រះរាជាត្រាស់តប មានព្រះបន្ទូលថា) បុរស (ជាអ្នកប្រទូស្ត) ក្នុងផ្ទះរបស់យើងមានដែរ ឯបុរសបែបនេះ (ឥឡូវនេះ) មានក្នុងទីនេះ តែបុរសអ្នកប្រកបដោយចំណែកនៃគុណ រកបានដោយក្រ បានជាយើងចូលចិត្តតែខន្តី ។

ចប់ ខន្តិវណ្ណនជាតក ទី ៥ ។

# កោសិយជាតកំ

(៣០១) កាលេ និក្ខមនា សាធុ នាកាលេ សាធុ និក្ខមោ

អកាលេន ហិ និក្ខម្ម ឯកកម្បិ ពហុជ្ជនោ

ន កិញ្ចិ អត្ថំ ជោតេតិ ធង្កសេនាវ កោសិយំ ។

(៣០២) ធីរោ ច វិធិវិធានញ្ញូ បរេសំ វិវរានុគូ

សព្វាមិត្តេ វសីកត្វា កោសិយោវ សុខី សិយាតិ ។

កោសិយជាតកំ ឆដ្ឋំ ។



# កោសិយជាតក

(៣០១) (ពាក្យតាបសពោលថា) ការចេញទៅក្នុងកាលគួរ ជាការប្រពៃ ការចេញទៅក្នុងកាលមិនគួរ មិនជាការប្រពៃទេ ព្រោះថា (ជនណាមួយ) ចេញទៅក្នុងកាលមិនគួរ រមែងមិនញុំាងប្រយោជន៍តិចតួចឲ្យកើតបាន ទុកជាសត្រូវដ៏ច្រើន នឹងដោយចាប់នូវបុរសតែម្នាក់ឯង (ដែលចេញទៅក្នុងកាលមិនគួរ ហើយឲ្យដល់នូវសេចក្តីវិនាសដ៏ធំ) ដូចសេនាក្អែក (ដោយចឹក) នូវសត្វមៀម (ដែលចេញទៅក្នុងកាលមិនគួរ) ។

(៣០២) អ្នកប្រាជ្ញដឹងនូវរបៀបនៃការចាត់ចែង ដឹងនូវទោសរបស់ជនទាំងឡាយដទៃ បានធ្វើនូវមិត្រទាំងពួងឲ្យលុះក្នុងអំណាចរបស់ខ្លួន គប្បីបាននូវសេចក្តីសុខដូចសត្វមៀម (មានប្រាជ្ញាចឹកក្បាលក្អែកឲ្យដាច់ស្លាប់) បានសេចក្តីសុខដូច្នោះ ។

ចប់ កោសិយជាតក ទី ៦ ។

## គូថបាណកជាតកំ

(៣០៣) សូរោ សូរេន សង្គម្ម វិក្កន្តេន បហារិនា
ឯហិ នាគ និវត្តស្សុ កិន្នុ ភីតោ បលាយសិ
បស្សន្តុ អង្គមគធា មម តុយ្ហញ្ច វិក្កមំ ។

(៣០៤) ន តំ បាទា វធិស្សាមិ ន ទន្តេហិ ន សោណ្ឌិយា
មីឡ្ហេន តំ វធិស្សាមិ បូតិ ហញ្ញតុ បូតិនា ។

គូថបាណកជាតកំ សត្តមំ ។

## កាមនីតជាតកំ

(៣០៥) តយោ គិរី អន្តរំ កាមយាមិ
បញ្ចាលេ កុរុយោ កេកកេ ច
តតុត្តរឹ ព្រាហ្មណ កាមយាមិ
តិកិច្ឆ មំ ព្រាហ្ម កាមនីតំ ។



## គូថបាណកជាតក

(៣០៣) (សត្វក្អែកពោលថា) អ្នកជាសត្វក្លៀវក្លា មកជួបប្រទះនឹងយើងជាអ្នកក្លៀវក្លា មានសេចក្តីប្រឹងប្រែង តបប្រហារគ្នាបាន នែដំរី អ្នកចូរមក អ្នកចូរត្រឡប់មក អ្នកខ្លាចឬ បានជារត់ទៅ អ្នកស្រុកអង្គៈនឹងមគធៈទាំងឡាយ ចូរមើលសេចក្តីព្យាយាម របស់យើងនឹងអ្នក ។

(៣០៤) (ដំរី ពោលថា) យើងនឹងមិនសម្លាប់អ្នក ដោយជើង មិនសម្លាប់ដោយភ្លុក មិនសម្លាប់ ដោយប្រមោយទេ យើងនឹងសម្លាប់អ្នកដោយលាមក សត្វស្អុយ គួរវិនាសដោយរបស់ស្អុយ ។

ចប់ គូថបាណកជាតក ទី ៧ ។

## កាមនីតជាតក

(៣០៥) (ព្រះបាទពារាណសី ត្រាស់ថា) យើងប្រាថ្នានូវដែន ជាចន្លោះនៃភ្នំទាំង ៣ គឺដែនបញ្ចាលៈ ១ កុរុ ១ កេកកៈ ១ ម្នាលព្រាហ្មណ៍ យើងត្រូវការផលសម្បត្តិ ក្នុងក្រុងទាំង ៣ នោះ ក្រៃលែងជាងផលសម្បត្តិ ក្នុងក្រុងពារាណសីនោះទៅទៀត ម្នាលព្រាហ្មណ៍ អ្នកចូរព្យាបាលយើង ដែលកាមនាំទៅហើយ ។

(៣០៦) កណ្ហាហិទដ្ឋស្ស ករោន្តិ ហេកេ
អមនុស្សវិដ្ឋស្ស ករោន្តិ បណ្ឌិតា
ន កាមនីតស្ស ករោតិ កោចិ
ឱក្កន្តសុក្កស្ស ហិ កា តិកិច្ឆា ។

កាមនីតជាតកំ អដ្ឋមំ ។

## បលាយិជាតកំ

(៣០៧) គជគ្គមេឃេភិ ហយគ្គមាលិភិ
រថូមិជាតេភិ សរាភិវស្សិភិ
ថរុគ្គហាវដ្ដទឡ្ហប្បហារិភិ
បរិវារិតា តក្កសិលា សមន្តតោ ។

(៣០៨) អភិធាវថ ចុប្បតថ ច
វិវិធវិនទិតា ទន្តិភិ
វត្តតេវ តុមុលោ ឃោសោ
យថា វិជ្ជុតា ជលធរស្ស គជ្ជតោ ។

បលាយិជាតកំ នវមំ ។



(៣០៦) (សក្កទេវរាជពោធិសត្វ ត្រាស់ថា) ពេទ្យពួកខ្លះ រមែងធ្វើ(នូវការរក្សា) ចំពោះបុគ្គលដែលពស់ចឹកហើយ បណ្ឌិតទាំងឡាយ តែងធ្វើ (នូវការរក្សា) ចំពោះបុគ្គលដែលខ្មោចចូលហើយ បុគ្គលណាមួយ (ក្រៅពីបណ្ឌិត) រមែងមិនធ្វើនូវការរក្សា ចំពោះបុគ្គលដែលកាមនាំទៅហើយ ព្រោះថា ការរក្សាដូចម្តេច ចំពោះបុគ្គលដែលមានធម៌សធ្លាក់ចុះហើយ ។

ចប់ កាមនីតជាតក ទី ៨ ។

## បលាយិជាតក

(៣០៧) (ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់ថា) ក្រុងតក្កសិលា យើងឡោមព័ទ្ធជុំវិញហើយ ដោយពពកគឺពលដំរី ស្រែកសំរាមដ៏ប្រសើរ ដោយកម្រងផ្កាគឺពលសេះដ៏ប្រសើរ ដោយរលកទឹកគឺពលរថ ដោយភ្លៀងគឺកូនសរ ដោយខ្មាន់ធ្នូជាអ្នកលបចាំប្រហារមាំ ។

(៣០៨) អ្នកទាំងឡាយ ចូរស្ទុះទៅផង ចូរលោតផ្លោះទៅផង ចូរស្រែកដោយសម្លេងផ្សេង ៗ (មួយអន្លើ) ដោយពលដំរីទាំងឡាយ សម្លេងគឹកកងដ៏ខ្លាំង (ប្រាកដស្មើដោយសម្លេងនៃខ្ទះ) ចូរប្រព្រឹត្តទៅក្នុងថ្ងៃនេះ ដូចជាផ្គរបន្ទោរ ដែលបញ្ចេញផុតចាកមេឃកាលគ្រហឹមដូច្នោះ ។

ចប់ បលាយិជាតក ទី ៩ ។

## ទុតិយបលាយិជាតកំ

(៣០៩) ធជមបរិមិតំ អនន្តបារំ

ទុប្បសហំ ធង្កេហិ សាគរំវ

គិរិំវ អនិលេន ទុប្បសហោ

ទុប្បសហោ អហមជ្ជ តាទិសេន ។

(៣១០) មា ពាលិយំ វិប្បលបិ នហិស្ស តាទិសំ

វិទយ្ហសេ ន ហិ លភសេ និសេធកំ

អាសជ្ជសិ គជមិវ ឯកចារិនំ

យោ តំ បទា នឡមិវ បោថយិស្សតីតិ ។

ទុតិយបលាយិជាតកំ ទសមំ ។

កាសាវវគ្គោ អដ្ឋមោ ។



## ទុតិយបលាយិជាតក

(៣០៩) *(ព្រះរាជាគន្ធារៈ ទ្រង់ត្រាស់ថា) ទង់សម្រាប់ធ្វើប្រមាណមិនបាន ពលពាហនៈមានត្រើយមិនមានទីបំផុត (រាប់មិនបាន) ពួកសត្រូវគ្រប់សង្កត់បានដោយក្រ ដូចជាសមុទ្រសាគរ ដែលហ្វូងក្អែក (គ្រប់សង្កត់បានដោយក្រ) (ពួកពលរបស់យើងនេះ) ពួកពលដទៃគ្រប់សង្កត់បានដោយក្រ ដូចជាភ្នំដែលខ្យល់គ្រប់សង្កត់បានដោយក្រ ក្នុងថ្ងៃនេះ អាត្មាអញប្រកបដោយពលប្រាកដដូច្នោះ កម្រអ្នកណានឹងគ្រប់សង្កត់បាន ។*

(៣១០) *(ព្រះរាជាពារាណសីពោធិសត្វ ពោលថា) ព្រះអង្គកុំនិយាយនូវអំពើពាលឡើយ ព្រោះបុគ្គលប្រហែលដូចព្រះអង្គមិន (អាចយកជ័យសម្បត្តិបានទេ) ព្រះអង្គក្តៅអន្ទះអន្ទែង (ដោយភ្លើងគឺរាគៈ ទោសៈ មោហៈ នឹងមានរកប៉ុណ្ណោះ) ម្យ៉ាងទៀតព្រះអង្គ ក៏មិនបាននូវបុគ្គលប្រាកដស្មើដោយខ្ញុំ ដែលជាអ្នកកំចាត់បង់ទេ ដំរីណា នឹងគក់បាតនូវព្រះអង្គ ដូចជាជាន់ឈ្លីនូវដើមបបុស ដោយជើង ព្រះអង្គ ដូចជាដំរី (ចុះប្រេង) ចូលទៅរក ត្រាច់ទៅតែម្នាក់ឯងនោះ ។*

ចប់ ទុតិយបលាយិជាតក ទី ១០ ។

ចប់ កាសាវវគ្គ ទី ៨ ។

# កល្យាទ្ធាំ

វេជ វេធា ឧមទីណា ធ ដល់
ចត្តុក្កេចទ្ធាំ បុរិសុត្តម
ជគ្គ មតធា ច តយោ គិរិ ធាម
គជត្តភោ ធជវេធ ធស ។





# ឧទ្ទាននៃកោសិយវគ្គនោះ គឺ

និយាយអំពីសិតក់ដីប្រសើរ ១ ពាក្យរបស់អាចារ្យ ១ ផ្លែឈើអស់ហើយ ១ ធម៌ដ៏ប្រសើរ ៤ យ៉ាង ១ បុរសដ៏ខ្ពង់ខ្ពស់ ១ សត្វក្អែក ១ ក្អួកដងកន់ដែលមានបះ ១ ដែន ៣ កន្លែង ១ ដីដ៏ប្រសើរស្រែកសំពារ ១ នេះដ៏ប្រសើរ ១ ត្រូវជា ១០ ។

## ឧបាហនវគ្គោ

### ឧបាហនជាតកំ

(៣១១) យថាបិ កីតា បុរិសស្សុបាហនា
សុខស្ស អត្ថាយ ទុក្ខំ ឧទព្ពហេ
ឃម្មាភិតត្តា តលសា បបីឡិតា
តស្សេវ បាទេ បុរិសស្ស ខាទរេ ។

(៣១២) ឯវមេវ យោ ទុក្កុលីនោ អនរិយោ
តុម្ហាក វិជ្ជញ្ច សុតញ្ច អាទិយ
តមេវ សោ តត្ថ សុតេន ខាទតិ
អនរិយោ វុច្ចតុបាហនូបមោតិ[១] ។

ឧបាហនជាតកំ បឋមំ ។

### វីណាថូណជាតកំ[២]

(៣១៣) ឯកចិន្តិតោ អយមត្ថោ ពាលោ អបរិណាយកោ
ន ហិ ខុជ្ជេន វាមេន ភោតិ សង្គន្តុមរហសិ[៣] ។

១ ម. ឆ. វុច្ចតិ ឧបាហនូបមោ ។ ២. ម. វីណាថូណជាតកំ ។ ៣ ម. សង្គន្តុមរហសិ ។

## ឧបាហនវគ្គ

### ឧបាហនជាតក

(៣១១) (គ្រូអាចារ្យពោធិសត្វ ពោលថា) ស្បែកជើងដែលបុរសទិញហើយ ដើម្បីប្រយោជន៍ដល់សេចក្តីសុខ ជាស្បែកជើងក្តៅហើយ ដោយកំដៅថ្ងៃ ទៀតទៀបនឹងផែនដី តែងនាំមកនូវសេចក្តីទុក្ខ តែងស៊ីនូវជើងនៃបុរសនោះឯង មានឧបមាយ៉ាងណា ។

(៣១២) បុគ្គលណា កើតក្នុងត្រកូលអាក្រក់ ជាអ្នកមិនប្រសើរ បានរៀននូវវិជ្ជានិងសុត្រ (ក្នុងសំណាក់) នៃអ្នកទាំងឡាយ (លោក) ហើយ ក៏មកស៊ីនូវខ្លួនបុគ្គលនោះឯង ព្រោះវិជ្ជានិងសុត្រដែលខ្លួនរៀនហើយ ក្នុងសំណាក់នៃអាចារ្យនោះ បុគ្គលនោះ (បណ្ឌិតពោលថា) ជាមនុស្សមិនប្រសើរ មានឧបមាដោយស្បែកជើងដែលធ្វើមិនល្អហើយ យ៉ាងនោះដែរ ។

ចប់ ឧបាហនជាតក ទី ១ ។

### វីណាថូណជាតក

(៣១៣) (សេដ្ឋីពោធិសត្វ ពោលថា) ប្រយោជន៍នេះ នាងគិតតែម្នាក់ឯង បុរសពាល នាំនាងទៅមិនបាន ម្នាលនាងដ៏ចំរើន ព្រោះថា នាងមិនគួរដើម្បីទៅជាមួយនឹងបុរសគមតឿឡើយ ។

(៣១៦) បុរិសូសភំ មញ្ញមានា អហំ ទុដ្ឋមកាមយឹ

សោយំ សង្ឃដិតោ សេតិ ឆិន្នតន្តិ យថា វីណាតិ ។

វីណាថូណជាតកំ ទុតិយំ ។

## វិកណ្ណកជាតកំ

(៣១៧) កាមំ យហឹ ឥច្ឆសិ តេន គច្ឆ

វិទ្ធោសិ មម្មម្ហិ វិកណ្ណកេន

ហតោសិ ភត្តេន សុវាទិតេន

លោលោ ច មច្ឆេ អនុពន្ធមានោ ។

(៣១៨) ឯវម្បិ លោកាមិសំ ឱបតន្តោ

វិហញ្ញតិ ចិត្តវសានុវត្តី

សោ ហញ្ញតិ ញាតិសខាន មជ្ឈេ

មច្ឆានុគោ សោរិវ សុំសុមារោតិ ។

វិកណ្ណកជាតកំ តតិយំ ។



(៣១៦) (សេដ្ឋីធីតា ពោលថា) ខ្ញុំសំគាល់បុរសគម ថាជាបុរសឧសភៈ បានប្រាថ្នាហើយ បុរសគមនេះ ដេកក្ញេញក្ដិញ ដូចជាពិណ ដែលមានខ្សែដាច់ ។

ចប់ វីណាថូណជាតក ទី ២ ។

## វិកណ្ណកជាតក

(៣១៧) (បុរសអ្នកឲ្យបាយក្រពើ ពោលថា) ឯងប្រាថ្នាក្នុងទីណា ប្រាកដ ចូរទៅក្នុងទីនោះចុះ ឯងត្រូវខ្សែកមុតហើយ ត្រង់ទីជាទីស្លាប់ ឯងជាសត្វលោលោ ដេញតាមចាប់ខ្លួនត្រីទាំងឡាយ ត្រូវគេសម្លាប់ហើយ ដោយបាយព្រមទាំងគ្រឿងប្រហិត ។

(៣១៨) (ព្រះសាស្ដាទ្រង់ត្រាស់ថា) បុគ្គលកាលប្រព្រឹត្តទៅតាមលោកាមិសៈ ជាអ្នកលុះក្នុងអំណាចនៃចិត្ត រមែងក្ដៅក្រហាយ បុគ្គលនោះ រមែងក្ដៅក្រហាយក្នុងកណ្ដាលពួកញាតិនឹងសំឡាញ់ បុគ្គលនោះ ដូចក្រពើដេញតាមខ្លួនត្រីដូច្នោះ ។

ចប់ វិកណ្ណកជាតក ទី ៣ ។

# អសិតាភុជាតកំ

(៣១៧) ត្វមេវ ទានិមករិ យំ កាមោ ព្យគមា តយិ

សោយំ អប្បដិសន្ធិកោ ខរឆិន្នំវ រេណុកំ ។

(៣១៨) អត្រិច្ឆា(១) អតិលោភេន អតិលោភមទេន ច

ឯវំ ហាយតិ អត្ថម្ហា អហំវ អសិតាភុយា ។

អសិតាភុជាតកំ ចតុត្ថំ ។

# វច្ឆនខជាតកំ

(៣១៩) សុខា ឃរា វច្ឆនខ សហិរញ្ញា សភោជនា

យត្ថ ភុត្វា បិវិត្វា ច សយេយ្យាសិ(២) អនុស្សុកោ ។

---

១ ម. អត្រិច្ឆំ ។ ២ ឱ. សយេយ្យាថ ។ ម. សយេយ្យាសិ ។



# អសិតាភុជាតក

(៣១៧) (នាងអសិតាភូ ពោលថា) (ទ្រង់) អស់សេចក្ដីស្រឡាញ់ ចំពោះ
ខ្ញុំព្រោះអំពើណា អ្នកបានធ្វើអំពើនេះ ក្នុងកាលឥឡូវនេះ
សេចក្ដីស្រឡាញ់នោះ មិនតជាប់វិញទេ ដូចជាភ្លុកដំរីដែលគេ
កាត់ដោយរណារដូច្នោះ ។

(៣១៨) (ព្រហ្មទត្តកុមារ មានបន្ទូលថា) បុគ្គលមានសេចក្ដីប្រាថ្នា
លើសលុប រមែងសាបសូន្យចាកប្រយោជន៍ ព្រោះលោភ
ហួសហេតុផង ព្រោះសេចក្ដីស្រវឹងក្នុងលោភដ៏ហួសហេតុ
ផង ដូចយើងសាបសូន្យចាកនាងធីតាឈ្មោះអសិតាភូ ។

ចប់ អសិតាភុជាតក ទី ៤ ។

# វច្ឆនខជាតក

(៣១៩) (ពារាណសីសេដ្ឋី ពោលថា) បពិត្រវច្ឆនខតាបស លោកជា
អ្នកមិនមានសេចក្ដីខ្វល់ខ្វាយ គប្បីបរិភោគផង ផឹកផង ហើយ
ដេកក្នុងផ្ទះទាំងឡាយណា ផ្ទះទាំងឡាយនោះ ប្រកបដោយ
ប្រាក់និងមាស ប្រកបដោយភោជន ជាសុខ(យ៉ាងក្រៃលែង) ។

(៣៦០) ឃរា នានីហមានស្ស ឃរា នាភណតោ មុសា
ឃរា នាទិន្នទណ្ឌស្ស បរេសំ អនិកុព្វតោ
ឯវំ ឆិទ្ទំ ទុរភិសម្ភវំ(១) កោ ឃរំ បដិបជ្ជតិ ។

វច្ឆនខជាតកំ បញ្ចមំ ។

## ពកជាតកំ

(៣៦១) ភទ្ទកោ វតាយំ បក្ខី ទិជោ កុមុទសន្និភោ
វូបសន្តេហិ បក្ខេហិ មន្ទមន្ទោវ ឈាយតិ ។

(៣៦២) នាស្ស សីលំ វិជានាថ អនញ្ញាយ បសំសថ
អម្ហេ ទិជោ ន បាលេតិ តេន បក្ខី ន ផន្ទតិ ។

ពកជាតកំ ឆដ្ឋំ ។

១. ម. ទុរភិរំ ។



(៣៦០) (វច្ឆនខតាបស ពោលថា) ការគ្រប់គ្រងផ្ទះ មិនមានដល់បុគ្គលឥតព្យាយាម ការគ្រប់គ្រងផ្ទះ មិនមានដល់បុគ្គលមិននិយាយពាក្យកុហក ការគ្រប់គ្រងផ្ទះ មិនមានដល់បុគ្គលមិនកាន់យកនូវដំបង មិនធ្វើទោសដល់ជនទាំងឡាយដទៃ បុគ្គលណានឹងគ្រប់គ្រងផ្ទះដែលធ្លុះ បំពេញបានដោយកម្រយ៉ាងនេះ ។

ចប់ វច្ឆនខជាតក ទី ៥ ។

## ពកជាតក

(៣៦១) (ពួកត្រី ពោលថា) សត្វស្លាបនេះ ស្រួលបួលពេក ដូចផ្កាកុមុទ មានស្លាបទាំងពីរស្ងប់ហើយ ឈរសំកុកហាក់ដូចជាមានគំនិតខ្សោយ ។

(៣៦២) (ត្រីពោធិសត្វ ពោលថា) អ្នកទាំងឡាយ មិនដឹងច្បាស់ នូវសីលរបស់កុកនោះទេ អ្នកទាំងឡាយ មិនដឹងហើយនាំគ្នាសរសើរ សត្វស្លាបមិនថែរក្សានូវយើងឡើយ ព្រោះហេតុនោះ ទើបសត្វស្លាប (នេះ) មិនកម្រើកខ្លួន ។

ចប់ ពកជាតក ទី ៦ ។

# សាកេតជាតកំ

(៣៤៣) កោ នុ ខោ ភគវា ហេតុ ឯកច្ចេ ឥធ បុគ្គលេ

អតីវ ហទយំ និព្វាតិ ចិត្តញ្ចាបិ បសីទតិ ។

(៣៤៤) បុព្វេវ សន្និវាសេន បច្ចុប្បន្នហិតេន វា

ឯវំ តំ ជាយតេ បេមំ ឧប្បលំវ យថោទកេ ។

សាកេតជាតកំ សត្តមំ ។

# ឯកបទជាតកំ

(៣៤៥) ឥង្ឃ ឯកបទំ តាត អនេកត្ថបទស្សិតំ(១)

កិញ្ចិ សង្គាហិកំ ព្រូហិ យេនត្ថេ សាធយេមសេ ។

---

១ ម. អនេកត្ថបទនិស្សិតំ ។



# សាកេតជាតក

(៣៤៣) (ពួកភិក្ខុ ពោលថា) បពិត្រព្រះមានព្រះភាគ ហេតុអ្វីហ្ន៎ ហឫទ័យត្រជាក់ យ៉ាងក្រៃលែង ទាំងចិត្តក៏ជ្រះថ្លាក្នុងបុគ្គលពួកខ្លះ ក្នុងលោកនេះ ។

(៣៤៤) (ព្រះសាស្តា ទ្រង់ត្រាស់ថា) សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុពីរយ៉ាង គឺដោយភ្ជាប់នៅរួមគ្នា ក្នុងកាលមុន ១ ដោយការទំនុកបម្រុងក្នុងបច្ចុប្បន្ននេះ ១ ដូចផ្កាឧប្បលដែលដុះក្នុងទឹក ដោយហេតុពីរយ៉ាង គឺទឹក ១ ភក់ ១ ។

ចប់ សាកេតជាតក ទី ៧ ។

# ឯកបទជាតក

(៣៤៥) (កុមារជាកូននៃព្រះរាជសេដ្ឋ ពោលថា) បពិត្របិតា យើងញុំាងប្រយោជន៍ឲ្យសម្រេច ដោយបទណា សូមអញ្ជើញលោកប្រាប់នូវបទនោះតែមួយ ដែលអាស្រ័យនូវបទ ជាប្រយោជន៍ច្រើន ដែលសង្គ្រោះ (រួមចូល) តែមួយ ។

(៣៦៦) ទក្ខេយ្យេកបទំ តាត អនេកត្ថបទស្សិតំ

តញ្ច សីលេន សំយុត្តំ ខន្តិយា ឧបបាទិតំ

អលំ មិត្តេ សុខាបេតុំ អមិត្តានំ ទុខាយ ចាតិ ។

ឯកបទជាតកំ អដ្ឋមំ ។

## ហរិតមាតជាតកំ

(៣៦៧) អាសីវិសម្បិ មំ សន្តំ បវិដ្ឋំ កុមិនាមុខំ

រុច្ចតេ ហរិតាមាតា យំ មំ ទសន្តិ មច្ឆកា ។

(៣៦៨) វិលុម្បតេវ បុរិសោ យាវស្ស ឧបកប្បតិ

យទា ចញ្ញេ វិលុម្បន្តិ សោ វិលុត្តោ វិលុម្បតីតិ ។

ហរិតមាតជាតកំ នវមំ ។



(៣៦៦) (បិតា ប្រាប់ថា) នែកូន សេចក្តីឧស្សាហ៍ (ប្រកបដោយញាណ) ជាបទតែមួយ ដែលអាស្រ័យនូវបទ ជាប្រយោជន៍ច្រើន តែសេចក្តីឧស្សាហ៍នោះ ប្រកបដោយសីល ប្រកបដោយខន្តិធម៌ អាចញ៉ាំងពួកមិត្រឲ្យសុខ ឬដើម្បីសេចក្តីទុក្ខ ដល់ពួកបុគ្គលមិនមែនជាមិត្រ ។

ចប់ ឯកបទជាតក ទី ៨ ។

## ហរិតមាតជាតក

(៣៦៧) (សត្វពស់ សួរថា) ម្នាលអ្នកជាកូន នៃហរិតមណ្ឌូកមាតា ត្រីទាំងឡាយ ស៊ីខ្លួនខ្ញុំ ដែលជាសត្វមានពិស ដែលចូលទៅកាន់មាត់លប ដោយហេតុណា ហេតុនេះ ពេញចិត្ត (ដល់អ្នកដែរឬ) ។

(៣៦៨) (ហរិតមណ្ឌូកពោលថា) (អស្សរោត) របស់បុរសនោះ មានប្រយោជន៍ទៅ ដរាបណា បុរស(នោះ) រមែងរឹបជាន់ (ជនដទៃ ដរាបនោះ) លុះពួកជនដទៃ (មានអស្សរោត) រមែងរឹបជាន់វិញ ក្នុងកាលណា បុរសអ្នករឹបជាន់នោះ ត្រូវពួកជនដទៃរឹបជាន់វិញ ក្នុងកាលនោះ ។

ចប់ ហរិតមាតជាតក ទី ៩ ។

# មហាបិង្គលជាតកំ

(៣២៩) សព្វោ ជនោ ហឹសិតោ បិង្គលេន

តស្មឹ មតេ បច្ចយំ វេទយន្តិ

បិយោ នុ តេ អាសិ អកណ្ហនេត្តោ

កស្មា នុ ត្វំ រោទសិ ទ្វារបាល ។

(៣៣០) ន មេ បិយោ អាសិ អកណ្ហនេត្តោ

ភាយាមិ បច្ចាគមនាយ តស្ស

ឥតោ គតោ ហឹសេយ្យ មច្ចុរាជំ

សោ ហឹសិតោ អានេយ្យ បុន ឥធ ។

(៣៣១) ឌឌ្ឍោ វាហសហស្សេហិ សិត្តោ ឃដសតេហិ សោ

បរិក្ខតា ច សា ភូមិ មា ភាយិ នាគមិស្សតីតិ ។

មហាបិង្គលជាតកំ ទសមំ ។

ឧបាហនវគ្គោ នវមោ ។



# មហាបិង្គលជាតក

(៣២៩)(ព្រះពោធិសត្វ ពោលថា) ជនទាំងអស់ ត្រូវស្តេចបិង្គលៈ បៀតបៀនហើយ កាលស្តេចនោះ សោយទិវង្គតហើយ ជនទាំងឡាយ រមែងបាននូវសេចក្តីត្រេកអរ ម្នាលទ្វារបាល ស្តេចអកណ្ហនេត្រ ជាទីស្រឡាញ់របស់អ្នកឬ ព្រោះហេតុអ្វី បានជាអ្នកយំ ។

(៣៣០)(ទ្វារបាលបុរស ពោលថា) ស្តេចអកណ្ហនេត្រ មិនមែនជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំខ្លាចស្តេចនោះត្រឡប់មកវិញ (ព្រោះស្តេចនោះ) ទៅអំពីមនុស្សលោកនេះ គប្បីបៀតបៀន នូវមច្ចុរាជ មច្ចុរាជនោះ ត្រូវស្តេចបិង្គលៈ បៀតបៀនហើយ គប្បីនាំមកទុក ក្នុងមនុស្សលោកនេះវិញ ។

(៣៣១)(ព្រះពោធិសត្វ ពោលថា) ព្រះបាទបិង្គលៈនោះ គេដុតដោយឧស ១ ពាន់រទេះ គេស្រោចដោយទឹកមួយរយក្អម ឯទីសម្រាប់ដុត គេបិទជុំវិញហើយ អ្នកកុំភ័យឡើយ ស្តេចបិង្គលៈនោះ នឹងមិនមកវិញបានទេ ។

ចប់ មហាបិង្គលជាតក ទី ១០ ។

ចប់ ឧបាហនវគ្គ ទី ៩ ។

## តស្សុទ្ទានំ

ឧបាហន ទុដ្ឋ វិកណ្ណកគោ
អសិតាភុយ បញ្ចុមវដ្ឋលទោ
ធិជ បេទកុក្កុម ឃកបធំ
ក្រុមិជាមុខ បិង្គលេន ទស ។

---



## ឧទ្ទាននៃឧបាហនវគ្គនោះ គឺ

និយាយអំពីស្បែកជើងប្រសើរ ១ បុរសគម ១ ក្រពើត្រូវខ្សែកមុខ ១ ព្រះរាជធីតាឈ្មោះអសិតាភូ ១ ខ្លែងខ្ទាបរស ១ សត្វកុក ១ សេចក្តីស្រឡាញ់ដ៏ប្រសើរឧត្តម ១ បទតែមួយ ១ មាតលប ១ ស្តេចឈ្មោះបិង្គលៈ ១ ត្រូវជា ១០ ។

---

## សព្វទាឋិជាតកំ

(៣៣២) សិគាលោ មានថទ្ធោ ច បរិវារេន អត្ថិកោ
បាបុណិ មហតឹ ភូមឹ រាជាសិ សព្វទាឋិនំ ។
(៣៣៣) ឯវមេវ មនុស្សេសុ យោ ហោតិ បរិវារវា
សោ ហិ តត្ថ មហា ហោតិ សិគាលោ វិយ ទាឋិនន្តិ ។

សព្វទាឋិជាតកំ បឋមំ ។

## សុណខជាតកំ

(៣៣៤) ពាលោ វតាយំ សុណខោ យោ វរត្តំ(១) ន ខាទតិ
ពន្ធនា ច បមោចេយ្យ អសិតោ ច ឃរំ វជេ ។
(៣៣៥) អដ្ឋិតំ មេ មនស្មឹ មេ អថោ មេ ហទយេ កតំ
កាលញ្ច បដិកង្ខាមិ យាវ បស្សុបតូ ជនោតិ ។

សុណខជាតកំ ទុតិយំ ។

១ ម. យោ ច យោត្តំ ។



## សព្វទាឋិជាតក

(៣៣២) (ព្រះសាស្តា ទ្រង់ត្រាស់ថា) ចចក រឹងត្អឹងដោយមានះ ត្រូវការដោយបរិវារ (ច្រើន) ក៏ដល់នូវសម្បត្តិដ៏ធំ បានជាស្តេចនៃពួកសត្វមានចង្កូមទាំងពួង ។
(៣៣៣) បណ្តាមនុស្សទាំងឡាយ មនុស្សណា ជាអ្នកមានបរិវារ មនុស្សនោះ ឈ្មោះថាជាធំក្នុងពួកបរិវារនោះ ដូចជាចចក (បានជាធំ) ជាងសត្វមានចង្កូមទាំងឡាយ ដូច្នោះឯង ។

ចប់ សព្វទាឋិជាតក ទី ១ ។

## សុណខជាតក

(៣៣៤) (ព្រះពោធិសត្វ ពោលថា) ឆ្កែណា មិនស៊ីព្រ័ត្រ ឆ្កែនុះ ពេញជាល្ងង់ ម្យ៉ាងទៀត ឆ្កែគួរដោះខ្លួនអំពីចំណង ស៊ីព្រ័ត្រឆ្អែតហើយ គប្បីទៅកាន់ផ្ទះ (របស់ខ្លួន) ។
(៣៣៥) (ឆ្កែ ពោលថា ពាក្យរបស់អ្នក) ខ្ញុំបានតាំងទុកក្នុងចិត្តខ្ញុំហើយ ម្យ៉ាងទៀត ខ្ញុំបានធ្វើទុកក្នុងហឫទ័យខ្ញុំហើយ ជនដេកលក់ស៊ប់វេលាណា ខ្ញុំនឹងចាំនូវកាល វេលានោះ ។

ចប់ សុណខជាតក ទី ២ ។

## គុត្តិលជាតកំ

(៣៣៦) សត្តតន្តិំ សុមធុរំ រាមណេយ្យំ អវាចយិំ
សោ មំ រង្គម្ហិ អវ្ហេតិ សរណំ មេ ហោហិ កោសិយ ។
(៣៣៧) អហំ តំ សរណំ សម្ម អហមាចរិយបូជកោ
ន តំ ជយិស្សតិ សិស្សោ សិស្សមាចរិយ ជេស្សសិ ។

គុត្តិលជាតកំ តតិយំ ។

## វិគតិច្ឆជាតកំ

(៣៣៨) យំ បស្សតិ ន តំ ឥច្ឆតិ យញ្ច ន បស្សតិ តំ កិរ ឥច្ឆតិ
មញ្ញាមិ ចិរំ ចរិស្សតិ ន ហិ តំ លច្ឆតិ យំ សោ ឥច្ឆតិ ។



## គុត្តិលជាតក

(៣៣៦) (ព្រះពោធិសត្វ ពោលថា) បពិត្រព្រះឥន្ទ្រកោសិយ ខ្ញុំបាន (ញុំាងសិស្សឈ្មោះមូសិលៈ) ឲ្យរៀននូវពិណមានខ្សែ ៧ មានសម្លេងពីរោះ ជាទីរីករាយនៃចិត្ត (ឥឡូវនេះ) សិស្សឈ្មោះមូសិលៈនោះ ហៅខ្ញុំក្នុងកណ្តាលរង្គមណ្ឌល (កន្លែងតក់) សូមព្រះអង្គជាទីពឹងនៃខ្ញុំ ។
(៣៣៧) (សក្កទេវរាជ ទ្រង់មានព្រះបន្ទូលថា) ម្នាលសំឡាញ់ ខ្ញុំនឹងជាទីពឹងរបស់អ្នក ខ្ញុំជាអ្នកបូជានូវអាចារ្យ សិស្សនឹងមិនឈ្នះអ្នក បពិត្រអាចារ្យ អ្នកនឹងឈ្នះនូវសិស្សវិញ ។

ចប់ គុត្តិលជាតក ទី ៣ ។

## វិគតិច្ឆជាតក

(៣៣៨) (តាបសពោធិសត្វ ពោលថា) បុគ្គលឃើញនូវរបស់ណា មិនប្រាថ្នានូវរបស់នោះ មួយទៀត មិនឃើញនូវរបស់ណា ចង់បាននូវរបស់នោះ យើងសំគាល់ថា បុគ្គលនោះ នឹងត្រាច់ទៅ (ក្នុងសង្សារ) អស់កាលយូរ ព្រោះថា បុគ្គលនោះប្រាថ្នារបស់ណា មិនបាននូវរបស់នោះ ។

(៣៥៩) យំ លភតិ ន តេន តុស្សតិ យំ បត្ថេតិ លទ្ធំ ហីឡេតិ

ឥច្ឆា ហិ អនន្តគោចរា វិគតិច្ឆាន នមោ ករោមសេ ។

វិគតិច្ឆជាតកំ ចតុត្ថំ ។

## មូលបរិយាយជាតកំ

(៣៦០) កាលោ ឃសតិ ភូតានិ សព្វានេវ សហត្តនា

យោ ច កាលឃសោ ភូតោ ស ភូតបចនឹ បចិ ។

(៣៦១) ពហូនិ នរសីសានិ លោមសានិ ព្រហានិ ច

គីវាសុ បដិមុក្កានិ កោចិទេវេត្ថ កណ្ណវា ។

មូលបរិយាយជាតកំ បញ្ចមំ ។



(៣៥៩) (បុគ្គលបានទ្រព្យរបស់ណា) មិនត្រេកអរនឹងរបស់នោះ ប្រាថ្នាសម្បត្តិណា មើលងាយនូវសម្បត្តិ ដែលបានហើយនោះ ព្រោះថាសេចក្តីប្រាថ្នា ជាដំណើររកទីបំផុតគ្មាន យើងសូមធ្វើនមស្ការចំពោះពួកបណ្ឌិត ដែលមានសេចក្តីប្រាថ្នាទៅប្រាសហើយ ។

ចប់ វិគតិច្ឆជាតក ទី ៤ ។

## មូលបរិយាយជាតក

(៣៦០) (គាថាប្រទិសាបាមោក្ខពោធិសត្វ សួរថា) កាលរមែងស៊ី នូវពួកសត្វទាំងអស់ ព្រមទាំងខ្លួនឯង. ចំណែកសត្វណា ជាអ្នកស៊ីនូវកាល សត្វនោះ ឈ្មោះថា ដុតនូវតណ្ហា ដែលជាធម្មជាតិដុតសត្វ ។

(៣៦១) (ព្រះពោធិសត្វ តិះដៀលថា) ក្បាលនៃជនទាំងឡាយដ៏ច្រើន ក្បាលទាំងនោះ មានរោមផង ធំផង ត្រូវបាននៅលើក បណ្ដាមនុស្សទាំងអម្បាលនេះ គង់មានមនុស្សណាមួយ ដែលមានប្រាជ្ញាមិនខាន ។

ចប់ មូលបរិយាយជាតក ទី ៥ ។

## ពាលោវាទជាតកំ(១)

(៣៦២) ហន្ត្វា ឈត្វា វធិត្វា ច ទេតិ ទានំ អសញ្ញតោ

ឯទិសំ ភត្តំ ភុញ្ជមានោ ស បាបមុបលិម្បតិ(២) ។

(៣៦៣) បុត្តទារម្បិ ចេ ហន្ត្វា ទេតិ ទានំ អសញ្ញតោ

ភុញ្ជមានោបិ សប្បញ្ញោ ន បាបមុបលិម្បតិ ។

ពាលោវាទជាតកំ ឆដ្ឋំ ។

## បាទញ្ជលិជាតកំ

(៣៦៤) អទ្ធា បាទញ្ជលី សព្វេ បញ្ញាយ អតិរោចតិ

តថា ហិ ឱដ្ឋំ ភញ្ជតិ ឧត្តរឹ នូន បស្សតិ ។

១ ម. តេលោវាទជាតកំ ។ ២ ម. សោ បាបេន ឧបលិម្បតិ ។



## ពាលោវាទជាតក

(៣៦២) (កុដុម្ពិកម្នាក់ពោលថា) បុគ្គលអ្នកមិនត្រូវសង្រួម ប្រហារសត្វផង ធ្វើសត្វឲ្យលំបាកផង ធ្វើសត្វឲ្យស្លាប់ផង ហើយឲ្យទាន(ដល់សមណៈណា) សមណៈនោះ កាលបរិភោគ នូវភត្តបែបនេះ ឈ្មោះថា ប្រឡាក់ដោយបាបដែរ ។

(៣៦៣) (ព្រះពោធិសត្វ តបថា) ប្រសិនបើបុគ្គលអ្នកមិនសង្រួម សម្លាប់នូវកូននឹងប្រពន្ធ ហើយឲ្យទាន (ដល់សមណៈណា) សមណៈនោះ ជាអ្នកប្រកបដោយប្រាជ្ញា ទុកជាកាលបរិភោគ ក៏មិនប្រឡាក់ដោយបាបឡើយ ។

ចប់ ពាលោវាទជាតក ទី ៦ ។

## បាទញ្ជលិជាតក

(៣៦៤) (អាមាត្យពោធិសត្វ សរសើរថា) ព្រះរាជកុមារព្រះនាមបាទ-ញ្ជលី ទ្រង់រុងរឿងកន្លងនូវពួកយើងទាំងអស់គ្នា ដោយប្រាជ្ញាពិតមែន ដូច្នោះ បានជាទ្រង់ពេបព្រះឱស្ឋ ទ្រង់ទតឃើញ នូវហេតុដ៏ក្រៃលែងដោយពិត ។

(៣៤៥) ណាយំ ធម្មំ អធម្មំ វា អត្ថានត្ថញ្ច ពុជ្ឈតិ

អញ្ញត្រ ទិជ្ជវិក្កោណា ណាយំ ជានាតិ កិញ្ចនន្តិ ។

បាទញ្ជលិជាតកំ សត្តមំ ។

## កឹសុកោបមជាតកំ

(៣៤៦) សព្វេហិ កឹសុកោ ទិដ្ឋោ កិំ ន្វេត្ថ វិចិកិច្ឆថ

ន ហិ សព្វេសុ ឋានេសុ សារថី បរិបុច្ឆិតោ ។

(៣៤៧) ឯវំ សព្វេហិ ញាណេហិ យេសំ ធម្មា អជានិតា

តេ វេ ធម្មេសុ កង្ខន្តិ កឹសុកស្មឹវ ភាតរោតិ ។

កឹសុកោបមជាតកំ អដ្ឋមំ ។



(៣៤៥) (ព្រះពោធិសត្វ ពោលថា) ព្រះរាជកុមារព្រះនាមបាទញ្ជលីនេះ មិនទ្រង់ជ្រាបនូវសភាពជាធម៌ ទាំងសភាពមិនមែនជាធម៌ផង នូវប្រយោជន៍ ទាំងមិនមែនជាប្រយោជន៍ផង ព្រះរាជកុមារព្រះនាមបាទញ្ជលីនេះ វៀរលែងតែការពេប នូវព្រះឱស្ឋបញ្ចេញហើយ ទ្រង់មិនជ្រាបនូវហេតុតិចតួចឡើយ ។

ចប់ បាទញ្ជលិជាតក ទី ៧ ។

## កឹសុកោបមជាតក

(៣៤៦) (ព្រះរាជា ពោលថា) ដើមពារ អ្នកទាំងអស់គ្នាបានឃើញហើយ អ្នកទាំងឡាយទៅសង្ស័យក្នុងដើមពារនោះ ដូចម្តេចហ្ន៎ ព្រោះអ្នកទាំងឡាយ មិនបានសាកសួរនាយសារថី ក្នុងទីទាំងពួងនោះ ។

(៣៤៧) (ព្រះសាស្តា ទ្រង់ត្រាស់ថា) ធម៌ទាំងឡាយ ដែលពួកជនណាមិនបានដឹងហើយ ដោយញាណទាំងឡាយទាំងពួង យ៉ាងនេះ ពួកជននោះឯង រមែងសង្ស័យក្នុងធម៌ទាំងឡាយ ដូចជា (ព្រះរាជបុត្រទាំង ៤ ព្រះអង្គ) ជាបងប្អូននឹងគ្នា សង្ស័យក្នុងដើមពារដូច្នោះ ។

ចប់ កឹសុកោបមជាតកទី ៨ ។

# សាលកជាតកំ

(៣៤៨) ឯកបុត្តកោ ភវិស្សសិ
ត្វញ្ច នោ ហេស្សសិ ឥស្សរោ កុលេ
ឱរោហិ ទុមស្មា សាលក
ឯហិ ទានិ ឃរកំ វជេមសេ ។

(៣៤៩) ននុ មំ សុហទយោតិ មញ្ញសិ
យញ្ច មំ ហនសិ វេឡុយដ្ឋិយា
បក្កម្ពវនេ រមាមសេ
គច្ឆ ត្វំ ឃរកំ យថាសុខំ ។

សាលកជាតកំ នវមំ ។

# កបិជាតកំ

(៣៥០) អយំ ឥសី ឧបសមសញ្ញមេ រតោ
ស តិដ្ឋតិ(១) សិសិរភយេន អដ្ដិតោ(២)
ហន្ទ អយំ បវិសតុមំ អគារកំ
វិនេតុ សីតំ ទរថញ្ច កេវលំ ។

១ ឱ. ម. សន្តិដ្ឋតិ ។ ២ ឱ. ម. អដ្ដិតោ ។



# សាលកជាតក

(៣៤៨) (គ្រូពស់ ពោលថា) នែសាលកៈ អ្នកជាកូនប្រុសតែមួយ (នៃយើង) មួយទៀត អ្នកនឹងបានជាធំក្នុងត្រកូលរបស់យើង ចូរអ្នកចុះអំពីដើមឈើមក យើងនឹងទៅផ្ទះ ក្នុងកាលឥឡូវនេះ ។

(៣៤៩) (ស្វាពោលតបថា) ក្រែងអ្នកសំគាល់ខ្ញុំថាជាសត្វមានហឫទ័យល្អ តែអ្នកបៀតបៀនខ្ញុំដោយដំបងឫស្សី ខ្ញុំត្រេកអរក្នុងព្រៃស្វាយដែលមានផ្លែទុំ អ្នកចូរទៅផ្ទះ តាមសប្បាយចុះ ។

ចប់ សាលកជាតក ទី ៩ ។

# កបិជាតក

(៣៥០) (តាបសកុមារ ពោលថា) ឥសីអង្គនេះ ត្រេកអរក្នុងការស្ងប់និងការសង្រួម លោកត្រូវភ័យអំពីរងាបៀតបៀនហើយ សូមឲ្យតាបសនេះ ចូលមកកាន់ផ្ទះនេះ ដើម្បីបន្ទោបង់នូវត្រជាក់និងសេចក្តីក្រវល់ក្រវាយចេញ កុំឲ្យមានសេសសល់ឡើយ ។

(៣៩៨) នាយំ ឥសិ ឧបសមសញ្ញមេ រតោ
កបិ អយំ ទុម្ពរសាខគោចរោ[១]
សោ ទូសកោ រោសកោ ចាបិ ជម្មោ
សចេ វជេ ឥមម្បិ ទូសយេ ឃរន្តិ ។

កបិជាតកំ ទសមំ ។

សិង្គាលវគ្គោ ទសមោ ។

## តស្សុទ្ទានំ

អថ កថា សិង្គាលកេ សុនខោ
គតា កោសិយ ឥច្ឆតិ កាលយសោ
អថ បាទតេជម្បិ សារថិកា
បុនប្បវតេ[២] សិសិរកាបិ ទស ។

## វគ្គុទ្ទានំ

ទឡ្ហញ្ច វគ្គំ អបរេន សន្ថវំ
កល្យាណវគ្គាសទិសោ ច រូហកំ
នតំទឡ្ហំ ពីរណត្ថម្ភកា បុន
កាសាវុបាហន សិង្គាលកេន ទសាតិ ។

ទុកនិបាតំ និដ្ឋិតំ ។

១. ឱ. ម. ទុមវរសាខគោចរោ ។ ២ បណ្ណរុក្ខគោតិ បញ្ចក្ខំ ។



(៣៩១) (ពោធិសត្វ ពោលថា) អ្នកនេះមិនមែនជាឥសី អ្នកត្រេកអរ
ក្នុងការស្ងប់និងការសង្រួមទេ អ្នកនេះជាសត្វស្វា ជាសត្វដើរ
នៅលើមែកឈើ ស្វានោះជាសត្វទីប្រទូស្ត មានសន្តានចិត្ត
ដ៏លាមក បើចូលមក មុខតែប្រទូស្តផ្ទះនេះមិនខាន ។

ចប់ កបិជាតក ទី ១០ ។

ចប់ សិង្គាលវគ្គ ទី ១០ ។

## ឧទ្ទាននៃសិង្គាលវគ្គនោះ គឺ

និយាយអំពីស្តេចចចក ១ សុនខ ១ ព្រះឥន្ទ្រកោសិយ ១ បុគ្គលប្រាថ្នា ១ បុគ្គលអ្នកស៊ីខ្ទៅកាល ១ ខានដ៏ប្រសើរ ១ ព្រះរាជកុមារ ពេបព្រះទស្ស ១ នាយសារថី ១ ព្រៃស្វាយ ១ ស្វានេះ ១ ត្រូវជា ១០ ។

## ឧទ្ទាននៃវគ្គ គឺ

និយាយអំពីទឡ្ហវគ្គ ១ សន្ថវវគ្គ ១ កល្យាណវគ្គ ១ អស-ទិសវគ្គ ១ រូហកវគ្គ ១ នតំទឡ្ហវគ្គ ១ ពីរណត្ថម្ភកវគ្គ ១ កាសាវវគ្គ ១ ឧបាហនវគ្គ ១ សិង្គាលវគ្គ ១ ត្រូវជា ១០ ។

ចប់ ទុកនិបាត ។

# តិកនិបាតជាតកំ

## សង្កប្បវគ្គោ

### សង្កប្បរាគជាតកំ

(៣៩២) សង្កប្បរាគធោតេន វិតក្កនិសិតេន ច

នេវាលង្កតភទ្រេន[១](ន) ឧសុការកតេន ច ។

(៣៩៣) ន កណ្ណាយតមុត្តេន នបិ មោរូបសេវិនា

តេនម្ហិ ហទយេ វិទ្ធោ សព្វង្គបរិទាហិនា ។

(៣៩៤) អាវេធញ្ច ន បស្សាមិ យតោ រុហិរមស្សវេ

យាវ អយោនិសោ ចិត្តំ សយំ មេ ទុក្ខមាភតំ ។

សង្កប្បរាគជាតកំ បឋមំ ។

១ ម. ឆ. នាលង្កតេន ភទ្រេន ។

# តិកនិបាតជាតក

## សង្កប្បវគ្គ

### សង្កប្បរាគជាតក

(៣៩២) (តាបសពោធិសត្វ ពោលថា) អាត្មាត្រូវ(សរគឺកិលេស)ដែល លាងដោយទឹក គឺសង្កប្បរាគៈ (រាគៈប្រកបដោយកាមវិតក្កៈ) ផង ដែលសំលៀងដោយថ្ម គឺកាមវិតក្កផង មិនបានចំរើនដោយ គ្រឿងតាក់តែងផង (មិនមែន) ជាងសរធ្វើហើយផង ។

(៣៩៣) មិនមែនទាញមក ត្រឹមត្រចៀកហើយលែងទៅវិញផង ទាំង មិនជាប់ដោយស្លាបក្ងោកផង ជាសរគេចដុតអវយវៈទាំងអស់ ឲ្យក្តៅនោះ បានមុតហើយត្រង់ហឫទ័យ ។

(៣៩៤) ឈាមគប្បីហូរចេញ ចាកមុខរបួស ដែលសរណាមុតហើយ អាត្មាមើលមិនឃើញមុខរបួស ដែលសរនោះមុតហើយទេ ចិត្ត (របស់អាត្មា ត្រូវសរមុតជាប់ហើយ) ព្រោះខុសទំនង អាត្មានាំ មកនូវសេចក្តីទុក្ខដោយខ្លួនឯង ។

ចប់ សង្កប្បរាគជាតក ទី ១ ។

## តិលមុដ្ឋិជាតកំ

(៣៨៥) អជ្ជាបិ មេ តំ មនសិ[១] យំ មំ ត្វំ តិលមុដ្ឋិយា
ពាហាយំ មំ គហេត្វាន លដ្ឋិយា អនុតាឡយិ ។

(៣៨៦) ននុ ជីវិតេ ន រមសិ យេនាសិ ព្រាហ្មណាគតោ
យំ មំ ពាហា គហេត្វាន តិក្ខត្តុំ អនុតាឡយិ ។

(៣៨៧) អរិយោ អនរិយំ កុព្វំ[២] យោ ទណ្ឌេន និសេធតិ
សាសនំ[៣] តំ ន តំ វេរំ ឥតិ នំ បណ្ឌិតា វិទូ ។

តិលមុដ្ឋិជាតកំ ទុតិយំ ។

## មណិកណ្ឋជាតកំ

(៣៨៨) មមន្នបានំ វិបុលំ ឧឡារំ
ឧប្បជ្ជតីមស្ស មណិស្ស ហេតុ
តន្តេ[៤] ន ទស្សំ អតិយាចកោសិ
ន ចាបិ តេ អស្សមមាគមិស្សំ ។

---

១ ម. សរេ ។ ២ ឱ. កុព្វានំ ។ ម. កុព្វន្តំ ។ ៣ ឱ. សាសនន្តំ ។ ៤ ម. តំ តេ ន ទស្សំ ។



## តិលមុដ្ឋិជាតក

(៣៨៥) (ព្រះបាទព្រហ្មទត្ត ពោលថា) អ្នកចាប់យើងត្រង់ដើមដៃ ហើយវាយនឹងដំបងរំពាត់ ព្រោះហេតុតែល្ងមួយក្តាប់ ការវាយនោះ ប្រាកដក្នុងចិត្តរបស់យើង ដរាបដល់ថ្ងៃនេះ ។

(៣៨៦) ម្នាលព្រាហ្មណ៍ អ្នកមកដោយហេតុណា អ្នកមិនត្រេកអរក្នុងជីវិតដោយហេតុនោះឬ ព្រោះអ្នកចាប់យើងត្រង់ដើមដៃ ហើយវាយ អស់វារៈបីដង ។

(៣៨៧) (ព្រាហ្មណ៍ ពោលថា) អរិយជនណា ហាមឃាត់នូវបុគ្គលមិនប្រសើរ កាលធ្វើនូវអំពើអាក្រក់ដោយអាជ្ញា ការហាមឃាត់របស់អរិយជននោះ ចាត់ជាពាក្យប្រៀនប្រដៅ ការហាមឃាត់របស់អរិយជននោះ មិនមែនជាពៀរឡើយ បណ្ឌិតទាំងឡាយ រមែងដឹងនូវហេតុនោះ ដូច្នេះឯង ។

ចប់ តិលមុដ្ឋិជាតក ទី ២ ។

## មណិកណ្ឋជាតក

(៣៨៨) (មណិកណ្ឋនាគរាជ ពោលថា) បាយនិងទឹក កើតដល់ខ្ញុំច្រើនក្រៃលែង ព្រោះហេតុតែកែវមណីនេះ ខ្ញុំនឹងមិនឲ្យកែវមណីនោះដល់លោក លោកជាអ្នកសូមហួសហេតុ ខ្ញុំនឹងមិនមកកាន់អាស្រមរបស់លោកទេ ។

(៣៥៩) សុសូ យថា សក្ខរធោតបាណី
តាសេសិ មំ សេលំ យាចមានោ
តំ តេ ន ទស្សំ អតិយាចកោសិ
ន ចាបិ តេ អស្សមមាគមិស្សំ ។

(៣៦០) ន តំ យាចេ យស្ស បិយំ ជិគីសេ
ទេស្សោ ហោតិ អតិយាចនាយ
នាគោ មណឹ យាចិតោ ព្រាហ្មណេន
អទស្សនំយេវ តទជ្ឈគមាតិ ។

មណិកណ្ឋជាតកំ តតិយំ ។

## កុណ្ឌកកុច្ឆិសិន្ធវជាតកំ

(៣៦១) ភុត្វា តិណបរិឃាសំ ភុត្វា អាចាមកុណ្ឌកំ
ឯតំ តេ ភោជនំ អាសិ កស្មា ទានិ ន ភុញ្ជសិ ។



(៣៥៩) លោកការសូមកែវមណី ដែលកើតក្នុងថ្ម នាំឲ្យខ្ញុំតក់ស្លុត ដូចមនុស្សកំលោះ មានដៃកាន់ដាវដែលសៀងហើយដោយថ្ម មកញាំងខ្ញុំឲ្យតក់ស្លុតដូច្នោះ ខ្ញុំមិនឲ្យកែវមណីនោះដល់លោកទេ (ព្រោះ) លោកជាអ្នកសូមហួសហេតុ ខ្ញុំនឹងលែងមកកាន់អាស្រមរបស់លោកហើយ ។

(៣៦០) (តាបសពោធិសត្វជាបង ពោលថា) បុគ្គលដឹងនូវវត្ថុណាថា ជាទីស្រឡាញ់របស់គេ មិនគួរសូមវត្ថុនោះទេ សេចក្ដីស្អប់ រមែងមាន ព្រោះការសូមហួសពេក ដូចស្ដេចនាគដែលត្រូវព្រាហ្មណ៍សូមកែវមណី ទៅកាន់វិស័យមើលមិនឃើញតាំងអំពីកាលនោះ ។

ចប់ មណិកណ្ឋជាតក ទី ៣ ។

## កុណ្ឌកកុច្ឆិសិន្ធវជាតក

(៣៦១) (ឈ្មួញសេះពោធិសត្វ ពោលថា) អ្នកធ្លាប់បរិភោគស្មៅដ៏សល់ដែល ធ្លាប់បរិភោគបាយក្ដាំនឹងកុណ្ឌកមកហើយ នេះជាភោជនរបស់អ្នក ឥឡូវនេះ ហេតុអ្វីក៏អ្នកមិនបរិភោគ ។

(៣៦២) យត្ថ ពោសំ ន ជានន្តិ ជាតិយា វិនយេន វា

ពហុំ តត្ថ មហាព្រហ្មេ អបិ អាចាមកុណ្ឌកំ ។

(៣៦៣) ត្វញ្ច ខោ មំ បជានាសិ យាទិសាយំ ហយុត្តមោ

ជានន្តោ ជានមាគម្ម ន តេ ភក្ខាមិ កុណ្ឌកំ ។

កុណ្ឌកកុច្ឆិសិន្ធវជាតកំ ចតុត្ថំ ។

## សុកជាតកំ

(៣៦៤) យាវ សោ មត្តមញ្ញាសិ ភោជនស្មឹ វិហង្គមោ

តាវ អទ្ធានមាបាទិ មាតរញ្ច អបោសយិ ។

(៣៦៥) យតោ ច ខោ សោ ពហុតរំ ភោជនំ អជ្ឈវាហរិ

តតោ តត្ថេវ សំសីទិ អមត្តញ្ញូ ហិ សោ អហុ ។



(៣៦២) (កូនសេះសិន្ធវៈ ពោលថា) បពិត្រមហាព្រាហ្មណ៍ ជនទាំងឡាយ មិនស្គាល់សត្វដែលគួរចិញ្ចឹមដោយជាតិ ឬដោយមារយាទដែលគួរខ្ពង់ខ្ពស់ ក្នុងទីណា ក្នុងទីនោះ ថ្វីតែខ្ញុំមិនបរិភោគបាយក្តាំង នឹងកុណ្ឌកច្រើន ។

(៣៦៣) ចំណែកលោកស្គាល់ខ្ញុំច្បាស់ថា សេះនេះឧត្តមយ៉ាងណាៗ ខ្ញុំកាលដឹង ព្រោះអាស្រ័យអ្នកជាអ្នកដឹង ទើបមិនបរិភោគនូវកុណ្ឌករបស់អ្នក ។

ចប់ កុណ្ឌកកុច្ឆិសិន្ធវជាតក ទី ៤ ។

## សុកជាតក

(៣៦៤) (ព្រះសាស្តា ត្រាស់ថា) សត្វស្លាបសេកនោះ ដឹងប្រមាណក្នុងភោជន ដរាបណា ក៏បានដល់នូវអាយុវែងផង បានចិញ្ចឹមមាតាផង ដរាបនោះ ។

(៣៦៥) មួយទៀត សេកនោះបរិភោគនូវភោជនដ៏ច្រើនលើសលុប ក្នុងកាលណា ក៏លិចចុះក្នុងសមុទ្រនោះឯង ក្នុងកាលនោះ ព្រោះសេកនោះមិនស្គាល់ប្រមាណ ។

(៣៦៦) តស្មា មត្តញ្ញុតា សាធុ ភោជនស្មឹ អគិទ្ធតា
អមត្តញ្ញូ ហិ សីទន្តិ មត្តញ្ញូ ច ន សីទរេតិ ។

សុកជាតកំ បញ្ចមំ ។

## ជរូទបានជាតកំ

(៣៦៧) ជរូទបានំ ខណមានា វាណិជា ឧទកត្ថិកា
អជ្ឈគ្គំសុ[១] អយសំ លោហំ តិបុសីសញ្ច វាណិជា[២]
រជតំ ជាតរូបញ្ច មុត្តា វេឡុរិយា ពហូ ។

(៣៦៨) តេ ច តេន អសន្តុដ្ឋា ភិយ្យោ ភិយ្យោ
ខណឹសុ តេ[៣]
តត្ថាសីវិសោ[៤] ឃោរោ តេជស្សី តេជសា ហនិ ។

(៣៦៩) តស្មា ខណេ នាតិខណេ អតិខាតញ្ហិ បាបកំ
ខាតេន ច ធនំ លទ្ធំ អតិខាតេន នាសិតន្តិ ។

ជរូទបានជាតកំ ឆដ្ឋំ ។

---

១ ម. អជ្ឈគមុំ អយសំ លោហំ ។ ២ ឱ. ម. វាណិជា ។ ៣ ម. អខណិំសុ ។
៤ ម. តត្ថាសីវិសោ ។



(៣៦៦) ព្រោះហេតុនោះ ការដឹងប្រមាណ មិនល្មោភក្នុងភោជន ជាការប្រពៃ ព្រោះពួកជនដែលមិនដឹងប្រមាណ រមែងលិច ពួកជនដែលដឹងប្រមាណ រមែងមិនលិចទេ ។

ចប់ សុកជាតក ទី ៥ ។

## ជរូទបានជាតក

(៣៦៧) (ព្រះសាស្ដា ត្រាស់ថា) ពួកឈ្មួញត្រូវការដោយទឹក កាលជីកអណ្ដូងចាស់ ក៏បាននូវដែកនិងទង់ដែងផង នូវសំណរ កក់ផង នូវកែវមណីទាំងឡាយផង នូវប្រាក់និងមាសផង នូវកែវមុក្តានិងកែវពៃទូរ្យទាំងឡាយផង ដ៏ច្រើន ។

(៣៦៨) តែពួកឈ្មួញទាំងនោះ មិនសន្តោសដោយទ្រព្យនោះ រឹតតែជីកចុះទៅទៀត សត្វមានពិសដ៏ក្លៀវក្លា មានតេជះ ក៏សម្លាប់នូវពួកឈ្មួញទាំងនោះ ដោយតេជះ (នៃពិស) ក្នុងអណ្ដូងទឹកនោះឯង ។

(៣៦៩) ព្រោះហេតុនោះ បុគ្គលគប្បីជីក តែកុំជីកឲ្យជ្រៅហួសពេក ព្រោះការជីកអណ្ដូងជ្រៅហួសពេក ជាការលាមក ទ្រព្យ(ដែលពួកឈ្មួញ) បានហើយដោយការជីក ក៏វិនាសអស់ ព្រោះតែការជីកជ្រៅហួសពេក ។

ចប់ ជរូទបានជាតក ទី ៦ ។

# គាមណិចន្ទជាតកំ

[៣៧០] នាយំ ឃរានំ កុសលោ លោលោ អយំ វលីមុខោ
កតំ កតំ ខោ ទូសេយ្យ ឯវំធម្មមិទំ កុលំ ។

[៣៧១] នយិទំ ចិត្តវតោ លោមំ នាយំ អស្សាសិកោ
មិគោ
សិដ្ឋំ(១) មេ ជនសន្ធេន នាយំ កិញ្ចិ វិជានាតិ ។

[៣៧២] ន មាតរំ បិតរំ វា ភាតរំ ភគិនិំ សកំ
ភរេយ្យ តាទិសោ បោសោ សិដ្ឋំ(២) ទសរថេន មេតិ ។

គាមណិចន្ទជាតកំ សត្តមំ ។

១ ម. សិដ្ឋំ ។ ២ ម. សដ្ឋំ ។



# គាមណិចន្ទជាតក

(៣៧០) (ព្រះរាជកុមារពោធិសត្វ ពោលថា) សត្វនេះជាសត្វមិនឈ្លាស (ក្នុងការធ្វើ) ខ្ទមផ្ទះទាំងឡាយ សត្វនេះជាសត្វទិលខ្ទះ មានមុខជ្រួញ បានតែកាន់ប្រទូស្ត ចំពោះកិច្ចការដែលគេធ្វើហើយៗ ត្រកូលនេះជាធម្មតាយ៉ាងនេះឯង ។

(៣៧១) រោមនេះ មិនមែនជារោមនៃសត្វមានចិត្ត (សម្បយុត្តដោយបញ្ញាជាគ្រឿងពិចារណា) ទេ ម្រឹគនេះមិនគាប់ដោះគួរឲ្យទុកចិត្តបានទេ ក្សត្រិយ៍ព្រះរាជបិតារបស់ខ្ញុំ ទ្រង់ព្រះនាមជនសន្ធៈ (បានត្រាស់ហើយ) ថា សត្វនេះមិនដឹងនូវហេតុតិចតួចឡើយ ។

(៣៧២) បុរសប្រាកដដូច្នោះ មិនគប្បីចិញ្ចឹមនូវមាតាបិតា បងប្អូនប្រុស និងបងប្អូនស្រីរបស់ខ្លួនបានទេ ព្រះបាទទសរថ (ជាព្រះបិតា) បានប្រៀនប្រដៅខ្ញុំ (យ៉ាងនេះ) ។

ចប់ គាមណិចន្ទជាតក ទី ៧ ។

# មន្ធាតុរាជជាតកំ

(៣៧៣) យាវតា ចន្ទិមសុរិយា (បរិហរន្តិ) ទិសា ភន្តិ
វិរោចនា (១)
សព្វេវ ទាសា មន្ធាតុ យេ បាណា បឋវិស្សិតា (២) ។
(៣៧៤) ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ
អប្បស្សាទា ទុខា កាមា ឥតិ វិញ្ញាយ បណ្ឌិតោ ។
(៣៧៥) អបិ ទិព្វេសុ កាមេសុ រតិំ សោ នាធិគច្ឆតិ
តណ្ហក្ខយរតោ ហោតិ សម្មាសម្ពុទ្ធសាវកោ ។

មន្ធាតុរាជជាតកំ អដ្ឋមំ ។

---

១ ឱ. ម. វិរោចមានា ។ ២ ឱ. បឋវិស្សិតា ។



# មន្ធាតុរាជជាតក

(៣៧៣) (ព្រះសាស្តា ត្រាស់ថា) ព្រះចន្ទ្រនិងព្រះអាទិត្យទាំងឡាយ (ដើរក្រឡឹង) ភ្លឺស្វាង ចាំងទិសទាំងឡាយភ្លឺរុងរឿង ហេតុតែមាន កំណត់ត្រឹមណា សត្វទាំងឡាយណា ដែលអាស្រ័យលើ ផែនដី សត្វទាំងអស់នោះ ជាទាសៈរបស់ស្តេចមន្ធាតុ ហេតុ តែមានកំណត់ត្រឹមណោះ ។
(៣៧៤) ការឆ្អែត ក្នុងកាមទាំងឡាយ រមែងមិនមាន ដោយភ្លៀង កហាបណៈ បណ្ឌិតបានដឹងថា កាមទាំងឡាយមានសេចក្តី សុខតិច មានសេចក្តីទុក្ខ (ច្រើន) ។
(៣៧៥) ព្រោះហេតុនោះ សាវ័កនៃព្រះសម្មាសម្ពុទ្ធនោះ មិនបាន ត្រេកអរក្នុងកាមទាំងឡាយសូម្បីជាទិព្វ ជាអ្នកត្រេកអរតែក្នុង ធម៌ ជាគ្រឿងអស់ទៅនៃតណ្ហា ។

ចប់ មន្ធាតុរាជជាតក ទី ៨ ។

# តិរីដវច្ឆជាតកំ

(៣៧៦) ន យិមស្ស វិជ្ជាមយមត្ថិ កិញ្ចិ
ន ពន្ធវេ នោ បន តេ សហាយោ
អថ កេន វណ្ណេន តិរីដវច្ឆោ
តេទណ្ឌិកោ ភុញ្ជតិ អគ្គបិណ្ឌំ ។

(៣៧៧) អាបាសុ មេ យុទ្ធបរាជិតស្ស
ឯកស្ស កត្វា វិវនស្មិំ ឃោរេ
បសារយិ កិច្ឆគតស្ស បាណឹ
តេនុទ្ធតាំ ទុក្ខសម្បរេតោ ។

(៣៧៨) ឯតស្ស កិច្ចេន ឥធានុបត្តោ
វេយ្យាសិតោ(*) វិសយ ជីវលោកេ
លាភារហោ តាត តិរីដវច្ឆោ
ទេថស្ស ភោគំ យជថញ្ច យញ្ញន្តិ ។

តិរីដវច្ឆជាតកំ តតិយំ ។

* ឱ. ម. វេសាយិនោ វិសយា ។





# តិរីដវច្ឆជាតក

(៣៧៦) (ទេវតាទូលសួរព្រះរាជាថា) កម្មកិច្ចនូវដែលសម្រេចដោយវិជ្ជារបស់តាបសនេះ មិនមានឡើយ មួយទៀត តាបសនេះ មិនមែនជាផៅពង្ស ទាំងមិនមែនជាសំឡាញ់ របស់ព្រះអង្គទេ កាលបើយ៉ាងនេះ ហេតុអ្វីបានជាតាបសឈ្មោះតិរីដវច្ឆៈ កាន់ឈើច្រត់មានចំពាម ៣ បរិភោគនូវដុំបាយមានរសដ៏ប្រសើរ ។

(៣៧៧) (ព្រះរាជា ត្រាស់ថា) ក្នុងគ្រាមានអន្តរាយ កាលអញច្បាំងចាញ់គេ (តាបសនេះ) បានធ្វើ (នូវសេចក្ដីអនុគ្រោះ) ដល់អញម្នាក់ឯង ក្នុងព្រៃគួរខ្លាចដ៏ពន្លឹក បានលាតនូវដៃ (ទៅរកអញ) ដែលដល់នូវសេចក្ដីលំបាក (ក្នុងអណ្ដូង) ព្រោះហេតុនោះ អញដែលត្រូវសេចក្ដីទុក្ខគ្របសង្កត់ ទើបបានឡើងរួចមក ។

(៣៧៨) អញ (បានមក) ក្នុងជីវលោក (នេះ ដល់) នូវវិស័យនៃសេចក្ដីស្លាប់ទៅហើយ តែមកក្នុងទីនេះបាន ព្រោះសេចក្ដីលំបាក នៃតាបសនេះ ម្នាលកូន តិរីដវច្ឆតាបស ជាបុគ្គលគួរដល់លាភ អ្នកទាំងឡាយ ចូរឲ្យនូវគ្រឿងបរិភោគផង ចូរបូជានូវវត្ថុដែលគួរបូជាផង ដល់លោក ។

ចប់ តិរីដវច្ឆជាតក ទី ៣ ។

## ទូតជាតកំ

(៣៧៩) យស្សត្ថា ទូរមាយន្តិ អមិត្តម្បិ យាចិតុំ
តស្សូទរស្សហំ ទូតោ មា មេ កុជ្ឈ[១] រថេសភ ។
(៣៨០) យស្ស ទិវា ច រត្តោ ច វសមាយន្តិ មាណវា
តស្សូទរស្សហំ ទូតោ មា មេ កុជ្ឈ រថេសភ ។
(៣៨១) ទទាមិ តេ ព្រាហ្មណ រោហិណីនំ
គវំ សហស្សំ សហ បុង្គវេន
ទូតោ ហិ ទូតស្ស កថំ ន ទជ្ជំ
មយម្បិ តស្សេវ ភវាម ទូតា ។

ទូតជាតកំ ទសមំ ។

សង្កប្បវគ្គោ បឋមោ ។

---
១ ម. កុជ្ឈិ ។



## ទូតជាតក

(៣៧៩) (លោលបុរស ពោលថា) សត្វទាំងឡាយមកកាន់ប្រទេសឆ្ងាយ
ដើម្បីសូមទ្រព្យ អំពីបុគ្គលសូម្បីជាសត្រូវ ដើម្បីប្រយោជន៍
ដល់ផ្ទៃណា ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គ
ប្រសើរក្នុងពលរថ សូមទ្រង់កុំក្រោធនឹងខ្ញុំព្រះអង្គឡើយ ។
(៣៨០) មាណពទាំងឡាយ លុះអំណាចនៃផ្ទៃណា ទាំងថ្ងៃទាំងយប់
ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ
សូមទ្រង់កុំក្រោធនឹងខ្ញុំព្រះអង្គឡើយ ។
(៣៨១) (ព្រះរាជា ទ្រង់ត្រាស់ថា) ម្នាលព្រាហ្មណ៍ យើងឲ្យនូវគោសម្បុរ
ក្រហម ១ ពាន់ ព្រមទាំងគោឧសភ ដល់អ្នក ព្រោះយើងជា
ទូត (របស់ផ្ទៃ) នឹងមិនឲ្យដល់អ្នក ជាទូត (របស់ផ្ទៃដែរ) ដូច
ម្តេចកើត យើងទាំងឡាយ សុទ្ធតែជាទូតរបស់ផ្ទៃដូចគ្នា ។

ចប់ ទូតជាតក ទី ១០ ។

ចប់ សង្កប្បវគ្គ ទី ១ ។

## តល្បុក្ខធំ

ឧស្មុគាររោ តិលមុដ្ឋិ បណ្ណិ
ហាយកជ វិហង្គម អសីតិសោ
ជនសទ្ធ ការហាបណោសេ្យ មុន
តិរីតិ មុន ធ្មការេន ធស ។

---



## ឧបាធនៃសង្ខប្បវត្ថុនោះ គឺ

មិយាយកើតផងសម្របសើរ ១ ល្អមួយគ្នាប់ ១ វែកវេណី ១ ស្តេចសេះ ១ សត្វហើរក្នុងអាកាស ១ ពស់មានពិសធំក្បៀកៀ ១ ស្តេចទ្រង់ព្រះនាមជនសន្ធៈ ១ ក្បៀនកហាបណៈ ១ តាបសឈ្មោះតិរិតវច្ឆៈ ១ ខ្ញុំគរបស់ផ្ទៃ ១ ត្រូវជា ១០ ។

---

# បទុមវគ្គោ

## បទុមជាតកំ

(៣៨២) យថា កេសា ច មស្សូ ច ឆិន្នំ ឆិន្នំ វិរូហតិ
ឯវំ រូហតុ តេ នាសា បទុមំ ទេហិ យាចិតោ ។

(៣៨៣) យថា សារទិកំ ពីជំ ខេត្តេ វុត្តំ វិរូហតិ
ឯវំ រូហតុ តេ នាសា បទុមំ ទេហិ យាចិតោ ។

(៣៨៤) ឧភោបិ វិលបន្តេតេ អបិ បទ្មានិ ទស្សតិ
វជ្ជុំ វា តេ ន វា វជ្ជុំ នត្ថិ នាសាយ រូហនា
ទេហិ សម្ម បទុមានិ បត្ថាមេ ទេហិ យាចិតោ(១) ។

បទុមជាតកំ បឋមំ ។

១ ម. ភន្តេហ៊ីវ៉ា យាចិតា ។ ឱ. អហំ យាចាមិ យាចិតោ ។

# បទុមវគ្គ

## បទុមជាតក

(៣៨២) (សេដ្ឋីបុត្រទី ១ ពោលថា) សក់ក្តី ពុកមាត់ក្តី ដែលគេកោរ កាត់ចោលហើយ តែងដុះឡើងវិញ យ៉ាងណា សូមឲ្យច្រមុះរបស់អ្នកដុះឡើងវិញ យ៉ាងនោះដែរ យើងសូមផ្កាឈូកហើយ អ្នកចូរឲ្យ ។

(៣៨៣) (សេដ្ឋីបុត្រទី ២ ពោលថា) ពូជក្នុងសរទកាល (រដូវរំហើយ) ដែលគេព្រោះក្នុងស្រែ តែងលូតលាស់ យ៉ាងណាមិញ សូមឲ្យច្រមុះរបស់អ្នកដុះឡើងវិញ យ៉ាងនោះដែរ យើងសូមផ្កាឈូកហើយ អ្នកចូរឲ្យ ។

(៣៨៤) (សេដ្ឋីបុត្រគោតិសត្វទី ៣ ពោលថា) ជនទាំងពីរនាក់នេះ និយាយកុហក ដោយគិតថា ធ្វើដូចម្ដេចហ្ន៎ (បុរសនេះ) នឹងឲ្យផ្កាឈូកទាំងឡាយខ្លះ តែជនទាំងពីរនាក់នោះ ពោលក្ដី មិនពោលក្ដី ការដុះឡើងនៃច្រមុះគ្មានទេ ម្នាលសំឡាញ់ សូមអ្នកឲ្យផ្កាឈូកទាំងឡាយ យើងសូមហើយ សូមអ្នកឲ្យផ្កាឈូកទាំងឡាយ ។

ចប់ បទុមជាតក ទី ១ ។

# មុទុបាណិជាតកំ

(៣៨៤) បាណិ ចេ មុទុកោ ចស្ស នាគោ ចស្ស សុការិតោ
អន្ធការោ ច វស្សេយ្យ អថ នូន តទា សិយា ។

(៣៨៥) អនលា មុទុសម្ភាសា ទុប្បូរា[១] តា នទីសមា
សីទន្តិ នំ វិទិត្វាន អារកា បរិវជ្ជយេ ។

(៣៨៦) យំ ឯតា ឧបសេវន្តិ ឆន្ទសា វា ធនេន វា
ជាតវេទោវ សំ ឋានំ ខិប្បំ អនុទហន្តិ នំ ។

មុទុបាណិជាតកំ តតិយំ ។

១ ឧ. ទុប្បូរា ។



# មុទុបាណិជាតក

(៣៨៤) (ព្រះរាជធីតា ពោលថា) បើ ដូចប្រធ្នាក មានដៃទន់ ១ ដំរី ដែលព្រះអង្គបង្ហាត់ល្អហើយ ១ ពេលងងឹតសូន្យឈឹង ១ ភ្លៀងបង្អុរចុះ ១ គប្បីមានក្នុងកាលណា សេចក្តីប៉ងក្នុងព្រះរាជហឫទ័យរបស់ព្រះអង្គ គង់នឹងសម្រេច ក្នុងកាលនោះមិនខាន ។

(៣៨៥) (ព្រះរាជាពោធិសត្វជាបិតា ពោលថា) ស្រីទាំងឡាយនោះ បុគ្គលមិនគួរនិយាយដោយពាក្យទន់ភ្លន់ឡើយ ជាស្រីដែលបំពេញបានដោយក្រ ប្រាកដស្មើដោយស្ទឹង រមែងលិចចុះ (ក្នុងអបាយ ៤) បណ្ឌិតបុរសដឹងច្បាស់ហើយ គួរគេចចេញអំពីចម្ងាយ ។

(៣៨៦) ស្រីទាំងនុ៎ះ ចូលទៅគប់រកបុរសណា ដោយសេចក្តីពេញចិត្តក្តី ដោយទ្រព្យក្តី តែងដុតបំផ្លាញបុរសនោះ (ឲ្យវិនាស) យ៉ាងឆាប់ ដូចភ្លើង (ដែលឆេះ) នូវទីនៅរបស់ខ្លួន ។

ចប់ មុទុបាណិជាតក ទី ២ ។

## ចុល្លបលោភនជាតកំ

(៣៨៨) អភិជ្ជមានេ វារិស្មឹ សយំ អាគម្ម ឥទ្ធិយា

មិស្សីភាវិត្ថិយា គន្ត្វា សំសីទសិ មហណ្ណវេ ។

(៣៨៩) អាវដ្ដនី មហាមាយា ព្រហ្មចរិយវិកោបនា

សីទន្តិ នំ វិទិត្វាន អារកា បរិវជ្ជយេ ។

(៣៩០) យំ ឯតា ឧបសេវន្តិ ឆន្ទសា វា ធនេន វា

ជាតវេទោវ សំ ឋានំ ខិប្បំ អនុទហន្តិ នំ ។

ចុល្លបលោភនជាតកំ តតិយំ ។

## មហាបនាទជាតកំ

(៣៩១) បនាទោ នាម សោ រាជា យស្ស យូបោ សុវណ្ណយោ

តិរិយំ សោឡសុព្វេធោ ឧទ្ធមាហុ[១] សហស្សធា ។

១ ម. ឧច្ចមាហុ ។



## ចុល្លបលោភនជាតក

(៣៨៨) (ព្រះពោធិសត្វពោលថា) លោកមក (តាមអាកាស) ដោយខ្លួនឯង លើទឹកមិនបែកស្រែក ដោយអំណាចនៃឫទ្ធិ លុះទៅប្រឡូកប្រឡំដោយស្រី ក៏លិចចុះក្នុងសមុទ្រធំ ។

(៣៨៩) ពួកស្រីទាំងឡាយ រមែងញ៉ាំងបុរសឲ្យវិលវល់ មានមាយាច្រើន ញ៉ាំងព្រហ្មចរិយធម៌ឲ្យកំរើក រមែងលិចចុះ (ក្នុងអបាយ៤) បណ្ឌិតបុរស ដឹងច្បាស់ហើយ គប្បីវៀរចេញ អំពីចម្ងាយ ។

(៣៩០) ស្រីទាំងឡាយនុ៎ះ ចូលទៅគប់រកបុរសណា ដោយសេចក្ដីពេញចិត្តក្ដី ដោយទ្រព្យក្ដី រមែងដុតបំផ្លាញបុរសនោះ (ឲ្យវិនាស) យ៉ាងឆាប់ ដូចភ្លើង (ដែលឆេះ) ទីលំនៅរបស់ខ្លួន ។

ចប់ ចុល្លបលោភនជាតក ទី ៣ ។

## មហាបនាទជាតក

(៣៩១) (ព្រះសាស្ដាត្រាស់ថា) ព្រះរាជាឈ្មោះនោះទ្រង់ព្រះនាមបនាទៈ មានប្រាសាទមាស មានទទឹងប្រវែងនៃការធ្លាក់ចុះនៃកូនសរ ១៦ (គន្លះយោជន៍) (អ្នកប្រាជ្ញទាំងឡាយ) ពោលថា ប្រាសាទនោះកំពស់ ១ ពាន់ត្រឹមណៃកូនសរ (៦៨យោជន៍) ។

(៣៩២) សហស្សកណ្ឌោ សតគេណ្ឌុ ធជាលុ ហរិតា-
មយោ
អនច្ចុំ តត្ថ គន្ធព្វា ឆ សហស្សានិ សត្តធា ។
(៣៩៣) ឯវមេតំ តទា អាសិ យថា ភាសសិ ភទ្ទជិ
សក្កោ អហំ តទា អាសឹ វេយ្យាវច្ចករោ តវំ ។

មហាបនាទជាតកំ ចតុត្ថំ ។

## ខុរប្បជាតកំ

(៣៩៤) ទិស្វា ខុរប្បេ ធនុវេគនុន្នេ
ខគ្គេ គហីតេ តិខិណេ តេលធោតេ
តស្មឹ ភយស្មឹ មរណេ វិយូឡ្ហេ
កស្មា នុ តេ នាហុ ឆម្ភិតត្តំ ។



(៣៩២) ប្រាសាទនោះ កំពស់ ១ ពាន់កំណល់នៃធ្នូសរ មានដាំទង់ព្រំពីរ
បរិបូណ៌ដោយទង់ ព័ន្ធព័ទ្ធហើយដោយកែវមណីមានពណ៌ខៀវ
ពួកទេព ៦០០០ ចែកជាប្រាំពីរចំណែក បានរាំលើប្រាសាទ
នោះ (គ្រប់ ១ ថ្នាក់) ។
(៣៩៣) ម្នាលភទ្ទជិ អ្នកពោលហើយយ៉ាងណា ប្រាសាទនោះមាន
ហើយ ក្នុងកាលនោះ យ៉ាងនោះ តថាគតកើតជាព្រះឥន្ទ្រ
ជាវេយ្យាវច្ចករ របស់អ្នក ។

ចប់ មហាបនាទជាតក ទី ៤ ។

## ខុរប្បជាតក

(៣៩៤) (កូនរបស់ឈ្មួញពេទរ ពោលថា) អ្នកឃើញនូវព្រួញដែលពួក
ចោរបាញ់ហើយដោយកម្លាំងនៃធ្នូផង នូវព្រះខាន់សំលៀង
ដោយប្រេងដ៏មុត ដែលពួកចោរកាន់ហើយផង កាលសេចក្តី
ស្លាប់ដែលរៀបទុកនោះ មកដល់នៅចំពោះមុខហើយ ហេតុ
អ្វីក៏អ្នកមិនមានសេចក្តីតក់ស្លុតសោះ ។

(៣៩៤) ទិស្វា ខុរប្បំ ធនុវេគនុន្នំ
ខគ្គេ ឋិតំ តិខិណំ តេលធោតំ
តស្មិំ ភយស្មិំ មរណេ វិយូឡ្ហេ
វេទំ អលត្ថំ វិបុលំ ឧឡារំ ។

(៣៩៥) សោ វេទជាតោ អជ្ឈភវិំ អមិត្តេ
បុព្វេវ មេ ជីវិតមាសិ ចត្តំ
ន ហិ ជីវិតេ អាលយំ កុព្វមានោ
សូរោ កយិរា សូរកិច្ចំ កទាចិ ។

ខុរប្បជាតកំ បឋមំ ។

## វាតគ្គសិន្ធវជាតកំ

(៣៩៧) យេនាសិ កិសិយា បណ្ឌុ យេន ភត្តំ ន រុច្ចតិ
អយំ សោ អាគតោ ភត្តា(១) កស្មា ទានិ បលាយសិ ។

(៣៩៨) ធុចេ(២) បនាទិកេនេវ សន្ថវោ នាម ជាយតិ
យសោ ហាយតិ ឥត្ថីនំ តស្មា តាត បលាយិហំ(៣) ។

១ ឱ. តត ។ ម. ភត្តា ។ ២ ម. សចេ ។ ឱ. ធេ ។ ៣ ម. បលាយតិ ។



(៣៩៤) (ពោធិសត្វ ជាមេអ្នកក្បួនដែនព្រៃ ពោលថា) ខ្ញុំឃើញ ខ្ញុំព្រួញដែលបាញ់ហើយ ដោយកំឡាំងនៃធ្នូ ខ្ញុំព្រះខាន់រលៀន ដោយប្រេងដ៏មុត ដែលពួកចោរកាន់ហើយ កាលសេចក្ដីស្លាប់ដែលគួរខ្លាចនោះ ចូលមកជិតនៅចំពោះមុខ ខ្ញុំក៏ត្រឡប់បានសេចក្ដីត្រេកអរច្រើន ដ៏លើសលុប ។

(៣៩៥) ខ្ញុំនោះមានសេចក្ដីត្រេកអរ បានគ្របសង្កត់នូវពួកសត្រូវ (ព្រោះថា) ខ្ញុំបានលះបង់ជីវិតមុនហើយ ព្រោះថា បុគ្គលក្លាហាន កាលធ្វើសេចក្ដីអាល័យក្នុងជីវិត គប្បីធ្វើនូវកិច្ចរបស់អ្នកក្លាហាន ក្នុងកាលណា ៗ មិនបានទេ ។

ចប់ ខុរប្បជាតក ទី ១ ។

## វាតគ្គសិន្ធវជាតក

(៣៩៧) (កុលលា ពោលថា) អ្នកម្ដាយកើតរោគស្គមស្លៀក ព្រោះតែប្ដីណា មិនពេញចិត្តនឹងភត្ត ព្រោះតែប្ដីណា ប្ដីនោះមកដល់ហើយ ឥឡូវនេះ ហេតុអ្វីបានជាអ្នកម្ដាយរត់ចេញទៅ ។

(៣៩៨) (មេលា ពោលថា) ម្នាលកូន ម្ដាយយល់ថា ធម្មតាសន្ថវៈ (របស់ស្ត្រី) កើតដោយហេតុពីដំបូង (ក្រម) យសរបស់ស្ត្រីទាំងឡាយក៏សាបសូន្យ ហេតុនោះបានជាអញរត់ចេញ ។

(៣៩៩) យស្ស ស្សុ ជិណ្ណកុលេ ជាតំ អាគតំ(១) យត្ថ ខ វត្តតិ

សោចតិ ចិរតាយ កតត្តុម្ពំ កច្ឆគតំ(២) ។

តុណ្ឌិលជាតកំ ឆដ្ឋំ ។

## សុវណ្ណកក្កដកជាតកំ

(៤០០) សិង្គី មិគោ អាយតចក្ខុនេត្តោ

អដ្ឋិត្តចោ វារិសយោ អលោមោ

តេនាភិភូតោ កបណំ រុទាមិ

មា ហេវ មំ បាណសមំ ជហេយ្យ ។

(៤០១) អយ្យ ន តំ ជហិស្សាមិ កុញ្ជរំ សដ្ឋិហាយនំ

បថព្យា ចាតុរន្តាយ សុប្បិយោ ហោសិ មេ តុវំ ។

(៤០២) យេ កុឡីរា សមុទ្ទស្មឹ គង្គាយ យមុនាយ ច

តេសំ ត្វំ វារិជោ សេដ្ឋោ មុញ្ច រោទន្តិយា បតិំ ។

សុវណ្ណកក្កដកជាតកំ សត្តមំ(៣) ។

១ ឱ. ម. អាគតំ ។ ២ ឱ. គុត្តលិ ។ ម. កុត្តលំ ។ ៣ ម. កុឡីរជាតកំ ។



(៣៩៩) (ព្រះសាស្តា ទ្រង់ត្រាស់ថា) ស្ត្រីណាមិនប្រាថ្នានូវបុរសមាន យសកើតក្នុងត្រកូល ដែលគេនាំមកឲ្យ ស្ត្រីនោះ រមែងសោក សៅអស់កាលយូរនៅខ្ទឹម ដូចជាមេណា (ដែលយំសោកស្តាយ) សេះសេនគណ្ឌកៈ ។

ចប់ តុណ្ឌិលជាតក ទី ៦ ។

## សុវណ្ណកក្កដកជាតក

(៤០០) (ដំរីពោធិសត្វ ពោលថា) ក្រញ៉ាំមានសម្បុរដូចមាស (ក្តាម) ជាសត្វមានភ្នែកលៀនចេញ មានឆ្អឹងជាស្បែក ជាសត្វនៅក្នុងទឹក មិនមានរោម យើងត្រូវក្តាមនោះគៀបហើយ ទើបកំសត់ខ្ញុំយំ សូមកុំលះបង់ខ្ញុំ ដែលស្មើដោយជីវិតឡើយ ។

(៤០១) (មេដំរីពោលថា) បតិ អ្នកជាម្ចាស់ ខ្ញុំមិនលះបង់អ្នកដែលជាដំរីថម ថយកំឡាំងក្នុងកាលនៃខ្លួនមានអាយុ ៦០ ឆ្នាំឡើយ ខ្ញុំស្រឡាញ់ អ្នកក្រៃលែងជាងប្រថពី ដែលវល់ទីងសមុទ្រទាំង ៤ ទៅទៀត ។

(៤០២) (មេដំរីពោលថា) ពួកក្តាមណា ដែលនៅក្នុងសមុទ្រក្តី ក្នុងទន្លេគង្គាក្តី យមុនាក្តី អ្នកជាសត្វទឹកប្រសើរ ជាងក្តាមទាំងនោះ សូមអ្នកមេត្តាលែងប្តី កាលដែលខ្ញុំកំពុងតែយំរកក្តី សូមអ្នកមេត្តាលែងប្តី (របស់ខ្ញុំ) មកវិញ ក្នុងកាលឥឡូវនេះ ។

ចប់ សុវណ្ណកក្កដកជាតក ទី ៧ ។

# អារាមទូសកជាតកំ

(៤០៣) យោ មេ សព្វសមេតានំ(១) អហុវា សេដ្ឋសម្មតោ
តស្សាយំ ឯទិសី បញ្ញា កិមេវ ឥតរា បជា ។

(៤០៤) ឯវមេវ តុវំ ព្រហ្មេ អនញ្ញាយ វិនិន្ទសិ
កថំ ហិ មូលំ អទិស្វា រុក្ខំ ជញ្ញា បតិដ្ឋិតំ ។

(៤០៥) នាហំ តុម្ហេ វិនិន្ទាមិ យេ(២) ចេត្ថ វានរា វនេ
វិស្សសេនោ ច គារយ្ហោ យស្សត្ថា រុក្ខរោបកា ។

អារាមទូសកជាតកំ និដ្ឋិតំ ។

---

១ ម. យោ វេ សព្វសមេតានំ ។ ២ ម. ឱ. យេ ចញ្ញេ ។



# អារាមទូសកជាតក

(៤០៣) (បុរសពោធិសត្វ ពោលថា) ស្វាណា ដែលគេសន្មតថាជាសត្វប្រសើរបំផុតជាងពួកស្វា ដែលមានជាតិស្មើគ្នានេះ ប្រាជ្ញារបស់ស្វានោះ មានតែត្រឹមប៉ុណ្ណេះ ពួកសត្វ (ស្វា) ក្រៅនេះ នឹងមានប្រាជ្ញា ដូចម្តេចទៅ ។

(៤០៤) (ហ្វូងស្វា ពោលថា) បពិត្រអ្នកដ៏ប្រសើរ លោកតិះដៀលយ៉ាងនេះ ព្រោះតែមិនដឹង បុគ្គលមិនឃើញឫស ហើយគប្បីដឹងនូវដើមឈើដែលតាំងនៅស៊ប់ ដូចម្តេចកើត ។

(៤០៥) (ពោធិសត្វ ពោលថា) យើងមិនតិះដៀលពួកអ្នក ដែលជាពានរ អាស្រ័យនៅក្នុងព្រៃនេះទេ តែថាពួកជនអ្នកដាំដើមឈើ ដើម្បីប្រយោជន៍ ដល់ស្តេចវិស្សសេនណា ស្តេចវិស្សសេននោះ គួរគេតិះដៀលបាន ។

ចប់ អារាមទូសកជាតក ទី ៦ ។

## សុជាតាជាតកំ

(៦០៦) នហិ វណ្ណេន សម្បន្នា មញ្ជុកា បិយទស្សនា
ខរវាចា បិយា ហោតិ អស្មឹ លោកេ បរម្ហិ ច ។

(៦០៧) ននុ បស្សសិមំ កាឡឹ ទុព្វណ្ណំ តិលកាហតំ
កោកិលំ សណ្ហភាណេន ពហូនំ បាណិនំ បិយំ ។

(៦០៨) តស្មា សខិលវាចស្ស មន្តភាណី អនុទ្ធតោ
អត្ថំ ធម្មញ្ច ទីបេតិ មធុរំ តស្ស ភាសិតំ ។

សុជាតាជាតកំ នវមំ ។

## ឧលូកជាតកំ

(៦០៩) សព្វេហិ កិរ ញាតីហិ កោសិយោ ឥស្សរោ កតោ
សចេ ញាតីហិ អនុញ្ញាតោ ភណេយ្យាហំ ឯកវាចិកំ ។



## សុជាតាជាតក

(៦០៦) (ព្រះពោធិសត្វ ត្រាស់ថា) ពួកជនប្រកបដោយសម្បុរ មានសំឡេងពីរោះ មានរូបជាទីស្រឡាញ់ គួររមិលមើល តែជាអ្នកមានវាចារឹងរូស មិនជាទីស្រឡាញ់របស់អ្នកដទៃ ក្នុងលោកនេះ និងលោកខាងមុខទេ ។

(៦០៧) ព្រះមាតា ឃើញមេកាអែខ្មៅនេះ ដែលមានសម្បុរអាក្រក់ ដេរដាសដោយពណ៌ព្រះអុច ១ តែជាទីស្រឡាញ់ របស់សត្វច្រើន ដោយសារវាចាពីរោះទេ ។

(៦០៨) ព្រោះហេតុនោះ បុគ្គល គប្បីជាអ្នកមានវាចាល្អិតល្អ ជាអ្នកពោលពាក្យពិតតាមប្រាជ្ញា មិនមានចិត្តរាយមាយ រមែងសំដែងនូវអត្ថនិងធម៌ ភាសិតរបស់បុគ្គលនោះ ទើបឈ្មោះថាពីរោះ ។

ចប់ សុជាតាជាតក ទី ៩ ។

## ឧលូកជាតក

(៦០៩) (ក្អែក ពោលថា) ឮថាពួកញាតិទាំងអស់ បានលើកកោសិយៈ (មៀម) ឲ្យធ្វើជាធំ ប្រសិនបើពួកញាតិ អនុញ្ញាតខ្ញុំសូម និយាយនូវពាក្យ ១ ម៉ាត់ ។

(៤១០) ភណ សម្ម អនុញ្ញាតោ អត្ថំ ធម្មញ្ច កេវលំ
សន្តិ ហិ ទហរា បក្ខី បញ្ញវន្តោ ជុតិន្ធរា ។

(៤១១) ន មេ រុច្ចតិ ភទ្ទំ វោ ឧលូកស្សាភិសេចនំ
អក្កុទ្ធស្ស មុខំ បស្ស កថំ កុទ្ធោ ករិស្សតិ ។

ឧលូកជាតកំ ទសមំ ។

បទុមវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

បទុមុត្តម នាគសិរីវ្ហយនោ
សមហណ្ណវ យុទ្ធ ជយេន បុន
អថ កន្ទលី កុញ្ជរ រុក្ខ បុន
វរកោច ឧលូកវរេន ទស ។

---



(៤១០) (ហ្វូងសត្វស្លាប ពោលថា) ម្នាលសំឡាញ់ យើងអនុញ្ញាតហើយ អ្នកចូរនិយាយនូវហេតុ និងពាក្យដែលជាប់ទាក់ទងដោយបវេណីប៉ុណ្ណោះ ព្រោះពួកបក្សីក្មេងៗ ដែលមានប្រាជ្ញា ទ្រទ្រង់នូវសេចក្តីរុងរឿងនៅមាន ។

(៤១១) (ក្អែក ពោលថា) សូមឲ្យអ្នកទាំងឡាយ មានសេចក្តីចំរើន ការដែលអភិសេកមៀម មិនពេញចិត្តខ្ញុំទេ អ្នកទាំងឡាយ ចូរមើលមុខមៀម ដែលមិនទាន់ខឹង (ដែលបានខះទាំហើយ) ចំណាន់បើខឹងហើយ តើវាធ្វើមុខ ដូចម្តេចទៅ ។

ចប់ ឧលូកជាតក ទី១០ ។

ចប់ បទុមវគ្គ ទី ២ ។

## ឧទ្ទាននៃបទុមវគ្គនោះគឺ

និយាយអំពីផ្កាឈូកដ៏ឧត្តម ១ ដំរីមានសិរី ១ សមុទ្រធំ ១ ប្រាសាទ ១ ព្រួញដ៏ប្រសើរ ១ សាញ៉ីឈ្មោះកន្ទលី ១ ដំរី ១ ដើមឈើ ១ កចារីដ៏រូស ១ ស្តេចមៀម ១ ត្រូវជា១០ ។

---

## ឧទបានទូសកជាតកំ

(៦១២) អារញ្ញកស្ស ឥសិនោ ចិរំ រត្តំ តបស្សិនោ
កិច្ឆាកតំ ឧទបានំ កថំ សម្ម អវាហសិ[១] ។

(៦១៣) ឯស ធម្មោ សិង្គាលានំ យំ បិត្វា ឱហទាមសេ
បិតុបិតាមហំ ធម្មោ ន តំ ឧជ្ឈាតុមរហសិ ។

(៦១៤) យេសំ វោ ឯទិសោ ធម្មោ អធម្មោ បន កីទិសោ
មា វោ ធម្មំ អធម្មំ វា អទ្ទសាម កុទាចនំ ។

ឧទបានទូសកជាតកំ បឋមំ ។

## ព្យគ្ឃជាតកំ

(៦១៥) យេន មិត្តេន សំសគ្គា យោគក្ខេមោ វិហីយតិ
បុព្វេវជ្ឈាភវំ តស្ស រក្ខេ អក្ខីវ បណ្ឌិតោ ។

១ ម. ឧ. អវហសិ ។



## ឧទបានទូសកជាតក

(៦១២) (ឥសីពោធិសត្វ សួរថា) ម្នាលសំឡាញ់ ហេតុអ្វីបានជាអ្នកប្រទូស្តអណ្តូងទឹក ដែលបុគ្គលធ្វើបានដោយក្រ របស់ឥសីអ្នកនៅក្នុងព្រៃ ប្រព្រឹត្តតបធម៌ អស់រាត្រី ដ៏យូរ ។

(៦១៣) (ចចក ពោលថា) ពួកយើងផឹកទឹកក្នុងទីណា ហើយជុះនោមបង្ហូរ (ទីនោះ) នេះជាធម្មតារបស់ចចកទាំងឡាយ នេះជាធម្មតារបស់បិតានិងជីតា អ្នកមិនគួរពោលទោស ចំពោះធម្មតានោះ ។

(៦១៤) (ពោធិសត្វ ពោលថា) អាការនេះជាធម្មតា របស់ពួកអ្នកណា ចំណង់បើអាការមិនមែនជាធម្មតា នឹងប្រាកដដូចម្តេចទៅ យើងសូមកុំឲ្យជួបប្រទះនឹងអាការជាធម្មតា ឬ មិនមែនជាធម្មតារបស់ពួកនោះ ក្នុងកាលណាឡើយ ។

ចប់ ឧទបានទូសកជាតក ទី ១ ។

## ព្យគ្ឃជាតក

(៦១៥) (រុក្ខទេវតាពោធិសត្វ ពោលថា) សេចក្តីក្សេមចាកយោគៈ គឺសេចក្តីសុខកាយ សុខចិត្ត រមែងសាបសូន្យទៅ ព្រោះប្រឡូកប្រឡំដោយបាបមិត្តណា បណ្ឌិតគប្បីញ៉ាំញីនូវបាបមិត្តនោះជាមុន ហើយគប្បីរក្សា (ខ្លួន) ដូចបុគ្គលកាលរក្សានូវភ្នែកដូច្នោះ ។

(៤១៦) យេន មិត្តេន សំសគ្គា យោគក្ខេមោ បវឌ្ឍតិ
ករេយ្យត្តសមំ វុត្តិំ សព្វកិច្ចេសុ បណ្ឌិតោ ។

(៤១៧) ឯថ ព្យគ្ឃា និវត្តវ្ហោ បច្ចុបេថ មហាវនំ
មា វនំ ឆិន្ទិ និព្យគ្ឃំ ព្យគ្ឃា មាហេសុ និព្វនាតិ ។

ព្យគ្ឃជាតកំ ទុតិយំ ។

## កច្ឆបជាតកំ

(៤១៨) កោ នុ ឧទ្ធិតភត្តោវ បូរហត្ថោវ ព្រាហ្មណោ
កហំ នុ ភិក្ខំ អចរិ កំ សទ្ធំ ឧបសង្កមិ ។

(៤១៩) អហំ កបិស្មិ ទុម្មេធោ អនាមាសានិ អាមសិំ
ត្វំ មំ មោចយ ភទ្ទន្តេ មុត្តោ គច្ឆេយ្យ បព្វតំ ។



(៤១៦) សេចក្តីក្សេមចាកយោគៈ រមែងចំរើនឡើង ព្រោះច្របូកច្របល់ [illegible] នឹងមិត្តណា បណ្ឌិតគប្បីធ្វើ នូវការប្រព្រឹត្តក្នុងកិច្ចទាំងពួងឲ្យស្មើនឹងខ្លួន ។

(៤១៧) (ទេវតាកាល ពោលថា) នែខ្លានឹងសីហៈ អ្នកទាំងឡាយ ចូរមក ចូរត្រឡប់ទៅកាន់ព្រៃធំវិញចុះ កុំឲ្យមហាជនកាប់ព្រៃរបស់យើង ព្រោះតែព្រៃមិនមានខ្លា កុំឲ្យខ្លានឹងសីហៈ ជាសត្វមិនមានព្រៃឡើយ ។

ចប់ ព្យគ្ឃជាតក ទី ២ ។

## កច្ឆបជាតក

(៤១៨) (កច្ឆបពោធិសត្វ ពោលថា) បុគ្គលណាហ្ន៎ ដើរមក ហាក់ដូចជាបុគ្គលអ្នកមានភត្ត ដួសស្រេចហើយ ឬដូចជាព្រាហ្មណ៍ មានលាភពេញដៃ អ្នកដើរទៅសូមភិក្ខាណា ឬអ្នកចូលទៅរកបុគ្គលណា ដែលមានសទ្ធា ។

(៤១៩) (ពានរ ពោលថា) ខ្ញុំជាស្វាឥតប្រាជ្ញា បានចាប់ពាល់នូវវត្ថុទាំងឡាយដែលគេមិនគួរចាប់ពាល់ សូមលោកម្ចាស់ដោះខ្ញុំឲ្យរួច សូមសេចក្តីចំរើន ចូរមានដល់លោក ខ្ញុំនោះបានរួចហើយ នឹងទៅកាន់ភ្នំវិញ ។

(៦៦០) កុញ្ជរា កស្សបា ហោន្តិ កោណ្ឌញ្ញា ហោន្តិ មក្កដា ។ មុញ្ច កស្សប កោណ្ឌញ្ញំ កតំ មេថុនកំ តយា ។

កច្ឆបជាតកំ តតិយំ ។

## លោលជាតកំ

(៦៦១) កាយំ ពលាកា សិខិនី ចោរី លង្ឃិបិតាមហា ឱរំ ពលាកេ អាគច្ឆ ចណ្ឌោ មេ វាយសោ សខា ។

(៦៦២) នាហំ ពលាកា សិខិនី អហំ លោលស្មិ វាយសោ អកត្វា វចនំ តុយ្ហំ បស្ស លូនោស្មិ អាគតោ ។

(៦៦៣) បុន បាបជ្ជសី សម្ម សីលំ ហិ តវ តាទិសំ ន ហិ មានុសកា ភោគា សុភុញ្ជា ហោន្តិ បក្ខិនា ។

លោលជាតកំ ចតុត្ថំ ។



(៦៦០) (ពោធិសត្វ ពោលថា) ពួកអណ្តើក ជាកស្សបគោត្ត ពួកស្វា ជាកោណ្ឌញ្ញគោត្ត ម្នាលកស្សប អ្នកចូរលែងកោណ្ឌញ្ញ (ស្វាទ្រុស្តសីលនេះ) ដែលធ្វើមេថុនកម្មនឹងអ្នក ។

ចប់ កច្ឆបជាតក ទី ៣ ។

## លោលជាតក

(៦៦១) (ព្រះពោធិសត្វ ពោលថា) កុកនេះដូចម្តេច មានសិរជាសត្វលួច មានពពក ជាជីតា នៃកុក អ្នកចូលមកអាយ (ព្រោះ) ក្អែកជាសំឡាញ់យើងជាសត្វកាច ។

(៦៦២) (ក្អែក ពោលថា) ខ្ញុំមិនមែនជាកុកមានសិរទេ ខ្ញុំជាក្អែកលោលំ អ្នកមើលចុះនែមក ចូរមើលខ្ញុំដែលត្រូវគេដកស្លាប ព្រោះតែមិនធ្វើតាមពាក្យរបស់អ្នក ។

(៦៦៣) (ពោធិសត្វ ពោលថា) ម្នាលសំឡាញ់ អ្នកនឹងប្រែ (បែបនេះ) ម្តងទៀតក៏បាន ព្រោះថាសីល (មារយាទ) របស់អ្នកប្រាកដដូច្នោះ គ្រឿងបរិភោគទាំងឡាយជារបស់នៃមនុស្ស មិនមែនសត្វស្លាបបរិភោគបាន ដោយងាយឡើយ ។

ចប់ លោលជាតក ទី ៤ ។

# រុចិរជាតកំ

(៤២៤) កាយំ ពលាកា រុចិរា កាកនីឡស្មិំ មច្ឆតិ[១]
ចណ្ឌោ កាកោ សខា មយ្ហំ យស្ស ចេតំ
កុលាវកំ ។

(៤២៥) ននុ មំ សម្ម ជានាសិ ទិជ សាមាកភោជនំ
អកត្វា វចនំ តុយ្ហំ បស្ស លូនោស្មិ អាគតោ ។

(៤២៦) បុន បាបជ្ជសី សម្ម សីលំ ហិ តវ តាទិសំ
ន ហិ មានុសកា ភោគា សុភុញ្ជា ហោន្តិ បក្ខិនា ។

រុចិរជាតកំ បញ្ចមំ ។

១ ម. ឆ. កាកនីឡស្មិមច្ឆតិ ។



# រុចិរជាតក

(៤២៤) (ពោធិសត្វ ពោលថា) កុកនេះជាអ្វី មានសម្បុរល្អើប មកនៅ
ក្នុងសំបុកក្អែក សំបុកនេះជារបស់ក្អែកណា ក្អែកជាសំឡាញ់
របស់ខ្ញុំនោះ កាចណាស់ ។

(៤២៥) (ក្អែក ពោលថា) ម្នាលសំឡាញ់ស្មើចិត្ត ជាសត្វមានកំណើត
ពីរ ក្រែងអ្នកស្គាល់ខ្ញុំដែលជាសត្វ មានពូជស្មៅជាភោជនដែរឬ
អ្នកទើបនឹងមក ចូរមើលខ្ញុំដែលគេដកស្លាប ព្រោះតែមិនធ្វើ
តាមពាក្យរបស់អ្នក ។

(៤២៦) (ពោធិសត្វ ពោលថា) ម្នាលសំឡាញ់ អ្នកនឹងប្រទះ (បែបនេះ)
មួយទៀតពុំខាន ព្រោះថាសីលធម៌ របស់អ្នកប្រាកដដូច្នោះ
គ្រឿងបរិភោគទាំងឡាយ ជារបស់មនុស្ស មិនមែនសត្វស្លាប
បរិភោគបាន ដោយងាយទេ ។

ចប់ រុចិរជាតក ទី ៥ ។

# កុរុធម្មជាតកំ(១)

(៤២៧) តវ សទ្ធញ្ច សីលញ្ច វិទិត្វាន ជនាធិប

វណ្ណំ អញ្ជនវណ្ណេន កាលិង្គស្មឹ និមិម្ហសេ ។

(៤២៨) អន្នភច្ចា ច ភច្ចា ច យោធ ឧទ្ទិស្ស គច្ឆតិ

សព្វេតេ អប្បដិក្ខិប្បា បុព្វាចរិយវចោ ឥទំ ។

(៤២៩) ទទាម វោ ព្រាហ្មណា នាគមេតំ

រាជារហំ រាជភោគ្គំ យសស្សិនំ

អលង្កតំ ហេមជាលាភិច្ឆន្នំ

សសារថឹ គច្ឆថ យេនកាមំ ។

កុរុធម្មជាតកំ ឆដ្ឋំ ។

១ ម. កុរុធម្មជាតកំ ។



# កុរុធម្មជាតក

(៤២៧) (ពួកព្រាហ្មណ៍ ក្រាបទូលថា) បពិត្រព្រះជនាធិបតី យើងទាំងឡាយ ដឹងច្បាស់នូវសទ្ធានឹងសីល របស់ព្រះអង្គ ហើយនឹងទទួលយកនូវដំរីមានសម្បុរប្រាកដស្មើ ដោយផ្កាអញ្ចន់ ទៅក្នុងលំណាក់នៃព្រះបាទកាលិង្គៈ ។

(៤២៨) (ព្រះរាជាត្រាស់តបថា) ពួកសត្វដែលយើងចិញ្ចឹមដោយបាយក្តី មិនចិញ្ចឹមក្តី សត្វណាក្តីដែលរកលាភនេះ ដើរមកសុំនៅយើង ពួកសត្វទាំងអស់នោះ យើងមិនបានឃាត់ឡើយ នេះជាពាក្យរបស់បុព្វាចារ្យ (មាតាបិតារបស់យើង) ។

(៤២៩) ម្នាលព្រាហ្មណ៍ទាំងឡាយ យើងឲ្យដំរីប្រសើរនេះ ដែលសមគួរដល់ព្រះរាជា ជាដំរីរបស់ព្រះរាជា មានយស ប្រដាប់តាក់តែងហើយ បំពាក់ហើយដោយបណ្តាញមាស ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ព្រមទាំងសារថី (ហ្មត់) ទៅតាមប្រាថ្នាចុះ ។

ចប់ កុរុធម្មជាតក ទី ៦ ។

# រោមជាតកំ

(៤៣០) វស្សានិ បញ្ញាស សមាធិកានិ
វសិម្ហ សេលស្ស គុហាយ រោមក
អសង្កមានា អភិនិព្វុតចិត្តា
ហត្ថត្ថមាយន្តិ មមណ្ឌជា បុរេ ។

(៤៣១) តេទានិ វក្កង្គ កិមត្ថមុស្សុក្កា
ភជន្តិ អញ្ញំ គិរិកន្ទរំ ទិជា
នូន ន មញ្ញន្តិ មមំ យថា បុរេ
ចិរប្បវុត្ថា អថវា ន តេ ឥមេ ។

(៤៣២) ជានាម តំ ន មយំ សម្បមូឡ្ហា
សោវ ត្វំ តេ មយមស្មា នាញ្ញេ
ចិត្តញ្ច តេ អស្មិំ ជនេ បទុដ្ឋំ
អាជីវកា តេន តំ ឧត្តសាមាតិ ។

រោមជាតកំ សត្តមំ ។



# រោមជាតក

(៤៣០) (តាបស ពោលថា) ម្នាលរោមកៈ យើងនៅក្នុងគុហាភ្នំ ជាង ៥០ ឆ្នាំ ពួកអណ្ឌជសត្វ (សត្វកើតអំពីពងទាំងនេះ) មិនមានសេចក្តីកន្ត្រៀស ជាសត្វមានចិត្តស្លូតត្រង់ ពីមុនមកកាន់កណ្តាប់ដៃ នៃយើងក្នុងកាលមុន ។

(៤៣១) ម្នាលសត្វមានអវយវៈកោង សព្វថ្ងៃនេះ ពួកទិជសត្វ (សត្វកើតពីរដង) ទាំងនោះ (ឃើញ) ហេតុអ្វីបានជាមានសេចក្តីខ្វល់ខ្វាយ (គេចចេញអំពីញកភ្នំនេះ) ទៅនៅញកភ្នំដទៃវិញ ក្រែង(ពួកបក្សីទាំងនេះ) ទៅឃ្លាតឆ្ងាយ បានជាមិនស្គាល់យើងដូចជាក្នុងកាលមុន ឬក៏ ពួកបក្សីទាំងនេះមិនមែនជាពួកបក្សីទាំងនោះទេ ។

(៤៣២) (ពពិសត្វ ពោលថា) ពួកយើងស្គាល់លោកមិនមែនវង្វេងទេ លោកក៏គឺលោកហ្នឹងដដែល ពួកយើងគឺសត្វទាំងនោះ មិនមែនជាសត្វដទៃទេ តែថា ចិត្តរបស់លោក ប្រទូស្តចំពោះពួកជននេះ ម្នាលអាជីវក ព្រោះហេតុនោះបានជាពួកយើងតក់ស្លុតនឹងលោក ។

ចប់ រោមជាតក ទី៧ ។

# មហិសជាតកំ

(៤៣៣) កាមមត្ថមភិសន្ធាយ លហុចិត្តស្ស ទូភិនោ

សព្វកាមទុហស្សេវ[១] ឥមំ ទុក្ខំ តិតិក្ខសិ ។

(៤៣៤) សិង្គេន និហនាហេតំ[២] បទសា ច អធិដ្ឋហ

ភិយ្យោ ពាលា បកុជ្ឈេយ្យុំ[៣] នោ ចស្ស បដិ-

សេធកោ ។

(៤៣៥) មមេវាយំ មញ្ញមានោ អញ្ញេបេវំ ករិស្សតិ

តេ នំ តត្ថ វធិស្សន្តិ សា មេ មុត្តិ ភវិស្សតិ ។

មហិសជាតកំ អដ្ឋមំ ។

---

១ ម. សព្វកាមទុហស្សេវ ។ ២ ឧ. និហនាហេតំ ។ ម. និហនាមេតំ ។ ៣ ឱ, ម. បកុជ្ជេយ្យុំ ។



# មហិសជាតក

(៤៣៣) (រុក្ខទេវតា ពោលថា) អ្នកអាស្រ័យហេតុដូចម្ដេច ទើបអត់ទ្រាំនូវសេចក្ដីលំបាកនេះ នឹងស្វាមានចិត្តរហ័ស ជាសត្វប្រទូស្តមិត្ត (ដូចជាបុគ្គលអត់ទ្រាំនឹងសេចក្ដីលំបាក) នឹងម្ចាស់ដែលជាអ្នកឲ្យសេចក្ដីប្រាថ្នាទាំងពួង ។

(៤៣៤) អ្នកចូរផ្ចាលស្វានេះដោយស្នែង ចូរជាន់កំទេចដោយជើងចុះ ប្រសិនបើ មិនមានអ្នកហាមឃាត់ទេ ពួកពាលនឹងរឹតតែបៀតបៀនឡើង ។

(៤៣៥) (ពោធិសត្វ ពោលថា) ស្វានេះ កាលមើលងាយខ្ញុំបាន គង់នឹងធ្វើ(អនាចារ)យ៉ាងនេះ នឹងក្របីដទៃទៀត ក្របីទាំងនោះនឹងសម្លាប់វាក្នុងទីនោះ ការរួច (ចាកសេចក្ដីលំបាក) នោះនឹងមានដល់ខ្ញុំ ។

ចប់ មហិសជាតក ទី ៨ ។

# សតបត្តជាតកំ

[៤៣៦] យថា មាណវកោ បន្ថេ សិគាលឹ វនគោចរឹ
អត្ថកាមំ បវេទន្តឹ អនត្ថកាមាតិ មញ្ញតិ
អនត្ថកាមំ សតបត្តំ អត្ថកាមោតិ មញ្ញតិ ។

[៤៣៧] ឯវមេវ ឥធេកច្ចោ បុគ្គលោ ហោតិ តាទិសោ
ហិតេហិ វចនំ វុត្តោ បដិគណ្ហាតិ វាមតោ ។

[៤៣៨] យេ ច ខោ នំ បសំសន្តិ ភយា ឧក្កំសយន្តិ វា
តញ្ហិ សោ មញ្ញតេ មិត្តំ សតបត្តំវ មាណវោ ។

សតបត្តជាតកំ នវមំ ។

# បូដិទូសកជាតកំ

[៤៣៩] អទ្ធា ហិ នូន មិគរាជា បុដកម្មស្ស កោវិទោ
តថា ហិ បុដំ ទូសេតិ អញ្ញំ នូន ករិស្សតិ ។



# សតបត្តជាតក

[៤៣៦] (ព្រះសាស្តា ត្រាស់ថា) មាណពសំគាល់នូវមេចចក ក្នុងផ្លូវ ជាសត្វគោចរទៅក្នុងព្រៃ ប្រាថ្នានូវសេចក្តីចំរើន ថែងប្រាប់ហេតុឲ្យដឹង ថាជាសត្វប្រាថ្នានូវសេចក្តីវិនាស សំគាល់នូវសត្វចចាត ជាសត្វប្រាថ្នានូវសេចក្តីវិនាស ថាជាសត្វប្រាថ្នានូវសេចក្តីចំរើន យ៉ាងណាមិញ ។

[៤៣៧] បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកប្រាកដដូច្នោះ ដែលជនទាំងឡាយ អ្នកប្រាថ្នានូវប្រយោជន៍ ពោលពាក្យ (ប្រៀនប្រដៅ) ទទួលយកខ្វេងទៅវិញ ក៏យ៉ាងនោះដែរ ។

[៤៣៨] មួយទៀត ពួកបុគ្គលណា សរសើរនូវបុគ្គលនោះក្តី លើកដំកើងបុគ្គលនោះ ព្រោះភ័យក្តី បុគ្គលនោះរមែងសំគាល់ពួកបុគ្គលថាជាមិត្ត ដូចមាណព(កាលសំគាល់)នូវសត្វចចាត ថាជាមិត្តដូច្នោះឯង

ចប់ សតបត្តជាតក ទី ៩ ។

# បូដិទូសកជាតក

[៤៣៩] (ពោធិសត្វ ពោលថា) មិគរាជ គឺស្តេចស្វា ជាសត្វឈ្លាសក្នុងការធ្វើកញ្ចប់ស្លឹកឈើដោយពិត ព្រោះហេតុដូច្នោះ ទើបបានបំផ្លាញកញ្ចប់ចោល នឹងធ្វើកញ្ចប់ដទៃឲ្យល្អជាងកញ្ចប់មុនដោយពិត ។

(៦៦០) ន មេ បិតា វា មាតា វា បុដកម្មស្ស កោវិទា
កតំ កតំ ខោ ទូសេម ឯវំ ធម្មមិទំ កុលំ ។

(៦៦១) យេសំ វោ ឯទិសោ ធម្មោ អធម្មោ បន កីទិសោ
មា វោ ធម្មំ អធម្មំ វា អទ្ទសាម កុទាចនន្តិ ។

បុដទូសកជាតកំ ទសមំ ។

ឧទបានវគ្គោ តតិយោ ។

## តស្សុទ្ទានំ

ឧទបានាវ វេយ្យគ្ឃ កបិ
សិខី ច ពលាការុចិរោ
សុជាតិប រោមកា ទុស បុន
សកុណ្ដកោ បុដកម្ម ទស ។

---



(៦៦០) (ពានរពោលថា) បិតា ឬមាតារបស់ខ្ញុំ មិនមែនជាសត្វឈ្លាសក្នុងការធ្វើកញ្ចប់ទេ តែពួកខ្ញុំ បានតែកាត់បំផ្លាញខូចតែផលគេធ្វើហើយ ៗ ប៉ុណ្ណោះ នេះជាត្រកូល(របស់ពានរ) តែងមានយ៉ាងនេះ ជាធម្មតា ។

(៦៦១) (ពោធិសត្វពោលថា) ធម្មតារបស់ពួកអ្នកណា ប្រាកដយ៉ាងនេះទៅហើយ ចំណែកឯមិនមែនធម្មតា តើនឹងដូចម្ដេចទៅវិញ យើងសូមកុំឲ្យជួបប្រទះនឹងការជាធម្មតា ឬមិនមែនជាធម្មតារបស់ពួកអ្នកនោះ ក្នុងកាលណាឡើយ ។

ចប់ ពុដទូសកជាតក ទី ១០ ។

ចប់ ឧទបានវគ្គ ទី ៣ ។

## ឧទ្ទាននៃឧទបានវគ្គនោះគឺ

និយាយអំពីអណ្ដូងទឹកប្រសើរ ១ ខ្លាក្នុងព្រៃ ១ ស្វា ១ កុកមានសីរ ១ កុកដ៏សើបល្អ ១ ផ្កាធិបតីល្អ ១ ព្រាបឈ្មោះរោមកៈ ១ ស្វាប្រទូស្ត ១ សត្វបចាក ១ ការធ្វើកញ្ចប់ ១ ត្រូវជា ១០ ។

---

# អម្ពវគ្គោ

## អម្ពជាតកំ

(៤៤២) អម្ពហេ(១) ឆាម តុមោ យស្ស និត្យម៉ន់ ជលំ

កញ្ញា គោមាធ្យ៊ី ធារី ចក្កវត្តិំ វិជាយតិ ។

(៤៤៣) ត្វម្បិ ភទ្ទេ មហេសីសិ សា ចាបិ បតិនោ បិយា

អាហរិស តំ ភោ ភជា វណ្ណំ អម្ពនំ ជលំ ។

(៤៤៤) ភគ្គរគ្គេ បវត្តោ យេ ហានមចិតព្ធតិ

ស្សេរោ អត្ថបរិច្ចាគី លភមានោ ភរិយហត្ថិ ។

អម្ពជាតកំ បឋមំ ។

១ ម. អម្ពនូ ។

# អម្ពវគ្គ

## អម្ពជាតក

(៤៤២) (សក្កទេវរាជ ត្រាស់ថា) នាងនារីមានរបបតាញ់វង្ស បាន

បរិភោគផ្លែឈើ (ស្វាយ) ឈ្មោះអម្ពនុះជាទិព្វហើយប្រសូត

(ព្រះរាជបុត្រ) ជាស្ដេចចក្រពត្តិ ។

(៤៤៣) ម្នាលនាងដ៏ចំរើន នាងជាមហេសី ជាទីស្រឡាញ់របស់

ព្រះរាជាជាភស្ដា ព្រះរាជានឹងនាំផ្លែស្វាយ ឈ្មោះអម្ពនុះនេះ

មកឲ្យនាង ។

(៤៤៤) (ភ្នំសោក ពោលថា) បុគ្គលអ្នកក្រៀវក្រា ស៊ូលះបង់ខ្លួនប្រឹង

ប្រែងក្នុងប្រយោជន៍ របស់បុគ្គលអ្នកចិញ្ចឹម(*)ខ្លួន រមែងបានខ្ញុំ

ឋានៈណា ទំបានខ្ញុំឋានៈនោះវិញ ។

ចប់ អម្ពជាតក ទី ១ ។

១ បុគ្គលអ្នកចិញ្ចឹម មាន៣ គឺមាតា បិតា ស្វាមី ។ អដ្ឋកថា ។

## សេយ្យជាតកំ

(៤៤៥) សេយ្យំសោ សេយ្យសោ ហោតិ យោ សេយ្យ-

មុបសេវតិ

ឯកេន សន្ធឹ កត្វាន សតំ វជ្ឈេ អមោចយឹ ។

(៤៤៦) តស្មា សព្វេន លោកេន សន្ធឹ កត្វាន ឯកតោ

បេច្ច សគ្គំ និគច្ឆេយ្យ ឥធ សុណាថ កាសិយា ។

(៤៤៧) ឥទំ វត្វា មហារាជា កំសោ ពារាណសិគ្គហោ

ធនុំ តុណ្ហិញ្ច(១) និក្ខិប្ប សញ្ញមំ អជ្ឈុបាគមីតិ ។

សេយ្យជាតកំ ទុតិយំ ។

---

១ ម. ធនុ តុណ្ហញ្ច ។



## សេយ្យជាតក

(៤៤៥) (ព្រះពោធិសត្វ ក្រាស់ថា) បុគ្គលណា គប់រកនូវបុគ្គលប្រសើរ (បុគ្គលនោះ) ជាអ្នកមានចំណែកប្រសើរ ជាអ្នកប្រសើរបំផុត ខ្ញុំបានធ្វើនូវការជាប់តជាមួយនឹងស្តេច ជាតែម្នាក់ (ដោយមេត្តាការនោះ) បានដោះអ្នកទាំងឡាយ ១០០ នាក់ ដែលត្រូវគេសំឡាប់ (ឲ្យរួចបាន) ។

(៤៤៦) ព្រោះហេតុនោះ បុគ្គលម្នាក់ឯង ធ្វើនូវការជាប់តជាមួយនឹងលោកទាំងមូល (ដោយមេត្តាការនោះ) លុះចំណាយខន្ធទៅ គប្បីបានឋានសួគ៌ អ្នកទាំងឡាយដែលនៅក្នុងដែនកាសី ចូរស្តាប់នូវពាក្យរបស់យើងនេះចុះ ។

(៤៤៧) (ព្រះសាស្តា ក្រាស់ថា) ព្រះរាជាជាធំ ព្រះនាមកំសៈ ព្រះអង្គគ្រប់គ្រងក្រុងពារាណសី បានត្រាស់ដូច្នេះហើយ ទ្រង់ដាក់ធ្នូនឹងព្រួញចោល ហើយទើបចូលទៅកាន់ការសង្រួម គឺបព្វជ្ជា ។

ចប់ សេយ្យជាតក ។

## វឌ្ឍកីសូករជាតកំ

(៤៨៨) វរំ វរំ ត្វំ និហនំ បុរេ ចរី
អស្មឹ បទេសេ អភិភុយ្យ សូករេ
សោ ទានិ ឯកោ ព្យបគម្ម ឈាយសិ
ពលន្នុ តេ ព្យគ្ឃ ន ចជ្ជ វិជ្ជតិ ។

(៤៨៩) ឥមស្សុតា(១) យន្តិ ទិសោទិសំ បុរេ
ភយដ្ឋិតា(២) លេណគវេសិនោ បុថូ
តេ ទានិ សង្គម្ម វសន្តិ ឯកតោ
យត្ថដ្ឋិតា ទុប្បសហជ្ជមេ មយា ។

(៤៩០) នមត្ថុ សង្ឃាន សមាគតានំ
ទិស្វា សយំ សខ្យំ វទាមិ អព្ភុតំ
ព្យគ្ឃំ មិគា យត្ថ ជិនឹសុ ទាឋិនោ
សាមគ្គិយា ទាឋពលេសុ មុច្ចរេតិ ។

វឌ្ឍកីសូករជាតកំ តតិយំ ។

---

១ ម. ឥមេ សុទំ យន្តិ ។ ២ ម. ភយទ្ទិតា ។ ឱ. ភយដ្ដិតា ។



## វឌ្ឍកីសូករជាតក

(៤៨៨) (ដង្កិលមានចក្ខុកាន់ ពោលថា) កាលពីដើមអ្នកបានជាន់ខ្ទប់ជ្រូកទាំងឡាយ ក្នុងប្រទេសនេះ តែងសំឡាប់ជ្រូកដ៏ប្រសើរៗបាន ម្នាលខ្លា ឥឡូវនេះ អ្នកនោះត្រឡប់មកម្នាក់ឯង សញ្ជប់សញ្ជឹង ម្នាលខ្លា ថ្ងៃនេះកំឡាំងកាយរបស់អ្នកគ្មានទេឬ ។

(៤៨៩) (ខ្លា ពោលថា) កាលពីដើមជ្រូកទាំងនេះជាច្រើន ត្រូវភ័យបៀតបៀនហើយ ក៏ស្វែងរកទីជ្រកកោន ហើយក៏រត់ទៅកាន់ទិសតូចទិសធំ ឥឡូវនេះជ្រូកទាំងនេះ ឋិតនៅក្នុងទីណា ដែលខ្ញុំបៀតបៀនមិនបាន ជ្រូកទាំងនោះ ក៏មកជួបជុំគ្នា នៅក្នុងទីនោះជាមួយគ្នា ។

(៤៩០) (រុក្ខទេវតា ពោលថា) យើងសូមថ្វាយបង្គំពួកជ្រូក ដែលមកជួបជុំគ្នា (ក្នុងទីនេះ) យើងបានឃើញនូវមិត្តភាព (របស់អ្នកទាំងឡាយ) ដ៏អស្ចារ្យដោយខ្លួនឯងទើបពោល ព្រោះថា ពួកម្រឹគមានខ្នាយ ហ៊ានឈ្នះនូវខ្លា រួចចាក (មរណភ័យ) ដោយសេចក្តីព្រមព្រៀងក្នុងពួកជ្រូកមានខ្នាយជាកំឡាំង ។

ចប់ វឌ្ឍកីសូករជាតក ទី ៣ ។

## សិរីជាតកំ

(៤៩១) យំ ឧស្សុក្កា សង្ឃរន្តិ អលក្ខិកា ពហុំ ធនំ
សិប្បវន្តោ អសិប្បា ច លក្ខិវា តានិ ភុញ្ជតិ(១)។
(៤៩២) សព្វត្ថ កតបុញ្ញស្ស អតិច្ចញ្ញេវ បាណិនោ
ឧប្បជ្ជន្តិ ពហូ ភោគា អប្បនាយតនេសុបិ ។
(៤៩៣) កុក្កុដោ មណយោ ទណ្ឌោ ថិយោ ច បុញ្ញលក្ខណា
ឧប្បជ្ជន្តិ អបាបស្ស កតបុញ្ញស្ស ជន្តុនោ ។

សិរីជាតកំ ចតុត្ថំ ។

## មណិសូករជាតកំ

(៤៩៤) ទរិយា សត្ត វស្សានិ តឹសមត្តា វសាមសេ
ហញ្ញាម មណិនោ អាភំ ឥតិ នោ មន្តរំ អហុ ។

១ ឱ. លក្ខិវ តានិ ភុញ្ជតិ ។ ម. លក្ខី វា តានិ ភុញ្ជតិ ។



## សិរីជាតក

(៤៩១) (ព្រះសាស្តា ត្រាស់ថា) ពួកបុគ្គលឥតបុណ្យ ខំខ្វល់ខ្វាយ ប្រមូលទ្រព្យណាដ៏ច្រើន ចំណែកខាងបុគ្គល អ្នកមានបុណ្យ ទោះមានសិល្បៈក្តី មិនមានសិល្បៈក្តី គង់តែងបានបរិភោគនូវទ្រព្យទាំងនោះ ។

(៤៩២) ភោគៈទាំងឡាយច្រើន តែងកន្លងនូវពួកបុគ្គលឥតបុណ្យ កើតឡើងសម្រាប់បុគ្គល អ្នកមានបុណ្យធ្វើហើយ ក្នុងទីទាំងពួង សូម្បីក្នុងទីមិនមែនជាកន្លែង សម្រាប់កើត ។

(៤៩៣) មាន់ឈ្មោលក្តី កែវមណីក្តី ឈើច្រត់ក្តី នាងបុញ្ញលក្ខណាទេវី ជាប្រពន្ធ (របស់សេដ្ឋី)ក្តី តែងកើតឡើងដល់អនាថបិណ្ឌិកសេដ្ឋី អ្នកមិនមានបាប ជាអ្នកមានបុណ្យធ្វើហើយ ។

ចប់ សិរីជាតក ទី ៤ ។

## មណិសូករជាតក

(៤៩៤) (ពួកជ្រូក ពោលថា) យើងទាំងប្រមាណ ៣០ នាក់ នៅក្នុងមណិគុហា អស់ប្រាំពីរឆ្នាំ យើងទាំងប្រឹក្សាគ្នាថា យើងទាំងគំចាត់បង់ នូវពន្លឺនៃកែវមណីដូច្នេះ ។

(៤៩៥) យាវតា មណឹ ឃំសាម(១) ភិយ្យោ វោទាយតេ មណិ

ឥទញ្ចទានិ បុច្ឆាម កឹ កិច្ចំ ឥធ មញ្ញសិ ។

(៤៩៦) អយំ មណិ វេឡុរិយោ អកាចោ វិមលោ សុភោ

នាស្ស សក្កា សិរឹ ហន្តុំ អបក្កមថ សូករាតិ ។

(២)

មណិសូករជាតកំ បញ្ចមំ ។

## សាលុកជាតកំ

(៤៩៧) មា សាលុកស្ស បិហយិ អាតុរន្នានិ ភុញ្ជតិ

អប្បោស្សុក្កោ ភុសំ ខាទ ឯតំ ទីឃាយុលក្ខណំ ។

(៤៩៨) ឥទានិ សោ ឥធាគន្ត្វា អតិថី យុត្តសេវកោ

អថ ទក្ខសិ សាលុកំ សយន្តំ មុសលុត្តរំ ។

១ ម. យាវ យាវ ឃំសាម ។ ២ ម. មណិសូករជាតកំ ។



(៤៩៥) យើងទាំងដុសកែវមណី ដរាបណា កែវមណី រឹតតែភ្លឺខ្លាំងឡើង ដរាបនោះ យើងទាំងសូមសួរនូវហេតុនេះថា លោកយល់នូវកិច្ចដូចម្តេច ក្នុងរឿងនេះ ។

(៤៩៦) (ពោធិសត្វ ពោលថា) កែវមណីនេះដូចជាកែវពិទូរ្យ មិនមែនកញ្ចក់ ជាកែវស្អាតឥតមន្ទិល អ្នកណាមួយមិនអាចដើម្បីកំចាត់បង់ពន្លឺនៃកែវមណីនុ៎ះ ឲ្យស្លាប់សម្បុរបាន នែជ្រូកទាំងឡាយ ពួកអ្នក ចូរចៀសចេញទៅ ។

ចប់ មណិសូករជាតក ទី ៥ ។

## សាលុកជាតក

(៤៩៧) (គោឈ្មោះមហាលោហិតៈពោធិសត្វ ពោលថា) អ្នកកុំប្រាថ្នា (នូវអាហារ) របស់ជ្រូកឈ្មោះសាលុកឡើយ (ព្រោះជ្រូកនេះ) បរិភោគបាយ ជាគ្រឿងក្តៅក្រហាយ អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិច ហើយបរិភោគនូវអង្កាមចុះ ការបរិភោគនូវអង្កាម នេះឯងហើយ ជាលក្ខណៈនៃហេតុឲ្យអាយុវែង ។

(៤៩៨) បុរសអ្នករៀបការនោះជាសេវកៈ (ប្រកបដោយបរិស័ទ) ជាភ្ញៀវ មកប្រជុំក្នុងទីនេះ ក្នុងកាលឥឡូវនេះ អ្នកនឹងឃើញជ្រូកឈ្មោះសាលុកដេកស្ងៀម ត្រូវគេសម្លាប់ក្នុងចុងនៃអង្រែមិនខាន ។

(៥៥៩) វិហន្តំ សូករំ ទិស្វា សយន្តំ មុសលុត្តរំ
ជរគ្គវា អចិន្តេសុំ(១) វរម្ហាកំ ភុសាមិវ ។

សាលុកជាតកំ ឆដ្ឋំ ។

## លាភគរហិកជាតកំ

(៥៦០) នានុម្មត្តោ នាបិសុណោ នានដោ នាកុតូហលោ
មូឡ្ហេសុ លភតេ លាភំ ឯសា តេ អនុសាសនី ។

(៥៦១) ធិរត្ថុ តំ យសលាភំ ធនលាភញ្ច ព្រាហ្មណ
យា វុត្តិ វិនិបាតេន អធម្មចរិយាយ វា(២) ។

---

១ ឱ. ជរគ្គវា ចិន្តេសុំ ។ ម. ជរគ្គវា ចិន្តេសុំ ។ ២ ម.ឱ. អធម្មចរណេន វា ។





(៥៥៩) (ព្រះសាស្ដាត្រាស់ថា) គោចាស់ (ទាំងពីរ) ឃើញជ្រូកដេកសៀម ក្រោយគេសម្លាប់ក្នុងចន្លោះ នៃអង្រែដែលគេកាប់ ហើយគិតថា អង្កាមជាអាហារដ៏ប្រសើរ របស់យើង ។

ចប់ សាលុកជាតក ទី ៦ ។

## លាភគរហិកជាតក

(៥៦០) (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលមិនឆ្កួត រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមិននិយាយញុះញង់ រមែងមិនបានលាភក្នុងសំណាក់ នៃមនុស្សល្ងង់ទេ បុគ្គលមិនមែនអ្នករបាំ រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមានសំដីក្រអឺមក្រអៀម រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ នេះជាពាក្យប្រៀនប្រដៅ របស់អ្នក ។

(៥៦១) (កូនសិស្ស ពោលថា) បពិត្រព្រាហ្មណ៍ ខ្ញុំសូមតិះដៀល នូវការបានយស នឹងការបានទ្រព្យ ព្រោះតែប្រព្រឹត្តចិញ្ចឹមជីវិតដោយធ្វើខ្លួនឲ្យលិចលង់ (ដោយកិច្ចមានកិរិយាសម្លាប់គេជាដើម) ឬដោយការប្រព្រឹត្តនូវទុច្ចរិត ។

(៤៦២) អបិ ចេ បត្តមាទាយ អនាគារោ បរិព្វជេ
ឯសាវ ជីវិកា សេយ្យោ យា ចាធម្មេន ឯសនា ។

លាភគរហិកជាតកំ សត្តមំ ។

# មច្ឆុទ្ទានជាតកំ

(៤៦៣) អគ្ឃន្តិ មច្ឆា អធិកំ សហស្សំ
ន សោ អត្ថិ យោ ឥមំ សទ្ទហេយ្យ
មយ្ហញ្ច អស្សុ ឥធ សត្ត មាសា
អហម្បិ តំ មច្ឆុទ្ទានំ កិណេយ្យំ ។
(៤៦៤) មច្ឆានំ ភោជនំ ទត្វា មម ទក្ខិណមាទិសិ
តំ ទក្ខិណំ សរន្តិយា កតំ អបចិតិំ តយា ។
(៤៦៥) បទុដ្ឋចិត្តស្ស ន ផាតិ ហោតិ
ន ចាបិ នំ ទេវតា បូជយន្តិ
យោ ភាតរំ បេត្តិកំ សាបតេយ្យំ
អវញ្ចយី ទុក្កដកម្មការី ។

មច្ឆុទ្ទានជាតកំ អដ្ឋមំ ។



(៤៦២) បុគ្គលសូវធ្វើជាអ្នកបួស កាន់បាត្រ (ដើរសូមគេ) (ព្រោះថា) ការប្រព្រឹត្តចិញ្ចឹមជីវិតនេះឯង ប្រសើរបំផុតជាងកិរិយាស្វែងរកចិញ្ចឹមជីវិតដោយអធម៌ ។

ចប់ លាភគរហិកជាតក ទី ៧ ។

# មច្ឆុទ្ទានជាតក

(៤៦៣) (ពោធិសត្វ ពោលថា) ត្រីទាំងឡាយ ថ្លៃមួយពាន់កហាបណៈ លើសដោយ (៧ មាសក) មិនមានអ្នកណាមួយ ជឿនូវហេតុនេះ តែថា (មក) ដល់អញក្នុងទីនេះនៅតែថ្លៃ ៧ មាសក អញគប្បីទិញនូវពួកត្រីនោះ ។
(៤៦៤) (ទេវតា ពោលថា) អ្នកបានឲ្យភោជនដល់ពួកត្រី ហើយផ្សាយចំណែកផលដល់ខ្ញុំ ខ្ញុំរលឹកនូវទក្ខិណានោះ ជាសេចក្តីគោរពដែលអ្នកធ្វើហើយ (ទើបរក្សាទ្រព្យនេះទុកឲ្យអ្នក) ។
(៤៦៥) សេចក្តីចំរើន មិនមានដល់បុគ្គល អ្នកមានចិត្តប្រទូស្តឡើយ មួយទៀត បុគ្គលណាធ្វើអំពើអាក្រក់ បោកប្រាស់ទ្រព្យសម្បត្តិ ដែលជាកេរ្តិ៍មរតក របស់បិតានឹងបងប្អូនឯង ពួកទេវតាក៏មិនបូជាបុគ្គលនោះឡើយ ។

ចប់ មច្ឆុទ្ទានជាតក ទី ៨ ។

# នានាឆន្ទជាតកំ

(៤៦៦) នានាឆន្ទា មហារាជ ឯកាគារេ វសាមសេ
អហំ គាមវរំ ឥច្ឆេ ព្រាហ្មណី ច គវំ សតំ ។

(៤៦៧) បុត្តោ អាជញ្ញរថំ(១) កញ្ញា ច មណិកុណ្ឌលំ
យា ចេសា បុណ្ណិកា ជម្មី ឧទុក្ខលំ អភិកង្ខតិ ។

(៤៦៨) ព្រាហ្មណស្ស គាមវរំ ព្រាហ្មណិយា គវំ សតំ
បុត្តស្ស អាជញ្ញរថំ កញ្ញាយ មណិកុណ្ឌលំ
យញ្ចេតំ បុណ្ណិកំ ជម្មឹ បដិបាទេថុទុក្ខលន្តិ ។

នានាឆន្ទជាតកំ នវមំ ។

១ ម. ឆត្តោ ច អាជញ្ញរថំ ។ ម. បុត្តោ ច អាជញ្ញរថំ ។



# នានាឆន្ទជាតក

(៤៦៦) (ព្រាហ្មណ៍បុរោហិត ពោលថា) បពិត្រមហារាជ យើងខ្ញុំទាំងឡាយ មានចំណង់ផ្សេងៗគ្នា នៅក្នុងផ្ទះជាមួយគ្នា ចំណែកខ្ញុំព្រះអង្គចង់បានស្រុកសួយ នាងព្រាហ្មណីជាប្រពន្ធ ចង់បានគោ ១០០ ។

(៤៦៧) កូនប្រុស (របស់ខ្ញុំព្រះអង្គ) ចង់បានរថទឹមដោយសេះអាជានេយ្យ នាងកញ្ញា (កូនប្រុសស្រី) ចង់បានកុណ្ឌលកែវមណី ចំណែកខាងនាងបុណ្ណិកាទាសី ថោកទាប ចង់បានត្បាល់ (មួយអន្លើ ដោយចង្អេរនិងអង្រែ) ។

(៤៦៨) (ព្រះរាជា ត្រាស់ថា) អ្នកទាំងឡាយ ចូរឲ្យស្រុកសួយដល់ព្រាហ្មណ៍ ចូរឲ្យគោ ១០០ ដល់នាងព្រាហ្មណី ចូរឲ្យរថទឹមដោយសេះអាជានេយ្យដល់បុត្ត (របស់ព្រាហ្មណ៍) ចូរឲ្យកុណ្ឌលកែវមណីដល់នាងកញ្ញា មួយទៀត អ្នកទាំងឡាយ ចូរចាត់ចែងត្បាល់ (ព្រមទាំងចង្អេរនិងអង្រែ) ឲ្យនាងបុណ្ណិកាទាសីថោកទាបនោះផង ។

ចប់ នានាឆន្ទជាតក ទី ៩ ។

# សីលវីមំសជាតកំ

(៦៦៩) សីលំ កិរេវ កល្យាណំ សីលំ លោកេ អនុត្តរំ
បស្ស ឃោរវិសោ នាគោ សីលវាតិ ន ហញ្ញតិ ។

(៦៧០) សោហំ សីលំ សមាទិស្សំ លោកេ អនុមតំ សិវំ
អរិយវុត្តិ សមាចារោ យេន វុច្ចតិ សីលវា ។

(៦៧១) ញាតីនញ្ច បិយោ ហោតិ មិត្តេសុ ច វិរោចតិ
កាយស្ស ភេទា សុគតឹ ឧបបជ្ជតិ សីលវា ។

សីលវីមំសជាតកំ ទសមំ ។

អត្ថវគ្គោ ចតុត្ថោ ។



# សីលវីមំសជាតក

(៦៦៩) (ព្រាហ្មណ៍ពោធិសត្វ ពោលថា) ឮថា សីល ជាគុណជាតល្អ សីល ជាគុណជាតប្រសើរបំផុត ក្នុងលោក អ្នកចូរមើលចុះ ពស់មានពិសដ៏ពន្លឹក មិនបៀតបៀន (ហ្នពស់) ព្រោះយល់ថា អ្នកមានសីល ។

(៦៧០) បុគ្គលប្រព្រឹត្តស្មើតាមការប្រព្រឹត្ត របស់ព្រះអរិយៈ ទើបបណ្ឌិត ហៅថា អ្នកមានសីល ដោយសីលណា យើងនឹងសមាទាន នូវសីលនោះ ដែលបណ្ឌិតយល់ព្រមហើយថា សីលនេះជា របស់ក្សេម (ពាក់ក្ស័យ) ក្នុងលោក ។

(៦៧១) ម្យ៉ាងទៀត បុគ្គលអ្នកមានសីលជាទីស្រឡាញ់ នៃពួកញាតិផង រមែងរុងរឿងក្នុងពួកមិត្រផង លុះបែកធ្លាយរាងកាយ ក៏ទៅ កើតក្នុងសុគតិភព ។

ចប់ សីលវីមំសជាតក ទី១០ ។

ចប់ អត្ថវគ្គ ទី៤ ។

## តស្សុទ្ទានំ

ធុម កាំស វុត្តមព្យក្ខមិតា
មណយោ មណី សាលុកាមត្ថយេនោ
អនុសាសនិយោ ប៉ិច មជ្ឈវ៉េក
មណិកុណ្ឌលកោធ ការិច ធស ។

---





## ឧទ្ទាននៃអដ្ឋុប្បត្តិនោះគឺ

និយាយអំពីផ្សែងឈើគន្ធនៈ ១ ព្រះរាជាព្រះនាមកំសៈ ១ ជ្រូកដ៏ប្រសើរទាំងប្រាំនាក់ ១ កែវមណី ១ ជ្រូកនៅក្នុងគុហាកែវមណី ១ ជ្រូកឈ្មោះសាលុក ១ ការប្រៀនប្រដៅ ១ គ្រឹះដ៏ប្រសើរ ១ កុណ្ឌលកែវមណី ១ ស័ល ១ ត្រូវជា ១០ ។

---

## កុម្ភវគ្គោ

### ភទ្រឃដភេទកជាតកំ

(៤៧២) សព្វកាមទទំ កុម្ភំ   កុដំ លទ្ធាន ធុត្តកោ
យាវ[១] ចំ អនុបាលេតិ   តាវ សោ សុខមេធតិ ។

(៤៧៣) យទា មត្តោ ច ទិត្តោ ច   បមាទា កុម្ភមព្ភិទា
កតោ[២] នគ្គោ ច បោត្ថោ ច   បច្ឆា ពាលោ វិហញ្ញតិ

(៤៧៤) ឯវមេវ យោ ធនំ លទ្ធា   បមត្តោ បរិភុញ្ជតិ
បច្ឆា តបតិ ទុម្មេធោ   កុដំ ភិត្វា[៣] ធុត្តកោតិ ។

ភទ្រឃដភេទកជាតកំ បឋមំ ។

### សុបត្តជាតកំ[៤]

(៤៧៥) ពារាណស្យំ មហារាជ   កាករាជា និវាសកោ
អសីតិយា សហស្សេហិ   សុបត្តោ បរិវារិតោ ។

---

១ ម. យាវ សោ ។ ២ ម. ឱ. តតោ ។ ៣ ម. ភិត្វា ។ ៤ ឱ. សុភាយជាតកំ ។

## កុម្ភវគ្គ

### ភទ្រឃដភេទកជាតក

(៤៧២) (ព្រះសាស្ដា ត្រាស់ថា) អ្នកលេងបាននូវឆ្នាំងកំណប់ ដែលឲ្យនូវសេចក្ដីប្រាថ្នាគ្រប់យ៉ាង ហើយរក្សាឆ្នាំងនោះ ដរាបណា អ្នកលេងនោះ ក៏ដល់នូវសេចក្ដីសុខ ដរាបនោះ ។

(៤៧៣) ក្នុងកាលណា អ្នកលេងស្រវឹងផង កឡើងផង បានបំបែកឆ្នាំង ព្រោះសេចក្ដីប្រមាទ ក្នុងកាលនោះ បុគ្គលពាលនោះជាអ្នកអាក្រាតផង ជាអ្នកស្លៀកសំពត់កន្ទបផង រមែងក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយ ។

(៤៧៤) បុគ្គលឥតប្រាជ្ញា បាននូវទ្រព្យយ៉ាងនេះហើយ ជាអ្នកមានសេចក្ដីប្រមាទ ប្រើប្រាស់ រមែងក្ដៅក្រហាយ ក្នុងកាលខាងក្រោយ ដូចជាអ្នកលេង (ដែលក្ដៅក្រហាយស្ដាយក្រោយ) ព្រោះតែបំបែកឆ្នាំងពោល ។

ចប់ ភទ្រឃដភេទកជាតក ទី ១ ។

### សុបត្តជាតក

(៤៧៥) (ស្ដេចក្អែក ពោលថា) បពិត្រមហារាជ ស្ដេចក្អែកឈ្មោះសុបត្តៈ នៅអាស្រ័យក្បែរក្រុងពារាណសី មានក្អែក ៨០.០០០ ជាបរិវារ ។

(៤៧៦) តស្ស ទោហឡិនី ភរិយា សុផស្សា(១) ភក្ខិតុមិច្ឆតិ
រញ្ញោ មហានសេ បក្កំ បច្ចគ្ឃំ រាជភោជនំ ។

(៤៧៧) តេសាហំ បហិតោ ទូតោ រញ្ញោ ចម្ហិ ឥធាគតោ
ភត្តុ អបចិតិំ កុម្មិ នាសាយមការំ វណន្តិ ។

សុបត្តជាតកំ ទុតិយំ ។

## កាយនិព្វិន្ទជាតកំ

(៤៧៨) ផុដ្ឋស្ស មេ អញ្ញតរេន ព្យាធិនា
រោគេន ពាឡ្ហំ ទុខិតស្ស រុប្បតោ
បរិសុស្សតិ ខិប្បមិទំ កឡេវរំ
បុប្ផំ យថា បំសុនិ អាតបេ កតំ ។

(៤៧៩) អជញ្ញំ ជញ្ញសង្ខាតំ អសុចឹ សុចិសម្មតំ
នានាកុណបបរិបូរំ ជញ្ញរូបំ អបស្សតោ ។

(១) ម. សុផស្សា មច្ឆមិច្ឆតិ ។ ឱ. សុពិស្សា ។



(៤៧៦) នាងសុបស្សា ជាភរិយារបស់ស្តេចក្អែកនោះ មានសេចក្តីចាញ់ថ្ងៃ ចង់បរិភោគនូវក្រយាស្ងោយមានថ្លៃច្រើន ដែលនាយពិសេស ចំអិន ដើម្បីថ្វាយព្រះរាជា ក្នុងរោងសំរាប់ចំអិនក្រយាស្ងោយ ។

(៤៧៧) ខ្ញុំព្រះអង្គជាទូត របស់ស្តេចក្អែកទាំងនោះ ត្រូវស្តេចបញ្ជូនមក បានជាមកក្នុងទីនេះ ខ្ញុំព្រះអង្គធ្វើនូវសេចក្តីគោរព ចំពោះម្ចាស់ ហើយបានធ្វើឲ្យមានរបួស ត្រង់ច្រមុះ (របស់នាយពិសេស) ។

ចប់ សុបត្តជាតក ទី ២ ។

## កាយនិព្វិន្ទជាតក

(៤៧៨) (តាបសពោធិសត្វ ពោលថា) កាលអាត្មាត្រូវព្យាធិរោគណាមួយប៉ះពាល់ហើយ ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំង ដែលរោគកំពុងបៀតបៀន ករកាយនេះ រីងរឹងស្ងួតយ៉ាងឆាប់ ដូចជាផ្កាឈើដែលគេដាក់លើកាចម៍ដី ដ៏ក្តៅ (ក៏ស្ងួតរួចទៅ) ។

(៤៧៩) (ករកាយនេះ) មិនជាទីគាប់ចិត្ត តែជនពាល ពោលថាជាទីគាប់ចិត្ត មិនស្អាតទេ តែជនពាល សន្មតថាជារបស់ស្អាត ករកាយដ៏ពេញប្រៀប ដោយសាកសពផ្សេងៗ មានសភាព ជាទីគាប់ចិត្តនៃជនពាល ។

(៤៨០) ធិរត្ថុមំ(១) អាតុរំ បូតិកាយំ
ជេគុច្ឆិយំ អសុចឹ ព្យាធិធម្មំ
យត្ថប្បមត្តា អធិមុច្ឆិតា បជា
ហាបេន្តិ មគ្គំ សុគតូបបត្តិយា ។

កាយនិព្វិន្ទជាតកំ តតិយំ ។

## ជម្ពុខាទកជាតកំ

(៤៨១) កោយំ ពិន្ទុស្សរោ វគ្គុ សរវន្តានមុត្តមោ(២)
អច្ចុតោ ជម្ពុសាខាយ មោរច្ឆាបោវ កូជតិ ។
(៤៨២) កុលបុត្តោវ ជានាតិ កុលបុត្តំ បសំសិតុំ
ព្យគ្ឃច្ឆាបសទិសវណ្ណ(៣) ភុញ្ជ សម្ម ទទាមិ តេ ។
(៤៨៣) ចិរស្សំ វត បស្សាមិ មុសាវាទី សមាគតេ
វន្តាទំ កុណបាទញ្ច អញ្ញមញ្ញំ បសំសកេ ។

ជម្ពុខាទកជាតកំ ចតុត្ថំ ។

---

១ ឱ. ធិរត្ថុ តំ ។ ២ ឱ. ជវន្តានមុត្តមោ ។ ៣ ឱ. ព្យគ្ឃច្ឆាបសរិវណ្ណ ។



(៤៨០) យើងគួរតិះដៀល នូវកាយស្អុយនេះ ជារបស់ឈឺជានិច្ច គួរខ្ពើមរអើម មិនស្អាត មានព្យាធិជាធម្មតា ដែលពួកសត្វប្រមាទ ជ្រប់ជាប់ ញ៉ាំងផ្លូវនៃសុគតិភព ឲ្យវិនាសសាបសូន្យ ។

ចប់ កាយនិព្វិន្ទជាតក ទី ៣ ។

## ជម្ពុខាទកជាតក

(៤៨១) (ចចក ពោលថា) អ្នកណានេះ មានសំឡេងក្រឡួច ពីរោះ ឧត្តមជាងពួកសត្វ ដែលមានសំឡេង ទំលើមែកព្រីង ហើយយំពីរោះ ដូចជាសំឡេងនៃកូនក្ងោក ។
(៤៨២) (ក្អែក ពោលថា) កុលបុត្តរមែងសរសើរកុលបុត្ត (ដូចគ្នា) ម្នាលសំឡាញ់ មានសម្បុរដូចជាសម្បុរនៃកូនខ្លា ខ្ញុំសូមជូន (ផ្លែព្រីង) ដល់អ្នក ចូរអ្នកពិសាចុះ ។
(៤៨៣) (រុក្ខទេវតា ពោលថា) យូរណាស់ហើយ យើងទើបតែឃើញនូវក្អែកជាសត្វស៊ីនូវកំអួតផង នូវចចកជាសត្វស៊ីនូវសាកសពផង ជាសត្វពោលពាក្យកុហក មកជួបគ្នា ហើយសរសើរគ្នាទៅវិញទៅមក ។

ចប់ ជម្ពុខាទកជាតក ទី ៤ ។

## អដ្ឋជាតកំ

(៤៨៤) ឧសភស្សេវ តេ ខន្ធោ សីហស្សេវ វិជម្ភិតំ
មិគរាជ នមោ ត្យត្ថុ អបិ កិញ្ចិ លភាមសេ ។

(៤៨៥) កុលបុត្តោវ ជានាតិ កុលបុត្តំ បសំសិតុំ
មយូរគីវសង្កាស ឥតោ បរិយាហិ វាយស ។

(៤៨៦) មិគានំ កោដ្ឋុកោ(១)អន្តោ បក្ខីនំ បន វាយសោ
ឯរណ្ឌោ អន្តោ រុក្ខានំ តយោ អន្តា សមាគតា ។

អដ្ឋជាតកំ ចតុត្ថំ ។

## សមុទ្ទជាតកំ

(៤៨៧) កោ នាយំ លោណតោយស្មឹ សមន្តា បរិធាវតិ
មច្ឆេ មករេ ច វារេតិ ឩមីសុ ច វិហញ្ញតិ ។

---

១ ឱ. កោត្ថុកោ ។



## អដ្ឋជាតក

(៤៨៤) (ក្អែក ពោលថា) ករបស់អ្នក ដូចជាកនៃគោឧសភ ការរម៉ិតកាយ
របស់អ្នក ដូចជាការរម៉ិតកាយនៃសត្វសីហៈ បពិត្រមិគរាជ ខ្ញុំ
សូមថ្វាយបង្គំអ្នក ធ្វើម្តេចយើងនឹងបានទទួលសាច់តិចតួច ។

(៤៨៥) (ចចក ពោលថា) កុលបុត្តទើបសរសើរនូវកុលបុត្តដូចគ្នា ម្នាល
ក្អែកមានកដូចជាក្ងោក អ្នកចូរចុះអំពីដើមឈើនេះមក ។

(៤៨៦) (រុក្ខទេវតា ពោលថា) ចចកជាសត្វថោកទាប ជាងម្រឹគទាំង
ឡាយ ក្អែកជាសត្វថោកទាប ជាងបក្សីទាំងឡាយដែរ ដើម
ល្ហុងជាឈើថោកទាបជាងឈើទាំងឡាយ ពួកថោកទាបទាំងបី
មកជួបប្រទះគ្នា ។

ចប់ អដ្ឋជាតក ទី ៤ ។

## សមុទ្ទជាតក

(៤៨៧) (សមុទ្ទទេវតា ពោលថា) អ្នកណានេះហ្ន៎ ស្ទុះទៅមក ជុំវិញ
ក្នុងសមុទ្រមានទឹកប្រៃ ហាមឃាត់ពួកត្រី និងពួក
មករ លំបាកក្នុងរលកទឹក ។

[៦៨៨] អនន្តបាយី សកុណោ អតិត្តោតិ ទិសា សុតោ
សមុទ្ទំ បាតុមិច្ឆាមិ សាគរំ សរិតម្បតិំ ។

[៦៨៩] សោយំ ហាយតិ ចេវ បូរតេ ចមហោទធិ
នាស្ស នាយតិ បីតន្តោ(១) អបេយ្យោ កិរ សាគរោតិ ។

សមុទ្ទជាតកំ ឆដ្ឋំ ។

## កាមវិលាបជាតកំ

[៦៩០] ឧច្ចេ សកុណ ឌេមាន(២) បត្តយាន វិហង្គម
វជ្ជាសិ ខោ ត្វំ វាមូរុំ ចិរំ ខោ សា ករិស្សតិ(៣) ។

[៦៩១] ឥទំ ខោ សា ន ជានាតិ អសឹ សត្តិញ្ច ឱឌ្ឌិតំ
សា ចណ្ឌី កាហតិ កោធំ តំ មេ តបតិ នោ ឥធ(៤) ។

---

១ ម. បីវន្តោ ។ ២ ឱ. ឌេមាន ។ ម. ឌេមាន ។ ៣ ម. សរិស្សតិ ។ ៤ ម. ឥធំ ។



(៦៨៨) (ក្អែកសមុទ្រ ពោលថា) ខ្ញុំជាសត្វស្លាប ជាសត្វផឹកទឹកមិនមានទីបំផុត ល្បីល្បាញទៅគ្រប់ទិស ជាសត្វមិនចេះឆ្អែត ប្រាថ្នាដើម្បីផឹកនូវទឹកសមុទ្រ គឺសាគរ ដែលជាម្ចាស់នៃទន្លេ ។

(៦៨៩) (សមុទ្ទទេវតា ពោលថា) សមុទ្ទធំនោះ ជួនកាល ក៏ស្រកទៅ ជួនកាល ក៏ជោរឡើង ទីបំផុតនៃទឹកសមុទ្ទនោះដែលសកល-លោកផឹកហើយ មិនប្រាកដទេ ឮថាសាគរ អ្នកណាមួយក៏មិនអាចផឹកទឹក ឲ្យអស់បានឡើយ ។

ចប់ សមុទ្ទជាតក ទី ៦ ។

## កាមវិលាបជាតក

(៦៩០) (បុរសម្នាក់ ពោលថា) ម្នាលសត្វស្លាប អ្នកទៅកន្លែងខ្ពស់ ទៅដោយស្លាបបាន ទៅតាមអាកាសបាន សូមអ្នកប្រាប់ (ប្រពន្ធខ្ញុំ) ដែលមានភ្លៅស្រលូនដូចដើមចេក ប្រពន្ធរបស់ខ្ញុំនោះ នឹងរលឹកខ្ញុំអស់កាលយូរ ។

(៦៩១) ប្រពន្ធខ្ញុំនោះ មិនដឹងនូវដាវនិងលំពែងនេះឯង ដែលគេដោតចុះហើយ ក៏ជាស្រីឆ្នាស តែនឹងធ្វើនូវសេចក្ដីក្រោធ ការក្រោធរបស់នាងនោះ រមែងក្ដៅក្រហាយដល់ខ្ញុំ (ឯដាវនិងលំពែងដែលគេដោត) ក្នុងទីនេះ មិនមែនក្ដៅក្រហាយដល់ខ្ញុំទេ ។

(៤៩២) ឯស ឧប្បលសន្នាហោ និក្ខញ្ចុស្សីសកោហិតំ(១)

កាសិកញ្ច មុទុំ វត្ថំ តប្បេតុ ធនកាមិយា ។

កាមវិលាបជាតកំ សត្តមំ ។

## ឧទុម្ពរជាតកំ

(៤៩៣) ឧទុម្ពរា ចិមេ បក្កា និគ្រោធា ច កបិត្ថនា

ឯហិ និក្ខម្ម ភុញ្ជស្សុ កឹ ជិឃច្ឆាយ មិយ្យសិ ។

(៤៩៤) ឯវំ សោ សុហិតោ ហោតិ យោ វុឌ្ឍមបចាយតិ

យថាហមជ្ជ សុហិតោ ទុមបក្កានិ មាសិតោ ។

(៤៩៥) យំ វនេជោ វនេជស្ស វញ្ចេយ្យ កបិនោ កបិ

ទហរោបិ ន សទ្ទេយ្យ(២) ន ហិ ជិណ្ណោ ជរាកបីតិ ។

ឧទុម្ពរជាតកំ អដ្ឋមំ ។

---

១ ម. និក្ខញ្ចុស្សីសកោហិតំ ។ ២ ម. ទហរោ ភតំ សទ្ទេយ្យ ។



(៤៩២) ឈ្នួតផ្កាជាម្កុដឧប្បល នឹងគ្រឿងនោះ ចិញ្ចៀនមាស សំពត់មានសាច់ដ៏ទន់ ដែលជននាំមកអំពីដែនកាសី ទុកដាក់លើក្បាល ដំណេក (ប្រពន្ធខ្ញុំ) ជាស្រីត្រូវការទ្រព្យ ចូរយកចំអែមជីវិតឲ្យស្កប់ស្កល់ចុះ ។

ចប់ កាមវិលាបជាតក ទី ៧ ។

## ឧទុម្ពរជាតក

(៤៩៣) (ស្វាធំ ពោលថា) ពួកដើមល្វាផង ដើមជ្រៃផង ដើមទ្រឹតផងទាំងនេះឯង សុទ្ធតែមានផ្លែទុំ អ្នកចូរមកហើយចេញទៅបរិភោគ (នូវផ្លែឈើទាំងនោះ) អ្នកស្លាប់ដោយសេចក្តីឃ្លាន ដូចម្តេចកើត ។

(៤៩៤) (ស្វាតូច ពោលថា) បុគ្គលណា គោរពកោតក្រែងចាស់ព្រឹទ្ធា-ចារ្យ បុគ្គលនោះ បានឈ្មោះថា ឆ្អែតស្កប់ស្កល់ហើយយ៉ាងនេះ ដូចជាខ្ញុំថ្ងៃនេះ ខ្ញុំបានបរិភោគផ្លែឈើទុំឆ្អែតស្កប់ស្កល់ហើយ ។

(៤៩៥) (ស្វាធំ ពោលថា) ស្វាដែលកើតក្នុងព្រៃ គប្បីបញ្ឆោតនូវស្វាដែលកើតក្នុងព្រៃដូចគ្នា ព្រោះហេតុណា ហេតុនោះ ស្វាដែលនៅក្មេង (ដូចជាអ្នក) មិនគប្បីជឿបានទេ ស្វាចាស់គ្រាំគ្រា (ដូចយើង) ក៏មិនគប្បីជឿបានដែរ ។

ចប់ ឧទុម្ពរជាតក ទី ៨ ។

## កោមារិយបុត្តជាតកំ

(៤៩៦) បុរេ តុវំ សីលវតំ សកាសេ
ឱក្កន្តិកំ កីឡសិ អស្សមម្ហិ
ករោហរេ មក្កដិយានិ មក្កដ
ន តំ មយំ សីលវតំ រមាម ។
(៤៩៧) សុតា ហិ មយ្ហំ បរមា វិសុទ្ធិ(១)
កោមារិយបុត្តស្ស ពហុស្សុតស្ស
មា ទានិ មំ មញ្ញិ តុវំ យថា បុរេ
ឈានានុយុត្តា(២) វិហរាម អាវុសោ ។
(៤៩៨) សចេបិ សេលស្មិំ វបេយ្យ ពីជំ
ទេវោ ច វស្សេ ន ហិ តំ វិរូឡ្ហេ
សុតា ហិ តេ សា បរមា វិសុទ្ធិ
អារា តុវំ មក្កដ ឈានភូមិយា ។

កោមារិយបុត្តជាតកំ នវមំ ។

---

១ ម. សុណោហិ មយ្ហំ បរមំ វិសុទ្ធិំ ។ ២ ឱ. ឈានានុយុត្តោ ។ ម. ឈានានុយុត្តោ វិហោមិ ។



## កោមារិយបុត្តជាតក

(៤៩៦) (ពួកតាបស ពោលថា) ម្នាលស្វា កាលពីដើមអ្នកឯង លោតលេងជិតអាស្រម ក្នុងសំណាក់នៃយើងអ្នកមានសីល អ្នកចូរធ្វើ (នូវអាការៈទាំងឡាយ មានញាក់មុខជាដើម) ដែលជាល្បែងរបស់ស្វា យើងមិនត្រេកអរនឹងសីលតែរបស់ឯង ។

(៤៩៧) (ស្វា ពោលថា) សេចក្តីបរិសុទ្ធិដ៏ក្រៃលែង របស់តាបសឈ្មោះកោមារិយបុត្ត ជាពហុស្សុត ខ្ញុំបានឮហើយឥឡូវនេះ លោកកុំសំគាល់ខ្ញុំដូចមុនឡើយ នែអាវុសោ (ឥឡូវនេះ) ពួកយើងជាអ្នកប្រកបក្នុងឈាន ។

(៤៩៨) (តាបស ពោលថា) ប្រសិនបើ បុគ្គលគប្បីព្រោះ ពូជលើថ្ម ទោះភ្លៀងបង្អុរចុះក៏ដោយ ឯពូជនោះមិនគប្បីលូតលាស់បានឡើយ សេចក្តីបរិសុទ្ធិដ៏ក្រៃលែង នោះអ្នកបានឮហើយ នែស្វា អ្នកឆ្ងាយអំពីឈានភូមិណាស់ ។

ចប់ កោមារិយបុត្តជាតក ទី ៩ ។

# ពកជាតកំ

(៤៩៩) បរបាណឃាតេ ជីវន្តោ   មំសលោហិតភោជនោ

ពកោ វតំ សមាទាយ   ឧបបជ្ជិ ឧបោសថំ ។

(៥០០) តស្ស សក្កោ វតញ្ញាយ   អជរូបេនុបាគមិ

វីតតបោ អជ្ឈប្បត្តោ   ភញ្ជិ លោហិតបោ តបំ ។

(៥០១) ឯវមេវ ឥធេកច្ចេ   សមាទានស្មិំ ទុព្វលា

លហុំ ករោន្តិ អត្តានំ   ពកោ អជការណាតិ ។

ពកជាតកំ ទសមំ ។

កុម្ភវគ្គោ បញ្ចមោ ។



# ពកជាតក

(៤៩៩) (ព្រះសុគត ទ្រង់ត្រាស់ថា) ចចកកាលរស់នៅ មានសាច់និងឈាមជាភោជន ព្រោះសម្លាប់នៃសត្វដទៃ (ហើយចចក) សមាទាននូវវត្តក្នុងឧបោសថ ។

(៥០០) សក្កទេវរាជ បានដឹងច្បាស់នូវវត្តរបស់ចចកនោះ ហើយចូលមកដោយ (ក្លែងខ្លួន) ជាពពែ ចចកមានតបៈទៅប្រាសហើយ ជាសត្វផឹកនូវឈាម (នៃសត្វដទៃ) បានស្ទុះចូលទៅ (ដើម្បីចាប់ពពែស៊ី) ហើយក៏ទំលាយបង់នូវតបៈ ដែលខ្លួនសមាទានហើយ ។

(៥០១) បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានកំឡាំងថយ ក្នុងការសមាទាន ឈ្មោះថា ធ្វើខ្លួនឲ្យស្រាល ដូចជាចចក (ដែលទំលាយនូវតបៈរបស់ខ្លួន) ព្រោះហេតុតែពពែ ក៏យ៉ាងនោះឯង ។

ចប់ ពកជាតក ទី ១០ ។

ចប់ វគ្គទី ៥ ។

## តស្សុទ្ទានំ

វិករុក្ខ សុបត្តសយ្ហយោ
សុចិសម្មត ពិន្ទុស្សរោ ចតុស្សរោ
សត្តិមបត្តិ ចណ្ឌី ជកការបិជា
អថ មណ្ណជយោ វការកោឋ ធសោតិ ។

## វគ្គុទ្ទានំ

សត្ថិយេហ្យ បធុមោទេវ នឧកាលេន តតិយំ
អក្ខគ្គំ យជវគ្គំ ទុកនិបាតម្ហិ សង្គហិតំ ។

ទុកនិបាតំ និដ្ឋិតំ

---





## ឧទ្ទាននៃកុម្ពវគ្គនោះ គឺ

និយាយអំពីផ្កានឹងប្រសើរ ១ ស្តេចក្អែកឈ្មោះសុបត្តៈ ១ រូបកាយដែលសន្មតថាស្អាត ១ ក្អែកមានសំឡេងក្រអៅ ១ ចចកមានកន្ទួប ១សេក ១ សម្ព្រេចម្ចាស់នៃខ្ទេ ១ ប្រពន្ធឆ្នាស ១ ស្វាចាស់ ១ ល្បែងរបស់ស្វា ១ កុក ១ ត្រូវជា ១០ ។

## ឧទ្ទាននៃវគ្គ គឺ

និយាយអំពីសន្ថវវគ្គ ១ បទុមវគ្គ ១ ឧទបានវគ្គ ជាគំរប់បី ១ អព្ភន្តរវគ្គ ១ កុម្ភវគ្គ ១ (ចាំងអស់នេះ) រួមបញ្ចូល ក្នុងទុកនិបាត ។

ចប់ ទុកនិបាត ។

## ចតុក្កនិបាតជាតកំ

## កាលិង្គវគ្គោ

## ចុល្លកាលិង្គជាតកំ

(៨០២) វិវរថ ឥមាសំ ទ្វារំ នគរន្តិ បវិសន្តុ(១)
អរុណរាជស្ស សីហេន សុសិដ្ឋេន សុរក្ខិតំ
នន្ទិសេនេន ។

(៨០៣) ជយោ កាលិង្គានំ អសយ្ហសាហិនំ
បរាជយោ អនយោ អស្សកានំ
ឥច្ចេវំ តេ ភាសិតំ ព្រហ្មចារិ
ន ឧជ្ជុភូតា វិតថំ ភណន្តិ ។

(៨០៤) ទេវា មុសាវាទមុបាតិវត្តា
សច្ចំ ធនំ បរមំ តេសុ សក្ក
តំ តេ មុសា ភាសិតំ ទេវរាជ
កឹ វា បដិច្ច មឃវា មហិន្ទ ។

១ ម. នគរំ បវិសន្តុ មយា ។

## ចតុក្កនិបាតជាតក

## កាលិង្គវគ្គ

## ចុល្លកាលិង្គជាតក

(៨០២) (នន្ទិសេនាមាត្យ ពោលថា) អ្នកទាំងឡាយ ចូរបើកទ្វារ ថ្វាយព្រះរាជធីតាទាំង ៤ ព្រះអង្គនេះ ដើម្បីស្តេចចូលទៅកាន់ក្នុងព្រះនគរ ដែលខ្ញុំជាអាមាត្យឈ្មោះនន្ទិសេន ជាបុរសសីហៈរបស់ព្រះបាទអរុណ ដែលអាចារ្យប្រៀនប្រដៅល្អ រក្សាល្អហើយ ។

(៨០៣) (ព្រះបាទកាលិង្គៈ ពោលថា) ម្នាលព្រហ្មចារីតាបស អ្នកពោលយ៉ាងនេះថា ជ័យជំនះនឹងមាន ដល់ពួកកាលិង្គៈ ដែលជាអ្នកអត់ធន់ចំពោះទុក្ខភ័យ ដែលគេអត់ធន់មិនបាន បរាជ័យនឹងមាន ដល់ពួកអស្សកៈដូច្នេះ ជនទាំងឡាយ អ្នកមានសន្តានស្មោះត្រង់ មិនពោលនូវពាក្យមិនពិតឡើយ ។

(៨០៤) (តាបសពោធិសត្វ ពោលថា) បពិត្រសក្កទេវរាជ ពួកទេវតា ប្រព្រឹត្តកន្លងហើយ នូវមុសាវាទ ព្រះអង្គទ្រង់ធ្វើ នូវពាក្យពិត ដ៏ទៀងទាត់យ៉ាងក្រៃលែង បពិត្រមឃវាទេវរាជ ជាធំលើផែនដី ម្យ៉ាងទៀត ព្រះអង្គអាស្រ័យហេតុអ្វី ទើបពោលនូវពាក្យមុសាវាទនោះ ។

(៨០៥) ននុ តេ សុតំ ព្រាហ្មណ ភញ្ញមានេ
ទេវា ន ឥស្សន្តិ បុរិសបរក្កមស្ស
ទមោ សមាធិ មនសោ អទេជ្ជោ
អព្យគ្គតា និក្ខមនញ្ច កាលេ
ទឡ្ហញ្ច វីរិយំ បុរិសបរក្កមោ ច
តេនេវ អាសិ វិជយោ អស្សកានន្តិ ។

ចូឡកាលិង្គជាតកំ បឋមំ ។

## មហាអស្សារោហជាតកំ

(៨០៦) អទេយ្យេសុ ទទំ[១] ទានំ ទេយ្យេសុ នប្បវេច្ឆតិ
អាបាសុ ព្យសនំ បត្តោ សហាយំ នាធិគច្ឆតិ ។
(៨០៧) អទេយ្យេសុ អទទំ ទានំ ទេយ្យេសុ យោ បវេច្ឆតិ
អាបាសុ ព្យសនំ បត្តោ សហាយំ អធិគច្ឆតិ ។

---
១ ម. ទទន្តំ ។



(៨០៥) (ព្រះអង្គ ពោលថា) បពិត្រព្រាហ្មណ៍ ក្រែងលោកបានឮពាក្យគេនិយាយថា ពពួកទេវតាមិនច្រណែន ចំពោះសេចក្តីព្យាយាមរបស់បុរសទេ ការទូន្មានខ្លួន ១ ការតម្កល់ចិត្ត មិនរែកចិត្ត ១ ការមិនបន្ធូរបន្ថយ ការប្រឹងប្រែង ក្នុងកាលគួរ ១ ព្យាយាមដ៏មាំ ១ ការសង្វាតរបស់បុរស ១ (មានដល់ពួកអស្សកៈ) ហេតុនោះបានជា ជ័យជំនះមានហើយ ដល់ពួកអស្សកៈ ។

ចប់ ចូឡកាលិង្គជាតក ទី ១ ។

## មហាអស្សារោហជាតក

(៨០៦) (ព្រះពោធិសត្វ ត្រាស់ថា) បុគ្គលណា កាលឲ្យចំពោះជនទាំងឡាយដែលមិនដែលឲ្យ (ដល់ខ្លួន) មិនឲ្យចំពោះជនទាំងឡាយដែលធ្លាប់ឲ្យ បុគ្គលនោះ បានដល់នូវសេចក្តីវិនាស មិនបាននូវមិត្រសំឡាញ់ ក្នុងគ្រាមានសេចក្តីអន្តរាយទាំងឡាយ ។
(៨០៧) បុគ្គលណា មិនឲ្យទានចំពោះជនទាំងឡាយ ដែលមិនដែលឲ្យ បានឲ្យចំពោះជនទាំងឡាយដែលឲ្យ បុគ្គលនោះ ក៏ដល់នូវសេចក្តីវិនាស មិនបាននូវសំឡាញ់ ក្នុងកាលមានសេចក្តីអន្តរាយ ទាំងឡាយ ។

(៨០៨) សញ្ញោគសម្ភោគវិសេសទស្សនំ
អនរិយធម្មេសុ សឋេសុ នស្សតិ
កតញ្ច អរិយេសុ ច អញ្ជសេសុ(១)
មហប្ផលំ ហោតិ អណុម្បិ តាទិសុ ។

(៨០៩) យោ បុព្វេ កតកល្យាណោ អកា លោកេសុ ទុក្ករំ
បច្ឆា កយិរា ន វា កយិរា អច្ចន្តំ បូជនារហោតិ ។

មហាអស្សារោហជាតកំ ទុតិយំ ។

## ឯករាជជាតកំ

(៨១០) អនុត្តរេ កាមគុណេ សមិទ្ធេ
ភុត្វាន បុព្វេ វសី ឯករាជ
សោទានិ ទុគ្គេ នរកម្ហិ ខិត្តោ
នប្បជ្ជហេ វណ្ណពលំ បុរាណំ ។

១ ម. អជ្ជវេសុ ។



(៨០៨) ការសំដែងនូវសេចក្តីស្និទ្ធស្នាល ទាំងការបរិភោគរួម ឲ្យវិសេស ក្នុងពួកជនអ្នកមានធម៌មិនប្រសើរ ជាអ្នកអួតអាង ក៏រមែងវិនាស ម្យ៉ាងទៀត សូម្បីទានបន្តិចបន្តួច ដែលបុគ្គលធ្វើហើយ ចំពោះពួកព្រះអរិយៈផង ចំពោះពួកបុគ្គលអ្នកមានចិត្តស្មោះត្រង់ផង ជាទានមានផលច្រើន ។

(៨០៩) បុគ្គលណា បានធ្វើឧបការៈដ៏ល្អទុកហើយ ក្នុងកាលមុន បុគ្គលនេះ ឈ្មោះថា បានធ្វើអំពើដែលគេធ្វើបាន ដោយក្រក្រពេក ក្នុងលោក លុះដល់កាលជាខាងក្រោយ បុគ្គលនោះធ្វើ (គុណនីមួយដទៃទៀតក្តី) មិនធ្វើក្តី ក៏ឈ្មោះថាជាបុគ្គលគួរដល់ការបូជាដោយពិត ។

ចប់ មហាអស្សារោហជាតក ទី ២ ។

## ឯករាជជាតក

(៨១០) (ព្រះបាទទុព្ភិសេន ទ្រង់ត្រាស់ថា) បពិត្រព្រះអង្គ ជាឯករាជ កាលពីដើម ព្រះអង្គនៅសោយកាមគុណទាំងឡាយ ជារបស់ស្តុកស្តម្ភ គេមិនប្រសើរជាងគ្មាន ឥឡូវនេះ ព្រះអង្គនោះ គេបោះទៅក្នុងរណ្តៅ ក្រហេងក្រហូងហើយ នៅតែមិនលះបង់នូវពណ៌សម្បុរនឹងកម្លាំងពីដើម ។

(៨១១) បុត្តោ ឧត្តិ ច តតោ ច មយ្ហំ

សម្បជ្ជតា ទុត្តិសេន អហោសិ

តស្មាតិ លទ្ធាន កាជេន្ទ ភជ

ជហោ អហំ វណ្ណពលំ បុរាណំ ។

(៨១២) សត្តិ ភោរេ បរិច្ចិតាធ

យសស្សិនំ បញ្ញវន្តំ វិសយ្ហ

យសោ ច លទ្ធា បុរិមំ ឧឡារំ

នប្បជ្ជហេ វណ្ណពលំ បុរាណំ ។

(៨១៣) បទុដ្ឋ ទុក្ខេន សុខំ ជហិត្វា

សុខេន វា ទុក្ខមសយ្ហសាហំ

ឧភយត្ថ សន្តោ អភិនិព្វុតត្តា

សុខេ ច ទុក្ខេ ច ភវន្តិ តុល្យាតិ ។

ឯកាទសជាតកំ តតិយំ ។



(៨១១) (ព្រះបាទពារាណសី ពោលថា) បពិត្រព្រះបាទទុត្តិសេន សេចក្តីអត់ធន់ក្តី សេចក្តីប្រព្រឹត្តិតបៈក្តី ខ្ញុំមានបំណងទុកហើយ ពីមុន បពិត្រមហារាជ សព្វថ្ងៃនេះ ខ្ញុំបានសម្រេចនូវសេចក្តីប្រាថ្នានោះហើយ កើតឡើងរបស់នូវពណ៌សម្បុរ និងកំឡាំង ពីដើម ដូចម្តេចកើត ។

(៨១២) (ពាន សីល ទេវបុត្តសថកម្ម) តាំងអស់របស់ខ្ញុំ សម្រេចហើយ បពិត្រព្រះអង្គមានយស មានប្រាជ្ញាអ្នកណាគ្រប់សង្កត់ មិនកើត ខ្ញុំបានយសធំ ដោយសារផលខ្ញុំ មិនធ្លាប់បានក្នុងកាលពីដើមហើយ ទើបខ្ញុំមិនលះបង់ពណ៌សម្បុរ និងកម្លាំង ពីដើម ។

(៨១៣) បពិត្រព្រះជនិន្ទ្រ ពួកសប្បុរស បន្ទាបង់នូវផលសុខ ដោយទុក្ខ បន្ទាបង់ នូវសេចក្តីទុក្ខ ដែលបុគ្គលគ្រប់សង្កត់មិនបាននោះ ដោយសារឈានសុខ ជាអ្នកមានចិត្តត្រជាក់ សេពនូវសេចក្តីសុខនិងទុក្ខទាំង ២ យ៉ាង ។

ចប់ ឯកាទសជាតក ទី ៣ ។

## ទទ្ទរជាតកំ

(៨១៤) ឥមានិ មំ ទទ្ទរ តាបយន្តិ
វាចាទុរុត្តានិ មនុស្សលោកេ
មណ្ឌូកភក្ខា ឧទកន្តសេវី
អាសីវិសំ មំ អវិសា សបន្តិ ។

(៨១៥) សកា រដ្ឋា បព្វាជិតោ អញ្ញំ ជនបទំ គតោ
មហន្តំ កោដ្ឋំ កយិរាថ ទុរុត្តានំ និធេតវេ ។

(៨១៦) យត្ថ បោសំ ន ជានន្តិ ជាតិយា វិនយេន វា
ន តត្ថ មានំ កយិរាថ វសំ អញ្ញាតកេ ជនេ ។

(៨១៧) វិទេសវាសំ វសតោ ជាតវេទសមេនបិ
ខមិតព្វំ សបញ្ញេន អបិ ទាសស្ស តជ្ជិតំ ។

ទទ្ទរជាតកំ ឆដ្ឋំ ។



## ទទ្ទរជាតក

(៨១៤) (នាគឈ្មោះចុល្លទទ្ទរៈ ពោលថា) បពិត្រមហាទទ្ទរៈ ពាក្យអាក្រក់ទាំងឡាយនេះ ក្នុងមនុស្សលោក ធ្វើឲ្យក្តៅក្រហាយ ពួកកង្កែបទាំងឡាយនេះ មិនមានពិសសោះ ប៉ុន្តែហ៊ានជេរខ្ញុំ ដែលមានពិស ជាអ្នកស៊ីកង្កែបផង នៅក្នុងទឹកផង ។

(៨១៥) (នាគឈ្មោះមហាទទ្ទរៈ និយាយតបទៅវិញថា) បុគ្គលដែលគេបំបរបង់ចេញចាកដែនរបស់ខ្លួនហើយ ទៅកាន់ជនបទឯទៀត គប្បីធ្វើជង្រុកឲ្យធំ ដើម្បីដាក់នូវពាក្យអាក្រក់ទាំងឡាយចុះ ។

(៨១៦) ពួកជនមិនដឹងនូវបុរស ដោយជាតិ ឬដោយវិន័យ គឺគុណសម្បត្តិ ក្នុងទីណា បុគ្គលកាលនៅក្នុងសំណាក់ នៃពួកជនដែលខ្លួនមិនស្គាល់ មិនគប្បីធ្វើសេចក្តីប្រកាន់ ក្នុងទីនោះឡើយ ។

(៨១៧) បុគ្គលប្រកបដោយប្រាជ្ញា (សូម្បីមានអានុភាព) ស្មើដោយភ្លើង កាលនៅក្នុងប្រទេសដទៃ គប្បីតែអត់សង្កត់ពាក្យ ទោះបីមនុស្សជាខ្ញុំគេគម្រាមក៏ដោយ ។

ចប់ ទទ្ទរជាតក ទី ៦ ។

# សីលវីមំសជាតកំ

(៨១៨) នត្ថិ លោកេ រហោ នាម បាបកម្មំ បកុព្វតោ
បស្សន្តិ វនភូតានិ តំ ពាលោ មញ្ញតេ រហោ ។
(៨១៩) អហំ រហោ ន បស្សាមិ អសុញ្ញំ វាបិ ន វិជ្ជតិ
យត្ថ អញ្ញំ ន បស្សាមិ អសុញ្ញំ ហោតិ តំ មយា ។
(៨២០) ទុជ្ជច្ចោ ច សុជច្ចោ ច នន្ទោ ច សុខវឌ្ឍតោ(១)
វជ្ជោ អទ្ធុវសីលោ ច តេ ធម្មំ ជហុមត្ថិកា ។
(៨២១) ព្រាហ្មណោ ច កថំ ជហេ សព្វធម្មាន បារគូ
យោ ធម្មំ អនុបាលេតិ ធិតិមា សច្ចនិក្កមោ ។

សីលវីមំសជាតកំ បញ្ចមំ ។

១ ម. សុខវឌ្ឍោ ។



# សីលវីមំសជាតក

(៨១៨) (មាណពពោធិសត្វ ពោលថា) ធម្មតាសេចក្ដីស្ងាត់កំបាំង របស់បុគ្គលអ្នកធ្វើអំពើអាក្រក់ មិនមានក្នុងលោកទេ ពួកភូតដែលនៅក្នុងព្រៃតែងឃើញបាន បុគ្គលពាល តែងសំគាល់ នូវអំពើអាក្រក់ ដែលធ្វើនោះថា ស្ងាត់កំបាំង ។

(៨១៩) ខ្ញុំមិនឃើញថា ស្ងាត់កំបាំងទេ ឬទីដែលសូន្យ (ចាកសត្វ) ក៏មិនមាន ខ្ញុំមិនឃើញថា សូន្យ ក្នុងទីណា ទីនោះក៏មិនសូន្យអំពីខ្ញុំទេ ។

(៨២០) (ព្រះសាស្ដា ត្រាស់ថា) ពួកមាណព គឺ ទុជ្ជច្ចៈ១ សុជច្ចៈ១ នន្ទៈ១ សុខវឌ្ឍនៈ១ វជ្ជៈ១ អទ្ធុវសីលៈ១ (ជាដើម) នោះជាអ្នកត្រូវការ (ដោយស្ត្រី) ក៏សាបសូន្យចាកសភាវៈ (ការបាននូវស្ត្រី) ។

(៨២១) ចំណែកព្រាហ្មណ៍ណា ដែលមានប្រាជ្ញា មានព្យាយាមក្នុងសច្ចៈ បានរក្សានូវធម៌ទុក ព្រាហ្មណ៍នោះជាអ្នកដល់នូវត្រើយនៃធម៌ទាំងពួង តើគប្បីសាបសូន្យ (ចាកការបាននូវស្ត្រី) ដូចម្ដេចកើត ។

ចប់ សីលវីមំសជាតក ទី ៥ ។

# សុជាតាជាតកំ

(៤៦៦) កឹ អណ្ឌកា ឥមេ ទេវ និក្ខិត្តា កំសមល្លកេ
ឧបលោហិតកា វគ្គូ តំ(១) មេ អក្ខាហិ បុច្ឆិតោ ។
(៤៦៧) យានិ បុរេ តុវំ ទេវិ ភណ្ឌុ នន្តកវាសិនី
ឧច្ឆង្គហត្ថា បចិនាសិ តស្សា តេ កោលិយំ ផលំ ។
(៤៦៨) ឧឌ្ឌយ្ហតេ ន រមតិ ភោគា វិប្បជហន្តិ តំ
តត្ថេវិមំ បដិនេថ យត្ថ កោលំ បចិស្សតិ ។
(៤៦៩) ហោន្តិ ហេតេ មហារាជ ឥទ្ធិប្បត្តាយ នារិយា
ខម ទេវ សុជាតាយ មាស្សា កុជ្ឈ រថេសភ ។

សុជាតាជាតកំ ឆដ្ឋំ ។

១ ឱ. ឥទំ ។





# សុជាតាជាតក

(៤៦៦) (នាងសុជាតាទេវី សួរថា) បពិត្រព្រះទេវៈ នេះផ្លែអ្វី មូលល្អិត មានពណ៌ក្រហម ដូចជាឈាម ដែលដាក់ក្នុងភាជន៍មាស ខ្ញុំម្ចាស់សួរហើយ សូមព្រះអង្គប្រាប់ឲ្យខ្ញុំ ។

(៤៦៧) (ព្រះបាទពារាណសី ទ្រង់ត្រាស់ថា) ម្នាលទេវី ក្នុងកាលមុន នាងមានក្បាលរលីង ស្លៀកកំណាត់សំពត់ចាស់ មានដៃក្នុងថ្នក់ ហើយបេះនូវផ្លែឈើទាំងឡាយណា (នេះ) គឺផ្លែពុទ្រារបស់នាងនោះហើយ ។

(៤៦៨) ស្រីថោកទាប រមែងក្តៅក្រហាយ មិនត្រេកអរ (ក្នុងរាជត្រកូល) ភោគៈរបស់ស្តេចទាំងឡាយ រមែងលះបង់នូវស្រីឥតបុណ្យនោះ ស្រីថោកទាប បេះនូវផ្លែពុទ្រាក្នុងទីណា អ្នកទាំងឡាយ ចូរនាំស្រីនោះទៅ ក្នុងទីនោះចុះ ។

(៤៦៩) (អាមាត្យពោធិសត្វ ទូលថា) បពិត្រមហារាជ ទោសខុស ព្រោះសេចក្តីប្រមាទទាំងនេះ រមែងមានដល់នារី ដែលដល់នូវយសសក្តិ បពិត្រព្រះទេវៈ សូមព្រះអង្គអត់ទោសដល់ព្រះនាងសុជាតាទេវី បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គកុំទ្រង់ព្រះពិរោធ ចំពោះព្រះនាងសុជាតាទេវីនោះឡើយ ។

ចប់ សុជាតាជាតក ទី ៦

# បលាសជាតកំ

(៤៦៦) អចេតនំ ព្រាហ្មណ អស្សុណន្តំ
ជានោ អជានន្តមិមំ បលាសំ
អារទ្ធវិរិយោ ធុវមប្បមត្តោ
សុខសេយ្យំ បុច្ឆសិ កិស្ស ហេតុ ។

(៤៦៧) ទូរេ សុតោ ចេវ ព្រហា ច រុក្ខោ
ទេសេ ឋិតោ ភូតនិវាសរូបោ
តស្មា នមស្សាមិ ឥមំ បលាសំ
យេ ចេត្ថ ភូតា តេ ធនស្ស ហេតុ ។

(៤៦៨) សោ តេ ករិស្សាមិ យថានុភាវំ
កតញ្ញុតំ ព្រាហ្មណ បេក្ខមានោ
កថំ ហិ អាគម្ម សតំ សកាសេ
មោឃា តេ អស្សុ បរិផន្ទិតានិ ។



# បលាសជាតក

(៤៦៦) (ព្រះទេវតាពោធិសត្វ ពោលថា) ម្នាលព្រាហ្មណ៍ អ្នកដឹង
ជាដើមពារនេះ ជាឈើឥតចេតនា ឥតចេះស្តាប់ ឥតដឹងអ្វីទេ
ជាអ្នកប្រារព្ធព្យាយាម មិនប្រហែសធ្វេសជានិច្ច ហេតុអ្វី ក៏សួរ
រកការដេកជាសុខ (របស់ដើមឈើ) ។

(៤៦៧) (ព្រាហ្មណ៍ ពោលថា) ដើមឈើ ប្រាកដក្នុងទីដ៏ឆ្ងាយផង ធំផង
ដុះនៅក្នុងទី (ខ្ពស់) មានសភាពជាទីនៅរបស់ភូត ហេតុនោះ
បានជា ខ្ញុំថ្វាយបង្គំដើមពារនេះ ពួកភូតណា នៅអាស្រ័យលើ
ដើមឈើនេះ (ខ្ញុំថ្វាយបង្គំ) ពួកភូតនោះ ព្រោះហេតុតែទ្រព្យ ។

(៤៦៨) (ព្រះទេវតា ពោលថា) ម្នាលព្រាហ្មណ៍ ខ្ញុំនោះឯង កាល
សម្លឹងឃើញនូវការដឹងគុណ ដែលអ្នកធ្វើហើយ ខ្ញុំនឹងធ្វើនូវការ
តបគុណដល់អ្នក តាមសមគួរដល់អានុភាព ការដែលអ្នក
មកខ្វល់ខ្វាយ ក្នុងសំណាក់សប្បុរស នឹងជារបស់សោះសូន្យ
ដូចម្តេចកើត ។

(៤៦៩) យោ តិន្ទុករុក្ខស្ស បរោ បិលក្ខោ
បរិវារិតោ បុព្វយញ្ញោ ឧឡារោ
តស្សេស មូលស្មឹ និធិ និខាតោ
អទាយាទោ គច្ឆ តំ ឧទ្ធរាហិ ។

បលាសជាតកំ សត្តមំ ។

## ជវសកុណជាតកំ[១]

(៤៧០) អករម្ហាសេ តេ កិច្ចំ យំ ពលំ អហុវម្ហសេ
មិគរាជ នមោ ត្យត្ថុ អបិ កិញ្ចិ លភាមសេ ។
(៤៧១) មម លោហិតភក្ខស្ស និច្ចំ លុទ្ទានិ កុព្វតោ
ទន្តន្តរគតោ សន្តោ ពហុំ យម្បិ ជីវសិ ។
(៤៧២) អកតញ្ញុមកត្តារំ កតស្ស អប្បដិការកំ
យស្មឹ កតញ្ញុតា នត្ថិ និរត្ថា តស្ស សេវនា ។

១ ឱ. សកុណជាតកំ ។



(៤៦៩) ដើមល្វៀបណា ដុះនៅខាងមុខដើមទន្លាប់ យញ្ញដែលគេធ្វើ ហើយក្នុងកាលមុនច្រើន ជាកំណប់ដែលគេកប់ទុកជុំវិញក្បែរ គល់ល្វៀបនោះឯង ជាកំណប់មិនមានអ្នកទទួល អ្នកចូរទៅ គាស់យកកំណប់ទ្រព្យនោះចុះ ។

ចប់ បលាសជាតក ទី ៧ ។

## ជវសកុណជាតក

(៤៧០) (សត្វសារសៈ ពោលថា) កម្លាំងណារបស់យើងមានហើយ យើងធ្វើកិច្ចដល់អ្នកតាមកម្លាំងនោះ បពិត្រមិគរាជ ខ្ញុំសូមក្រាបថ្វាយបង្គំអ្នក យើងគួរបានសាច់បន្តិចបន្តួចខ្លះ ។
(៤៧១) (រាជសីហ៍ ឆ្លើយតបថា) អ្នកឯងចូលទៅតាមចន្លោះ នៃធ្មេញរបស់ខ្ញុំ ដែលជាអ្នកស៊ី(សាច់)និងឈាម ធ្វើនូវអំពើអាក្រក់ ចាំនិងឡាយជានិច្ច រស់នៅ ដោយសាច់ណា សាច់នោះមានច្រើន ។
(៤៧២) (សារសៈឆ្លើយតបថា) សេចក្ដីដឹងគុណដែលគេធ្វើហើយ មិនមានក្នុងបុគ្គលណា ការសេពគប់នឹងបុគ្គល អ្នកមិនដឹងគុណដែលគេធ្វើហើយ មិនធ្វើ (គុណនឹងអ្នកណា) មិនតបស្នងសងគុណដល់អ្នកដែលធ្វើគុណហើយដល់ខ្លួននោះ ជាការឥតប្រយោជន៍ទេ

(៨៣៣) យត្ថ(១) សម្មុខចិណ្ណេន មិត្តធម្មោ ន លព្ភតិ

អនុស្សុយ្យមនក្កោសំ សណិកំ តម្ហា អបក្កមេតិ ។

ពិសកុណជាតកំ អដ្ឋមំ ។

## ឆវជាតកំ

(៨៣៤) សព្វំ ឥទញ្ច មរិកតំ ឧភោ ធម្មំ ន បស្សរេ

ឧភោ បកតិយា ចុតា យោ ចាយំ មន្តំ វាចេតិ

យោ ច មន្តំ អធីយតិ ។

(៨៣៥) សាលីនំ ឱទនំ ភុញ្ជេ សុចិំ មំសូបសេចនំ

តស្មា ឯតំ ន សេវាមិ ធម្មំ ឥសីភិ សេវិតំ ។

(៨៣៦) បរិព្វជ មហា លោកោ បចន្តញ្ញេបិ បាណិនោ

មា តំ អធម្មោ អាចរិតោ អស្មា កុម្ភមិវាភិទា ។

១ ម. យស្ស ។



(៨៣៣) បណ្ឌិត មិនបានមិត្តធម៌ ដោយសារគុណដែលខ្លួនសន្សំហើយ ក្នុងទីចំពោះមុខបុគ្គលណា បណ្ឌិតមិនត្រូវប្រច្រណ៍ មិនត្រូវជេរ ត្រូវតែគេចចេញចាកបុគ្គលនោះ ដោយសន្សឹម ៗ ។

ចប់ ពិសកុណជាតក ទី ៨ ។

## ឆវជាតក

(៨៣៤) (ពោធិសត្វ ក្រាបទូលព្រះបាទពារាណសីថា) កិច្ចដែលយើងទាំងពីរនាក់ធ្វើហើយ ទាំងអស់នេះជាកិច្ចលាមក បុគ្គលណា (អង្គុយក្នុងទីទាប) បង្ហាញមន្ត ១ បុគ្គលណា (អង្គុយក្នុងទីខ្ពស់) រៀនយកមន្ត ១ បុគ្គលទាំងពីរនាក់(នោះ) មិនឃើញនូវបោរាណធម៌ផង បុគ្គលទាំងពីរនាក់ (នោះ) ឃ្លាតចាកប្រក្រតីផង ។

(៨៣៥) (ព្រាហ្មណ៍បុរោហិត ឆ្លើយតបថា) ខ្ញុំបរិភោគបាយស្រូវសាលីស្អាត (របស់ស្ដេចនេះ) លាយដោយសាច់ ហេតុនោះបានជាខ្ញុំមិនសេពគប់នូវធម៌ ដែលពួកឥសីសេពគប់ហើយនោះទេ ។

(៨៣៦) (ពោធិសត្វពោលថា) អ្នកចូរចៀសចេញពីទីនេះទៅ លោកនេះធំទូលាយ ពួកសត្វឯទៀត តែងស្ងោរចំអិនដែរ អ្នកកុំប្រព្រឹត្តអធម៌ ដូចជាថ្មដែលបំបែកនូវឆ្នាំងឡើយ ។

(៨៣៧) ធិរត្ថុ តំ យសលាភំ ធនលាភញ្ច ព្រាហ្មណ
យា វុត្តិ វិនិបាតេន អធម្មចរណេន វា ។

ឆវកជាតកំ នវមំ ។

## សយ្ហជាតកំ

(៨៣៨) សសមុទ្ទបរិយាយំ មហឹ សាគរកុណ្ឌលំ
ន ឥច្ឆេ សហ និន្ទាយ ឯវំ សយ្ហ វិជានហិ ។

(៨៣៩) ធិរត្ថុ តំ យសលាភំ ធនលាភញ្ច ព្រាហ្មណ
យា វុត្តិ វិនិបាតេន អធម្មចរណេន វា ។

(៨៤០) អបិ ចេ បត្តមាទាយ អនាគារោ បរិព្វជេ
សា ឯវ ជីវិកា សេយ្យោ យា ចាធម្មេន ឯសនា ។



(៨៣៧) ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលនូវការបានយសនឹងការបានទ្រព្យ ព្រោះការប្រព្រឹត្តិបំផ្លាញខ្លួន ឬដោយកិរិយាប្រព្រឹត្តិអធម៌ ។

ចប់ ឆវកជាតក ទី ៩ ។

## សយ្ហជាតក

(៨៣៨) (តាបសពោធិសត្វ ពោលថា) បុគ្គលមិនគប្បីប្រាថ្នានូវផែនដី ដែលមានសណ្ឋានដូចកុណ្ឌល គឺកណ្ដាលសាគរ មានសមុទ្រព័ទ្ធជុំវិញ មួយអន្លើដោយពាក្យនិន្ទាឡើយ ម្នាលសយ្ហអាមាត្យ ចូរអ្នកដឹងយ៉ាងនេះចុះ ។

(៨៣៩) ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលការបានយស នឹងការបានទ្រព្យ ព្រោះការប្រព្រឹត្តិបំផ្លាញខ្លួន ឬដោយការប្រព្រឹត្តិអធម៌ ។

(៨៤០) សូម្បីអាត្មាជាអ្នកមិនមានផ្ទះសម្បែង ប្រព្រឹត្តកាន់បាត្រ(សូមគេ) ការចិញ្ចឹមជីវិតនោះឯង ប្រសើរជាជាងការស្វែងរក មិនប្រកបដោយធម៌ ។

(៥៤១) អបិ ចេ បត្តមាទាយ អនាគារោ បរិព្វជេ
អញ្ញំ អហឹសយំ លោកេ អបិ រជ្ជេន តំ វរន្តិ ។

សញ្ញជាតកំ ទសមំ ។

កាលិង្គវគ្គោ បឋមោ ។

## តស្សុទ្ទានំ

វិវរ ច អទេយ្យ សមិទ្ធវរំ
អថ ទទ្ទរ បាបមហត្ថិកខោ
អថ គោធ បលាសវរញ្ចវរោ
បុនបិ សសមុទ្ទវរេន ទស ។

---



(៥៤១) សូវកាត្អល់អ្នកមិនមានផ្ទះសម្បែង ប្រព្រឹត្តកាន់បាត្រ មិនបៀតបៀនសត្វដទៃក្នុងលោក ការប្រព្រឹត្តនោះ ប្រសើរជាជាងរាជសម្បត្តិទៅទៀត ។

ចប់ សញ្ញជាតក ទី ១០ ។

ចប់ កាលិង្គវគ្គ ទី ១ ។

## ឧទ្ទាននៃកាលិង្គវគ្គនោះ គឺ

និយាយអំពីការបើកទ្វារ ១ ជនមិនឲ្យ ១ កាមគុណដ៏មាំមួន ១ នាគឈ្មោះទទ្ទរៈ ១ អំពើបាបមិនមានស្នាក់កំបាំង ១ ផ្លែពុទ្រា ១ ដើមពារ ១ ការធ្វើអំពើដ៏ប្រសើរ ១ អំពើលាមក ១ ផែនដីមានសមុទ្រព័ទ្ធជុំវិញ ១ ត្រូវជា ១០ ។

# បុចិមន្ទវគ្គោ

## បុចិមន្ទជាតកំ

(៨៦២) ឧដ្ឋេហិ ចោរ កឹ សេសិ កោ អត្ថោ សុបិនេន តេ
មា តំ គហេសុ រាជានោ គាមេ កិព្ពិសការកំ ។
(៨៦៣) យន្នុ ចោរំ គហេស្សន្តិ គាមេ កិព្ពិសការកំ
កឹ តត្ថ បុចិមន្ទស្ស វនេ ជាតស្ស តិដ្ឋតោ ។
(៨៦៤) ន ត្វំ អស្សត្ថ ជានាសិ មម ចោរស្ស ចន្តរំ
ចោរំ គហេត្វា រាជានោ គាមេ កិព្ពិសការកំ
អប្បេន្តិ[១] និម្ពសូលស្មឹ តស្មឹ មេ សង្កតេ មនោ ។
(៨៦៥) សង្កេយ្យ សង្កិតព្វានិ រក្ខេយ្យានាគតំ ភយំ
អនាគតភយា ធីរោ ឧភោ លោកេ អវេក្ខតីតិ ។

បុចិមន្ទជាតកំ បឋមំ ។

---
១ ម. ឧប្បេន្តិ ។

# បុចិមន្ទវគ្គ

## បុចិមន្ទជាតក

(៨៦២) (និម្ពរុក្ខទេវតា ពោលថា) ម្នាលចោរ អ្នកចូរក្រោកឡើង អ្នកដេកធ្វើអ្វី ប្រយោជន៍អ្វីដោយការដេកលក់របស់អ្នក កុំឲ្យរាជ-បុរសទាំងឡាយ ចាប់អ្នកដែលធ្វើកម្មអាក្រក់ ក្នុងស្រុកឡើយ ។

(៨៦៣) (អស្សត្ថទេវតា និយាយថា) រាជបុរសទាំងឡាយនឹងចាប់នូវចោរ ដែលធ្វើកម្មអាក្រក់ ក្នុងស្រុកនោះ ប្រយោជន៍អ្វី ដល់បុចិមន្ទ-ទេវតា ដែលកើតនៅក្នុងព្រៃនោះ ។

(៨៦៤) (បុចិមន្ទទេវតា ពោលថា) ម្នាលអស្សត្ថទេវតា អ្នកមិនដឹងនូវទោសនៃខ្ញុំផង នៃចោរផង ពួករាជបុរសចាប់បាននូវចោរ អ្នកធ្វើអំពើអាក្រក់ ក្នុងស្រុក ហើយដោតចោរនោះ ដោយមែកស្ដៅស្រួច ខ្ញុំរង្កៀសចិត្តក្នុងហេតុនោះ ។

(៨៦៥) (អស្សត្ថទេវតា ពោលថា) អ្នកប្រាជ្ញគប្បីរង្កៀសនូវហេតុ ដែលគួររង្កៀស គប្បីរក្សាទុកភ័យ ដែលមិនទាន់មកដល់ អ្នកប្រាជ្ញរមែងសំឡឹងមើលនូវលោកទាំងពីរ ព្រោះអនាគតភ័យ ។

ចប់ បុចិមន្ទជាតក ទី ១ ។

# កស្សបមន្ទិយជាតកំ

(៤៦៦) អបិ កស្សប មន្ទិយា យុវា សបតិ ហន្តិ វា

សព្វំ ខមន្តេ ធីរា បណ្ឌិតា តំ តិតិក្ខរេ ។

(៤៦៧) សចេបិ សន្តោ វិវទន្តិ ខិប្បំ សន្ធិយរេ បុន

ពាលា បត្តាវ ភិជ្ជន្តិ ន តេ សមថមជ្ឈគូ ។

(៤៦៨) ឯតេ ភិយ្យោ សមាយន្តិ សន្ធិ តេសំ ន ជីរតិ

យោ ចាធិបន្នំ ជានាតិ យោ ច ជានាតិ ទេសនំ ។

(៤៦៩) ឯសោ ហិ ឧត្តរិតរោ ភារវហោ ធុរទ្ធរោ

យោ បរេសាធិបន្នានំ សយំ សន្ធាតុមរហតិ ។

កស្សបមន្ទិយជាតកំ ទុតិយំ ។



# កស្សបមន្ទិយជាតក

(៤៦៦) (តាបសៈពោធិសត្វពោលថា) បពិត្រកស្សបជាបិតា បើក្មេងតូច ជេរប្រទេច ព្រោះតែជាក្មេង បណ្ឌិតអ្នកមានប្រាជ្ញា តែងអត់សង្កត់ខ្លួនក្រិចហុសកំនិតរបស់នោះ ។

(៤៦៧) ប្រសិនបើសប្បុរសទាំងឡាយ ទាស់ទែងគ្នា សប្បុរសរមែងតបានវិញយ៉ាងឆាប់ ឯក្មេងពាលទាំងឡាយ រមែងបែកគ្នាដូចបាត្រដី ក្មេងពាលទាំងនោះ មិនដល់នូវការស្ងប់រម្ងាប់ឡើយ ។

(៤៦៨) ជនណាដឹងនូវទោស ដែលខ្លួនធ្វើឲ្យកន្លងហួសទៅហើយផង ជនណាដឹងនូវការសំដែងនូវទោសផង ជនទាំងពីរពួកនោះ (បើទុកជាបែកគ្នាហើយ) ច្រើនរួបរួមគ្នាវិញបាន ការតមិត្តរបស់ជនទាំងពីរពួកនោះ មិនរលុបរលាយឡើយ ។

(៤៦៩) ជនណា ស្គាល់នូវមិត្តភាពរបស់ពួកជនដទៃ ដែលទោសគ្របសង្កត់ហើយ ដោយខ្លួនឯងបាន ជននោះជាមនុស្សខ្ពង់ខ្ពស់លើសលុប ជាមនុស្សនាំទៅនូវភារៈបាន ជាមនុស្សទ្រទ្រង់នូវធុរៈបាន ។

ចប់ កស្សបមន្ទិយជាតក ទី ២ ។

# ខន្តិវាទិជាតកំ

(៤៤០) យោ តេ ហត្ថេ ច បាទេ ច កណ្ណនាសញ្ច ឆេទយិ
តស្ស កុជ្ឈ មហាវីរ មា រដ្ឋំ វិនស្ស ឥទំ ។

(៤៤១) យោ មេ ហត្ថេ ច បាទេ ច កណ្ណនាសញ្ច ឆេទយិ
ចិរំ ជីវតុ សោ រាជា ន ហិ កុជ្ឈន្តិ មាទិសា ។

(៤៤២) អហុ អតីតមទ្ធានេ សមណោ ខន្តិទីបនោ
តំ ខន្តិយាយេវ ឋិតំ កាសិរាជា អឆេទយិ ។

(៤៤៣) តស្ស កម្មផរុសស្ស វិបាកោ កដុកោ អហុ
យំ កាសិរាជា វេទេសិ និរយម្ហិ សមប្បិតោ ។

ខន្តិវាទិជាតកំ តតិយំ ។



# ខន្តិវាទិជាតក

(៤៤០) (សេនាបតី ពោលថា) បពិត្រលោកមានព្យាយាមធំ ព្រះរាជាណាកាត់ព្រះហស្តទាំងពីរក្តី កាត់ព្រះបាទទាំងពីរក្តី កាត់ត្រចៀកនឹងច្រមុះក្តី របស់លោក សូមលោកខ្ញាល់ចំពោះបុគ្គលនោះចុះ សូមលោកកុំញ៉ាំងដែននេះ ឲ្យវិនាសឡើយ ។

(៤៤១) (តាបសពោធិសត្វ ពោលថា) ព្រះរាជាណា កាត់ដៃទាំងពីរក្តី កាត់ជើងទាំងពីរក្តី កាត់ត្រចៀកនឹងច្រមុះក្តី របស់អាត្មា សូមឲ្យព្រះរាជានោះ ទ្រង់មានព្រះជន្មយឺនយូរ ពួកអ្នកប្រាជ្ញដូចយ៉ាងអាត្មា មិនខឹងឡើយ ។

(៤៤២) (ព្រះសាស្តា ទ្រង់ត្រាស់ថា) សមណៈជាអ្នកសំដែងនូវខន្តី មានហើយក្នុងអតីតកាល ព្រះបាទកាសី ទ្រង់ត្រាស់ឲ្យពេជ្ឈឃាតកបុរសសម្លាប់សមណៈនោះ អ្នកតាំងនៅក្នុងខន្តី ។

(៤៤៣) ព្រះបាទកាសី តាំងនៅក្នុងនរក សោយនូវផល នៃកម្មណា ផលនៃកម្មអាក្រក់នោះ ជាផលក្តៅក្រហាយ ។

ចប់ ខន្តិវាទិជាតក ទី ៣ ។

# លោហកុម្ភិជាតកំ

(៨៨៤) ទុជ្ជីវិតមជីវិម្ហ យេ សន្តេ ន ទទាមសេ
វិជ្ជមានេសុ ភោគេសុ ទីបំ នាកម្ហ អត្តនោ ។
(៨៨៥) សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ
និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ ។
(៨៨៦) នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ
តទា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិស ។
(៨៨៧) សោ ហិ នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ
វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុំ ។

លោហកុម្ភិជាតកំ ចតុត្ថំ ។



# លោហកុម្ភិជាតក

(៨៨៤) (សត្វនរកម្នាក់ពោលថា) ពួកយើងដែលមិនបានឲ្យទាន បានជាពួកយើងរស់នៅ ដោយត្រដាបត្រដួស កាលភោគៈទាំងឡាយមាន ពួកយើងមិនបានធ្វើ នូវទីពឹងបម្រុងទុកខ្លួនសោះ ។

(៨៨៥) (សត្វនរកម្នាក់ទៀត ពោលថា) ពួកយើងដែលឆេះ ក្នុងនរក គ្រប់ជា ៦០.០០០ ឆ្នាំ ដោយអាការទាំងពួងហើយ កាលណា នឹងមានទីបំផុត(នៃទុក្ខ) ។

(៨៨៦) (សត្វនរកម្នាក់ទៀត ពោលថា) ម្នាលអ្នកនិទ្ទុក្ខ ទីបំផុត (នៃទុក្ខយើង) មិនមានទេ ទីបំផុតនឹងមានមកពីណា ទីបំផុតនឹងមិនប្រាកដទេ ព្រោះថា ខ្ញុំនឹងអ្នកបានធ្វើបាប ក្នុងកាលនោះ ។

(៨៨៧) (សត្វនរកម្នាក់ទៀត ពោលថា) ខ្ញុំនោះ លុះទៅអំពីទីនេះបាន កំណើតជាមនុស្ស ចាប់អំពីដឹងក្តីទៅ សូមជាអ្នកបរិបូណ៌ដោយ សីល ធ្វើកុសលឲ្យច្រើន ។

ចប់ លោហកុម្ភិជាតក ទី ៤ ។

# មំសជាតកំ(១)

(៤៥៨) ផរុសា វត តេ វាចា មំសំ យាចនកោ អសិ

កិលោមសទិសី វាចា កិលោមំ សម្ម ទម្មិ តេ ។

(៤៥៩) អង្គមេតំ មនុស្សានំ ភាតា លោកេ បវុច្ចតិ

អង្គស្ស សទិសី វាចា អង្គំ សម្ម ទទាមិ តេ ។

(៤៦០) តាតាតិ បុត្តោ វទមានោ កម្បេតិ ហទយំ បិតុ

ហទយស្ស សទិសី វាចា ហទយំ សម្ម ទម្មិ តេ ។

(៤៦១) យស្ស គាមេ សខា នត្ថិ យថារញ្ញំ តថេវ តំ

សព្វស្ស សទិសី វាចា សព្វំ សម្ម ទទាមិ តេ ។

មំសជាតកំ បញ្ចមំ ។

១ ម. សព្វមំសលាភជាតកំ ។



# មំសជាតក

(៤៥៨) (ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្រទី ១ ថា) ពាក្យរបស់អ្នកគ្រោតគ្រាតណាស់ អ្នកជាអ្នកសុំសាច់ តែពាក្យប្រហាលនឹងកេរ នែសំ-ឡាញ់ យើងនឹងឲ្យកេរដល់អ្នក ។

(៤៥៩) (ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្រទី ២ ថា) បងជាបងប្អូន គេទុកជាអវយវៈរបស់មនុស្សទាំងឡាយ ក្នុងលោក ពាក្យរបស់អ្នកប្រហាលនឹងអវយវៈ នែសំឡាញ់ យើងនឹងឲ្យសាច់អវយវៈដល់អ្នក ។

(៤៦០) (ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្រទី ៣ ថា) កូនកាលហៅថាពុក ពុក ដូច្នេះ រមែងធ្វើបេះដូងបិតាឲ្យកម្រើក ពាក្យរបស់អ្នកប្រហាលនឹងបេះដូង នែសំឡាញ់ យើងនឹងឲ្យបេះដូងដល់អ្នក ។

(៤៦១) (ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្រទី ៤ ថា) សំឡាញ់របស់បុរសណា មិនមានក្នុងស្រុក លំនៅរបស់បុរសនោះ ក្នុងស្រុកនោះឯង ដូចព្រៃ ពាក្យរបស់អ្នកប្រហាលនឹងសម្បត្តិទាំងពួង នែសំឡាញ់ យើងនឹងឲ្យសាច់ទាំងអស់ដល់អ្នក ។

ចប់ មំសជាតក ទី ៥ ។

## សសបណ្ឌិតជាតកំ

(៤៦២) សត្ត មេ រោហិតា មច្ឆា ឧទកា ថលមុព្ភតា
ឥទំ ព្រាហ្មណ មេ អត្ថិ ឯតំ ភុត្វា វនេ វស ។

(៤៦៣) ទុស្ស មេ ខេត្តបាលស្ស រត្តិំ ភត្តំ អបាភតំ
មំសសូលា ច ទ្វេ គោធា ឯកញ្ច ទធិវារកំ
ឥទំ ព្រាហ្មណ មេ អត្ថិ ឯតំ ភុត្វា វនេ វស ។

(៤៦៤) អម្ពបក្កំ ទកំ(១) សីតំ សីតច្ឆាយា មនោរមា
ឥទំ ព្រាហ្មណ មេ អត្ថិ ឯតំ ភុត្វា វនេ វស ។

(៤៦៥) ន សសស្ស តិលា អត្ថិ ន មុគ្គា នបិ តណ្ឌុលា
ឥមិនា អគ្គិនា បក្កំ មមំ ភុត្វា វនេ វសាតិ ។

សសបណ្ឌិតជាតកំ(២) ឆដ្ឋំ ។

---

១ ឱ. អម្ពបក្កោទកំ ។ ២ ម. សសជាតកំ ។



## សសបណ្ឌិតជាតក

(៤៦២) (ភេ និយាយនឹងឥន្ទព្រាហ្មណ៍ថា) ខ្ញុំមានត្រីក្រហម ៧ ដែលព្រានសន្ទូចស្រង់ឡើង ពីទឹកដាក់លើគោក ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ(ចំរើនសមណធម៌) នៅក្នុងព្រៃចុះ ។

(៤៦៣) (ចចក និយាយនឹងឥន្ទព្រាហ្មណ៍ថា) ភត្តរបស់អ្នកយាមស្រែឯណោះ គឺសាច់ពីរដុំខ្លួនផង ទន្សងមួយផង ដបទធិមួយផង ខ្ញុំបាននាំមក ក្នុងវេលាយប់ ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ(ចំរើនសមណធម៌)នៅក្នុងព្រៃចុះ ។

(៤៦៤) (ស្វា និយាយនឹងឥន្ទព្រាហ្មណ៍ថា) ផ្លែស្វាយទុំ ទឹកត្រជាក់ ទីមានម្លប់ត្រជាក់ ជាទីគាប់ចិត្ត ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ ( ចំរើនសមណធម៌ ) នៅក្នុងព្រៃចុះ ។

(៤៦៥) (ទន្សាយ និយាយនឹងឥន្ទព្រាហ្មណ៍ថា) ទន្សាយ មិនមានល្ង មិនមានសណ្តែក មិនមានអង្ករទេ អ្នកចូរបរិភោគ ខ្លួនខ្ញុំដែលឆ្អិនដោយភ្លើងនេះ ហើយ (ចំរើនសមណធម៌)នៅក្នុងព្រៃចុះ ។

ចប់ សសបណ្ឌិតជាតកទី ៦ ។

## មតរោទនជាតកំ

(៩៦៦) មតំ មតំ ឯវ រោទថ ន ហិ តំ រោទថ យោ មរិស្សតិ
សព្វេ សរីរធារិនោ អនុបុព្វេន ជហន្តិ ជីវិតំ ។

(៩៦៧) ទេវមនុស្សា ចតុប្បទា បក្ខិគណា ឧរគា ច ភោគិនោ
យម្ហិ[១] សរីរេ អនិស្សរា រមមានា ជហន្តិ ជីវិតំ ។

(៩៦៨) ឯវំ ចលិតំ អសណ្ឋិតំ សុខទុក្ខំ មនុជេសុ អបេក្ខិយ
កន្ទិតំ រុទិតំ និរត្ថកំ កឹ វោ សោកគណាភិកីររេ ។

(៩៦៩) ធុត្តា សោណ្ឌា អកតា ពាលា សូរា អយោគិនោ
ធីរំ មញ្ញន្តិ ពាលោតិ យេ ធម្មស្ស អកោវិទា ។

មតរោទនជាតកំ សត្តមំ ។

១ អស្មិំ បិ យុត្តំ ។



## មតរោទនជាតក

(៩៦៦) (សេដ្ឋីពោធិសត្វ ពោលថា) អ្នកទាំងឡាយ យំតែបុគ្គលស្លាប់ទៅហើយៗ តែម្យ៉ាង បុគ្គលណា ប្រុងនឹងស្លាប់ អ្នកទាំងឡាយ មិនយំតែបុគ្គលនោះសោះ ពួកសត្វទាំងអស់ ជាអ្នកទ្រទ្រង់នូវសរីរៈ តែងលះបង់នូវជីវិតតាមលំដាប់ ។

(៩៦៧) ពួកទេវតា មនុស្ស សត្វជើង ៤ ពួកសត្វស្លាប នឹងពួកពស់ប្រកបដោយភោគ មិនជាធំក្នុងសរីរៈឡើយ តែងលះបង់ជីវិត ទាំងកំពុងត្រេកអរ (ក្នុងភពៈដែលខ្លួនកើតហើយ) ។

(៩៦៨) សុខនឹងទុក្ខជាធម្មជាតកម្រើក មិនតាំងនៅយ៉ាងនេះ បុគ្គលគួរមើលមើល ក្នុងពួកមនុស្ស ការកន្ទក់កន្ទេញ ការយំសោក ជារបស់មិនមានប្រយោជន៍ទេ ព្រោះហេតុអ្វី ក៏គំនរនៃសេចក្តីសោក គ្របសង្កត់អ្នកទាំងឡាយ ។

(៩៦៩) ពួកជនណា ជាអ្នកលេង ជាអ្នកស្រវឹង មិនធ្វើ (សេចក្តីចំរើន) ជាមនុស្សពាល ក្លៀវក្លា មិនមានសេចក្តីព្យាយាម មិនឈ្លាសក្នុងធម៌ ពួកជននោះ តែងសំគាល់នូវអ្នកប្រាជ្ញ (ដែលមិនយំសោកជាដើម) ថាជាមនុស្សពាលទៅវិញ ។

ចប់ មតរោទនជាតក ទី ៧ ។

## កណវេរជាតកំ

(៤៧០) យន្តំ វសន្តសមយេ កណវេរេសុ ភាណុសុ
សាមំ ពាហាយ បីឡេសិ សា តំ អារោគ្យមព្រវិ ។

(៤៧១) អម្ភោ ន កិរ សទ្ធេយ្យំ យំ វាតោ បព្វតំ វហេ
បព្វតញ្ចេ វហេ វាតោ សព្វម្បិ បឋវឹ វហេ
យត្ថ សាមា កាលកតា សា មំ អារោគ្យមព្រវិ ។

(៤៧២) ន ចេវ សា កាលកតា ន ច សា អញ្ញមិច្ឆតិ
ឯកភត្តា កិរ សាមា តមេវ អភិកង្ខតិ ។



## កណវេរជាតក

(៤៧០) (ពួកចោរ ច្រៀងថា) អ្នកឱបនាងសាមាណា ដោយដើមដៃ ក្បែរគុម្ពច្បាររាំងឡាយ មានផ្កាក្រហម ដូចពន្លឺព្រះអាទិត្យ ក្នុងវសន្តសម័យ (ហើយនាំទៅ ផ្សេងនេះ) នាងសាមានោះ ប្រាប់មកអ្នក (ថានាង) មិនមានរោគទេ ។

(៤៧១) (ពោធិសត្វ ពោលថា) នែនាងដ៏ចំរើន បានឮថា ខ្យល់បក់ ផាត់ភ្នំ ដោយហេតុណា ទំមិនគប្បីជឿ នូវហេតុនោះទេ បើ ខ្យល់បក់ផាត់ភ្នំបាន បក់ផាត់ផែនដីទាំងមូល ក៏បានដែរ នាង សាមាណា ស្លាប់បាត់ទៅហើយ អ្នកពោលថានាងសាមានោះ មិនមានរោគ (ទំមិនគប្បីជឿទេ) ។

(៤៧២) (ពួកចោរ ច្រៀងថា) នាងសាមានោះ មិនស្លាប់ផង នាងមិនចង់ បានបុរសដទៃផង ឮថា នាងសាមា មានប្តីតែមួយ នាងចង់ បានតែប្តីនោះឯង ។

(៤៧៣) អសន្ធុតំ មំ ចិរសន្ធុតេន
និមីនិ សាមា អធុវំ ធុវេន
មយាបិ សាមា និមិនេយ្យ អញ្ញំ
ឥតោ អហំ ទូរតរំ គមិស្សំ ។

កណវេរជាតកំ អដ្ឋមំ ។

## តិត្តិរជាតកំ

(៤៧៤) សុសុខំ វត ជីវាមិ លភាមិ ចេវ ភុញ្ជិតុំ
បរិបន្ថេវ តិដ្ឋាមិ កា នុ ភន្តេ គតី មម ។
(៤៧៥) មនោ ចេ តេ នប្បណមតិ បក្ខិ បាបស្ស កម្មុនោ
អព្យាវដស្ស ភទ្រស្ស ន បាបមុបលិម្បតិ ។
(៤៧៦) ញាតកោ នោ និសិន្នោតិ ពហុ អាគច្ឆតេ ជនោ
បដិច្ច កម្មំ ផុសតិ តស្មឹ មេ សង្កតេ មនោ ។



(៤៧៣) (ព្រះពោធិសត្វ ពោលថា) នាងសាមា ប្ដូរយកខ្ញុំដែលមិនធ្លាប់ស្និទ្ធស្នាល ដោយប្ដីដែលស្និទ្ធស្នាល អស់កាលយូរ ប្ដូរយកខ្ញុំជាប្ដីមិនពិតប្រាកដ ដោយប្ដីពិតប្រាកដ នាងសាមា មុខតែប្ដូរយកបុរសដទៃ ដោយខ្ញុំ ខ្ញុំនឹងទៅកាន់ទីឆ្ងាយ លើសពីនេះទៅទៀត ។

ចប់ កណវេរជាតក ទី ៨ ។

## តិត្តិរជាតក

(៤៧៤) (សត្វទទា សួរតាបសពោធិសត្វថា) ខ្ញុំរស់នៅជាសុខសប្បាយណាស់ ទាំងបានបរិភោគ (ដោយស្រួល) តែខ្ញុំឋិតនៅក្នុងសេចក្ដីអន្តរាយ បពិត្រលោកដ៏ចំរើន. គតិរបស់ខ្ញុំដូចម្ដេច ។
(៤៧៥) (ព្រះពោធិសត្វ ឆ្លើយថា) ម្នាលបក្សី បើចិត្តរបស់អ្នក មិនបន្អោនទៅកាន់អំពើបាបទេ បាបក៏មិនប្រឡាក់ នូវអ្នកដ៏ចំរើន ដែលជាអ្នកមិនខ្វល់ខ្វាយឡើយ ។
(៤៧៦) (ទទា ពោលថា) សត្វទទាជាច្រើនមក ព្រោះគិតថា ញាតិយើងទំនៅ(ត្រង់ទីនោះ) ព្រានប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះអាស្រ័យខ្ញុំ ចិត្តរបស់ខ្ញុំ ក៏រង្កៀសក្នុងរឿងនោះ ។

(៨៧៧) ន បដិច្ច កម្មំ ផុសតិ មនោ ចេ នប្បទុស្សតិ
អប្បោស្សុក្កស្ស ភទ្រស្ស ន បាបមុបលិម្បតីតិ ។

តិត្តិរជាតកំ នវមំ ។

## សុចជជាតកំ

(៨៧៨) សុចជំ វត ន ចជិ វាចាយ អទទំ គិរឹ
កិញ្ហិ តស្ស ចជន្តស្ស វាចាយ អទទ បព្វតំ ។

(៨៧៩) យញ្ហិ កយិរា តញ្ហិ វទេ យំ ន កយិរា ន តំ វទេ
អករោន្តំ ភាសមានំ បរិជានន្តិ បណ្ឌិតា ។

(៨៨០) រាជបុត្ត នមោ ត្យត្ថុ សច្ចេ ធម្មេ ឋិតោ វសិ
យស្ស តេ ព្យសនំ បត្តោ សច្ចស្មិំ រមតេ មនោ ។



(៨៧៧) (ពោធិសត្វ ពោលថា) ព្រោះមិនបំពាល់ នូវបាណាតិបាតកម្ម ព្រោះការស្រែយអ្នកទេ បើចិត្តអ្នកមិនប្រទូស្ត បាបមិនប្រឡាក់ នូវអ្នកដ៏ចំរើន ដែលមិនមានសេចក្តីខ្វល់ខ្វាយឡើយ ។

ចប់ តិត្តិរជាតក ទី ៩ ។

## សុចជជាតក

(៨៧៨) (នាងទេវី ពោលថា) ព្រះរាជាកាលមិនប្រទានភ្នំ(សូម្បី)ដោយព្រះវាចា ឈ្មោះថា មិនលះបង់ នូវរបស់ដែលគួរលះបង់ដោយពិតទេ (ប្រសិនបើព្រះរាជាបានប្រទានភ្នំ (សូម្បី) ដោយព្រះវាចា ព្រះរាជានោះ (ដែលខ្ញុំសូមហើយ) គង់លះបង់ភ្នំនុ៎ះ ។

(៨៧៩) (ព្រះរាជា ត្រាស់ថា) បុគ្គលធ្វើអំពើណា គប្បីនិយាយអំពើនោះ មិនធ្វើអំពើណា មិនគប្បីនិយាយអំពើនោះ ពួកបណ្ឌិតរមែងកំណត់ដឹងនូវបុគ្គល ដែលមិនធ្វើ(ត្រឹមតែ)និយាយ ។

(៨៨០) (ព្រះនាងទេវី ពោលថា) បពិត្រព្រះរាជបុត្រ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ដែលឋិតនៅក្នុងធម៌សច្ចៈផង ក្នុងសភាវធម៌ផង សូម្បីដល់នូវសេចក្តីវិនាស ក៏ព្រះហឫទ័យ របស់ព្រះអង្គនៅតែត្រេកអរក្នុងសច្ចៈ ។

(៩៨៧) យា ទលិទ្ទី ទលិទ្ទស្ស អឌ្ឍា អឌ្ឍស្ស កិត្តិមា សា ហិស្ស បរមា ភរិយា សហិរញ្ញស្ស ឥត្ថិយោតិ ។

សុចិតតិតក ទសមំ ។

ឧព្វរិវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

អជ ចោរ សការស្សប ទត្តិកោ

ឧទ្ទិដ្ឋកា ច វក ជលោ

អជ សស មតំ ច សេដ្ឋិ សុទំ

សុចជំ វតំ ច ចជិតា ចចស ។

---



(៩៨៧) (ព្រះតេពិសត្ត សំដែងគុណរបស់ព្រះនាងទៀត) ស្ត្រីណា របស់ប្តីអ្នកទីលក្រ ក៏ជាស្ត្រីទីលក្រផង របស់ប្តីអ្នកសុកស្តម្ភ ក៏ជាស្ត្រីសុកស្តម្ភ មានកេរ្តិ៍ឈ្មោះផង ស្ត្រីនោះឈ្មោះថាជា ស្ត្រីដ៏ឧត្តមរបស់ប្តីនោះ ស្រីទាំងឡាយរបស់អ្នកមានប្រាក់ (ក៏ដូច្នោះដែរ) ។

ចប់ សុចិតតិតក ទី ១០ ។

ចប់ ឧព្វរិវគ្គ ទី ២ ។

## ឧទ្ទាននៃឧព្វរិវគ្គនោះគឺ

និយាយអំពីតោ ១ កស្សបតាបស ១ តាបសទត្តិកទី ១ ការសៅរៅកាត្រក់ ១ សំដីកាក្រក់ ១ ទន្សាយ ១ បុគ្គលស្លាប់ ១ សេដ្ឋកាល ១ ការរស់នៅជាសុខ ១ ព្រះរាជាមិនលះបង់ នូវរបស់ដែលលះបង់ហើយ ១ ត្រូវជា ១០ ។

## កុដិទូសកវគ្គោ

## កុដិទូសកជាតកំ[1]

(៨៨២) មនុស្សស្សេវ តេ សីសំ ហត្ថបាទា ច វានរ
អថ កេន នុ វណ្ណេន អគារំ តេ ន វិជ្ជតិ ។

(៨៨៣) មនុស្សស្សេវ មេ សីសំ ហត្ថបាទា ច សិង្គិល
យាហុ សេដ្ឋា មនុស្សេសុ សា មេ បញ្ញា ន វិជ្ជតិ ។

(៨៨៤) អនវដ្ឋិតចិត្តស្ស លហុចិត្តស្ស ទុព្ភិនោ
និច្ចំ អទ្ធុវសីលស្ស សុខភាវោ ន វិជ្ជតិ ។

(៨៨៥) សោ ករស្សុ អានុភាវំ វីតិវត្តស្សុ សីលិយំ
សីតវាតបរិត្តាណំ ករស្សុ កុដវំ កបិ ។

កុដិទូសកជាតកំ បឋមំ ។

---

១ ម. សិង្គាលសកុណជាតកំ ។

## កុដិទូសកវគ្គ

## កុដិទូសកជាតក

(៨៨២) (គ្រលេងគ្រលោង ពោលថា) ម្នាលវានរ ក្បាល ដៃនិងជើង របស់អ្នក ដូចជាមនុស្សដែរ តែព្រោះហេតុអ្វី បានជាផ្ទះរបស់អ្នកគ្មាន ។

(៨៨៣) (វានរ ឆ្លើយថា) ម្នាលគ្រលេងគ្រលោង ក្បាល ដៃនិងជើងរបស់ខ្ញុំ ដូចមនុស្សមែនហើយ តែប្រាជ្ញាណាដែលលោកពោលថា ប្រសើរក្នុងពួកមនុស្ស ប្រាជ្ញានោះ របស់ខ្ញុំមិនមានទេ ។

(៨៨៤) (គ្រលេងគ្រលោង ពោលថា) ធម្មតាអ្នកមានចិត្តមិននឹងនួន មានចិត្តរហ័សរហួន ជាអ្នកប្រទូស្តចំពោះមិត្រ មានមារយាទមិនទៀង ជានិច្ច តែងមិនមានសេចក្តីសុខ ។

(៨៨៥) ម្នាលវានរ អ្នកនោះចូរធ្វើនូវអានុភាព(ឱ្យកើតបញ្ញា) ចូរផ្លាស់មារយាទចេញ ចូរធ្វើខ្ទមជាគ្រឿងការពារនូវត្រជាក់និងខ្យល់ ។

ចប់ កុដិទូសកជាតក ទី ១ ។

## ទុទ្ទុភាយជាតកំ

(៥៨៦) ទុទ្ទុភាយតិ ភទ្ទន្តេ យស្មឹ ទេសេ វសាមហំ
អហម្បេតំ ន ជានាមិ កិមេតំ ទុទ្ទុភាយតិ ។

(៥៨៧) ពេលុវំ បតិតំ សុត្វា ទុទ្ទុភន្តិ សសោ ជវិ
សសស្ស វចនំ សុត្វា សន្តត្តា មិគវាហិនី ។

(៥៨៨) អប្បត្វា បទវិញ្ញាណំ បរឃោសានុសារិនោ
បនាទបរមា ពាលា តេ ហោន្តិ បរបត្តិយា ។

(៥៨៩) យេ ច សីលេន សម្បន្នា បញ្ញាយុបសមេ រតា
អារកា វិរតា ធីរា ន ហោន្តិ បរបត្តិយាតិ ។

ទុទ្ទុភាយជាតកំ ទុតិយំ ។



## ទុទ្ទុភាយជាតក

(៥៨៦) (ទន្សាយ និយាយថា) សូមសេចក្ដីចំរើនមានដល់លោកចុះ ខ្ញុំនៅក្នុងប្រទេសណា ប្រទេសនោះឮសំឡេងឮទុទ្ទុក(១) តែខ្ញុំមិនដឹងនូវប្រទេសនុះថា អ្វីនេះ ធ្វើសំឡេងឮទុទ្ទុក ។

(៥៨៧) (ព្រះសាស្ដា ទ្រង់សំដែងថា) ទន្សាយឮស្នូរផ្លែព្នៅជ្រុះថា ទុទ្ទុក ដូច្នេះ ក៏ស្ទុះរត់បោលប្រូច ហ្វូងសត្វម្រឹគបានឮពាក្យទន្សាយ ក៏ភ័យតក់ស្លុត ។

(៥៨៨) ពួកជនពាលនោះ មិនទាន់សម្រេចនូវចំណែកនៃសាកវិញ្ញាណ ឮសំឡេងនៃជនដទៃ មានសេចក្ដីប្រហែសធ្វេសដ៏ក្រៃលែង ជនពាលទាំងនោះ រមែងលុះតាមពាក្យជនដទៃ ។

(៥៨៩) ចំណែកពួកជនណា បរិបូណ៌ដោយសីលនឹងបញ្ញា ត្រេកអរក្នុងការស្ងប់រម្ងាប់ ជាធីរជន អ្នកឆ្ងាយ អ្នកវៀរចាកបាប ធីរ-ជននោះ មិនលុះតាមពាក្យជនដទៃទេ ។

ចប់ ទុទ្ទុភាយជាតក ទី ២ ។

---

១ ឮទុក ។

# ព្រហ្មទត្តជាតកំ

(៤៩០) ទ្វយំ យាចនកោ រាជ ព្រហ្មទត្ត និគច្ឆតិ
អលាភំ ធនលាភំ វា ឯវំធម្មា ហិ យាចនា ។

(៤៩១) យាចនំ រោទនំ អាហុ បញ្ចាលានំ រថេសភ
យោ យាចនំ បច្ចក្ខាតិ តមាហុ បដិរោទនំ ។

(៤៩២) មា មទ្ទសំសុ រោទន្តំ បញ្ចាលា សុសមាគតា
តុវំ វា បដិរោទន្តំ តស្មា ឥច្ឆាមហំ រហោ ។

(៤៩៣) ទទាមិ តេ ព្រាហ្មណ រោហិណីនំ
គវំ សហស្សំ សហ បុង្គវេន
អរិយោ ហិ អរិយស្ស កថំ ន ទជ្ជា
សុត្វាន គាថា តវ ធម្មយុត្តា ។

ព្រហ្មទត្តជាតកំ តតិយំ ។



# ព្រហ្មទត្តជាតក

(៤៩០) (តាបសពោធិសត្វ ពោលថា) បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសូម រមែងបានផលពីរយ៉ាង គឺការមិនបានទ្រព្យ ១ ការបានទ្រព្យ ១ ព្រោះថា ការសូម មានយ៉ាងនេះជាធម្មតា ។

(៤៩១) បពិត្រព្រះអង្គជាឥស្សរៈលើរថ នៃដែនបញ្ចាល អ្នកប្រាជ្ញទាំងឡាយ បានពោលនូវការសូមថាជាការយំ បុគ្គលណា ឃាត់នូវការសូម អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះ ថាជាអ្នកមានការយំតប ។

(៤៩២) កុំឲ្យពួកជនអ្នកដែនបញ្ចាលមកប្រជុំគ្នា ឃើញអាត្មាភាព កំពុងយំ ឬព្រះអង្គកំពុងយំតបឡើយ ព្រោះហេតុនោះ បានជាអាត្មាភាពត្រូវការទីស្ងាត់ ។

(៤៩៣) (ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់ថា) បពិត្រព្រាហ្មណ៍ ខ្ញុំនឹងឲ្យគោញីសម្បុរក្រហម ១០០០ ព្រមទាំងគោឈ្មោលដល់លោក ព្រោះថាអរិយជន បានស្តាប់នូវគាថាប្រកបដោយធម៌ របស់លោកជាអរិយៈ មិនគប្បីឲ្យ ដូចម្តេចកើត ។

ចប់ ព្រហ្មទត្តជាតក ទី ៣ ។

## ចម្មសាដកជាតកំ

(៨៩៤) កល្យាណរូបោ វតាយំ ចតុប្បទោ
សុភទ្ទកោ ចេវ សុបេសលោ ច
យោ ព្រាហ្មណំ ជាតិមន្តូបបន្នំ
អបចាយតិ មេណ្ឌវរោ យសស្សី ៕

(៨៩៥) មា ព្រាហ្មណ ឥត្តរទស្សនេន
វិស្សាសមាបជ្ជិ ចតុប្បទស្ស
ទឡ្ហប្បហារំ អភិកង្ខមានោ
អវសក្កតិ ទស្សតិ សុប្បហារំ ៕

(៨៩៦) ឩរុដ្ឋិ ភគ្គា បតិតោ ខារិភារោ
សព្វំ ភណ្ឌំ ព្រាហ្មណស្សេវ ភិន្នំ
ឧភោបិ ពាហា បគ្គយ្ហ កន្ទតិ
អភិធាវថ ហញ្ញតិ ព្រហ្មចារី ៕

(៨៩៧) ឯវំ សោ និហតោ សេតិ យោ អបូជំ បសំសតិ
យថាហមជ្ជ បហតោ ហតោ មេណ្ឌេន ទុម្មតិ៕

ចម្មសាដកជាតកំ ចតុត្ថំ ៕



## ចម្មសាដកជាតក

(៨៩៤) (ចម្មសាដកបរិព្វាជក ពោលថា) ឱ ពពែប្រសើរនេះ ជាសត្វជើង ៤ មានសភាពល្អ ដំណើរល្អ មានមារយាទ ជាទីស្រឡាញ់ មានយស តែងគោរពព្រាហ្មណ៍អ្នកបរិបូណ៌ដោយជាតិនិងមន្ត ៕

(៨៩៥) (បណ្ឌិតពាណិជពោធិសត្វ ពោលថា) ម្នាលព្រាហ្មណ៍ អ្នកកុំស្និទ្ធស្នាលនឹងសត្វជើង ៤ ដោយការឃើញមួយរំពេចឡើយ ព្រោះសត្វពពែនេះ ប្រាថ្នានឹងធ្វើនូវការប្រហារដ៏មាំ បានជាថយក្រោយ នឹងត្រៀលនូវការប្រហារឲ្យត្រូវ ៕

(៨៩៦) (ព្រះសាស្ដា ទ្រង់ត្រាស់ថា) ឆ្អឹងភ្លៅរបស់ព្រាហ្មណ៍ក៏បាក់ អំរែករបស់ព្រាហ្មណ៍ក៏ធ្លាក់ចុះ គ្រឿងទាំងអស់របស់ព្រាហ្មណ៍ក៏បែកហើយ ព្រាហ្មណ៍លើកដៃទាំងពីរឡើងកន្ទក់កន្ទេញថា ពពែស្ទុះមកសម្លាប់ព្រហ្មចារីបុគ្គល ៕

(៨៩៧) (បរិព្វាជក និយាយតទៅទៀតថា) ខ្ញុំជាមនុស្សឥតប្រាជ្ញា ត្រូវពពែចុះសម្លាប់ក្នុងថ្ងៃនេះយ៉ាងណា បុគ្គលណាសរសើរបុគ្គលដែលមិនគួរបូជា បុគ្គលនោះត្រូវគេសម្លាប់ដេកនៅ (ក្នុងទីនេះ) យ៉ាងនោះដែរ ៕

ចប់ ចម្មសាដកជាតក ទី ៤ ៕

# គោធជាតកំ[១]

(៥៩៨) សមណន្តំ មញ្ញមានោ ឧបគច្ឆឹ អសញ្ញតំ
សោ មំ ទណ្ឌេន បាហាសិ យថា អស្សមណោ តថា ។
(៥៩៩) កិន្តេ ជដាហិ ទុម្មេធ កិន្តេ អជិនសាដិយា
អព្ភន្តរន្តេ គហនំ ពាហិរំ បរិមជ្ជសិ ។
(៦០០) ឯហិ គោធ និវត្តស្សុ ភុញ្ជ សាលីនមោទនំ
តេលំ លោណញ្ច មេ អត្ថិ បហុតំ មយ្ហំ បិប្ផលិ ។
(៦០១) ឯស ភិយ្យោ បវេក្ខាមិ វម្មិកំ សតបោរិសំ
តេលំ លោណញ្ច កិត្តេសិ អហិតំ មយ្ហំ បិប្ផលីតិ ។

គោធជាតកំ បញ្ចមំ ។

១ ម. គោធរាជជាតកំ ។



# គោធជាតក

(៥៩៨) (ទន្សែងគោធសត្វ និយាយនឹងតាបសថា) ខ្ញុំស្មានអ្នកថាជាសមណៈ បានចូលទៅរកអ្នក ជាអ្នកមិនសង្រួម អ្នកនោះប្រហារខ្ញុំដោយដំបង ដូចមនុស្សមិនមែនជាសមណៈដែរ ។

(៥៩៩) ម្នាលតាបសកំឡៅ ប្រយោជន៍អ្វីដោយជដាសក់ របស់អ្នក ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ខាងក្នុងរបស់អ្នកសាំញ៉ាំដោយកិលេស អ្នកដុសលាងតែសរីរៈខាងក្រៅ ។

(៦០០) (តាបស និយាយថា) នែទន្សែង ឯងចូរមកណេះ ឯងត្រឡប់មកវិញ ចូរបរិភោគបាយស្រូវសាលីចុះ ប្រេងនឹងអំបិលរបស់អញក៏មាន ដីប្លីរបស់អញក៏មានច្រើន ។

(៦០១) (ទន្សែងឆ្លើយថា) ខ្ញុំនោះនឹងចូលទៅកាន់ដំបូក ជំរៅ ១០០ ជួរបុរស យ៉ាងដ៏ក្រៃលែង ថ្វីបើអ្នកឯងមានប្រេងនឹងអំបិល ដីប្លីរបស់អ្នក មិនជាប្រយោជន៍ដល់ខ្ញុំឡើយ ។

ចប់ គោធជាតក ទី ៥ ។

# កក្ការុជាតកំ

[៦០២] កាយេន យោ នាវហរេ វាចាយ ន មុសា ភណេ
យសោ លទ្ធា ន មជ្ជេយ្យ ស វេ កក្ការុមរហតិ ។
[៦០៣] ធម្មេន វិត្តមេសេយ្យ ន និកត្យា ធនំ ហរេ
ភោគេ លទ្ធា ន មជ្ជេយ្យ ស វេ កក្ការុមរហតិ ។
[៦០៤] យស្ស ចិត្តំ អហាលិទ្ទំ សទ្ធា ច អវិរាគិនី
ឯកោ សាទុំ ន ភុញ្ជេយ្យ ស វេ កក្ការុមរហតិ ។
[៦០៥] សម្មុខា វា តិរោក្ខា វា យោ សន្តេ ន បរិភាសតិ
យថាវាទី តថាការី ស វេ កក្ការុមរហតិ ។

កក្ការុជាតកំ ឆដ្ឋំ ។



# កក្ការុជាតក

(៦០២) (ទេវបុត្តជាធំ ពោលថា) បុគ្គលណាមិនលួចទ្រព្យគេដោយកាយ មិននិយាយកុហកដោយវាចា បានយសស័ក្តិហើយ មិនស្រវឹង បុគ្គលនោះឯង គួរប្រដាប់ផ្កាក្រឡាបជាទិព្វទាំងឡាយ ។

(៦០៣) (ទេវបុត្រទី២ ពោលថា) បុគ្គលណាស្វះស្វែងរកទ្រព្យដោយធម៌ មិនឆក់យកទ្រព្យគេដោយបោកប្រាស បានទ្រព្យទាំងឡាយហើយ មិនស្រវឹង បុគ្គលនោះឯង ទើបគួរប្រដាប់ផ្កាក្រឡាបបាន ។

(៦០៤) (ទេវបុត្រទី ៣ ពោលថា) បុគ្គលណាមានចិត្តមិនជាប់ហើរដូចរមៀត មានសទ្ធាមិនរសាយ មិនបរិភោគភោជនាហារឆ្ងាញ់តែម្នាក់ឯង បុគ្គលនោះ ទើបគួរប្រដាប់ផ្កាក្រឡាបបាន ។

(៦០៥) (ទេវបុត្រទី ៤ ពោលថា) បុគ្គលណាមិនជេរប្រទេចពួកសប្បុរស ក្តីទីចំពោះមុខ ក្តីកំបាំងមុខ ជាអ្នកនិយាយយ៉ាងណា ធ្វើយ៉ាងនោះ បុគ្គលនោះ ទើបគួរប្រដាប់ផ្កាក្រឡាបបាន ។

ចប់ កក្ការុជាតក ទី ៦ ។

# កាកាតិជាតកំ

(៦០៦) វាតិ ចាយំ តតោ គន្ធោ យត្ថ មេ វសតី បិយា
ទូរេ ឥតោ ហិ កាកាតិ យត្ថ មេ និរតោ មនោ ។

(៦០៧) កថំ សមុទ្ទមតរិ កថំ អតរិ កេបុកំ
កថំ សត្ត សមុទ្ទានិ កថំ សិម្ពលិមារុហិ ។

(៦០៨) តយា សមុទ្ទមតរឹ តយា អតរិ កេបុកំ
តយា សត្ត សមុទ្ទានិ តយា សិម្ពលិមារុហឹ ។

(៦០៩) ធិរត្ថុ មំ មហាកាយំ ធិរត្ថុ មំ អចេតនំ
យត្ថ ជាយាយហំ ជារំ អាវហាមិ វហាមិ ចាតិ ។

កាកាតិជាតកំ សត្តមំ ។



# កាកាតិជាតក

(៦០៦) (ផុស្សវត្តីគន្ធព្វ ច្រៀងថា) ស្ត្រីជាទីស្រឡាញ់របស់ខ្ញុំព្រះបង្គំនៅក្នុងទីណា ក្លិនក្រអូបនេះបក់មកអំពីទីនោះ ចិត្តរបស់ខ្ញុំព្រះបង្គំត្រេកអរក្នុងស្ត្រីណា ស្ត្រីនោះឈ្មោះនាងកាកាតិ នៅនៅក្នុងទីឆ្ងាយអំពីទីនេះ ។

(៦០៧) (ស្តេចគ្រុឌ ពោលថា) អ្នកបានឆ្លងសមុទ្រ ដោយឧបាយដូចម្តេច បានឆ្លងទន្លេឈ្មោះកេបុកៈ ដោយឧបាយដូចម្តេច បានឆ្លងសមុទ្រទាំង ៧ ជាន់ ដោយឧបាយដូចម្តេច បានឡើងដើមរកា (ជាលំនៅរបស់យើង) ដោយឧបាយដូចម្តេច ។

(៦០៨) (ផុស្សវត្តីគន្ធព្វ ឆ្លើយតបថា) ខ្ញុំបានឆ្លងសមុទ្រជាមួយនឹងលោក បានឆ្លងទន្លេឈ្មោះកេបុកៈជាមួយនឹងលោក បានឆ្លងសមុទ្រទាំង ៧ ជាន់ជាមួយនឹងលោក បានឡើងដើមរកាជាមួយនឹងលោក ។

(៦០៩) (ស្តេចគ្រុឌ ពោលថា) អញនាំមកទាំងនាំទៅនូវសហាយរបស់ប្រពន្ធ ហេតុណា ហេតុនោះ គួរតិះដៀលខ្លួនអញ មានកាយធំ គួរតិះដៀលខ្លួនអញ ដែលមិនមានគំនិត ។

ចប់កាកាតិជាតក ទី ៧ ។

## អននុសោចិយជាតកំ

(៦១០) ពហូនំ វិជ្ជតី ភោតី តេហិ មេ កិំ ភវិស្សតិ
តស្មា ឯតំ ន សោចាមិ បិយំ សម្មិល្លហាសិនឹ ។

(៦១១) តំ តញ្ចេ អនុសោចេយ្យ យំ យំ តស្ស ន វិជ្ជតិ
អត្តានមនុសោចេយ្យ សទា មច្ចុវសំ បតំ ។

(៦១២) នហេវ ឋិតំ នាសីនំ ន សយានំ ន បទ្ទគុំ
យាវ ព្យាតិ និមិស្សតិ តត្រាបិ សរតី វយោ ។

(៦១៣) តត្ថត្តនិ វតប្បទ្ធេ វិនាភាវេ អសំសយេ
ភូតំ សេសំ ទយិតព្វំ វីតំ អននុសោចិយន្តិ ។

អននុសោចិយជាតកំ អដ្ឋមំ ។



## អននុសោចិយជាតក

(៦១០) (តាបសពោធិសត្វ ពោលថា) នាងសម្មិល្លហាសិនី ជាស្រីដ៏ចំរើន មានគតិដូចពួកសត្វដ៏ច្រើនដែលស្លាប់ហើយ ពួកសត្វដែលស្លាប់ហើយនោះ នឹងមានប្រយោជន៍អ្វីដល់ខ្ញុំ ហេតុនោះបានជា ខ្ញុំមិនសោកស្តាយនាងសម្មិល្លហាសិនី ជាទីស្រឡាញ់នុះឡើយ ។

(៦១១) វត្ថុណា ៗ មិនមានដល់សត្វនោះ បើសត្វគប្បីសោកស្តាយចំពោះវត្ថុដែលគ្មាននោះ ៗ គប្បីសោយសោកចំពោះខ្លួនឯងដែលលុះក្នុងអំណាច នៃមច្ចុគ្រប់កាលផង ។

(៦១២) អាយុសង្ខារមិនទៅតាមសត្វណាមួយ ដែលឈរអង្គុយដេក ដើរទៅមកឡើយ សត្វបើកភ្នែក ធ្មេចភ្នែក ដរាបណា វ័យរបស់សត្វតែងរំកិលទៅដរាបនោះ ។

(៦១៣) កាលបើសេចក្តីព្រាត់ប្រាសក្នុងខ្លួន ជាដំណើរផុតសង្ស័យនោះហើយ បុគ្គលគប្បីអាណិតសត្វរស់នៅដ៏សេសសល់ មិនគួរសោយសោក ចំពោះសត្វដែលច្យុតហើយទេ ។

ចប់ អននុសោចិយជាតក ទី ៨ ។

# កាឡពាហុជាតកំ

(៦១៤) យំ អន្នបានស្ស បុរេ លភាម
តំ ទានិ សាខមិគមេវ គច្ឆតិ
គច្ឆាម ទានិ វនមេវ រាធ
អសក្កតា ចម្ហ ធនញ្ជយាយ ។

(៦១៥) លាភោ អលាភោ យសោ អយសោ ច
និន្ទា បសំសា ច សុខំ ច ទុក្ខំ
ឯតេ អនិច្ចា មនុជេសុ ធម្មា
មា សោចិ កឹ សោចសិ ពោដ្ឋបាទ ។

(៦១៦) អទ្ធា តុវំ បណ្ឌិតកោសិ រាធ
ជានាសិ អត្ថានិ អនាគតានិ
កថំ នុ សាខាមិគំ ទក្ខិសាម
និច្ឆារិតំ រាជកុលតោវ ជម្មំ ។



# កាឡពាហុជាតក

(៦១៤) (សេកឈ្មោះពោដ្ឋបាទជាប្អូននិយាយថា) កាលពីដើម យើងបានបាយនឹងទឹកណា អំពីសំណាក់នៃស្តេចនោះ ឥឡូវនេះ បាយនឹងទឹកនោះ បានទៅស្វាវិញហើយ បពិត្របងរាធៈ ឥឡូវនេះ យើងនឹងនាំគ្នាទៅព្រៃវិញ ព្រោះព្រះបាទធនញ្ជ័យ លែងរាប់អានយើងហើយ ។

(៦១៥) (សេកពោធិសត្វ ឈ្មោះរាធៈជាបង និយាយតបថា) លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី លោកធម៌ទាំង ៨ នោះ មិនទៀង ក្នុងមនុស្សសត្វទាំងឡាយទេ ម្នាលពោដ្ឋបាទ អ្នកកុំសោកស្តាយឡើយ អ្នកនឹងសោកស្តាយធ្វើអ្វី ។

(៦១៦) (សេកឈ្មោះពោដ្ឋបាទ និយាយថា) បពិត្របងរាធៈ បងជាអ្នកប្រាជ្ញមែនពិតហើយ បងដឹងនូវប្រយោជន៍ ដែលមិនទាន់មានមក តើយើងនឹងឃើញស្វាដ៏លាមក ដែលត្រូវគេបណ្តេញពីរាជត្រកូល ដោយងាយ ដូចម្តេចហ្ន៎ ។

(៦៦៧) ចាលេតិ កណ្ណំ ភកុដឹ ករោតិ
មុហុំ មុហុំ ភាយយតេ កុមារេ
សយមេវ តំ កាហតិ កាឡពាហុ
យេនារកា ឋស្សតិ អន្នបានំ ។

កាឡពាហុជាតកំ នវមំ ។

# សីលវីមំសជាតកំ

(៦៦៨) សីលំ កិរេវ កល្យាណំ សីលំ លោកេ អនុត្តរំ
បស្ស ឃោរវិសោ នាគោ សីលវាតិ ន ហញ្ញតិ ។
(៦៦៩) យាវទេវស្សហូ កិញ្ចិ តាវទេវ អខាទិសុំ
សង្គម្ម កុលលា លោកេ ន ហឹសន្តិ អកិញ្ចនំ ។
(៦៧០) សុខំ និរាសា សុបតិ អាសា ផលវតី សុខា
អាសំ និរាសំ កត្វាន សុខំ សុបតិ បិង្គលា ។



(៦៦៧) (ភរិយា និយាយថា) សត្វខ្មៅឈ្មោះកាឡពាហុ ញាក់ត្រចៀក ធ្វើមុខក្រញូវ គំរាមឲ្យព្រះរាជកុមារភិតភ័យ ដោយការសម្លុត ថា មុហុំមុហុំ កម្មុជាតិទីឋិតនៅឆ្ងាយអំពីបាយនិងទឹក ដោយហេតុណា ក៏នឹងធ្វើខ្លួនហេតុនោះ ដោយខ្លួនឯងពុំខានឡើយ ។

ចប់ កាឡពាហុជាតក ទី ៩ ។

# សីលវីមំសជាតក

(៦៦៨) (បុរោហិតពោធិសត្វ និយាយថា) បានឮមកថា សីល ជាគុណជាតដ៏ល្អ សីល ជាគុណដ៏ប្រសើរក្រៃលែងក្នុងលោក សូមព្រះអង្គទតមើលចុះ ដូចយ៉ាងនាគ ជាសត្វមានពិសដ៏ខ្លាំងពន្លឹក មិនហ៊ានបៀតបៀន ដោយយល់ថា បុគ្គលនេះមានសីល ។
(៦៦៩) (ពោធិសត្វ ពោលថា) ដុំសាច់បន្តិចបន្តួច នៅមានដល់ខ្លួននោះ ដរាបណា ពួកប្រមង់ក្នុងលោក តាមចឹកខ្លួននោះ ដរាបនោះដែរ សត្វបក្សីទាំងសេស មិនបានបៀតបៀនខ្លួនដែលមិនមានសាច់ជាគ្រឿងកង្វល់នោះ ។
(៦៧០) បុគ្គលដេកលក់ជាសុខ ព្រោះមិនមានសេចក្ដីប្រាថ្នា សេចក្ដីប្រាថ្នាដែលមានលទ្ធផលក៏ជាសុខ នាងបិង្គលាទាសី បានធ្វើឲ្យសេចក្ដីប្រាថ្នា ឲ្យគ្មានសេចក្ដីប្រាថ្នាវិញ ក៏ដេកលក់ជាសុខដែរ ។

[២៦១] ន សមាធិបរោ អត្ថិ អស្មិំ លោកេ បរម្ហិ ច
ន បរំ នាបិ អត្តានំ វិហឹសតិ សមាហិតោតិ ។

សីលវីមំសជាតកំ ទសមំ ។

កុដិទូសកវគ្គោ តតិយោ ។

## តស្សុទ្ទានំ

សមនុស្ស សបុណ្ណ សយាចនកោ
អថ មេណ្ឌវរុត្តម គោធវរោ
អថ កាយ សកេបុក គោតិវរោ
អថ ភទ្ទ សុសីលវរេន ទស ។

---



[២៦១] ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី មិនមានធម៌ដទៃប្រសើរជាងសមាធិឡើយ (ព្រោះ) បុគ្គលអ្នកតាំងនៅក្នុងសមាធិហើយ រមែងមិនបៀតបៀនបុគ្គលដទៃផង មិនបៀតបៀនខ្លួនឯងផង ។

ចប់ សីលវីមំសជាតក ទី ១០ ។

ចប់ កុដិទូសកវគ្គ ទី ៣ ។

## ឧទ្ទាននៃកុដិទូសកវគ្គនោះ គឺ

និយាយអំពីក្បាលទឹកដៃដើម របស់ស្វាដូចមនុស្ស ១ ប្រពោស ធ្វើឲ្យសំឡេងជាទុទ្ទុភៈ ១ បុគ្គលអ្នកសូម ១ សត្វពពែប្រសើរ ១ សត្វទន្សងប្រសើរ ១ កាមមិនល្អជាងកាយ ១ ចន្ទ្រឈ្មោះកេពុកៈ ១ ស្តេចបារែនប្រសើរ ១ សេកឈ្មោះភទ្ទៈ ១ សីលប្រសើរ ១ ត្រូវជា ១០ ។

## កោកាលិកជាតកំ

(៦៦២) យោ វេ កាលេ អសម្បត្តេ អតិវេលំ បភាសតិ

ឯវំ សោ និហតោ សេតិ កោកិលាយេវ អត្រជោ ។

(៦៦៣) ន ហិ សត្ថំ សុនិសិតំ វិសំ ហលាហលាមិវ

ឯវំ និក្កដ្ឋេ បាតេតិ វាចា ទុព្ភាសិតា យថា ។

(៦៦៤) តស្មា កាលេ អកាលេ វា វាចំ រក្ខេយ្យ បណ្ឌិតោ

នាតិវេលំ បភាសេយ្យ អបិ អត្តសមម្ហិ វា ។

(៦៦៥) យោ ច កាលេ មិតំ ភាសេ មតិបុព្វោ វិចក្ខណោ

សព្វេ អមិត្តេ អាទេតិ សុបណ្ណោ ឧរគម្មិវ ។

កោកាលិកជាតកំ ចប់ ។



## កោកាលិកជាតក

(៦៦២) (អាមាត្យពោធិសត្វ ពោលថា) បុគ្គលណានិយាយហួសប្រមាណ ក្នុងកាលដែលមិនសមគួរ(លុះដល់) បុគ្គលនោះត្រូវគេកំចាត់ចេញ ដេកនៅតែម្នាក់ឯង ដូចកូនតាវៅ (ដែលមេក្អែកចឹកកំចាត់ចេញ) ។

(៦៦៣) កាំបិតមុតដែលគេសំលៀងមុតហើយ ឬថ្នាំពិសដ៏ក្លាខ្លាំង ក៏មិនទាញបុគ្គលឲ្យធ្លាក់ចុះ ដូចវាចាទុព្ភាសិតទេ ។

(៦៦៤) ហេតុនោះ អ្នកប្រាជ្ញគួររក្សាវាចាទុក ក្នុងកាលដែលគួរ នឹងកាលមិនគួរ មិនគួរនិយាយហួសប្រមាណ សូម្បីចំពោះបុគ្គលដែលស្មើនឹងខ្លួន ។

(៦៦៥) ចំណែកបុគ្គលណាមានគំនិតគិតទុកមុន មានប្រាជ្ញាជាគ្រឿងពិចារណា និយាយល្មមប្រមាណ ក្នុងកាលគួរ បុគ្គលនោះ អាចចាប់សត្រូវទាំងពួងបាន ដូចគ្រុឌចាប់នាគដូច្នោះ ។

ចប់ កោកាលិកជាតក ទី ១ ។

# រថលដ្ឋិជាតកំ

(៦៦៦) អបិ ហន្ត្វា ហតោ ព្រូតិ ជេត្វា ជិតោតិ ភាសតិ
បុព្វមក្ខាយិនោ រាជ ឯកទត្ថុ ន សទ្ទហេ ។

(៦៦៧) តស្មា បណ្ឌិតជាតិយោ សុណេយ្យ ឥតរស្សបិ
ឧភិន្នំ វចនំ សុត្វា យថា ធម្មោ តថា ករេ ។

(៦៦៨) អលសោ គិហី កាមភោគី ន សាធុ
អសញ្ញតោ បព្វជិតោ ន សាធុ
រាជា ន សាធុ អនិសម្មការី
យោ បណ្ឌិតោ កោធនោ តំ ន សាធុ ។

(៦៦៩) និសម្ម ខត្តិយោ កយិរា នានិសម្ម ទិសម្បតិ
និសម្មការិនោ រាជ យសោ កិត្តិ ច វឌ្ឍតីតិ ។

រថលដ្ឋិជាតកំ ទុតិយំ ។



# រថលដ្ឋិជាតក

[៦៦៦] (ពាក្យពោធិសត្វពោលថា) បពិត្រព្រះរាជា បុគ្គលខ្លះប្រហារខ្លួន ដោយខ្លួនឯង ហើយនិយាយថា គេប្រហារក៏មាន ផ្ចាញ់គេហើយនិយាយថា គេផ្ចាញ់ខ្លួនក៏មាន អ្នកប្រាជ្ញកុំគប្បីជឿពាក្យនៃអ្នកនិយាយមុន ដោយដាច់ខាតឡើយ ។

(៦៦៧) ហេតុនោះ បណ្ឌិតជាតិ គួរស្តាប់ពាក្យរបស់បុគ្គលក្រៅពីនេះផង លុះស្តាប់ពាក្យរបស់ជនទាំងពីរនាក់ហើយ គប្បីធ្វើតាមច្បាប់ចុះ ។

(៦៦៨) គ្រហស្ថអ្នកបរិភោគកាម ជាអ្នកខ្ជិលច្រអូស មិនប្រពៃ អ្នកបួសមិនសង្រួម មិនប្រសើរ ព្រះរាជាមិនពិចារណាហើយធ្វើ មិនប្រសើរ បណ្ឌិតដែលជាអ្នកច្រើនក្រោធ ក៏ពុំប្រសើរ ។

(៦៦៩) បពិត្រព្រះអង្គជាម្ចាស់នៃទិស ក្សត្រិយ៍គប្បីពិចារណាហើយសឹមធ្វើ បើមិនទាន់ពិចារណា មិនត្រូវធ្វើទេ យសក្តិ កិត្តិសព្ទក្តី រមែងចំរើន ដល់ព្រះរាជា ដែលពិចារណាហើយទើបធ្វើ ។

ចប់ រថលដ្ឋិជាតក ទី ២ ។

# គោធជាតកំ

(៦៣០) តទេវ មេ ត្វំ វិទិតោ
វនមជ្ឈេ រថេសភ
យស្ស តេ ខគ្គពទ្ធស្ស
សន្នទ្ធស្ស តិរីដិនោ
អស្សត្ថទុមសាខាយ
បក្កា គោធា បលាយថ ។

(៦៣១) នមេ នមន្តស្ស ភជេ ភជន្តំ
កិច្ចានុកុព្វស្ស ករេយ្យ កិច្ចំ
នានត្ថកាមស្ស ករេយ្យ អត្ថំ
អសម្ភជន្តម្បិ ន សម្ភជេយ្យ ។

(៦៣២) ចជេ ចជន្តំ វនថំ ន កយិរា
អបេតចិត្តេន ន សម្ភជេយ្យ
ទិជោ ទុមំ ខីណផលន្តិ ញត្វា
អញ្ញំ សមេក្ខេយ្យ មហា ហិ លោកោ ។



# គោធជាតក

(៦៣០) (នាងទេវី ក្រាបបង្គំទូលថា) ព្រះអង្គណា ដែលមានព្រះខ័នសៀត ទ្រង់ស្អិតស្អាងហើយ ទ្រទ្រង់នូវសំពត់តិរីដ ទ្រង់មានខ្សឹងស្អើរ បានបោលទៅអំពីមែកអស្សត្ថព្រឹក្ស ព្រះអង្គនោះ ទ្រង់ប្រសើរក្នុងរថ ខ្ញុំដឹងច្បាស់ហើយ ក្នុងកណ្ដាលព្រៃ ក្នុងកាលនោះឯង ។

(៦៣១) (ពោធិសត្វ ពោលថា) បុគ្គលគប្បីសំពះបុគ្គល អ្នកសំពះខ្លួន គប្បីសេពគប់បុគ្គលអ្នកសេពគប់ខ្លួន គប្បីធ្វើកិច្ច របស់បុគ្គល ដែលជួយធ្វើកិច្ចខ្លួន មិនគប្បីធ្វើនូវសេចក្ដីចំរើន ដល់បុគ្គល អ្នកប្រាថ្នាសេចក្ដីវិនាស មិនគប្បីគប់រកនូវបុគ្គលដែលមិនគប់រក (ខ្លួននោះឡើយ) ។

(៦៣២) គប្បីលះបង់នូវបុគ្គល ដែលលះបង់ខ្លួន មិនគប្បីធ្វើនូវសេចក្ដីស្រឡាញ់ដោយតណ្ហា (ក្នុងបុគ្គលនោះ) មិនគប្បីគប់រកនូវបុគ្គលដែលមានចិត្តរើរាយ ដូចសត្វបក្សីដឹងថា ឈើមានផ្លែអស់ហើយ (ហើរទៅរកដើមឈើដែលមានផ្លែបរិបូណ៌) គប្បីមើលមើលបុគ្គលដទៃ ព្រោះថាលោកសន្និវាសធំណាស់ ។

(២៣៣) សោ តេ ករិស្សាមិ យថានុការំ
កតញ្ញុតំ ខត្តិយោ បេក្ខមានោ
សព្វញ្ច តេ ឥស្សរិយំ ទទាមិ
យស្សិច្ឆសិ តស្ស តុវំ ទទាមីតិ ។

គោធជាតកំ តតិយំ ។

## រាជោវាទជាតកំ

(២៣៤) គវញ្ចេ តរមានានំ   ជិម្ហំ គច្ឆតិ បុង្គវោ
សព្វា តា ជិម្ហំ គច្ឆន្តិ   នេត្តេ ជិម្ហំ គតេ សតិ ។
(២៣៥) ឯវមេវ មនុស្សេសុ   យោ ហោតិ សេដ្ឋសម្មតោ
សោ ចេ អធម្មំ ចរតិ   បគេវ ឥតរា បជា
សព្វំ រដ្ឋំ ទុខំ សេតិ   រាជា ចេ ហោតិ អធម្មិកោ ។



(២៣៣) (ព្រះរាជា ត្រាស់ថា) យើងនោះ ជាក្សត្រិយ៍ កាលឃើញនូវភាពនៃកតញ្ញូ នឹងធ្វើតបដល់នាងតាមសមគួរភាព យើងនឹងឲ្យឥស្សរិយយសទាំងអស់ ដល់នាង នាងចង់បានរបស់ណា យើងនឹងឲ្យរបស់នោះ ដល់នាង ។

ចប់ គោធជាតក ទី ៣ ។

## រាជោវាទជាតក

(២៣៤) (ព្រះពោធិសត្វ ពោលថា) កាលដែលពួកគោឆ្លងដើរទៅ បើគោមេហ្វូងដើរវៀច ពួកគោញី ក៏ដើរវៀចតាមដែរ ព្រោះគោមេហ្វូងដើរវៀចនោះ ។

(២៣៥) គឺពួកមនុស្ស ក៏យ៉ាងនោះដែរ មនុស្សណាដែលគេសន្មតថា ប្រសើរជាងគេ បើមនុស្សនោះប្រព្រឹត្តអធម៌ នឹងបាច់និយាយទៅថ្វី ដល់ប្រជាជនឯទៀត បើព្រះរាជាជាអ្នកប្រព្រឹត្តអធម៌ ក្រុងទាំងអស់ រមែងដេកជាទុក្ខ ។

(២៣៦) គវញ្ចេ តរមានានំ ឧជុំ គច្ឆតិ បុង្គវោ
សព្វា គាវី ឧជុំ យន្តិ នេត្តេ ឧជុំ គតេ សតិ ។
(២៣៧) ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ
សោ ចេបិ ធម្មំ ចរតិ បគេវ ឥតរា បជា
សព្វំ រដ្ឋំ សុខំ សេតិ រាជា ចេ ហោតិ ធម្មិកោតិ ។

រាជោវាទជាតកំ ចតុត្ថំ ។

## ជម្ពុកជាតកំ

(២៣៨) ព្រហា បវឌ្ឍកាយោ សោ ទីឃទាឋ ជម្ពុក
ន ត្វំ តត្ថ កុលេ ជាតោ យត្ថ គណ្ហន្តិ កុញ្ជរំ ។
(២៣៩) អសីហោ សីហមានេន យោ អត្តានំ វិកុព្វតិ
កោត្ថុវ គជមាសជ្ជ សេតិ ភូម្យា អនុត្ថុនំ ។
(២៤០) យសស្សិនោ ឧត្តមបុគ្គលស្ស
សញ្ជាតខន្ធស្ស មហព្ពលស្ស
អសមេក្ខិយ ថាមពលូបបត្តឹ
ស សេតិ នាគេន ហតោយំ ជម្ពុកោ ។



(២៣៦) កាលដែលពួកគោញីដើរទួងទៅ បើគោមេហ្វូងដើរត្រង់ ពួកគោញីទាំងអស់ក៏ដើរត្រង់ដែរ កាលៈបើគោមេហ្វូងនាំដើរទៅត្រង់ ។
(២៣៧) ក្នុងពួកមនុស្សក៏យ៉ាងនោះដែរ មនុស្សណាដែលគេសន្មតថាប្រសើរជាងគេ បើមនុស្សនោះប្រព្រឹត្តធម៌ ចាំបាច់និយាយទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាជាអ្នកប្រព្រឹត្តធម៌ ក្រុងទាំងអស់ក៏ដេកជាសុខ ។

ចប់ រាជោវាទជាតក ទី៤ ។

## ជម្ពុកជាតក

(២៣៨) (កជស័ហ៍ និយាយថា) នែចចក ដំរីនោះធំណាស់ មានកាយក៏ខ្ពស់ មានភ្លុកក៏វែង ពួកសត្វកើតក្នុងត្រកូលរាជសីហ៍ណា រមែងចាប់ដំរីបាន អ្នកឯងមិនមែនកើតក្នុងត្រកូលរាជសីហ៍នោះទេ ។
(២៣៩) សត្វណា មិនមែនជារាជសីហ៍ ក្លែងខ្លួនដោយមានះថា អញជារាជសីហ៍ សត្វនោះ រមែងដេកថ្ងូរលើផែនដី ដូចជាចចកមកកានដំរី (ត្រូវដំរីជាន់) ។
(២៤០) ចចកនេះ មិនពិនិត្យកំឡាំងកាយកំឡាំងប្រាជ្ញា និងកំណើតរបស់សីហៈ ដែលជាសត្វមានយស ជាសត្វឧត្តម ជាសត្វមានខ្លួនមាំមួន ជាសត្វមានកំឡាំងខ្លាំងនោះ ទើបត្រូវដំរីជាន់ស្លាប់ ។

(៦៦១) យោ ចីធ កម្មំ កុរុតេ បមាយ
ថាមព្វលំ អត្តនិ សំវិទិត្វា
ជប្បេន មន្តេន សុភាសិតេន
បរិក្ខវា សោ វិបុលំ ជិនាតីតិ ។

ជម្ពុកជាតកំ បញ្ចមំ ។

## ព្រហាឆត្តជាតកំ

(៦៦២) តិណំ តិណន្តិ លបសិ កោ នុ តេ តិណមាហរិ
កិំ នុ តេ តិណកិច្ចត្ថិ តិណមេវ បភាសសិ ។
(៦៦៣) ឥធាគមា ព្រហ្មចារី ព្រហាឆត្តោ ពហុស្សុតោ
សោ មេ សព្វំ សមាទាយ តិណំ និក្ខិប្ប គច្ឆតិ ។



(៦៦១) ក្នុងលោកនេះ បុគ្គលណា បានពិចារណាឲ្យដឹងច្បាស់នូវកំឡាំងកាយ និងកំឡាំងប្រាជ្ញាក្នុងខ្លួន ជាអ្នកកំណត់ដោយការស្វា-ធ្យាយ ដោយការប្រឹក្សា ដោយសុភាសិត (ជាមុន) ទើបធ្វើការងារ បុគ្គលនោះឈ្មោះថា ឈ្នះនូវប្រយោជន៍ធំ គឺមិនសាបសូន្យប្រយោជន៍ ។

ចប់ ជម្ពុកជាតក ទី ៥ ។

## ព្រហាឆត្តជាតក

(៦៦២) (ពាក្យពោធិសត្វទូលថា) ព្រះអង្គត្រាស់ថា ស្មៅៗ ដូច្នេះ តើនរណាហ្ន៎ លួចយកស្មៅ របស់ព្រះអង្គទៅ ហេតុដូចម្តេច បានជាព្រះអង្គមានកិច្ច ដោយស្មៅ ទើបត្រាស់តែស្មៅប៉ុណ្ណោះ ។

(៦៦៣) (ព្រះបាទពារាណសីត្រាស់ថា) តាបសឈ្មោះឆត្ត មានកាយធំខ្ពស់ ជាព្រហ្មចារីបុគ្គល ជាពហុស្សុត បានមកក្នុងទីនេះ លោកបានប្រមូលទ្រព្យរបស់យើងទាំងអស់ រួចដាក់ស្មៅ (ក្នុងពាងទាំងឡាយ) ហើយទៅបាត់ ។

(៦៤៤) ឯវេតំ ហោតិ កត្តព្វំ អប្បេន ពហុមិច្ឆតា

សព្វំ សកស្ស អាទានំ អនាទានំ តិណស្ស ច

តិណស្ស ចាជិសុ ករោ គត្តកា បរិទេវនា ។

(៦៤៥) សីលវន្តោ ន ករោន្តិ ពាលោ សីលានិ ការតិ

អនិច្ចសីលំ ទុស្សីល្យំ កឹ បណ្ឌិច្ចំ ករិស្សតិ ។

ព្រហ្មទត្តជាតកំ ឆដ្ឋំ ។

## ចិបជាតកំ

(៦៤៦) ន តេ បីឋមទាសិម្ហា ន បានំ នបិ ភោជនំ

ព្រហ្មចារី ខមស្សុ មេ ឯតំ បស្សាមិ អច្ចយំ ។



(៦៤៤) (ព្រះរាជាពោធិសត្វ ពោលថា) ការកាន់យកទ្រព្យទាំងអស់ របស់ខ្លួនក្តី ការមិនកាន់យកស្មៅ (ដែលមិនគួរយកទៅ) នេះក្តី ជាកិច្ចដែលអ្នកប្រាថ្នាទ្រព្យច្រើន ដោយយកស្មៅបន្តិចបន្តួច (ជារបស់) គប្បីធ្វើយ៉ាងនេះឯង (ព្រោះហេតុនោះ) គួរគតបស ដាក់ស្មៅក្នុងការតាំងឡាយហើយទៅបាត់ ចុះការធ្វើកន្ទេលរបស់អ្នក ក្នុងរបស់នោះ ។

(៦៤៥) (ព្រះបាទពោធិសត្វ ត្រាស់ថា) ពួកពាលអ្នកមានសីលធម៌ មិនធ្វើបែបនេះទេ ចំណែកមនុស្សពាល ទើបធ្វើសីលធម៌តាំងឡាយរបស់ខ្លួន (ឲ្យពាក្រក់) ភាពជាបណ្ឌិត នឹងធ្វើខ្លួនឲ្យជាបុគ្គលអ្នកប្រព្រឹត្តសីល មានសីលមិនខ្ជាប់ខ្ជួន ដូចម្តេចកើត ។

ចប់ ព្រហ្មទត្តជាតក ទី ៦ ។

## ចិបជាតក

(៦៤៦) (ពាណិជសិរិសត្ថិ ពោលថា) យើងខ្ញុំទាំងឡាយមិនបានប្រគេនតាំង មិនបានប្រគេនទឹក ទាំងមិនបានប្រគេនភោជនាហារ ដល់លោក សូមលោកជាព្រហ្មចារីអត់ទោសដល់ខ្ញុំ ខ្ញុំឃើញទោសនុ៎ះហើយ ។

(២៦៧) នេកកិសន្ធាមិ ជហាមិ កាលេ
ន ហាមិ មេ អប្បិយមាសិ[1] តាតំ
អជោមិ មេ អាសំ មហោរិតញ្ញោ
ឯតាទិសោ នូន កុលស្ស ធម្មោ ។

(២៦៨) ឯសស្មាកំ កុលេ ធម្មោ បិតុបិតាមហោ សទា
អាសនំ ឧទកំ បជ្ជំ សព្វេតំ និបតាមសេ ។

(២៦៩) ឯសស្មាកំ កុលេ ធម្មោ បិតុបិតាមហោ សទា
សក្កច្ចំ ឧបតិដ្ឋាម ឧត្តមំ វិយ ញាតកំ ។

ចីបជាតកំ សត្តមំ ។

## ថុសជាតកំ

(២៧០) វិទិតំ ថុសំ ឧន្ទុរានំ វិទិតំ បន តណ្ឌុលំ
ថុសំ ថុសំ វិវជ្ជិត្វា តណ្ឌុលំ បន ខាទរេ ។

[1] ម. អប្បិយមាហុ ។



(២៦៧) (ពោធិសត្វ ពោលថា) អាត្មាមិនដាច់ចំពោះផង មិនរឹងផង
ទាំងតែតិចតួច ដែលមិនជាទីស្រឡាញ់របស់អាត្មា ក៏មិនមាន
ឡើយ មួយទៀត អាត្មាមានសេចក្តីក្រែង ក្នុងចិត្តថា ធម្មតា
នៃត្រកូលក្រោកជួយខ្ទះ ដោយពិត ។

(២៦៨) (សេដ្ឋី ពោលថា) យើងខ្ញុំបានប្រគេនអាសនៈ ប្រគេនទឹក
ប្រគេនប្រេងសម្រាប់លាបជើង ទាំងអស់នេះ នេះជាធម្មតារបស់
ដូនតានិងជីតា ក្នុងត្រកូលរបស់យើងខ្ញុំ សព្វ ៗ កាល ។

(២៦៩) យើងខ្ញុំនឹងបម្រើ (សមណព្រាហ្មណ៍អ្នកប្រព្រឹត្តធម៌ល្អ) ដូចជា
ញាតិជាន់ខ្ពស់ ដោយសេចក្តីគោរព នេះជាធម្មតារបស់ដូនតា
និងជីតា ក្នុងត្រកូលរបស់យើងខ្ញុំ សព្វ ៗ កាល ។

ចប់ ចីបជាតក ទី ៧ ។

## ថុសជាតក

(២៧០) (ព្រះរាជា ទ្រង់ត្រាស់ថា) កណ្តុរទាំងឡាយ ស្គាល់ច្បាស់
នូវអង្កាម ស្គាល់ច្បាស់នូវអង្ករ កណ្តុរទាំងឡាយ វៀរចេញ
នូវអង្កាម ស៊ីតែអង្ករ ។

(៦៨១) យា មន្តនា អរញ្ញស្មិំ    យា ច គាមេ និកណ្ណិកា
យញ្ចេតំ ឥតិ ចីតិ ច    ឯតម្បិ វិទិតំ មយា ។
(៦៨២) ធម្មេន កិរ ជាតស្ស    បិតា បុត្តស្ស មក្កដោ
ទហរស្សេវ សន្តស្ស    ទន្តេហិ ផលមច្ឆិទា ។
(៦៨៣) យមេតំ បរិសប្បសិ    អជកាណោវ សាសបេ
យោបាយំ ហេដ្ឋតោ សេតិ    ឯតម្បិ វិទិតំ មយាតិ ។

ថុសជាតកំ អដ្ឋមំ ។

## ពាវេរុជាតកំ

(៦៨៤) អទស្សនេន មោរស្ស    សិខិនោ មញ្ជុភាណិនោ
កាកំ តត្ថ អបូជេសុំ    មំសេន ច ផលេន ច ។
(៦៨៥) យទា ច សរសម្បន្នោ    មោរោ ពាវេរុមាគមា
អថ លាភោ ច សក្ការោ    វាយសស្ស អហាយថ ។



(៦៨១) ការប្រឹក្សាគ្នាណាក្នុងព្រៃ ការខ្សឹបណាក្នុងស្រុក ទាំងការគិត (ប្រុងប្រហារ) ណា រឿងទាំងនេះ អញដឹងច្បាស់ហើយ ។

(៦៨២) ឮថាទំនៀម ស្វាជាឪពុក តែងយកធ្មេញទៅខាំផ្តាច់ខ្ទង់អណ្ឌជាត របស់កូនតូច ដែលកើតហើយ ។

(៦៨៣) អ្នកឯងលួចលក់ ដូចជាពពែខ្វាក់ ក្នុងចម្ការស្ពៃ បុគ្គលណា ដេកនៅក្រោមទីដេក ដំណើររបស់បុគ្គលនោះ យើងដឹងច្បាស់ហើយ ។

ចប់ ថុសជាតក ទី ៨ ។

## ពាវេរុជាតក

(៦៨៤) (ព្រះសាស្តា ត្រាស់ថា) ជនទាំងឡាយបានយកសាច់នឹងផ្លែឈើ បូជាក្អែក ក្នុងដែននោះ ព្រោះមិនទាន់ឃើញសត្វក្ងោក ជាសត្វមានសក់ មានសំឡេងពីរោះ ។

(៦៨៥) ក្ងោកជាសត្វបរិបូណ៌ ដោយសំឡេងពីរោះ បានមកដល់ដែនពាវេរុ ក្នុងកាលណា លាភនឹងសក្ការៈរបស់ក្អែក ក៏សាបសូន្យ ក្នុងកាលនោះ ។

(៦៨៦) យាវ នុប្បជ្ជតិ ពុទ្ធោ ធម្មរាជា បភង្ករោ
តាវ អញ្ញេ អបូជេសុំ បុថូ សមណព្រាហ្មណេ ។
(៦៨៧) យទា ច សរសម្បន្នោ ពុទ្ធោ ធម្មំ អទេសយិ
អថ លាភោ ច សក្ការោ តិត្ថិយានំ អហាយថាតិ ។

ពាវេរុជាតកំ នវមំ ។

## វិសយ្ហជាតកំ

(៦៨៨) អទាសិ ទានានិ បុរេ វិសយ្ហ
ទទតោ ច តេ ខយធម្មោ អហោសិ
ឥតោ បរញ្ច ន ទទេយ្យ ទានំ
តិដ្ឋេយ្យុំ តេ សំយមន្តស្ស ភោគា ។
(៦៨៩) អនរិយមរិយេន សហស្សនេត្ត
សុទុគ្គតេនាបិ អកិច្ចមាហុ
មា វេ ធនំ តំ អហុ វជិន្ទ(១)
យំ ភោគហេតុ វិជហេមុ សទ្ធំ ។

១ ម. មា វេ ធនំ អហុ ទេវរាជ ។



(៦៨៦) ព្រះពុទ្ធជាធម្មរាជទ្រង់ធ្វើនូវពន្លឺ មិនទាន់កើតឡើងដរាបណា ពួកជនឯទៀត បានបូជាសមណព្រាហ្មណ៍ដ៏ច្រើន ដរាបនោះ ។

(៦៨៧) ព្រះពុទ្ធព្រះអង្គបរិបូណ៌ ដោយសំឡេង បានសំដែងនូវព្រះធម៌ ក្នុងកាលណា លាភនិងសក្ការៈរបស់តិរ្ថិយទាំងឡាយ ក៏សាបសូន្យអស់ ក្នុងកាលនោះ ។

ចប់ ពាវេរុជាតក ទី ៩ ។

## វិសយ្ហជាតក

(៦៨៨) (សក្កទេវរាជ ត្រាស់ថា) នែវិសយ្ហសេដ្ឋី ក្នុងកាលមុន អ្នកបានឲ្យទានទាំងឡាយហើយ កាលអ្នកចេះតែឲ្យ សភាវៈអស់ទៅនៃភោគៈទាំងឡាយ បានកើតមានហើយ ចាប់ដើមអំពីនេះទៅ បើអ្នកមិនឲ្យទានទេ ភោគសម្បត្តិទាំងឡាយ របស់អ្នក ដែលឈប់ឲ្យ ទើបគង់នៅ ។

(៦៨៩) (វិសយ្ហសេដ្ឋី ពោលថា) នែសហស្សនេត្រ ព្រះអរិយៈទាំងឡាយ បានពោលថា អំពើដ៏លាមក អោយជនសូម្បីជាអ្នកកំសត់ ក៏មិនគប្បីធ្វើដែរ នែជមិន្ទ្រ យើងលះបង់ហើយនូវសេចក្តីជឿក្នុងទាន ព្រោះហេតុតែទ្រព្យណា ទ្រព្យនោះកុំមានដល់យើងឡើយ ។

(៦៦០) យេន ឯកោ រថោ យាតិ យាតិ តេនាបរោ រថោ
បោរាណំ និហិតំ វត្តំ វត្តតញ្ញេវ វាសវ ។
(៦៦១) យទិ ហេស្សតិ ទស្សាម អសន្តេ កឹ ទទាមសេ
ឯវំភូតាបិ ទស្សាម មា ទានំ បមទម្ហសេ ។

វិសយ្ហជាតកំ ទសមំ ។

កោកិលវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

អតិវេលំ មកសតិ ជំពុកោ
វរមេជ្ជ រថេសភ ជិម្ហគោ
អថ ជម្ពុ តិណកាសន បីឋំ
អថ តណ្ហុលំ ហោរ វិសយ្ហ ទស ។

---



(៦៦០) រថមួយ បរទៅតាមផ្លូវណា រថឯទៀត ក៏បរទៅតាមផ្លូវនោះដែរ វត្តចាស់ កិច្ចវត្តដែលយើងបំពេញមក ក្នុងកាលមុន ចូរប្រព្រឹត្តទៅចុះ ។

(៦៦១) បើទ្រព្យមាន យើងនឹងឲ្យបាន កាលបើ ទ្រព្យមិនមាន យើងនឹងឲ្យដូចម្ដេចកើត ថ្វីបើយើងជាអ្នក(ច្រូតស្មៅលក់) យើងនៅតែឲ្យទាន យើងមិនប្រហែសក្នុងទានទេ ។

ចប់ វិសយ្ហជាតក ទី ១០ ។

ចប់ កោកិលវគ្គ ទី ៤ ។

## ឧទ្ទាននៃកោកិលវគ្គនោះ គឺ

និយាយអំពីបុគ្គលនិយាយហួសប្រមាណ ១ បុគ្គលផ្ដាញ់ខ្លួនឯង ១ ព្រះរាជាប្រសើរក្នុងវេលាកណ្ដាលរាត្រ ១ គោជើងវៀច ១ ចចក ១ ស្ដេចក្រាស់ជាស្មៅ ១ ដើមត្រាំងជាអាសនៈដ៏ប្រសើរ ១ អង្ករ ១ សត្វក្ងោក ១ វិសយ្ហសេដ្ឋី ១ ត្រូវជា ១០ ។

## ចុល្លកុណាលវគ្គោ

## កុណ្ឌលិកជាតកំ[១]

[៦៦២] ចកចមាកមកាកសុ ចារីសុ
អនេកចិត្តាសុ អនិគ្គហាសុ ច
សព្វត្ថ បីតិករាបិ េច សិយុំ
ន វិស្សសេ តិត្ថសមា ហិ នារិយោ ។

[៦៦៣] យញ្ច ទិស្វា កណ្ឌរកិន្នរីនំ
សព្វិត្ថិយោ ន រមន្តិ អគារេ
តំ តាទិសំ មច្ចំ ចជិត្វា ភរិយា
អញ្ញំ ទិស្វា បុរិសំ បីឋសប្បិំ ។

[៦៦៤] ពកស្ស ច ពាវរិកស្ស រញ្ញោ
អច្ចន្តកាមានុគតស្ស ភរិយា
អជ្ឈាចរី ពទ្ធវសានុគស្ស[២]
កឹ វ ឥត្ថី នាចរេ តទញ្ញំ ។

១ ម. កុណ្ឌលិកជាតកំ ។ ២ ម. បទ្ធវសានុគតស្ស ។

## ចុល្លកុណាលវគ្គ

## កុណ្ឌលិកជាតក

[៦៦២] (ព្រះអង្គ ត្រាស់ថា) ស្ត្រីទាំងឡាយអ្នកធ្វើនូវសេចក្តីក្រេកអរ ចំពោះបុរសទាំងឡាយ ជាស្ត្រីមានចិត្តច្រើនផង ផ្ចាញ់ផ្ចាល់មិនបានផង ប្រសិនបើស្ត្រីទាំងអស់ ធ្វើនូវសេចក្តីពេញចិត្ត (ចំពោះបុរស) ដោយខ្លួនឯងក៏ដោយ បុរសមិនគប្បីទុកចិត្តទេ ព្រោះថា ស្ត្រីទាំងឡាយ ស្មើដោយកំពង់ទឹក ។

[៦៦៣] ហេតុនៃសេចក្តីធុញទ្រាន់ណា នៃព្រះរាជាទ្រង់ព្រះនាមកិន្នរៈ និងនាងទេវីទ្រង់ព្រះនាមកិន្នរី (ហេតុនៃសេចក្តីធុញទ្រាន់នោះ) បុគ្គលឃើញហើយ (គប្បីដឹងច្បាស់) ស្ត្រីទាំងពួង រមែងមិនត្រេកអរ (នឹងស្វាមី) ក្នុងផ្ទះរបស់ខ្លួន នាងកិន្នរីទេវី ជាភរិយា លះបង់នូវព្រះរាជាកិន្នរៈនោះ ជាស្វាមីប្រាកដដូច្នោះ ព្រោះតែឃើញនូវបុរសខ្វិនដទៃ ។

[៦៦៤] នាងបញ្ចបាបី ជាភរិយារបស់ព្រះបាទពកៈផង របស់ព្រះបាទពាវរិកៈផង ដែលលុះក្នុងកាមដ៏ជ្រុលពេក ក៏បានប្រព្រឹត្តបទមិនគួរ ជាមួយនឹងបុរសអ្នកបម្រើ ចុះម្តេចហ្ន៎ ស្ត្រីមិនប្រព្រឹត្តបទមិនគួរនឹងបុរសដទៃនោះ ។

(៦៦៥) បិយង្គនិ សព្វលោកស្សស្ស
ញោត្ថា បិយា ព្រហ្មទត្តស្ស ភរិយា
អត្ថចរី ពន្ធសោទកស្ស
តំ កឹបិ សា ជាត្បុតា កាមគាមិនី ។

កុណ្ឌលិកជាតកំ បឋមំ ។

## វានរជាតកំ

(៦៦៦) អសក្ខឹ វត អត្តានំ   ឧទ្ធាតុំ ឧទកា ថលំ
ន ទានាហំ បុន តុយ្ហំ   វសំ គច្ឆាមិ វានរ ។
(៦៦៧) អលមេតេហិ អម្ពេហិ   ជម្ពូហិ បនសេហិ ច
យានិ បារំ សមុទ្ទស្ស   វរំ មយ្ហំ ឧទុម្ពរោ ។
(៦៦៨) យោ ច ឧប្បតិតំ អត្ថំ   ន ខិប្បមនុពុជ្ឈតិ
អមិត្តវសមន្វេតិ   បច្ឆា ច អនុតប្បតិ ។



(៦៦៥) អគ្គមហេសីឈ្មោះនាងបិយង្គនី ជាទីគាប់ព្រះហឫទ័យ របស់ព្រះបាទព្រហ្មទត្ត ជាធំក្នុងលោកទាំងមូល បានប្រព្រឹត្តបទមិនគួរជាមួយនឹងបុរសអ្នកឃ្វាលសេះបង្គល ជាអ្នកបម្រើនៃអគ្គមហេសីនោះ ជាស្រីប្រាថ្នាកាម ក៏មិនបាននូវបុរសអ្នកឃ្វាលសេះនោះផង (នូវទីជាអគ្គមហេសីផង) ។

ចប់ កុណ្ឌលិកជាតក ទី ១ ។

## វានរជាតក

(៦៦៦) (ពានរពោធិសត្វ ពោលថា) នែសត្វក្រពើ អញអាចរើខ្លួនអំពីទឹកមកលើគោកហើយ អំពីថ្ងៃនេះ អញមិនលុះអំណាចនៃអ្នកឯងទៀតទេ ។
(៦៦៧) ផ្លែឈើទាំងឡាយណា ដែលយើងគប្បីទៅកាន់ត្រើយនៃសមុទ្រហើយស៊ី ផ្លែឈើទាំងឡាយនោះ គឺផ្លែស្វាយ ផ្លែព្រីង ផ្លែខ្នុរ មិនគួរដល់យើងឡើយ ឯផ្លែល្វារបស់យើងនេះប្រសើរជាង ។
(៦៦៨) បុគ្គលណា មិនដឹងនូវហេតុដែលកើតឡើងរហ័ស ៗ ទេ បុគ្គលនោះ តែងលុះក្នុងអំណាចសត្រូវផង តែងក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយផង ។

[២៦៩] យោ ច ឧប្បតិតំ អត្ថំ ខិប្បមេវ និពោធតិ
មុច្ចតេ សត្តុសម្ពាធា ន ច បច្ឆានុតប្បតិ ។

វានរជាតកំ ទុតិយំ ។

## កុន្តិនីជាតកំ

[២៧០] អវសិម្ហ តវាគារេ និច្ចំ សក្កតបូជិតា
ត្វមេវ ទានិមករិ ហន្ទ រាជ វជាមហំ ។

[២៧១] យោ វេ កតេ បដិកតេ កិព្វិសេ បដិកិព្វិសេ
ឯវំ តំ សម្មតី វេរំ វស កុន្តិនិ មាគមា ។

[២៧២] ន កតស្ស ច កត្តា ច មេត្តិ សន្ធីយតេ បុន
ហទយំ នានុជានាតិ គច្ឆញ្ញេវ រថេសភ ។



[២៦៩] បុគ្គលណា ដឹងនូវហេតុដែលកើតឡើងភ្លាម បុគ្គលនោះគង់រួចចាកសេចក្ដីចង្អៀតគឺសត្រូវផង មិនក្ដៅក្រហាយ ក្នុងកាលជាខាងក្រោយផង ។

ចប់ វានរជាតក ទី ២ ។

## កុន្តិនីជាតក

[២៧០] (មេក្រៀលទូលស្ដេចថា) ខ្ញុំនៅអាស្រ័យ ក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ៗ ធ្វើសក្ការបូជាជានិច្ច ឥឡូវនេះព្រះអង្គបានធ្វើ (នូវហេតុឲ្យខ្ញុំចេញទៅ) បពិត្រមហារាជ បើដូច្នោះខ្ញុំព្រះអង្គនឹងទៅ ។

[២៧១] (ព្រះរាជាពោធិសត្វ ត្រាស់ថា) បុគ្គលណា (ដឹង) អំពើអាក្រក់ដែលអ្នកដទៃធ្វើហើយចំពោះខ្លួន (ដឹង) អំពើអាក្រក់តប ដែលខ្លួនធ្វើតបវិញ ពៀររបស់បុគ្គលនោះ រមែងស្ងប់រម្ងាប់ដោយអាការយ៉ាងនេះ នែនាងក្រៀល ចូរនាងនៅចុះ កុំទៅឡើយ ។

[២៧២] (មេក្រៀល និយាយថា) មិត្តភាពនៃបុគ្គលដែលត្រូវគេធ្វើនឹងបុគ្គលអ្នកធ្វើ (តប) រមែងមិនតភ្ជាប់ទៀតបានឡើយ ចិត្តរបស់ខ្ញុំមិនយល់តាមទេ បពិត្រព្រះអង្គប្រសើរក្នុងរថ ខ្ញុំនឹងទៅមិនខាន ។

(៦៩៣) កាកស្ស ទេវកាត្ត ច  មិត្តិ សន្ធិយតេ មុន
ធីកដំ ទោ ច ពាលានំ  វេសាកុត្តិធិ មា តមាតិ។

កុក្កុដជាតកំ តតិយំ ។

# អម្ពជាតកំ

(៦៩៤) យោ នីលិយំ មណ្ឌយតិ  សណ្ឌាសេន វិហញ្ញតិ
តស្ស សា វសមន្វេតុ  យា តេ អម្ពេ អវាហរិ។

(៦៩៥) វីសំ វា បញ្ចវីសំ វា  ឩនតឹសំវ ជាតិយា
តាទិសា បតិ មា លទ្ធា  យា តេ អម្ពេ អវាហរិ។

(៦៩៦) ទីឃំ គច្ឆតុ អទ្ធានំ  ឯកិកា អភិសារិយា
សង្កេតេ បតិ មា អទ្ទស  យា តេ អម្ពេ អវាហរិ។



(៦៩៣) (គ្រះកដា ក្រស់ថា) មិត្តភាពរបស់បុគ្គលដែលត្រូវគេធ្វើ ទីន បុគ្គលអ្នកធ្វើ(តប) រមែងឥតតាំងទៀត តាមចំពោះពួកជនជាអ្នកប្រាជ្ញ មិនចំពោះពួកជនពាលទេ ឆ្ងាយនាំងក្រៀល នាំងបួរនៅចុះ នាំកុំទៅឡើយ ។

ចប់ កុក្កុដជាតក ទី ៣ ។

# អម្ពជាតក

(៦៩៤) (សេដ្ឋីពោលគាថាទី ១ ពោលថា) ស្ត្រីណាលួចស្វាយ របស់លោកម្ចាស់ ស្ត្រីនោះ ចូរស្លុះក្នុងអំណាចនៃបុរសដែលប្រដាប់ដោយក្រ សម្រាប់ធ្វើសក់ឡើងខ្មៅ លំបាកដោយសណ្ដាសចុះ(បាតម្ចាស់)។

(៦៩៥) (សេដ្ឋីពោលគាថាទី ២ ពោលថា) ស្ត្រីណាលួចស្វាយ របស់លោកម្ចាស់ ស្ត្រីបែបនោះ ពេះបីកាយុដល់ ២០ ឆ្នាំ ឬ ២៥ ឆ្នាំ ឬក៏ថយពី ៣០ ឆ្នាំ ក៏កុំឲ្យបានប្ដីឡើយ ។

(៦៩៦) (សេដ្ឋីពោលគាថាទី ៣ ពោលថា) ស្ត្រីណាលួចស្វាយ របស់លោកម្ចាស់ ស្ត្រីនោះតែម្នាក់ឯង គឺនៅផ្សុកតែនឹងប្ដីហើយដើរទៅកាន់ផ្លូវឆ្ងាយ កុំឲ្យជួបនឹងប្ដីក្នុងទីដែលសន្យាគ្នាឡើយ ។

(៦៧៧) អលង្កតា សុវសនា មាលិនី ចន្ទនុស្សទា
ឯកិកា សយនេ សេតុ យា តេ អម្ពេ អវាហរីតិ ។

អម្ពជាតកំ ចតុត្ថំ ។

## គជកុម្ភជាតកំ

(៦៧៨) វនំ យទគ្គិ ទហតិ បាវកោ កណ្ហវត្តនី
កថំ ករោសិ បចលក ឯវំ ទន្ធបរក្កមោ ។

(៦៧៩) ពហូនិ រុក្ខច្ឆិទ្ទានិ បថព្យា វិវរានិ ច
តានិ ចេ នាភិសម្ភោម ហោតិ នោ កាលបរិយាយោ ។

(៦៨០) យោ ទន្ធកាលេ តរតិ តរណីយេ ច ទន្ធតិ
សុក្ខបណ្ណំវ អក្កម្ម អត្ថំ ភញ្ជតិ អត្តនោ ។



(៦៧៧) (សេដ្ឋីទី ៤ ពោលថា) ស្ត្រីកាលល្អស្អាយ របស់លោក ព្រាស់ ស្ត្រីនោះមានខ្លួនប្រដាប់ហើយ មានសំលៀកបំពាក់ដ៏ស្អាត ទ្រទ្រង់កម្រងផ្កា ប្រោះព្រំដោយខ្លឹមចន្ទន៍ ចូរដេកនៅលើទីដេកតែម្នាក់ឯងចុះ ។

ចប់ អម្ពជាតក ទី ៤ ។

## គជកុម្ភជាតក

(៦៧៨) (អាមាត្យពោធិសត្វ ពោលថា) កាលណាភ្លើង(១) នេះឆេះព្រៃ ម្នាលបចលកៈ អ្នកនឹងធ្វើដូចម្តេច ព្រោះអ្នកមានសេចក្តីព្យាយាមយឺតយូរយ៉ាងនេះ ។

(៦៧៩) (គជកុម្ភៈ (ខ្យងសោក) ពោលថា) ប្រហោងឈើក្រហែងដីមានច្រើន បើយើងទៅមិនដល់ទីទាំងនោះទេ យើងនឹងតែស្លាប់ ។

(៦៨០) (ពោធិសត្វ ពោលថា) បុគ្គលណា ហ័សហួនក្នុងកាលដែលខ្លួនត្រូវធ្វើការដោយយឺតយូរផង យឺតយូរក្នុងការងារដែលគេត្រូវធ្វើឲ្យហ័សហួនផង បុគ្គលនោះឈ្មោះថា បំផ្លាញប្រយោជន៍របស់ខ្លួនចោល ដូចជាបុរសដើរជាន់ស្លឹកឈើស្ងួតឲ្យខ្ទេចដូច្នោះ ។

---

១ អគ្គិ បាវកោ កណ្ហវត្តនី ទាំង ៣ សព្ទនេះជាឈ្មោះនៃភ្លើងតែម្យ៉ាង ។ អដ្ឋកថា ។

(២៨១) យោ ទន្ធកាលេ ទន្ធេតិ តរណីយេ ច តារយេ
សសីវ រត្តឹ វិភជំ តស្សត្ថោ បរិបូរតិ ។

គជកុម្ភជាតកំ បញ្ចមំ ។

## កេសវជាតកំ

(២៨២) មនុស្សិន្ទំ ជហិត្វាន សព្វកាមសមិទ្ធិនំ
កថំ នុ ភគវា កេសី កប្បស្ស រមតិ អស្សមេ ។

(២៨៣) សាទូនិ រមណីយានិ សន្តិ វក្ខា មនោរមា
សុភាសិតានិ កប្បស្ស នារទ រមយន្តិ មំ ។



(២៨១) បុរសណា យឺតយូរក្នុងការងារ ដែលខ្លួនត្រូវធ្វើឲ្យយឺតយូរផង រហ័សរហួនក្នុងការងារដែលខ្លួនត្រូវធ្វើឲ្យរហ័សផង ប្រយោជន៍របស់បុរសនោះ តែងពេញគ្រប់គ្រាន់ ដូចជាព្រះចន្ទ្រចែករាត្រី (ឲ្យរលេចពន្លឺគ្រប់ក្នុងបក្ខ ១) ។

ចប់ គជកុម្ភជាតក ទី ៥ ។

## កេសវជាតក

(២៨២) (នារទអាមាត្យ ទូលសួរកេសវតាបសថា) កេសវតាបស មានព្រះភាគ(របស់យើងខ្ញុំ)នេះ លះបង់ព្រះបាទពារាណសី ជាធំជាងមនុស្ស អ្នកឲ្យសម្រេចសេចក្តីប្រាថ្នាទាំងពួង ហើយត្រេកអរសប្បាយ ក្នុងអាស្រម របស់កូនសិស្សឈ្មោះកប្បកៈ តើដោយឧបាយដូចម្តេច ។

(២៨៣) (កេសវតាបស និយាយថា) ម្នាលអាមាត្យ រសជាតិឆ្ងាយដ៏ឆ្ងាញ់ គួរត្រេកអរក៏មាន ដើមឈើទាំងឡាយ ជាទីត្រេកអរចិត្តក៏មាន ពាក្យជាសុភាសិតទាំងឡាយរបស់កប្បកៈ តែងធ្វើឲ្យអាត្មាត្រេកអរបាន ។

(៦៨៤) សាលីនំ ឱទនំ ភុញ្ជេ សុចិំ មំសូបសេចនំ
កថំ សាមាកនិវារំ អលោណំ ឆាទយន្តិ តំ ។

(៦៨៥) សាទុំ វា យទិ វាសាទុំ អប្បំ វា យទិ វា ពហុំ
វិស្សត្ថោ យត្ថ ភុញ្ជេយ្យ វិស្សាសបរមា រសាតិ ។

កេសវជាតកំ ឆដ្ឋំ ។

## អយកូដជាតកំ

(៦៨៦) សព្វាយសំ កូដមតិប្បមាណំ
បគ្គយ្ហ យោ តិដ្ឋសិ អន្តលិក្ខេ
រក្ខាយ មេ ត្វំ វិហិតោ នុសជ្ជ
ឧទាហុ មេ ភយមសេ[1] វធាយ ។

---

១ ម. ចេតយសេ ។



(៦៨៤) (នារទាមាត្យ ពោលថា) លោកម្ចាស់ ឆាន់បាយស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាត ហេតុដូចម្តេច បានជាស្រូវស្រែ និងស្មៅដែលលាក់ដែលមិនមានរសប្រៃសោះ ធ្វើឱ្យលោកម្ចាស់ ត្រេកអរបាន ។

(៦៨៥) (កេសវតាបស និយាយតបថា) បុគ្គលមានសេចក្តីស្និទ្ធស្នាល បរិភោគភោជនាហារបើឆ្ងាញ់ក្តី មិនឆ្ងាញ់ក្តី តិចក្តី ច្រើនក្តី ក្នុងទីកន្លែងណា ភោជន (ណាមួយដែលបុគ្គលបរិភោគហើយ ក្នុងទីកន្លែងនោះជាភោជនប្រសើរ) ព្រោះរស មានសេចក្តីស្និទ្ធស្នាលជាយ៉ាងក្រៃលែង ។

ចប់ កេសវជាតក ទី ៦ ។

## អយកូដជាតក

(៦៨៦) (ពោធិសត្វ ពោលថា) អ្នកណា ឈរកាន់ញញួរដែកទាំងមូលធំហួសប្រមាណ លើអាកាស អ្នកនោះមកឋិតនៅ ដើម្បីរក្សាអញ (ក្នុងថ្ងៃនេះ) ឬព្យាយាម ដើម្បីសម្លាប់អញ ។

(២៨៧) ទាសោ អហំ ភជិត រក្ខសានំ
វធាយ តុយ្ហំ បហិតោហមស្មិ
ឥន្ទោ ច តំ រក្ខតិ ទេវរាជា
តេនុត្តមង្គំ ន តេ ផាលយាមិ ។

(២៨៨) សចេ ច មំ រក្ខតិ ទេវរាជា
ទេវានមិន្ទោ មឃវា សុជម្បតិ
កាមំ បិសាចា វិនទន្តុ សព្វេ
ន សន្តសេ រក្ខសិយា បជាយ ។

(២៨៩) កាមំ កន្ទន្តុ កុម្ភណ្ឌា សព្វេ បំសុបិសាចកា
នាលំ បិសាចា យុទ្ធាយ មហតី សា វិភិសិកា(១) ។

អយកូដជាតកំ សត្តមំ ។

១. វិភីសិកា ។



(២៨៧) (យក្ស ពោលថា) បពិត្រមហារាជ ខ្ញុំព្រះអង្គជាខ្ញុំរបស់យក្ស ទឹក ខ្ញុំព្រះអង្គត្រូវពួកយក្សទឹកប្រើមកក្នុងទីនេះ ដើម្បីសម្លាប់ ព្រះអង្គ តែថា ព្រះឥន្ទ្រជាស្តេចទេវតារក្សាព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គនឹងបំបែកព្រះសិរ្សរបស់ព្រះអង្គមិនបានទេ ។

(២៨៨) (ពោធិសត្វ ពោលថា) បើទេវរាជ ទេវានមិន្ទ្រ មឃវា សុជម្បតិ ត្រូវរក្សាអញ ម្នាលបិសាច ពួកយក្សទាំងអស់ ចូរបន្លឺឡើងតាមសេចក្តីប្រាថ្នាចុះ យ៉ាងណាអញមិនតក់ស្លុត ចំពោះពួកយក្សទឹកទេ ។

(២៨៩) ពួកកុម្ភណ្ឌ នឹងពួកបិសាច នៅលើធូលីដីទាំងអស់ ចូរកំដាក់តាមសេចក្តីប្រាថ្នាចុះ តែបិសាច ពួកបិសាចទាំងអស់ មិនអាច ដើម្បីច្បាំងនឹងអញបានទេ ការបន្លាចគួរឲ្យខ្លាចនោះធំណាស់ (តែអញមិនខ្លាចឯងទេ) ។

ចប់ អយកូដជាតក ទី៧ ។

# អរញ្ញជាតកំ

(៦៩០) អរញ្ញា គាមមាគម្ម តំសីលំ តំវតំ អហំ
បុរិសំ តាត សេវេយ្យំ តំ មេ អក្ខាហិ បុច្ឆិតោ ។

(៦៩១) យោ តំ វិស្សាសយេ តាត វិស្សាសញ្ច ខមេយ្យ តេ
សុស្សូសី ច តិតិក្ខី ច តំ ភជេហិ ឥតោ គតោ ។

(៦៩២) យស្ស កាយេន វាចាយ មនសា នត្ថិ ទុក្កដំ
ឧរសីវ បតិដ្ឋាយ តំ ភជេហិ ឥតោ គតោ ។



# អរញ្ញជាតក

(៦៩០) (តាបសកុមារ និយាយក្រាបបិតាថា) បពិត្របិតា ខ្ញុំបាទ ចេញអំពីព្រៃ មកកាន់ស្រុកវិញ គួរសេពគប់នឹងបុរសមានមារយាទដូចម្តេច មានវត្តប្រតិបត្តិដូចម្តេច ខ្ញុំបាទសួរហើយ សូមបិតាប្រាប់ហេតុនោះ (ដល់ខ្ញុំ) ផង ។

(៦៩១) (តាបសពោធិសត្វជាបិតា ប្រាប់ថា) ម្នាលកូន បុរសណាគប្បីស្និទ្ធស្នាលនឹងអ្នក គប្បីអត់ទ្រាំនូវសេចក្តីស្និទ្ធស្នាល របស់អ្នក ជាអ្នកចង់ស្តាប់ពាក្យរបស់អ្នក អត់ទោសដល់អ្នក អ្នកទៅអំពីព្រៃនេះទៅ ចូរសេពគប់នឹងបុរសនោះចុះ ។

(៦៩២) បុរសណា មិនមានអំពើអាក្រក់ដោយកាយវាចាចិត្ត បើអ្នកចេញអំពីព្រៃនេះទៅ អ្នកចូរសេពគប់បុរសនោះចុះ ធ្វើដូចជាកូនដែលតាំងនៅឰដ៏ទ្រូង ។

(២៤៣) ហលិទ្ទិរាគំ កបិចិត្តំ បុរិសំ រាគវិរាគិនំ

តាទិសំ តាត មា សេវិ និម្មនុស្សម្បិ ចេ សិយា។

អរញ្ញជាតកំ អដ្ឋមំ ។

## សន្ធិភេទជាតកំ

(២៤៤) នេវ ឥត្ថីសុ សាមញ្ញំ នាបិ ភក្ខេសុ សារថិ

អថស្ស សន្ធិភេទស្ស បស្ស យាវ សុចិន្តិតំ ។

(២៤៥) អសិ តិក្ខោវ មំសម្ហិ បេសុញ្ញំ បរិវត្តតិ

យត្ថូសភញ្ច សីហញ្ច ភក្ខយន្តិ មិគាធមា ។

(២៤៦) ឥមំ សោ សយនំ សេតិ យមិមំ បស្សសិ សារថិ

យោ វាចំ សន្ធិភេទស្ស បិសុណស្ស និពោធតិ។



(២៤៣) បើទុកជាប្រទេសនេះ គ្មានមនុស្សអ្នកនៅក្រៅពីកាយកូនតែម្នាក់ឯងទេ ម្នាលកូន អ្នកកុំសេពគប់នឹងបុរសដែលមានចិត្តដូចទឹកល្មៀតជាគ្រឿងជ្រលក់ (មានចិត្តមិនបានខ្ជាប់ខ្ជួន) មានចិត្តដូចជាអាការនៃស្វា ជួនត្រេកអរ ជួនមិនត្រេកអរ (ប្រែប្រួលភ្លាមៗ) ប្រាកដដូច្នោះឡើយ ។

ចប់ អរញ្ញជាតក ទី ៨ ។

## សន្ធិភេទជាតក

(២៤៤) (ព្រះរាជា មានព្រះឱង្ការនឹងសារថីថា) ម្នាលសារថី សេចក្ដីស្មើគ្នា (របស់សត្វទាំងពីរ) ក្នុងស្ត្រីទាំងឡាយមិនមាន ក្នុងចំណីអាហារទាំងឡាយ ក៏មិនមានដែរ អ្នកចូរមើលគំនិតរបស់បុគ្គលអ្នកបំបែកនូវចំណងនៃមិត្រនោះ គិតមើលឲ្យល្អចុះ ។

(២៤៥) ពួកម្រឹគអធម៌ (ចចក) ស៊ីគោផង ស៊ីសីហៈផង ព្រោះសេចក្ដីញុះញង់ណា សេចក្ដីញុះញង់នោះ រមែងប្រែប្រួល ដូចជាដាវមុតក្នុងសាច់ ។

(២៤៦) ម្នាលសារថី អ្នកឃើញគ្រាដេកស្លាប់(នៃសត្វទាំងពីរ) នេះ បុគ្គលណា ជឿពាក្យរបស់បុគ្គលអ្នកញុះញង់ បំបែកនូវចំណងនៃមិត្រ បុគ្គលនោះ រមែងដេកស្លាប់យ៉ាងនេះ (ដូច្នេះ) ។

(៦៩៧) តេ ជនា សុខមេធន្តិ នរា សគ្គគតារិវ

យេ វាចំ សន្ធិភេទស្ស នាវពោធន្តិ សារថិ ។

សន្ធិភេទជាតកំ នវមំ ។

## ទេវតាបញ្ហជាតកំ

(៦៩៨) ហន្តិ ហត្ថេហិ បាទេហិ មុខញ្ច បរិសុម្ភតិ

ស វេ រាជ បិយោ ហោតិ កំ តេន ត្វាភិបស្សសិ ។

(៦៩៩) អក្កោសតិ យថាកាមំ អាគមញ្ចស្ស ឥច្ឆតិ(១)

ស វេ រាជ បិយោ ហោតិ កំ តេន ត្វាភិបស្សសិ ។

(៧០០) អព្ភក្ខាតិ អភូតេន អលិកេនាភិសារយេ

ស វេ រាជ បិយោ ហោតិ កំ តេន ត្វាភិបស្សសិ ។

១ ម. ឥច្ឆតិ ។



(៦៩៧) ម្នាលសារថី ពួកជនណា មិនជឿពាក្យញុះញង់ របស់អ្នកបំបែកនូវគំនំនៃមិត្រ ពួកជននោះ តែងបាននូវសេចក្តីសុខ ដូចជាពួកនរជនអ្នកទៅកើត ក្នុងឋានសួគ៌ដូច្នោះ ។

ចប់ សន្ធិភេទជាតក ទី ៩ ។

## ទេវតាបញ្ហជាតក

(៦៩៨) (ទេវតា សួរថា) បុគ្គលណា ប្រហារ ដោយដៃទាំងពីរផង ដោយជើងទាំងពីរផង ប្រហារនូវមាត់ផង បពិត្រមហារាជ បុគ្គលនោះ ជាទីស្រឡាញ់នៃគេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ។

(៦៩៩) បុគ្គលណា ជេរប្រទេច តាមសេចក្តីប្រាថ្នា តែមិនប្រាថ្នានូវការមកដល់បុគ្គលនោះ បពិត្រមហារាជ បុគ្គលនោះ ជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ។

(៧០០) បុគ្គលណា ពោលបង្កាច់ដោយពាក្យមិនពិត ប្រកាសប្រាប់ឲ្យឮដោយពាក្យឡេឡោ បពិត្រមហារាជ បុគ្គលនោះជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ។

[៧០៧] ហរំ អន្នញ្ច បានញ្ច វត្ថសេនាសនានិ ច

(អញ្ញទត្ថុ ហរា សន្តា)

តេ វេ ភដ បិយា ហោន្តិ ការេន្ត ទ្វារិបស្សសិតា ។

ទេវតាបញ្ហាគាថា ទសមំ ។

ចុល្លកុណ្ឌលវគ្គោ បញ្ចមោ ។

## តស្សុទ្ទានំ

ឆកាលិ អសក្ខិ សេដ្ឋិវរោ
និលិយ មត្តិវញ្ច ឋុន
ឋុន សោយសញ្ញជវរោ
តជារញ្ញ សាវដិ ហន្តិ ទស ។

## តត្ថ វគ្គុទ្ទានំ ភវតិ

ឧរំ ឧព្ពរិ ចូឡញ្ច ការូដិកុសំ ពហុកាណការំ

ចុល្លកុណ្ឌលវគ្គោ សោ បញ្ចមោ សុប្បកាសិតោតិ ។

ពេតវត្ថុបាឡិ និដ្ឋិតំ ។

---





[៧០៧] ពួកអ្នកនាំយកទៅ បាននាំយកបាយផង ទឹកផង សំពត់ទីផង សេនាសនៈទាំងឡាយផង ដោយគិត បពិត្រមហារាជ ពួកពួកអ្នកនាំយកទៅនោះ ជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា ។

ចប់ ទេវតាបញ្ហាគាថា ទី ១០ ។

ចប់ ចុល្លកុណ្ឌលវគ្គ ទី ៥ ។

## ឧទ្ទាននៃចុល្លកុណ្ឌលវគ្គនោះ គឺ

និយាយអំពីស្រីថ្មីសេដ្ឋីក្រេតអរ ដល់ពួកបុរស ១ ព្រះពោធិ-សត្វបានរើរូន ១ មេក្រៀលនៅក្នុងដំណាក់ស្តេច ១ ក្នុងថ្ងៃសក់ឡៅ ១ ក្មេងដែលប្រសើរ ១ ស្រុកទាំងឡាយ ១ ញញ្ញាំផែកដីប្រសើរ ១ ការបេញអំពីព្រៃ ១ ខាយសារថី ១ ប្រហារដោយដៃ ១ ត្រូវជា១០ ។

## ឧទ្ទាននៃវគ្គក្នុងពេតវត្ថុនិបាតនោះ គឺ

ឧរគវគ្គ ១ ឧព្ពរិវគ្គ ១ ចុល្លវគ្គ ១ មហាវគ្គ ១ ចុល្លកុណ្ឌលវគ្គ គឺរបស់ជា ៥ លោកសំដែងល្អហើយ ។

ចប់ ពេតវត្ថុនិទាន ។